# អភិធម្មត្ថាធិប្បាយ



## ភាគ ១

## បរិច្ឆេទទី ១-២-៣



# ពាក្យប្រារព្ធ

ខ្ញុំព្រះករុណាខ្ញុំបាទបានឃើញខ្លឹមសារនៃព្រះអភិធម្មពិស្តារនេះសំខាន់ ហើយមានន័យទូលំទូលាយ ត្រឹមត្រូវតាមពុទ្ធដិកា នឹងថេរដិកាត្រឹមត្រូវល្អ ខ្ញុំព្រះករុណាខ្ញុំបាទនូ បុណ្ណចន្ទ . ចៅ ឧត្តមវឌ្ឍា ក៏បានមូលមតិគ្នាផ្ដើមធ្វើសៀវភៅនេះ ឱ្យមានទ្រង់ទ្រាយជាប្រយោជន៍សំខាន់ ក្នុងព្រះពុទ្ធសាសនា ដើម្បីទុនសំរាប់អ្នកយល់ ចូលចិត្តសិក្សាព្រះអភិធម្មពិស្តារដោយខ្លួនឯង ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពដឹងគុណចំពោះសប្បុរសជនដែលមានឧបការៈ ជួយជ្រោមជ្រែង និងឧបត្ថម្ភ គាំទ្រគ្រប់បែបយ៉ាង ដើម្បីឱ្យបានសម្រេចនូវសៀវភៅអភិធម្មពិស្តារនេះ ចែកជាធម្មទាន ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌខាងមុខនេះ ។

ដោយសៀវភៅនេះ មានការឃ្លៀងឃ្លាតបាលី

សំរាយមួយចំនួន ដោយពីការវាយកំព្យូទ័រ និងការផ្ទៀងផ្ទាត់ មានការភ្លាំងភ្លាត់ ដូច្នេះទើបមានការខុសខ្លះ ·សូមអភ័យទោសទុកជាមុន និង រង់ចាំទទួលរិះគន់ កែលំអរអំពីសប្បុរសជនទាំងឡាយ ។

រាជធានីភ្នំពេញ, ថ្ងៃសៅរ៍ បិណ្ឌ ៣

ខែ ភទ្របទ ពុទ្ធសករាជ ២៥៤៤

ខ្ញុំព្រះករុណាខ្ញុំបាទ

ទុំ ប៊ុណ្ណរោចន្ទ , ចៅ ឧត្តមរដ្ឋា

បោះពុម្ពលើកទី១

សម្រាប់ជាធម្មទានតែម្យ៉ាង





ទុំ ប៊ុណ្ណរោចន្ទ ចៅ ឧត្តមរដ្ឋា

# បុណ្យកុសលនៃការបោះពុម្ព

សៀវភៅនេះ សូមឧទិសកុសលប្រគេនជូនព្រះតេជគុណព្រះនាម ចង ខាំ នឹង មាតា បិតា របស់លោក ដែលអនិច្ចធម្ម និង ធ្វើមរណកាលទៅហើយ នឹង ជូនដល់បុព្វការីជនទាំងអស់ តែដោយកុសលនៃការព្យាយាមរបស់ព្រះតេជគុណ ទើបសមាគម ធម្មិកសង្គហបានមូលមតិគ្នាដើម្បីបោះពុម្ពសៀវភៅដ៏កម្រនេះឡើង ។

អ្នករៀបរៀង និង កែសំរួល

ឧបាសក ឡៅម ស៊ីម៉ឿន

ឧបាសក ដាំ កុយ

ឧបាសក នូ បុណ្ណាចន្ទ

ឧបាសក ចៅ ឧត្តមរដ្ឋា

ឧបាសិកា អ៊ុន សារឿន អ្នកបរិច្ចាគប្រាក់ក្នុងការបោះពុម្ព

# ក. អភិធម្មសិក្សាសង្ខេប

✵ ✵ ✵ ✵

**មាតរំ មុខំ កត្វា តស្សា បញ្ញាយ តេជសា**
**អភិធម្មកថាមគ្គំ ទេវានំ សម្បវត្តយិ**

ប្រែ មុននឹងលោកអ្នកអានឬសិក្សា ព្រះអភិធម្មនេះ លោក អ្នកអានឬ សិក្សាគួរដឹងរឿង ព្រះអភិធម្មនេះសិនថា ព្រះ អភិធម្មមាន ច្បាប់ជាពុទ្ធភាសិតសុទ្ធៗឯសាវ័ក ឬ អ្នកប្រាជ្ញណាមួយ ពុំអាចសំដែងតាមអត្តនោម័តិរបស់ខ្លួនឡើយ ។ ព្រោះគោល អត្ថកថា ព្រះអភិធម្មអធិប្បាយថា" **អភិធម្មោ នាម ពុទ្ធវិសយោ** " គឺព្រះអភិធម្មនេះ ជាពុទ្ធវិស័យពិតៗសូម្បី សម័យពុទ្ធកាលព្រះអរហន្តទាំងឡាយដែលមានឈ្មោះបោះសំឡេង ដូចជាព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះមហាកច្ចាយនៈព្រះមហាកស្សប ព្រះអានន្ទ ជាដើម ។ សូម្បីលោកពេញ

ប្រៀបដោយ បដិសម្ភិទា ទេវិជ្ជា វិសេសយ៉ាងណាក៏មិន
អាចទេសនានូវ ព្រះអភិធម្មបានក្រៅអំពីព្រះសាស្តា ។

ព្រះអភិធម្មនេះ រមែងមានផលានិសង្សច្រើន សូមបានជ្រាបតាមនិទានកថាដូចនេះគឺ ព្រះបរមលោក នាថទ្រង់ជា **សព្វញ្ញូ** ។ កាលបឋមពោធិកាល រាប់ពីសម័យថ្ងៃបានសំរេច សម្មាសម្ពោធិញ្ញាណនោះដល់ទៅ ២១ ថ្ងៃ គឺវារៈ ដែលនឹងដល់ **ចតុត្ថ សត្តាហៈ** នោះទ្រង់បានពិចារណាព្រះអភិធម្ម ៧ គម្ពីរមានកំណត់៧ថ្ងៃ (ថ្ងៃពេញបូណ៌មី ) ហើយទ្រង់ អាស្រ័យព្រះអភិធម្មនោះ បានទទួលរស្មី ( ឆព្វណ្ណរង្សី គឺ **ពណ៌ខៀវ លឿង ក្រហម ស ហង្សបាទ** និងពណ៌ចម្រុះ (ផ្លេកពណ្ណរាយ) ចេញពីព្រះកាយព្រះអង្គ ។

ព្រះអភិធម្មអាចប្រហារ ឬ សម្លាប់គឿងសៅហ្មងដូចជា **លោកៈ បរិទេវៈ សោកៈ ទោមនស្ស ឧបាយាស** បានថ្មីក ឬបានស្ងាត់ជំនាញ នាំព្រះទ័យ

ប្រាសចាក គ្រឿងសៅហ្មង រមែងទៅកាន់សភាវៈ ដែលស្អាតស្អំ ផូរផង់មានព្រះទ័យថ្លាស្អាត ប្រដូចជាមាស ឬជាឈាមដែលគ្មានមន្ទិល ។

ព្រោះហេតុដូច្នោះ ទើបឈ្មោះថា ព្រះអភិធម្ម ។

**ព្រះអភិធម្ម ( អភិ + ធម្ម )**

**អភិ** ប្រែថា ល្អិត ឬ ក្រៃលែង

**ធម្ម** ប្រែថា សភាវទ្រទ្រង់

**ទំព្រ** អត្ថនៃពុទ្ធភូមិ ឬ ជាទីអាស្រ័យនៃពុទ្ធភូមិដែលកន្លងទៅគ្រប់ៗព្រះអង្គ ឬ មានព្រះពុទ្ធគ្រប់ៗព្រះអង្គដែលកន្លងទៅហើយក្តី ក្នុងអតីតកាលកន្លងទៅហើយក្តី ត្រូវតែអាស្រ័យព្រះអភិធម្មជាពុទ្ធមាតាគ្រប់ៗព្រះអង្គ ។ ព្រះអភិធម្មដែលព្រះអង្គសំដែង គឺខ្ញុំម្ចាស់ពោលធានាដល់លោកអ្នកសិក្សា ព្រះអភិធម្ម ព្រះវិន័យ ព្រះសូត្រទាំងឡាយដោយចំពោះ ។ លោកអ្នកប្រាជ្ញទាំងពាមេត្តាមើលព្រះសូត្រ មហាវារបាលី ក្នុងខុទ្ទកនិកាយ ព្រះបាលី

ដែលសំដែង ព្រះប្រវត្តិមហាវារៈ ។

**ឥ.** បាលីព្រមទាំងអត្ថកថាពោលដោយ ឯកច្ឆ័ន្ទ ព្រះអភិធម្មដែលជាធម៌ បរិបូណ៌ដោយមហាឫទ្ធានុភាព ។ កាលព្រះបរមសាស្តាមានវារៈគ្រប់ព្រះជន្ម ៧ ព្រះវស្សា មហាសករាជឆ្នាំ ១១០ ពេញបូណ៌មីខែអាសាធ ក្រោយពេលដែលសំដែង **យមកប្បាដិហារិយ៍** ដល់អ្នកជនជាតិឥណ្ឌាមានប្រមាណ ៣៦ កោដិ ក្នុងនគរសាវត្ថី ។ ព្រះអង្គយាងទៅកាន់តាវតឹង្សទេវលោក ហើយព្រះអង្គសំដែងធម៌ទេសនា ដល់ព្រហ្មទេវតា មានប្រមាណមិនបានរហូតដល់ ៣ ខែគត់ ( ពេញ ៣ ខែ ) ថ្ងៃ ១ រោចខែអាសាធ ព្រះអង្គយាងចូលទៅកាន់ ព្រៃហេមពាន្ត ព្រះអង្គសំដែងធម៌ទេសនាដល់ ព្រះសារីបុត្រ បង្រៀនព្រះអភិ-ធម្មដល់ជនជាតិ មនុស្ស សត្វនិករ ទូទៅ រហូតដល់ ៣ ខែប្រហែលគ្នានឹងពេលដែលទ្រង់សំដែងធម៌ទេសនា ក្នុងទេវលោកដែរ ។ ថ្ងៃជាអវសាន នៃការសំដែងព្រះអភិធម្ម

នៅទេវលោក និង មនុស្សលោកជាថ្ងៃជាបួយព្កា ពី ថ្ងៃ ពេញបូណ៌មី គឺ ថ្ងៃ ១៥កើត ខែ អស្សុជ ។ អង្គសម្តេច ព្រះភគវន្តមុនី កំពូលអ្នកប្រាជ្ញ ស្តេច និវត្តត្រឡប់កាន់ សំកស្សនគរ ហើយផ្តើមបង្រៀនព្រះអភិធម្មបិដកនេះក៏ ផ្សព្វផ្សាយទូទៅគ្រប់ប្រទេសជាតិ ដូចជា ព្រះអាទិត្យ ឬ ព្រះច័ន្ទ ឆ្លុះពិភពលោកឱ្យភ្លឺ ដោយអាការៈដូច្នេះ ឯង ។

ខាងក្រោយព្រះពុទ្ធបរិនិព្វានទៅក្នុងកាលព្រះមហា សករាជ ១៤៨ ខែ ៨ ៨រោច ថ្ងៃ១រោច **ព្រះកស្សប** **យ**~ ព្រះឧបាលី ព្រះអានន្ទ ជាប្រធាន ព្រមទាំងព្រះ-អរហន្ត ៥០០អង្គទៀត សុទ្ធតែបានសំរេច បដិសម្ភិទា ឆឡភិញ្ញា ទេវវិជ្ជា រួមគ្នាក្នុងពិធីធ្វើ សង្គាយនា ព្រះ-អភិធម្ម ព្រះវិន័យ ព្រះសូត្រ ៨៤ ០០០ ព្រះធម្មក្ខន្ធ ។ បានលើកតំម្កើងព្រះអភិធម្មបិដកជាបិដកដែលសំខាន់ ។ ការជួយឧបត្ថម្ភ ដោយព្រះបាទ អជាតសត្រូវ កាល ព.ស បាន ១០០ឆ្នាំ ព្រះអរហន្ត ៧០០ ព្រះអង្គដែលមានព្រះ

សព្វកាមីជាប្រមុខ ឬ ជាប្រធាន និង ព្រះចៅកាឡាសោករាជ ជាសាសនូបត្ថម្ភ សឹងរាប់ថាជា សង្គាយនាទី ២ ដែលលើកតំកើង សង្គាយនាព្រះអភិធម្មបិដក ម្តងទៀត ។

កាល ព.ស ២០០ ឆ្នាំជាង សម័យព្រះចៅ អសោកមហា - រាជ ក្រុងបាតលីបុត្រមហានគរ ព្រះមោគ្គលីបុត្រទេសត្ថេរ ជាប្រធាន ព្រមទាំងព្រះអរហន្ត ជួយគ្នាក្នុង ពិធីធ្វើ-សង្គាយនា ព្រះអភិធម្មបិដកនេះ ចំនួន ៣ ខែ ។ ព្រះមោគ្គលីបុត្រ វិនិច្ឆ័យបញ្ហាព្រះអភិធម្ម ១០០០ បញ្ហា ទុកក្នុងកថាវត្ថុព្រះបាលី ដែលជាគម្ពីរទី ៥ នៃគម្ពីរព្រះអភិធម្ម ៧ គម្ពីរ សម័យនោះរាប់ថា បិដកនេះ សំខាន់ជាងបិដកដទៃៗ ព្រោះមានអ្នកសិក្សាច្រើនដល់ថ្នាក់សង្គាយនាត្រូវវិនិច្ឆ័យ បញ្ហាទាំង ១០០០ ខាងលើ ។

សេចក្តី ឬ ពាក្យបានប្រកែកគ្នានានា ក្នុងប្រទេសក៏ត្រូវឈប់ ។ ដោយមានគម្ពីរ ព្រះអភិធម្មជាទីអាង (បទដ្ឋាន) ។

ការសិក្សាក្នុងអភិធម្ម ទាក់ទងពីនោះមកដល់ ព.ស ៩០០ មានព្រះសង្ឃមួយអង្គ ព្រះនាម ព្រះអនុរុទ្ធាចារ្យ ដែលជាអ្នកស្រុក កាវិលញ្ជិ ប្រទេសតាំងនៅខាង ត្បូង ឥណ្ឌា តំបន់ មទ្ធវ៉ា បានឆ្លងទន្លេមកសិក្សាព្រះអភិធម្ម ។

**១.** ក្នុងអនុរាជនគរ នៃលង្កាទ្វីប ។ ថ្ងៃក្រោយតមកបានជាអ្នកប្រាជ្ញមាននាម ឧឃោសក្នុងវត្តឧម្វេល សោមារាម ឬ មូលមារាម ។

តមក មានពាក្យអារាធនារបស់ នមពយាមក មួយនាក់ សំណូមពរឱ្យចងក្រងគម្ពីរព្រះអភិធម្ម ដើម្បីប្រយោជន៍ដ៏ធំទូលំ ទូលាយ ដល់អ្នកសិក្សា ព្រះអភិធម្មទាំងឡាយក្នុងអនាគតឱ្យ ចូលចិត្ត ងាយយល់ហើយ ងាយស្រាវជ្រាវ កត់ចាំឈ្មោះ កងធមិ ឬ អត្ថកថា ឱ្យបានស្ទាត់ជំនាញ ទើបព្យាយាមរូបរួមចងក្រង ព្រះអភិធម្ម ៧ គម្ពីរ នេះដោយសង្ខេប ។

គម្ពីរនេះ គឺព្រះអភិធម្មសង្គហៈ ដែលលោកអ្នកទាំងឡាយសិក្សា រៀនសូត្ររាល់ថ្ងៃនេះឯង ។ ដោយហេតុផ្សេងៗ (នេះឯង ) ដែលបរិយាយមកហើយពីខាងដើម ។ ព្រះអភិធម្ម៧គម្ពីរ ឬ ព្រះអភិធម្មបិដក ដែលជាធម៌វិសេស ជាទីអាស្រ័យរបស់ពុទ្ធភូមិរមែងមានប្រយោជន៍ដល់ទេវតា និង មនុស្សទាំងឡាយ ដោយចំពោះយ៉ាងក្រៃលែង ដូចជាអ្នកយកចិត្តទុកដាក់ក្នុងចិត្តវិទ្យា អ្នកយកចិត្តទុកដាក់ ក្នុងសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាន យកចិត្តទុកដាក់ជំរះចិត្តល្អស្អាត ក្នុងផ្លូវរូប និង នាម ហើយនឹង យកចិត្តទុកដាក់បញ្ញាបារមី ខាងមុខរហូតដល់បដិសម្ភិទា ។ល។

ខ្ញុំម្ចាស់អ្នកមានឈ្មោះខាងក្រោយនេះ រៀបរៀងប្រែពីបាលីដើមឡើងជាគម្ពីរថ្មី ។ ដែលមានឈ្មោះថា ព្រះអភិធម្ម ពិស្តារតាមភាសាខ្មែរ ។ សម័យនេះនិយមចូលចិត្តព្រមទាំង មានភស្តុតាង ទាំងព្រះបាលី និង អដ្ឋកថា

ដែលបាន រៀនសូត្រ មកពីប្រទេស ភូមា លង្កាទ្វីប និង ឥណ្ឌា ។

សៀវភៅនេះជាសៀវភៅ សំរេចចុះដោយកុសលចេតនា បរិសុទ្ធរបស់ខ្ញុំម្ចាស់ ប្រសិនបើខ្វះខាតដោយប្រការណាមួយ ខ្ញុំម្ចាស់មានសេចក្ដីត្រេកអរ សុំជួយកែ តែនាំ ដាស់តឿន អំពី លោកអ្នកជាបណ្ឌិត ទាំងឡាយ ដោយសេចក្ដីគោរពជានិច្ច ។

## ៦- វិធីសិក្សា

ព្រះអភិធម្មពិស្ដារនេះ អ្នកសិក្សាត្រូវដឹង និង ធ្វើតាមសេចក្ដី ដែលនឹងពោលដូចតទៅនេះ :

១- ត្រូវរាប់សរុបកងធមិ ឬ អង្គធមិ ទាល់តែចាំបាន ។

២- ត្រូវញែកស័ព្ទបាលី វេយ្យាករណ៍ ដែលសំដែងទុកក្នុងភាគនេះ ។

ត្រូវពិចារណា ត្រិះរិះ ( ត្រិះរិះពិចារណា )ស័ព្ទណា ស័ព្ទនោះទាល់តែយល់ចូលចិត្តសព្វគ្រប់ អត្ថន័យសេចក្តីយ៉ាងណាប្រសិនបើត្រង់ណាដែលមិនយល់ចូលចិត្ត កុំគប្បីសិក្សាតទៅទៀត ជាដាច់ខាត ការសិក្សាតាមបែបវិធី ដែលពោលមកហើយ បើនៅមានសេចក្តីសង្ស័យខណាមួយកុំគប្បីបណ្តោយឱ្យឆ្លងហួសទៅ មេត្តាសាកសួររកគម្ពីរច្បាប់ខាងដើម ឬ អដ្ឋកថា ។ សំរាប់អ្នកសិក្សានៅឆ្ងាយនោះមេត្តាទាក់ទង សាកសួរពុទ្ធសាសនិក ក្នុងព្រះពុទ្ធសាសនា ។

កាលដែលទទួលគម្ពីរ ដែលមាននាមថាគម្ពីរ ពិស្តារនេះ សុំមេត្តាសិក្សាឱ្យចូលចិត្តទាល់តែបាន ដើម្បីឱ្យដឹងសភាវធម៌ តាមសេចក្តីពិតនៃ ព្រះពុទ្ធសាសនា ដែលជា

បរិច្ឆេទទី ១

មង្គលដ៏ប្រសើរក្នុងលោកទាំងឡាយ គឺ ជាតិនេះ និងជាតិខាងមុខ ។

✵ ✵ ✵ ✵ ✵

✵ ✵ ✵

✵

សាយ កុសលម្ព៍

អាចារ្យព្រះបរមត្ថ សំណាក់វត្តរវៀងមហោសធិ-

ការាម ខេត្ត ឃុនប៊ូរី ។

# ៦. សំនាំ

ព្រះអភិធម្មជាបរមត្ថទេសនា អង្គសម្តេចព្រះដ៏មានព្រះភាគទ្រង់ឆ្លាតក្នុងបរមត្ថ ទ្រង់ទេសនា ទុកហើយដ៏ច្រើន ។ បរមត្ថធម៌នោះគឺ ចិត្ត ចេតសិក រូប និព្វាន ព្រះអភិធម្មដ្ឋាន ពាក្យប្រៀនប្រដៅដោយព្រះអង្គ ទ្រង់បង្រៀនពួកសត្វ អ្នកដែលមានសេចក្តីសំគាល់ខុសក្នុង សភាវធម៌ : ខ័ន្ធ ៥ រូប និព្វាន ថាជាយើងជា របស់យើងតាមសមត្ថរនៃសភាវធម៌ ព្រះអភិធម្មជានាមរូប (បរិច្ឆេទកថា) ។ ព្រោះព្រះអង្គទ្រង់ត្រាស់កំណត់ ដឹងនាមរូបដែលជា សត្រូវចំពោះកិលេស មានរាគៈជាដើម ព្រះអភិធម្មជា បញ្ញាសិក្ខា ប្រព្រឹត្តទៅដើម្បីលះអនុស័យកិលេស ដាច់ជា សមុច្ឆេទ ។ ក្នុងសៀវភៅអភិធម្មពិស្តាររបស់អាចារ្យ **សាយ ភសេម** ជាអាចារ្យបង្រៀនព្រះអភិធម្មជំនាន់ដំបូង ( ព្រះអភិធម្មដ្ឋាន ) បានប្រែរៀបរៀងទុកពីរភាគ ព្រមទាំងភស្តុតាងទីកន្លែង ដែលសួរ និង

សិក្សាជាគ្រឿងឧបករណ៍ សំរាប់អ្នកសិក្សា ព្រះអភិធម្ម ។ អ្នកយកចិត្តទុកដាក់ ប្រាថ្នាសិក្សាប្រតិបត្តិ ឬ បដិបត្តិ វិបស្សនាព្រម ដោយគណសិក្សា អែល- អេ រដ្ឋកាលី- ហ្វញ៉ាប្រទេសអាមេរិក ។ អ្នកបដិបត្តិវិបស្សនា ខេត្ត សមុទ្រសាគរ ចាប់ផ្តើមបោះពុម្ពឡើង ដើម្បីចែកជាធម្មទាន វត្ថុបំណងដើម្បី រក្សាសៀវភៅល្អ មានភស្តុតាង ពឹងផ្អែក ជាចំណែកនៃ បរិយត្តិសាសនា ដែលជាឫសគល់នៃបដិបត្តិ សាសនា កាលពុទ្ធបរិស័ទ សិក្សា ចូលចិត្តយ៉ាងប្រពៃ បដិបត្តិដោយល្អ ប្រសើរ ដើម្បីសេចក្តីចំរើនមាំមួន លូត- លាស់ដរាបណា ។

៥. សូមអនុមោទនាមួយអន្លើដោយគណសិស្សគ្រប់គ្នា ដែលរួមបរិចាគជាធម្មក្នុងគ្រានេះ ចូរជាអ្នកក្សេមក្សាន្ត គ្មានសេចក្តីទុក្ខស្មៀមស្ងាត់ គ្មានសេចក្តីសោក មិនមាន កម្មពៀរ មានឥស្សរ ចំរើនលូតលាស់បរិបូណ៌ ក្នុងព្រះ សទ្ធម្ម ដែលព្រះសុគតជាម្ចាស់ត្រាស់ទុកដោយល្អហើយ ។

ព្រះមហា បតន្តរោ វត្តព្រះគោំង ៤ គណ
ក្រួចឆេប ឃាចកក ឲ លោកអាចារ្យស
ជាអាចារ្យ បង្រៀន វិបស្សនា គ.ម ២
ចៅហ្វាយស្រុក ធុម~បែន ខេត្តសមុទ្ទសាខ
៧៤៣០ ២៩ តុលា ព.ស.២៥៣២ ឲ

✵ ✵ ✵ ✵ ✵
✵ ✵ ✵
✵

# រតនបណាមគាថា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

ខ្ញុំព្រះករុណា សូមបង្អោននមស្ការ ចំពោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយដែលទ្រង់ឃើញ៉ បរមត្ថធម៌ទាំងអស់ដោយព្រះអង្គឯង ហើយជាអ្នកមានបារមី ខ្ពស់បំផុតដោយ សីលាទិគុណ ។ អ្នកប្រែគម្ពីរ ដែលមានឈ្មោះព្រះអភិធម្មត្ថសង្គហៈ តទៅនេះ

## បរិច្ឆេទទី ១ គឺ ចិត្តបរមត្ថ

**សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។**

**ប្រែ** ខ្ញុំម្ចាស់សូមបង្អោនកាយ ថ្វាយបង្គំ ដោយអភិវាទដល់ ព្រះពុទ្ធជាម្ចាស់ ជាអ្នកដ៏ឧត្តម ដោយសីលាទីគុណគ្មានអ្នកណា ប្រៀបស្មើ ព្រមដោយព្រះសទ្ធម្ម ហើយ និង

ព្រះអរិយសង្ឃជា ម្ចាស់នឹងពោលនូវ គម្ពីរដែលមាន នាម ជា **ព្រះអភិធម្ម ឬ ព្រះអភិធម្មសង្ខេប** ដូចតទៅ ។

បណាមគាថា របស់លោកអនុរុទ្ធាចារ្យ ៖

**តត្ថ វុត្តា អភិធម្មត្ថា ចតុធា បរមត្ថតោ ចិត្តំ ចេតសិកំ រូបំ និព្វានមីតិ សព្វថា**

ប្រែ អត្ថនៃព្រះអភិធម្ម ៧ គម្ពីរនេះដោយសេចក្តីជា បរមត្ថមាន

**៤ប្រការ (៤ប្រភេទ) ៖**

**១. ចិត្ត** **២. ចេតសិក**

**៣. រូប** **៤. និព្វាន**

ពាក្យអធិប្បាយបរមត្ថ ៤ ប្រការ

ពាក្យថា **បរមត្ថ** ញែកបានពីរបទ គឺ

**បរម + អត្ថ = បរមត្ថ**

ប្រែ សេចក្តីដែល ល្អិត សុខុម ឬ ល្អិតជាងធម៌ដទៃៗ

ទាំងអស់ដែលមាននៅក្នុងព្រះអភិធម្ម ៧ គម្ពីរ បានដល់បរមត្ថធម៌ ៤ ប្រការ ។

**ពាក្យថា ចិត្ត**

**ប្រែ** ធម្មជាតិជាបរមត្ថមួយយ៉ាង ដែលមានលក្ខណៈដឹងកាលណាប៉ះទង្គិច អារម្មណ៍ទាំង ៦ ដូចជា

- ភ្នែក ប៉ះរូប ដឹងថាជារូបារម្មណ៍

* ត្រចៀកបានប៉ះសំឡេង ដឹងថា ជាសទ្ទារម្មណ៍ ជាដើម ។

ចិត្តមានចំនួន ៨៩ ដួង ដោយសង្ខេប ឬ ១២១ ដួង ដោយពិស្តារ ។

**ពាក្យថា ចេតសិក**

**ប្រែ** ធម្មជាតិមួយយ៉ាង ដែលអាស្រ័យជាមួយចិត្ត ហើយកើត និង រលត់ព្រមជាមួយចិត្ត មានអារម្មណ៍ ជាមួយគ្នា និង ចិត្ត មានវត្ថុតែមួយជាមួយចិត្ត មានសទ្ធាចេតសិក និង សតិចេតសិកជា ដើម ។

**ចេតសិកទាំងអស់ (មានចំនួន) ៥២ ដួង ៗ**

**ពាក្យថារូប**

**ប្រែ** ធម្មជាតិមួយយ៉ាងដែលមានសភាព ត្រឡប់ឡើងចុះជានិច្ច ( ដែលមានសភាពប្រែប្រួលជានិច្ច ) កាលណាប៉ះទង្គិច ត្រជាក់ ឬ ក្តៅជាដើម

**រូប មានចំនួន ២៨ រូប ។**

---

**ពាក្យថា និព្វាន**

**ប្រែ** ធម្មជាតិមួយយ៉ាង ដែលរមែងរំលត់នូវទុក្ខទាំងពួងបាន មានលក្ខណៈសន្តិសុខ (សន្តិបទ) ដោយសេចក្តីបរមត្ថ ហើយ មានតែមួយដោយបរិយាយនេះ ។

## បរិច្ឆេទទី ១ ទំព័រទី៣

**តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ**

**កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ**

ប្រែ ខាងដើមនេះ និង អធិប្បាយចិត្ត ៤ ប្រការ

១- ចិត្តជា កាមាវចរ ឬ កាមាវចរចិត្ត

២- ចិត្តជា រូបាវចរ ឬ រូបាវចរចិត្ត

៣- ចិត្តជា អរូបាវចរ ឬ អរូបាវចរចិត្ត

៤- ចិត្តជា លោកុត្តរៈ ឬ លោកុត្តរចិត្ត

**អធិប្បាយចិត្ត ៤ ប្រការ**

ពាក្យថា **កាមាវចរ** ញែកបានពីរបទ គឺ

**កាម + អវចរ**

ប្រែ ចិត្តដែលកើតនៅច្រើនក្នុងកាមភព និង កាមបុគ្គល មាន ចំនួន ៥៤ ដួង

ពាក្យថា រូបាវចរ ញែកបានពីរបទ គឺ

**រូប + អវចរ**

ប្រែ ចិត្តដែលកើតច្រើនក្នុងរូបភព ឬ ក្នុងរូបព្រហ្មមាន ចំនួន ចិត្ត ១៥ ដួង

ពាក្យថា **អរូបាវចរ** ញែកបានពីរបទ គឺ

**អរូប + អវចរ**

**ប្រែ** ចិត្តដែលកើតច្រើនទៀត ក្នុងអរូបភព អរូបព្រហ្ម ដែល មានចំនួនចិត្ត ១២ ដួង

ពាក្យថា **លោកុត្តរៈ** ញែកបានពីរបទ គឺ

**លោកៈ + ឧត្តរៈ**

**ប្រែ** ចិត្តដែលផុតចាកលោកទាំងបី

ចិត្តបែបនេះ កើតចំពោះសន្តាននៃព្រះអរិយបុគ្គល ប៉ុណ្ណោះ មានចំនួន ៨ ដួង ឬ ៤០ដួង

# ព្រះអភិធម្មពិស្តារ

រួមចិត្តទាំងអស់ ក្នុងកាមាវចរមាន ៥៤ ដួង

រូបាវចរមាន ១៥ ដួង អរូបាវចរមាន ១២ ដួង លោកុត្តរ

មាន ៨ ដួង ឬ ៤០ ដួង

រួម ៨៩ ដួង =(៥៤ + ១៥ + ១២ +៨)

ឬ ១២១ ដួង = (៥៤ +១៥ +១២ +៤០)

ចិត្ត ភូមិ កាមាវចរ

* ចិត្តជាកាមាវចរ ឬ កាមាវចរចិត្ត នោះ មានប៉ុន្មាន ?

ចិត្តជាកាមាវចរមាន ៥៤ដួង គឺ :

| | | |
|---|---|---|
| ១. | ចិត្តជាអកុសល | ១២ ដួង |
| ២. | ចិត្តជាអហេតុកៈ | ១៨ ដួង |
| ៣. | ចិត្តជាកាមាវចរសោភណៈ | ២៤ ដួង |
| | រួម | ៥៤ ដួង |

អកុសលចិត្ត ១២ ដួងនោះ គឺ :

| | | |
|---|---|---|
| ចិត្តជា | លោភមូល | ៨ ដួង |
| ចិត្តជា | ទោសមូល | ២ ដួង |
| ចិត្តជា | មោហមូល | ២ ដួង |
| | រួម | ១២ ដួង |

ដោយត្រង់បានដល់សេចក្ដីអាក្រក់ចិត្ត ដែលជាអកុសល មាន ចំនួន ១២ ដួង គឺ

**លោភមូលចិត្ត ៨ដួង ទោសមូលចិត្ត ២ដួង មោហមូល ចិត្ត ២ ដួង ។**

ពាក្យថា **លោភមូលចិត្ត** ញែកបានពីរបទ គឺ

**លោភ + មូល**

លោភ សេចក្ដីចង់បាន ( សេចក្ដីជាប់ជំពាក់ក្នុង អារម្មណ៍ )

មូល  ឫស ឬ ឫសគល់  ឬ ឫសកែវ

**មានន័យថា** ចង់បានជាមូលហេតុ ឬ ជាឫសកែវនៃចិត្ត ជា លោភៈ ។

**ទោសមូលចិត្ត** ញែកបានពីរបទ គឺ

**ទោស** + **មូល**

**ទោសៈ** សេចក្តីប្រទូសរ៉ាយ ( សេចក្តីក្រោធខឹងប្រទូសក្នុងអារម្មណ៍ )

**មូល** ឫស ឬ ឫសគល់ ឬ ឫសកែវ

**មានន័យថា** ចិត្តដែលមានសេចក្តីរឹងត្អឹង ជាឫសកែវ

**មោហមូលចិត្ត** ញែកបានពីរបទ គឺ

**មោហៈ** + **មូល**

**មោហៈ** ចិត្តដែលវង្វេងភាន់ច្រឡំ

**មូល** ឫស ឬ ឫសគល់ ឬ ឫសកែវ

**មានន័យថា** ចិត្តដែលវង្វេង មិនដឹងសេចក្តីពិតនៃសភាវៈទាំងឡាយ ព្រោះធម៌ពប្រការនេះ ( **លោភមូល**

**ទោសមូល មោហមូល** ) ជួនកាលសំដែងថា **លោភ-ហេតុ ទោសហេតុ មោហហេតុ** ព្រមទាំង អកុស-ចេតសិក ១៤ ដួង ទៀត ។

ក្នុងព្រះសាសនានេះ ព្រះពុទ្ធទ្រង់សំដែងទេសនាថា អកុស-ល ទាំងអស់កើតមកអំពីមូល ៣ ប្រការ គឺ

**លោភៈ ទោសៈ មោហៈ** ។ ធម៌ ៣ប្រការនេះប្រៀប ដូចជាឫសកែវរបស់ ដើមឈើ ទ្រង់ទេសនាថា លោភមូល **ទោសមូល មោហមូល** ជួនកាលទ្រង់ ទេសនាថា **លោភហេតុ ទោសហេតុ មោហហេតុ** ព្រោះធម៌៣ ប្រការនេះជាហេតុឱ្យអកុសលចិត្ត ១២ ដួង ព្រមទាំងអកុសលចេតសិក ១៤ ដួង កើតឡើងបាន ដូច្នេះ ជាមួយគ្នា ។

---

## វិធីរាប់ចិត្តជាលោភមូល ៨ ដួង

១. **សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ** (បាលីនេះមានតែទី១+២)

២. សោមនស្សគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ សសង្ខារិកមេកំ

៣. ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកមេកំ សសង្ខារិកមេកំ

៤. ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ សសង្ខារិកមេកំ

ប្រែ - ចិត្តកើតព្រមដោយសោមនស្ស ប្រកបដោយ មិច្ឆា ទិដ្ឋិ ជាអសង្ខារិក ១ ដួង ជាសសង្ខារិក ១ ដួង ។

-ចិត្តកើតព្រមដោយសោមនស្ស ប្រាសចាកមិច្ឆាទិដ្ឋិ ជាអសង្ខារិក ១ ដួង ជា ស.សង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយ ឧបេក្ខា ប្រកបដោយ មិច្ឆាទិដ្ឋិ ជាអសង្ខារិក ១ដួង ជា សសង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយឧបេក្ខា ប្រាសចាកមិច្ឆាទិដ្ឋិ ជា អសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង ។

❊ រួមទាំងអស់ ៨ ដួងគឺ

សោមនស្ស ៤ដួង ឧបេក្ខា ៤ដួង

ឬទិដ្ឋិគតសម្បយុត្ត ៤ដួង ទិដ្ឋិគតវិប្បយុត្ត ៤ដួង

ឬ អសង្ខារិក ៤ដួង សសង្ខារិក ៤ដួង

ពាក្យអធិប្បាយ លោភមូល ៨ ដួង

ពាក្យថា **សោមនស្ស** ញែកបានពីរបទ គឺ

**សុ + មន**

**សុ** ល្អ ឬ ស្អាត

**មន** ចិត្ត

**<u>មានន័យថា</u>** សេចក្តីត្រេកអរ ជាឈ្មោះរបស់វេទនាចេតសិក ១ដួងក្នុងវេទនាទាំង ៣ ឬ វេទនាទាំង ៥ ។

ពាក្យថា **ឧបេក្ខា** ញែកបានពីរបទ គឺ

**ឧប + ឥក្ខា**

**ឧប** តាមសមគួរ ឬ តាមបែបយ៉ាង

**ឥក្ខា** ឃើញ

ពាក្យថា **វេទនា** ប្រែថា ការសោយ

**<u>មានន័យថា</u>** ការសោយតាមសមគួរ បានដល់សេចក្តីព្រងើយកន្តើយចំពោះអារម្មណ៍ ជាឈ្មោះរបស់វេទនា

ចេតសិក ១ដួង ក្នុងវេទនាទាំង ៣ ឬ វេទនាទាំង ៥ ដូចគ្នា ។

ក្នុងទីនេះ សោមនស្សវេទនា បានដល់សេចក្តីត្រេកអរ ក្នុងលោភៈ ឬការសោយលោភៈដោយសេចក្តីត្រេកអរក៏បាន។

ចំណែកឧបេក្ខាវេទនានោះមិនមានសេចក្តីត្រេកអរដូច សោមនស្សទេ ។

**<u>មានន័យថា</u>**

កម្លាំងរបស់ចិត្តទន់ជាងសោមនស្សក្នុងការដែលត្រេកអរចំពោះលោភៈ ហេតុដូច្នោះត្រូវហៅថា ឧបេក្ខា គឺសេចក្តីត្រេកអរបន្តិចបន្តួច ។

**<u>ពាក្យថា</u>** ទិដ្ឋិគតសម្បយុត្ត ប្រែថា ប្រកបដោយមិច្ឆាទិដ្ឋិ គឺសេចក្តីឃើញខុស បានដល់មិច្ឆាទិដ្ឋិចំនួន ៦២ ប្រការ ។

**<u>ពាក្យថា</u>** ទិដ្ឋិគតវិប្បយុត្ត ប្រែថា ប្រាសចាកមិច្ឆាទិដ្ឋិ ៦២ ប្រការ ។

**<u>មានន័យថា</u>** ក្នុងចិត្តលោភមូល ៨ ដួងនេះមានពីរបែប

គឺ មួយបែបដែលមានមិច្ឆាទិដ្ឋិ និង មួយបែបទៀតមិន

មាន មិច្ឆាទិដ្ឋ ។

__ពាក្យថា__ អសង្ខារិក ញែកបានពីរបទ គឺ

**ន + សង្ខារិក**

__ប្រែថា__ មិនមានសង្ខារ

ក្នុងទីនេះសង្ខារ បានដល់បយោគ ឬ ឧបាយ

__ប្រែថា__ បយោគ បានដល់សេចក្ដីព្យាយាមព្រោះការ ដឹកនាំ

របស់អ្នកដទៃ គឺ កាយបយោគ

វិធីបយោគរបស់អ្នកដទៃ ឬ

**កាយ + ឧបាយ => កាយុបាយ**

កាយុបាយ ឬ វិធុបាយរបស់អ្នកដទៃក៏បាន ។

__មាននំយថា__ អសង្ខារិក

សំដៅហេតុ ឧបេក្ខា ប្រែថា ព្រងើយៗ សំដៅដល់ឧបេក្ខា

ក្នុងលោកុត្តរចិត្ត ។ មេត្តាមើលពាក្យអធិប្បាយ ឧបេក្ខា

១០ ប្រការ ក្នុងវេទនាសង្គហបរិច្ឆេទទី ៣ ។

មិនមានកាយសង្ខារ វចីសង្ខាររបស់អ្នកដទៃ (តាមភាសាអ្នកស្រុក) មិនមានការដឹកនាំ ឬ ការហ៊ានដោយខ្លួនឯងក៏ បាន ។

ពាក្យថា **សសង្ខារិក** ញែកបានពីរបទ ដូចគ្នាគឺ

**សហ + សង្ខារ ប្រែថា ព្រមគ្នា ២**

សង្ខារពីរនោះគឺ :

**កាយសង្ខារ**

**វចីសង្ខារ**

កាយសង្ខារ វចីសង្ខារ អំពីអ្នកដទៃ ឬ អាស្រ័យសង្ខារ អ្នកដទៃ មកជួយ ឬ មិនហ៊ានដោយខ្លួនឯងក៏បាន ។

**មានសេចក្តីថា** សសង្ខារិកអាស្រ័យកាយសង្ខារ វចី - សង្ខារ របស់អ្នកដទៃ

អសង្ខារិក មិនត្រូវអាស្រ័យកាយសង្ខារ វចីសង្ខារ របស់អ្នកដទៃ

បរិច្ឆេទទី ១

# ទី៣ៈ អំពីចិត្តទោសមូលពីរដួង

**តាមបាលី**

**ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ** ប្រែសេចក្តីថា ចិត្តកើតព្រមដោយទោមនស្ស ប្រកបដោយ បដិឃៈជាអសង្ខារិក ១ដួង . ជាសសង្ខារិក ១ដួង រួមពីរដួង ។

## អធិប្បាយចិត្តទោសមូល ២ ដួង

ពាក្យថា **ទោសមូល** មកពីបាលី

**ទុ + មន**

**ទុ ប្រែថា មិនល្អ មិនស្អាត**

**មន ប្រែថា ចិត្ត**

**មានន័យថា** ~ ចិត្តដែលមិនល្អ មិនស្អាត មិនប្រពៃ បានដល់សេចក្តីខូចចិត្ត ដែលជាចេតសិក ១ដួង របត វេទនា ទាំង ៣ និង វេទនាទាំង ៥ ។

ពាក្យថា **បដិឃសម្បយុត្ត**

**ប្រែថា** ប្រកបដោយបដិឃៈ គឺ សេចក្ដីខឹងក្រោធនោះឯង ចំណែក អសង្ខារិក និង សសង្ខារិកនោះ ក៏ទំនងជាមួយគ្នា និង ចិត្តជាលោភមូល ដែលពោលមកហើយ ព្រោះហេតុដូច្នោះ ចិត្តជាទោសមូល ២ ដួងនេះ (អសង្ខារិក ឬ សសង្ខារិក ) ក៏ ដោយ ត្រូវមានទោសកើតព្រមជាមួយទោមនស្សវេទនា ជានិច្ច ។

## វិធីរាប់ចិត្តជាមោហមូលពីរដួង

**តាមបាលី ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ**

**ប្រែសេចក្ដីថា** ចិត្តកើតព្រមដោយ ឧបេក្ខាប្រកបដោយ វិចិកិច្ឆា ១ ដួង

ចិត្តកើតព្រមដោយឧទ្ធច្ច ប្រកបដោយឧបេក្ខា ១ ដួង

អធិប្បាយចិត្តជា មោហមូល ២ ដួង

ពាក្យថា **ឧបេក្ខា**

**ប្រែ** ~ សេចក្ដីជាកណ្ដាលរបស់ចិត្ត គឺ ចិត្តមិនជាសោមនស្ស និង មិនទោមនស្ស ឬ មិនត្រេកអរ ( មិនជាប់ ជំពាក់ ) ឬតាមន័យរបស់លោភៈ ឧបេក្ខាប្រែថា ត្រេកអរបន្តិច បន្តួចក៏បាន ។

**ប្រែ** ~ សេចក្ដីសង្ស័យ មកពីបាលីថា **សំសយំ** បានដល់សេចក្ដីសង្ស័យក្នុងព្រះពុទ្ធ **ព្រះធម៌ ព្រះសង្ឃ ខន្ធអាយតនៈ បដិច្ចសមុប្បាទ** ជាដើម ។

**មានន័យថា** សេចក្ដីមិនដឹង នូវសេចក្ដីពិត

ពាក្យ **ឧទ្ធច្ចៈ**

**ប្រែ** ~ សេចក្ដីអណ្ដែតអណ្ដូង រាយមាយរបស់ចិត្ត បានដល់ ចិត្តដែលមិនស្ងប់ ជាធម៌ផ្ទុយ និង ឯកគ្គតាចេតសិក ។

ឥច្ចេវំ សព្វថាបិ ទ្វាទស អកុសលចិត្តានិ សមត្តានិ

ប្រែ ៈ ដូចដែលពោលមកហើយ ចិត្តជាអកុសល ១២ ដួង ចប់ដោយបរិបូរណ៌ហើយដូច្នេះ ។

---

## សំដែងគាថាសង្គហៈ

អដ្ឋានិ លោភមូលានិ ទោសមូលានិ ច ទ្វិធា មោហមូលានិ ច ទ្វេតិ ទ្វាទស កុសលា សិយុំ

ប្រែ ៈ ចិត្តជាលោភមូលមាន ៨ ដួង
ចិត្តជាទោសមូលមាន ២ ដួង
ចិត្តជាមោហមូលមាន ២ ដួង

រួមទាំងអស់ ចិត្តជាអកុសលមានចំនួន ១២ ដួង ប៉ុណ្ណោះ ៕

# បរិច្ឆេទទី ១

វិធីរាប់ចិត្តជាអកុសល ១២ ដួង

- សោមនស្សវេទនា ៤ដួង
- ឧបេក្ខាវេទនា ៦ដួង
- ទោមនស្សវេទនា ២ដួង

---

រួម ១២ដួង

អសង្ខារិក ៥ដួង

សសង្ខារិក ៥ដួង

✵ ផុតសង្ខារទាំងពីរ ២ដួង

---

រួម ១២ដួង

ទិដ្ឋិគតសម្បយុត្ត ៤ដួង

ទិដ្ឋិគតវិប្បយុត្ត ៤ដួង

បដិឃសម្បយុត្ត ២ដួង

✵ ក្រៅអំពីទិដ្ឋិ និង ទោមនស្សសហគត សហិសដិឃសម្បយុត្ត ទៀត ២ដួង រួម ១២ ដួង (៤ + ៤ + ២ + ២)

## សំដែងពីរូបភាពអកុសលចិត្ត ១២ ដួង

| ចិត្តជាលោភមូល ៨ | | | | ទោសមូល ២ | មោហមូល ២ | |
|---|---|---|---|---|---|---|
| សោមនស្សវេទនា | | ឧបេក្ខាវេទនា | | ទោមនស្សវេទនា | ឧបេក្ខាវេទនា | |
| ទិដ្ឋិគត សម្បយុត្ត | ទិដ្ឋិគត វិប្បយុត្ត | ទិដ្ឋិគត សម្បយុត្ត | ទិដ្ឋិគត វិប្បយុត្ត | បដិឃសម្បយុត | ——— | |
| អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | អសង្ខារិក សសង្ខារិក | វិចិកិច្ឆា | ឧទ្ធច្ច |
| ២ | ២ | ២ | ២ | ២ | ១ | ១ |

# អភិធម្មពិស្តារ

សំនួរ-ចំម្លើយ ក្នុងអកុសលចិត្ត ១២ ដួង

**សួរពាក្យថា** ~ ចិត្តជាអកុសល ( ឬ អកុសលចិត្ត ) នោះគឺ ចិត្តអាក្រក់ថោកទាបមួយយ៉ាង ( ម្យ៉ាង ) ដែលទាក់ទងមក អំពី **លោភៈ ទោសៈ មោហៈ** នោះឯង ។

**សួរ** កុសល និង អកុសលផ្សេងគ្នាយ៉ាងណា ?

**ឆ្លើយ** កុសលបានដល់សេចក្តីល្អទាំងអស់ អកុសលបានដល់សេចក្តីអាក្រក់ ទាំងអស់ ។

ការធ្វើសេចក្តីល្អ រមែងបានផលល្អហើយ ការធ្វើសេចក្តីអាក្រក់ រមែងបានទទួលផលអាក្រក់ដូច្នេះឯង ។ ព្រោះហេតុដូច្នោះ កុសលក៏ផ្សេងគ្នាដោយការធ្វើ និងផលរបស់ការ ធ្វើនោះដែរ ។

**សួរ** អកុសលចិត្តមានត្រឹម ១២ ដួង ប៉ុណ្ណោះ ឬ ច្រើនជាងនេះ ?

**ឆ្លើយ** តាមដែលព្រះបរមសាស្តា ទ្រង់ទេសនាទុកក្នុងបរមត្ថនោះថា អកុសលទាំងពួងមានត្រឹមចំនួន ១២ដួង ប៉ុណ្ណោះ មិនមានច្រើនជាងនេះទេ ព្រោះធម្មតា អកុសលរមែងកើតមក អំពី **លោភៈ ទោសៈ មោហៈ** ៣ ប្រការនេះឯង

លោភៈនោះមានត្រឹម ៨ដួង

ទោសៈមានត្រឹម ២ដួង

មោហៈមានត្រឹម ២ដួង

**រួមជាអកុសលចិត្ត ១២ដួង**

ប៉ុណ្ណោះ គ្មានច្រើន ឬ តិចជាងនេះទៀតឡើយ ។

**សួរ** ក្នុងចិត្ត លោភមូល ៨ដួង ព្រមដោយ សោមនស្ស នោះ សោមនស្ស គឺជាអ្វី ?

**ឆ្លើយ** ពាក្យថាសោមនស្ស មកអំពីភាសាបាលី

**សុ + មន**

គឺក្នុងខណៈប៉ះទង្គិចអារម្មណ៍ណាមួយ ហើយ ត្រេកអរ ឡើងចិត្តដែល ប្រកបដោយសេចក្តីត្រេកអរនោះ ហៅ ថា **សោមនស្សវេទនា** ជាឈ្មោះវេទនាចេតសិក ១ ដួង ។

**សួរ** សោមនស្ស និង ឧបេក្ខា ទាំងពីរនេះ ណាមួយមានកម្លាំងច្រើនជាង ?

**ឆ្លើយ** តាមគម្ពីរផ្សេងៗ អធិប្បាយទុកថា សោមនស្ស និង ឧបេក្ខា ទាំងពីរនេះ ម្នាក់ៗក៏មានកម្លាំង និង អានិសង្ស-ច្រើនស្មើគ្នា សឹងតែមានឋានៈ និង សភាពនៃចិត្ត ជាកាមដូចគ្នា សោមនស្សមានកម្លាំង និង អានិសង្សច្រើនជាងឧបេក្ខាណាស់ តែក្នុងមហគ្គតកុសល និង លោកុត្តរកុសលនោះ ឧបេក្ខាមាន កម្លាំងហើយ និងអានិសង្ស ច្រើនជាងសោមនស្ស ព្រោះក្នុង មហគ្គតៈ និង លោកុត្តរចិត្តនោះសោមនស្សផ្ទុយគ្នា និងសមាធិ គឺឯកគ្គតាចេតសិក បានសេចក្តីថា អ្នកដែលសោមនស្ស ច្រើននោះ មិនអាចដល់សមាធិរបស់ អប្បនាសមាធិបាន ។ ហើយម្យ៉ាងទៀតឧបេក្ខានោះចូលក្នុង បញ្ចមជ្ឈានផង ព្រោះ ហេតុដូច្នេះឧបេក្ខាខ្ពស់ជាងសោមនស្សច្រើនតែ ក្នុងមហគ្គតកុសល-ចិត្ត និងលោកុត្តរៈ ។

**សួរ** ពាក្យថាទិដ្ឋិគតសម្បយុត្ត និង វិប្បយុត្តនោះ មានន័យយ៉ាងណា ?

**ឆ្លើយ** ទិដ្ឋិទាំងពីរនេះមាន សេចក្តីថាអ្នកមានចិត្តជាអកុសលទាំងអស់មានមិច្ឆាទិដ្ឋិប្រកបជាមួយ អធិប្បាយថា ក្នុងខណៈដែលធ្វើ អកុសលនោះ អ្នកធ្វើរមែងប្រកាន់មិច្ឆាទិដ្ឋិ ម្យ៉ាង ។

អ្នកដែលមិនប្រកាន់ មិច្ឆាទិដ្ឋិ ហៅថា **ទិដ្ឋិគតសម្បយុត្ត** និង **វិប្បយុត្ត** ។

**សួរ** ក្នុងពាក្យឆ្លើយតប ក្នុងរឿងសោមនស្ស និង ឧបេក្ខានោះក្នុងចិត្តជាកាម ថាបើ ប្រកបដោយសោមនស្ស មាន ផលានិសង្ស ច្រើនជាង មានន័យថា ធ្វើអកុសលសោមនស្ស (សោមនស្សប្រកបដោយ លោភៈ) រមែងមានបាបច្រើនជាង នោះ ប្រពៃហើយ យ៉ាងនោះឯងក្នុងកាលមានទិដ្ឋិ និង មិនមាន ទិដ្ឋិយ៉ាងណា និង មានបាបច្រើនជាងគ្នា ?

**ឆ្លើយ** តាមដែលព្រះបរមសាស្តា សំដែង **មិច្ឆាទិដ្ឋិ បរមានិ ភិក្ខវេ មហាសាវជ្ជានិ**

**ប្រែសេចក្តី** ~ ក្នុងការធ្វើអកុសលនោះ មានមិច្ឆាទិដ្ឋិ ប្រមាណមិនបាន ។

**មានន័យថា** ~ អ្នកមានមិច្ឆាទិដ្ឋិ បាបច្រើន គឺជាអ្នកមិនប្រាសចាកមិច្ឆាទិដ្ឋិ ព្រោះជាអ្នកមានចិត្តមិច្ឆាទិដ្ឋិ នោះត្រូវ ទោសច្រើនប្រការ គឺការប្រកាន់ខុសតែម្យ៉ាង ហើយការធ្វើ អកុសលកម្មបថផ្សេងៗទៀត ក៏ដូច្នោះដែរ ។

**សួរ** ពាក្យថាអសង្ខារិក និង សសង្ខារិក មានន័យ យ៉ាងណា ?

**ឆ្លើយ** ចិត្តជាអសង្ខារិក ប្រែ ចិត្តដែលមិនមានសង្ខារដឹកនាំ ចំណែក សសង្ខារិក នោះមានអ្នកដឹកនាំ ឬ មានសង្ខារដឹកនាំ ។

**សួរ** សង្ខារបានដល់អ្វី ? ប្រែថាយ៉ាងណាខ្លះ ?

**ឆ្លើយ** សង្ខារ ប្រែបានច្រើនន័យ

- **សព្វេ សង្ខារា អនិច្ចា**

សង្ខារនេះបានដល់ រូប និង នាម ។

- **អវិជ្ជា បច្ចយា សង្ខារា**

សង្ខារនេះបានដល់ កុសល និង អកុសល ក្នុងខន្ធ ៥ ។

- **សង្ខារក្ខន្ធោ**

បានដល់ចេតសិក ៥០ ដួង ។

- **តយោមេ ភិក្ខវេ សង្ខារា កាយសង្ខារោ វចីសង្ខារោ**

សង្ខារនេះបានដល់ ខ្យល់ដកដង្ហើមចូល ដកដង្ហើមចេញ ។

ក្នុងទីនេះ **កាយសង្ខារ វចីសង្ខារ** បានដល់ **កាយបយោគ វចីបយោគ** គឺជាហេតុឱ្យព្យាយាមនោះឯង ដូច្នោះ ក្នុងសសង្ខារិក កាយ និង វាចារបស់អ្នកដទៃ ជាហេតុធ្វើឱ្យមានអកុសល ។ អសង្ខារិកក៏ដូចគ្នា សសង្ខារិក គឺ គ្មានអ្នកដទៃដឹកនាំទេ មានចេតនា

កើតឡើងឯង ។

**សួរ៖ លោភៈ ទោសៈ មោហៈ** ជាចេតសិក ឬចិត្ត ?

**ឆ្លើយ៖ លោភៈ ទោសៈ មោហៈ** ទាំងបីនេះជាចេតសិក តែងកើត ព្រមជាមួយ ចិត្តនោះដែរ អង្គុត្តរ

**បាលី មនោ តេសំ ធម្មានំ បឋមំ ឧប្បជ្ជតិ**

**ប្រែ** ចិត្តកើតមុន ចេតសិក

ពន្យល់សេចក្តីតទៅទៀត **បភស្សរមិទំ មិទំ ភិក្ខវេ ចិត្តំ តញ្ចខោ អាគន្តុកេហិ ឧបកិលេសេហិ ឧបក្កិលិដ្ឋំ**

## ❋ សេចក្តីព្រះបាលីនេះពន្យល់ថា

កាលចិត្តកកើតពីដំបូង មិនដឹងថាជាចិត្តអ្វី ? ព្រោះថា ធម្មជាតិចិត្ត ប្រាសចាកគ្រឿងសៅហ្មងផ្សេងៗ កាលចេតសិក កើតឡើងទើបដឹងបានថាជា **លោភៈ ទោសៈ មោហៈ**កាលនឹងបានដឹងក៏ព្រោះ **លោភៈ ទោសៈ**

**មោហ**ចេតសិក ។ ( ក្នុងទីនេះមានពាក្យ **តេសំ ធម្មានំ** មានន័យដល់ចិត្ត និង ចេតសិក ដែលជា នាមធម៌ផង ) ។

មោហចេតសិក ជាប់តាមក្រោយមក ដូចស្រមោលជាប់វត្ថុជានិច្ច ដូច្នេះទើបព្រះអនុរុទ្ធាចារ្យ សំដែងទុកក្នុងអភិធម្មត្ថ សង្គហៈថា **លោភមូល ទោសមូល មោហមូល** មានន័យថា ចេតសិកអម្បាលនេះជា លោភចេតសិកជា មូល, ទោសចេតសិក ជាមូល, មោហ-ចេតសិកជាមូល ដូច្នេះ

## សំដែងចិត្តជាអហេតុកៈ ១៨ ដួង

**តាមបាលី**

**ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ តថា សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ ទុក្ខសហគតំ កាយវិញ្ញាណំ ឧបេក្ខាសហគតំ សម្បដិច្ឆន្នំ ចិត្តំ ឧបេក្ខាសហគតំ សន្តីរណ-**

**ចិត្តព្យេតិ ឥមានិ សត្តបិ អកុសលវិបាកចិត្តានិ នាម**

**ប្រែ** ព្រមដោយឧបេក្ខាវេទនា ចិត្តជាចក្ខុវិញ្ញាណ ១ដួង សោតវិញ្ញាណ ១ដួង ឃានវិញ្ញាណ ១ដួង ជីវ្ហាវិញ្ញាណ ១ ដួង ព្រមដោយទុក្ខវេទនាកាយវិញ្ញាណ ១ដួង ព្រមដោយ ឧបេក្ខាវេទនា គឺ សម្បដិច្ឆន្ន និង សន្តីរណៈរួម ៧ ដួងដែលពោលមកហើយនេះ ហៅថា អកុសល វិបាកចិត្ត ។

## ពាក្យអធិប្បាយអកុសលវិបាកចិត្ត ៧ដួង

✧✧✧✧✧

ពាក្យថា **អហេតុកៈ** ញែកបានពីរបទ

**ន + ហេតុកៈ**

**ន** ប្រែថា **មិនមាន**

**ហេតុកៈ** ប្រែថា **ហេតុ**

មានន័យថាចិត្តដែលមិនមានហេតុ គឺ **លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ** រួមហេតុ ៦ ប្រការ ។

ន័យមួយទៀត ពាក្យថាអហេតុកៈ ជានាមរបស់រូបទាំងអស់ ព្រោះហេតុដូច្នេះ អហេតុកៈ

**ប្រែថា** រូបមានចិត្ត ( ថ្មើម ) ដែលរមែងកើតមកអំពីអហេតុកៈ គឺ ចក្ខុបសាទជារូប រូបារម្មណ៍ជារូប រួមទាំងពីរហៅថា អហេតុកៈ ។

កាលអហេតុកៈទាំងពីរ ប៉ះទង្គិចគ្នាភ្លាមហើយ ចិត្តជាចក្ខុវិញ្ញាណ ក៏រមែងកើត ចក្ខុវិញ្ញាណកើតមកដោយព្រោះ អហេតុកៈនោះឯង ។ ព្រោះហេតុដូច្នោះ ចិត្តដួងនេះក៏ហៅថា អហេតុកចិត្ត ( មេត្តាមើល បរិច្ឆេទ ទី ៦ )

✵ ពាក្យថា **អកុសលវិបាក** ញែកបាន ៣ បទគឺ

| | | |
|---|---|---|
| **ន** + | **កុសល** + | **វិបាក** |
| **ន** | **ប្រែថា** | មិនមែន |

**កុសល ប្រែថា សេចក្តីល្អ**

**វិបាក ប្រែថា ជាផល**

មានន័យថា ជាផលរបស់សេចក្តីមិនល្អ បានដល់ ផលធម៌របស់សេចក្តីអាក្រក់ ឬ ជាផល របស់ចិត្ត អកុសល ឬ ចិត្តដួង នេះបានកើតព្រោះអកុសល ។

ពាក្យថា ចក្ខុវិញ្ញាណ ញែកបាន ២ បទគឺ :

**ចក្ខុ + វិញ្ញាណ**

**ចក្ខុបសាទ ឬ ភ្នែក វិញ្ញាណ**

សេចក្តីដឹងខ្លួន

**មានន័យថា** ចិត្តដួងនេះដឹងបាន ព្រោះអាស្រ័យភ្នែក ឬ កាលណាប៉ះទង្គិចភ្នែកហើយ សេចក្តីដឹងខ្លួន កើតបានមួយរំពេច ។

**ពាក្យថា សោតវិញ្ញាណ** វិញ្ញាណសេចក្តីដឹងខ្លួន

**មានន័យថា** ចិត្តដួងនេះដឹងបានព្រោះអាស្រ័យ ត្រចៀក ឬ កាលសំឡេងប៉ះទង្គិចត្រចៀក ហើយសេចក្តីដឹងកើតដូច

ជាមួយ និង ភ្នែកដែរ ។

- **ឃានវិញ្ញាណ** ញែកបាន ២ បទ

**ឃាន + វិញ្ញាណ**

**វិញ្ញាណ** សេចក្ដីដឹងខ្លួន

**មានន័យថា** ចិត្តដួងនេះដឹងបានព្រោះអាស្រ័យ ច្រមុះ ឬ កាលក្លិនប៉ះទង្គិចច្រមុះ ហើយសេចក្ដីដឹង ដូចជាមួយគ្នា ។

ពាក្យថា **ជីវ្ហាវិញ្ញាណ** ញែកបាន ២ បទ

**ជីវ្ហា + វិញ្ញាណ**

**ជីវ្ហា = អណ្ដាត**

**វិញ្ញាណ** = សេចក្ដីដឹងខ្លួន

**មានន័យថា** ចិត្តដួងនេះ ដឹងបានព្រោះអណ្ដាត ឬ កាលរសជាតិ ប៉ះទង្គិចអណ្ដាតហើយ សេចក្ដីដឹងក៏កើត រួមជាមួយគ្នា ដូចវិញ្ញាណ ៤នេះកើតព្រមដោយ ឧបេក្ខាវេទនាទាំងអស់ ចំណែកកាយវិញ្ញាណ កើតព្រម ដោយទុក្ខវេទនា ។

- **ពាក្យថា . កាយវិញ្ញាណ** ញែកបាន ២ បទ

កាយ ( រាងកាយ  វិញ្ញាណ ( សេចក្ដីដឹង ខ្លួន)

**មានន័យថា** ចិត្តដួងនេះ ដឹងបាន ព្រោះអាស្រ័យ រាងកាយ ឬ កាលប៉ះវត្ថុណាមួយ មកប៉ះពាល់កាយហើយ សេចក្ដីដឹងកើតឡើង ។ សេចក្ដីដឹងនោះជាទុក្ខវេទនាប្រកប ដោយខ្លួនឯង ។

- **ពាក្យថា សម្បដិច្ឆន្នៈ** ញែកបានពីរបទ

**សំ** + **បដិច្ឆន្នៈ**

**សំ** **ប្រែ** ដោយល្អ

**បដិច្ឆន្នៈ** **ប្រែថា** ទទួលទុក

**មានន័យថា** ចិត្តនេះកាលវិញ្ញាណចិត្ត ៥ ដួង រលត់ហើយ ទទួលតអារម្មណ៍ ដែលវិញ្ញាណឱ្យមក ។

ពាក្យថា **សន្តីរណៈ** ញែកបានពីរបទ

**សំ** + **តីរណៈ**

**សំ** **ប្រែថា** ដោយល្អ

**តីរណៈ** **ប្រែថា** ត្រិះរិះ , សាក សួរ

ដោយល្អ ឬទេ ។

**មានន័យថា** ចិត្តដួងនេះ កាលមានចិត្តជាសម្បដិច្ឆន្នៈទទួលអារម្មណ៍មកហើយ ពិចារណាសាកសួរថា ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍រួមទាំង សម្បដិច្ឆន្នៈ សន្តីរណៈទាំងពីរនេះជាឧបេក្ខាទាំងអស់ ។ ព្រោះក្នុងខណៈនោះ មិនមានសោមនស្ស ឬ ទោមនស្សយ៉ាងណាមួយក្នុងអកុសលវិបាក

នោះទេ ។

## សំដែងពី កុសលវិបាកចិត្ត ៨ ដួង

**តាមបាលី**

**ឧបេក្ខាសហគតំ កុសលវិបាកំ ចក្ខុវិញ្ញាណំ តថា សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ សុខសហគតំ កាយវិញ្ញាណំ ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ សោមនស្ស-សហគតំ(1) ឧបេក្ខាសហគតំ សន្តីរណចិត្តពេ្វតិ ឥមានិ អដ្ឋបិ (កុសលវិបាកា អហេតុក-ចិត្តានិ) នាម**

**សេចក្តីថា**

ព្រមដោយឧបេក្ខាវេទនាចិត្ត ជាចក្ខុវិញ្ញាណ ១ ដួង ដែលជាផលរបស់កុសល ដូចជា

---

(១) **សន្តីរណចិត្តំ**

សោតវិញ្ញាណ ១ដួង ឃានវិញ្ញាណ ១ដួង ជីវ្ហាវិញ្ញាណ ១ដួង កើតព្រមដោយ សុខវេទនា កាយវិញ្ញាណ ១ដួង ព្រមដោយ ឧបេក្ខាវេទនា សម្បដិច្ឆន្នចិត្ត ១ដួង ព្រមដោយ សោមនស្សវេទនា សន្តីរណចិត្ត ១ដួង

រួម ៨ ដួង នេះហៅថា កុសលវិបាក អហេតុកចិត្ត ។

<u>កុសលវិបាក ចិត្ត ៨ ដួង</u>

**ពាក្យថាវិបាក** - ប្រែថា ជាផល

**មានន័យថា** - ចិត្ត ៨ ដួងនេះកើតបានព្រោះ កុសល ឬ នឹង ថាជាផលនៃកុសល ក៏បាន ។

**ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយៈ**

**រួមជា = បញ្ចវិញ្ញាណ ចិត្ត៥ ដួង និង សម្បដិច្ឆន្នៈ ១ដួង សន្តីរណៈ ២ ដួង**

**រួមជា = ៨ដួង** ។ ៨ដួងនេះក៏ទំនងជា១គ្នា និង ចិត្តជា កុសលវិបាក ( និង អកុសលវិបាកចិត្ត ) ។

គ្រប់ប្រការ ផ្សេង គ្នាតែអកុសលវិបាកចិត្ត ៧ ដួងនេះ ជាផលរបស់ អកុសល ។ កុសលវិបាកចិត្ត ៨ ដួងនេះ ជាផលរបស់កុសលប៉ុណ្ណោះ ក្នុងទី នេះ ព្រះបរមសាស្តា ទ្រង់ទេសនា កុសលវិបាកចិត្ត ៨ ដួង និង អកុសល វិបាកចិត្ត ៧ ដួងដែលមិនស្មើគ្នានោះ ព្រោះចំណែក កុសល វិបាកចិត្ត មានអារម្មណ៍ច្រើនជាងអកុសលវិបាកចិត្ត ។

ដូច្នេះ ចាំបាច់ដែលនឹងត្រូវទ្រង់ ទេសនា សន្តីរណៈ ២ ដួង គឺ សោមនស្ស ១ ដួង ឧបេក្ខា ១ ដួង ។

## សំដែងកិរិយាចិត្ត ៣ ដួង

## តាមបាលី

ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ តថា មនោទ្វារាវជ្ជនចិត្តំ សោមនស្សសហគតំ ( ហសិតុប្បាទ ចិត្តញ្ចេតិ ) ឥមានិ តីណិបិ ( អហេតុក កិរិយា ចិត្តានិ ) នាម

ប្រែសេចក្តីថា

ព្រមដោយឧបេក្ខាវេទនាចិត្តជាបញ្ចទ្វារាវជ្ជន ១ដួង និង មនោទ្វារាវជ្ជនៈ ១ ដួង ព្រមដោយសោមនស្សវេទនាចិត្តជាហសិតុប្បាទ ១ ដួង រួម ៣ ដួងនេះ ហៅថា អហេតុកកិរិយាចិត្ត ។

# អធិប្បាយចិត្តជាកិរិយា ៣ ដួង
# អធិប្បាយកិរិយាចិត្ត ៣ ដួង

ពាក្យថា បញ្ចទ្វារាវជ្ជន ញែកបាន ៣ បទ គឺ

បញ្ច + ទ្វារៈ + អាវជ្ជនៈ

បញ្ច ប្រែថា ប្រាំ

ទ្វារៈ ប្រែថា ទ្វារ

អាវជ្ជនៈ ប្រែថា ការពិចារណា

**មានន័យថា**

កាលដែលចិត្តជា ភវង្គុបច្ឆេទរលត់ហើយ ចិត្តដែលពិចារណា ទទួលអារម្មណ៍ថ្មី ដែលប៉ះទង្គិចទ្វារ ទាំង ៥ ហៅថា បញ្ចទ្វារាវជ្ជនៈ បានដល់ចិត្តចំនួន ៥ ដួង គឺ

- **ចក្ខុទ្វារាវជ្ជនៈ**
- **សោតទ្វារាវជ្ជនៈ**
- **ឃានទ្វារាវជ្ជនៈ**
- **ជិវ្ហាទ្វារាវជ្ជនៈ**
- **កាយទ្វារាវជ្ជនៈ តាមលំដាប់ ៗ**

ពាក្យថា មនោទ្វារាវជ្ជនៈ ញែកបាន ៣ បទ គឺ

មនោ + ទ្វារៈ + អាវជ្ជនៈ

មនោ ប្រែថា ចិត្ត

ទ្វារៈ ប្រែថា ទ្វារ

**អាវជ្ជនៈ** **ប្រែថា** ការពិចារណា

**មានន័យថា**

ចិត្តដែលពិចារណា កាលដែលអារម្មណ៍ទាំង ៦ មកប៉ះ ទង្គិច ទ្វារទាំង ៦ ។

**បញ្ចទ្វារាវជ្ជនៈ និង មនោទ្វារាវជ្ជនៈ** ពីរដួងនេះ រមែងកើតជាមួយឧបេក្ខាទាំងអស់ ។

**ពាក្យថា**

**ហសិតុប្បាទ** ញែកបានពីរបទ

**ហសិត** + **ឧប្បាទៈ**

**ហសិត** **ប្រែ** ញញឹមញញែម

**ឧប្បាទៈ** **ប្រែ** កើត

**មានន័យថា** ចិត្តដែលធ្វើកើត ការញញឹមញញែម បានដល់ចិត្ត របស់ព្រះអរហន្ត ចិត្តព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទាំងឡាយ ១ ដួង ។ ចិត្ត ១ ដួងនេះ កើតព្រមដោយសោមនស្សវេទនា ។

**ឥច្ចេវំ សព្វថាបិ អដ្ឋារស អហេតុក-**
**ចិត្តានិ សមត្តានិ ។**

ប្រែ ដូចដែលពោលមកហើយ ចិត្តជាអហេតុក ១៨ ដួង ចប់ដោយបរិបូរណ៍ ដោយប្រការដូច្នេះ ។

## ពាក្យថាសង្គហៈ

**សត្តា កុសលបាកានិ បុញ្ញបាកានិ អដ្ឋធា**
**ក្រិយា ចិត្តានិ តីណីតិ អដ្ឋារស អហេតុកា**

ប្រែ អកុសលវិបាកចិត្ត ៧ ដួង កុសលវិបាកចិត្ត ៨ ដួង កិរិយាចិត្ត ៣ ដួង រួមជា អហេតុកចិត្ត ១៨ ដួង ។ (ដោយបរិបូរណ៍)

បរិច្ឆេទទី ១

# សំដែងវិធីរាប់ អហេតុកចិត្ត ១៨ដួង

| | |
|---|---|
| ~ អកុសលវិបាកចិត្ត | ៧ដួង |
| ~ កុសលវិបាកចិត្ត | ៨ដួង |
| ~ កិរិយាចិត្ត | ៣ដួង |
| រួម | ១៨ដួង |

| | |
|---|---|
| ~ ទ្វិបញ្ចវិញ្ញាណចិត្ត | ១០ដួង |
| ~ មនោធាតុ | ៣ដួង |
| ~ មនោវិញ្ញាណធាតុ | ៥ដួង |
| រួម | ១៨ដួង |

| | |
|---|---|
| ចិត្តជាសោមនស្សវេទនា | ២ដួង |
| ចិត្តជាទុក្ខវេទនា | ១ដួង |
| ចិត្តជាសុខវេទនា | ១ដួង |
| ចិត្តជាឧបេក្ខាវេទនា | ១៤ដួង |
| រួម | ១៨ដួង |

# តារាងសំដែង អហេតុកចិត្ត ១៨ដួង

✧✧✧✧✧✧

| ឈ្មោះចិត្ត | ឧបេក្ខា | ឧបេក្ខា | ឧបេក្ខា | ឧបេក្ខា | ទុក្ខ | សុខ | ឧបេក្ខា | ឧបេក្ខា | ឧបេក្ខា | សោមនស្ស | រួម |
|---|---|---|---|---|---|---|---|---|---|---|---|
| អកុសល វិបាក | ចក្ខុ | សោត | ឃាន | ជីវ្ហា | កាយ | × | សម្បដិច្ឆន្ន | សន្តីរណ | × | × | ៧ |
| កុសល វិបាក | ចក្ខុ | សោត | ឃាន | ជីវ្ហា | | កាយ | សម្បដិច្ឆន្ន | សន្តីរណ | × | សន្តីរណ | ៨ |
| កិរិយា | × | × | × | × | × | × | × | × | វោដ្ឋព្វន២ | ហសិតុប្បាទ១ | ៣ |
| រួម | ២ | ២ | ២ | ២ | ១ | ១ | ២ | ២ | ២ | ២ | ១៨ |

# បរិច្ឆេទទី ១

## ពាក្យសួរ ឆ្លើយ អំពីអហេតុកចិត្ត ១៨ ដួង

**សួរ** អហេតុកចិត្តគឺអ្វី ?

**ឆ្លើយ** អហេតុចិត្ត សំដៅដល់ចិត្តដែលប្រាសចាកហេតុ ៦ គឺ

**លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ** រួម ៦ ប្រការ ។

**មានន័យថា**

ចិត្ត ១៨ ដួង រមែងកើតដោយធម្មតា គ្មានចិត្តដែលកើត មកដោយហេតុណាមួយទេ ។

**សួរ** ពាក្យថា ចិត្ត និង វិញ្ញាណ ផ្សេង១យ៉ាងណា ?

**ឆ្លើយ** ពាក្យថា ចិត្ត និង វិញ្ញាណ និង ពាក្យថា មនោ សំដៅ ដល់ពេលជាមួយគ្នា (ពេលតែមួយខណៈ ) តាមវិគ្គហៈរបស់ សព្ទថា អារម្មណំ ចិន្តេតីតិ ចិត្តំ ។

**ពាក្យថា ចិត្ត** ប្រែថា ព្រោះដឹងអារម្មណ៍ ដូច្នេះ ហៅថា **ចិត្ត** ។

ពាក្យថា **វិញ្ញាណ** បទវិគ្គហៈថា **វិជានាតីតិ វិញ្ញាណំ**

**ប្រែ** ព្រោះដឹងដូច្នេះហៅថា **វិញ្ញាណ**

ពាក្យថា **មនោ** ក៏ដូចគ្នា គឺ តាម**វិគ្គហៈថា មនតិ ជានាតីតិ មនោ**

**ប្រែ** ព្រោះដឹង ដូច្នេះហៅថា **មនោ**

រួមទាំង ៣ **ចិត្ត វិញ្ញាណ មនោ** សំដៅ ដល់ សេចក្តីដឹងអារម្មណ៍ជាមួយគ្នា គឺ ចិត្តនោះឯង ជា វិញ្ញាណ វិញ្ញាណនោះឯងជាមនោ មនោនោះជាចិត្ត ដូច្នេះ ក្នុង បដិសម្ភិទា ព្រះបាលីមហាវគ្គ សំដែងថា **យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ**

# ព្រះអភិធម្មពិស្តារ

## ប្រែសេចក្តីថា

ពាក្យថា **ចិត្តំ មនោ វិញ្ញាណំ មានសំ ហទយំ បណ្ឌរំ ... ធាតុ**

មនោធាតុទាំងអម្បាលនេះ ហៅថា ចិត្តទាំងអស់ **ស្នូរ** ពាក្យថាចិត្ត ប្រែ ដឹងអារម្មណ៍

- ពាក្យថាវិញ្ញាណ ប្រែ ដឹងអារម្មណ៍ ដូចគ្នា

ដូចនេះហើយ ហេតុក្នុងកុសលវិបាក អកុសលវិបាក ចិត្ត នោះហៅថា **ចក្ខុចិត្ត** ហៅថា **វិញ្ញាណចិត្ត** នោះ មិនហួស ពាក្យទៅឬ ?

**ឆ្លើយ** ការតាំងឈ្មោះចិត្តនោះ ព្រះបរមសាស្តាអាស្រ័យ តាមហេតុតាមផល គឺ ចិត្តតែម្យ៉ាង ទ្រង់ហៅដោយ អាស្រ័យ ហេតុ តួយ៉ាងចិត្តជា **លោភមូល ទោសមូល**

ជាដើម បាន តែម្យ៉ាង១ ក៏ទ្រង់ហៅដោយអាស្រ័យទ្វារ ដូច្នោះ ដូចជាចក្ខុទ្វារវិថីចិត្ត មនោទ្វារវិថី ចិត្តជាដើម

ចិត្តម្យ៉ាងទៀត ក៏ទ្រង់ ហៅដោយអាស្រ័យវត្ថុ ដូចជា ចក្ខុវិញ្ញាណ សោតវិញ្ញាណ ជាដើម ព្រោះកាល រូបារម្មណ៍ ប៉ះទង្គិច ចក្ខុវត្ថុ សេចក្តីដឹង កើតឡើង ក្នុងខណៈនោះ ។

ហេតុដូច្នេះ សេចក្តីដឹងនេះ ហៅថា ចក្ខុវិញ្ញាណ ។ ចក្ខុវិញ្ញាណ នេះឯង ជាជាតិចិត្ត ជាបរមត្ថ ដូច្នេះហៅថា **ចក្ខុវិញ្ញាណចិត្ត** ។

ថាបើមិនប្រកបដោយវិញ្ញាណស័ព្ទ ក៏អាចនិងមាន មនុស្ស ចូលចិត្តខុសបានថា ចក្ខុនេះឯងជាចិត្ត ដោយ ត្រង់ដែលជា សេចក្តី ពិតគ្មានដូច្នេះទេ ។ ពាក្យថាចក្ខុ ជាធម្មជាតិរូប ចិត្តជាធម្មជាតិ នាម ។

ដូច្នេះដើម្បីសេចក្តីចូលចិត្តខុសថា ចក្ខុបសាទរូប ជាចិត្ត ។

ព្រះបរមសាស្តាទ្រង់ទេសនា ចក្ខុវិញ្ញាណចិត្ត ។ ចក្ខុវិញ្ញាណ មាននិយ័យថា សេចក្តីដឹង ដែលអាស្រ័យ ការ ប៉ះទង្គិច រូប និង ចក្ខុ ហៅថា ចក្ខុវិញ្ញាណចិត្ត ដូចនេះ ។

**សួរ** ក្នុងបសាទរូបទាំង ៥ នេះ **ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ** ទាំងអម្បាលនេះ កាលអារម្មណ៍ ខាងក្រៅ មកប៉ះទង្គិច សេចក្តីដឹងហៅថា វិញ្ញាណ ។ វិញ្ញាណ ទាំងអម្បាលនេះ កើតព្រមដោយឧបេក្ខាវេទនា បានគ្រប់ចិត្ត ហេតុដូចម្តេច កាយវិញ្ញាណទាំងពីរ ទើបកើតព្រមដោយ ឧបេក្ខាវេទនា មិនបានដូចវិញ្ញាណដទៃៗទេ ។

**ឆ្លើយ** ព្រោះ **ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ** ចិត្ត ៤ ដួងនេះទាក់ទងមកអំពី ឧបាទាយរូប រូបារម្មណ៍ ក៏ជាឧបាទាយរូបដែរ ការប៉ះទង្គិច នៃ ឧបាទាយរូបនោះ ដូចការប៉ះទង្គិចសំឡី និង សំឡី ។ ការប៉ះទង្គិចនោះរមែង មិនអាក្រក់ខ្លាំង

ទើបជាឧបេក្ខាវេទនាទាំងអស់ ។ ការប៉ះទង្គិចរបស់ផោដ្ឋព្វៈ ជាមួយ និង កាយនោះ មិន ដូចគ្នាទេ ពីជាការប៉ះទង្គិច នៃមហាភូត និង មហាភូត មាន ន័យថា **បឋវី តេជោ វាយោ** ធាតុទាំង ៣ នេះមកប៉ះ ទង្គិចកាយ ដែលជាគណរបស់ **បឋវី តេជោ វាយោ** ដែលជាមហាភូត ដូចគ្នានេះដែរ ទើបមានកម្លាំងខ្លាំង ដូច្នេះជាទុក្ខវេទនា ឬ សុខវេទនា កើតបានដោយហេតុនេះ ។

**សួរ** ក្នុងអកុសលវិបាកចិត្តនោះ ចិត្តជាសន្តីរណៈមានតែមួយដួង ដែលជាឧបេក្ខាវេទនា តែក្នុងកុសលវិបាកចិត្តដូចម្តេចមាន ២ ដួង គឺ **សោមនស្សសន្តីរណៈ** និង **ឧបេក្ខាសន្តីរណៈ** ?

**ឆ្លើយ** ធម្មតា សន្តីរណៈ រមែងពិចារណា សាកសួរអារម្មណ៍ ដែលសម្បដិច្ឆន្នៈ ទទួលមកអំពី វិញ្ញាណចិត្តទាំង ៥ ដួង អារម្មណ៍មានពីរ គឺ គ្រេកអរ និង មិនគ្រេកអរ ( ជាប់ជំពាក់ និង មិន ជាប់ជំពាក់ ) ។

• ក្នុងកាត្រេកអរ រមែងចែកជាពីរគឺ **ឥដ្ឋារម្មណ៍** និង **អនិដ្ឋារម្មណ៍** ។ ចំណែកមិនត្រេកអរនេះ មានត្រឹមតែមួយ គឺ **អនិដ្ឋារម្មណ៍** អារម្មណ៍ដែលមិន ជាទីគាប់ចិត្ត ជានាទី របស់ឧបេក្ខា បើជាអតិឥដ្ឋារម្មណ៍ ត្រូវជាសោមនស្សជានិច្ច ។ ចំណែកអកុសលវិបាកចិត្តនោះ ជាអនិដ្ឋារម្មណ៍ច្រើន ឬ តិច ប៉ុន្មានក្តី ជានាទីរបស់ឧបេក្ខាទាំងអស់ ព្រោះធម្មតាអ្នកដែល ទទួល អនិដ្ឋារម្មណ៍គ្រប់គ្នា រមែងមិនចូលចិត្ត និង ព្យាយាម គេចឱ្យផុតអំពីអនិដ្ឋារម្មណ៍ ជានិច្ច គឺ មិនមែនព្យាយាមជា មួយអារម្មណ៍នេះបាន ដូច្នេះ បើវិញ្ញាណទាំង៥ រលត់ទៅហើយ អារម្មណ៍ទាំងប្រាំ ដែលសម្បដិច្ឆន្នៈ ទទួលទុក ក៏រមែងទៅកាន់សេចក្តីព្រងើយកន្តើយ គឺ ក្លាយជាឧបេក្ខាវេទនាទៅ អកុសលវិបាកទើបមានតែសន្តីរណចិត្ត ១ ដួង គឺ គ្មានសោមនស្សវេទនា ព្រោះបើជាទោមនស្សវេទនាហើយ ចាំបាច់ដែលនឹង ត្រូវយក បដិឃៈមកប្រកបជាមួយ ។

តែបដិឃៈ ជាធម្មជាតិ ជាអកុសលចិត្ត ។ សន្តីរណៈជាធម្មជាតិ អហេតុកវិបាកចិត្ត ដែលជាអព្យាកតធម៌ ។ ព្រោះហេតុដូច្នេះ ក្នុងអកុសលវិបាកចិត្តទាំង ៧ ដួងនេះ ទើបមិនមានទោមនស្ស ( ដូចនេះ ) វេទនា ។

**សួរ** អហេតុកចិត្ត ១៨ ដួង ពាក្យថា សន្តីរណៈ ប្រែថា ពិចារណា ពាក្យថាបញ្ចទ្វារាវជ្ជនៈ មនោទ្វារាវជ្ជនៈ ក៏ប្រែថាពិចារណា ។ ការពិចារណាទាំង អម្បាលនេះផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាបញ្ចទ្វារាវជ្ជនៈ

**ប្រែថា** ចិត្តដែលពិចារណាទ្វារទាំង ៥ គឺ កាលអារម្មណ៍ទាំង៥ ប៉ះទង្គិចទ្វារទាំង៥នោះ ចិត្តដែលពិចារណាអារម្មណ៍គ្រាដំបូង ដូចចាត់តាមតម្រួតរក្សាទ្វាររបស់ព្រះរាជា ។

**ពាក្យថា** សន្តីរណៈ

**ប្រែថា** ចិត្តដែលសាកសួរអារម្មណ៍ ថានេះជាឥដ្ឋារម្មណ៍ ឬ អនិដ្ឋារម្មណ៍ ក្រោយអំពីសម្បដិច្ឆន្នៈដែលទទួលអារម្មណ៍

ចូលមក ហើយប្រដូចភ្នាក់ងារដែល អនុញ្ញាតចូលក្នុងផ្ទះបាន ដូច្នេះ ពាក្យមនោទ្វារាវជ្ជនៈ ប្រែថា ចិត្តរមែងពិចារណាទទួលខុសត្រូវ ជាទីបំផុត ដូចព្រះរាជាអ្នកមានអំណាច គ្រប់បែប គ្រប់យ៉ាង ក្នុងទីនេះ បញ្ចទ្វារាវជ្ជនៈជាចិត្តមួយបែប មនោធាតុសន្តីរណៈ និង មនោទ្វារាវជ្ជនៈជាបែបចេតសិក ។ មនោវិញ្ញាណធាតុផ្សេង គ្នាដូច្នេះ ។

(សេចក្តីបែបផ្សេងៗ របស់មនោធាតុ និង មនោវិញ្ញាណធាតុ មានអធិប្បាយក្នុងបរិច្ឆេទទី ៧ ហើយ ) ។

**សួរ** ពាក្យថា ហសិតុប្បាទ មានន័យថាយ៉ាងណា ?

**ឆ្លើយ** ពាក្យថា ហសិតុប្បាទនេះមានន័យ ជាកិរិយាចិត្ត ១ ដួង ដែលធ្វើឱ្យព្រះអរហន្តញញឹម ក្នុងអារម្មណ៍ដែលប្រកបដោយ សោមនស្សវេទនា ទាំងនេះ ។

**សួរ** ការសើច ការញញឹមរបស់បុថុជ្ជន ជាហសិតុប្បាទឬទេ ?

ឆ្លើយ មិនមែនទេ ព្រោះ ការសើចនោះ ជាវិញ្ញត្តិរូប ដែលជារូបធម៌ ។ ចំណែកហសិតុប្បាទនោះ ជាកិរិយាចិត្ត ដែលជានាម ធម៌ ។

សួរ បុថុជ្ជនសើចដោយចិត្តអ្វី ? បើមិនមែនហសិតុប្បាទ ?

ឆ្លើយ បុថុជ្ជនសើច ដោយចិត្តសោមនស្ស ៨ ដួង គឺ ក្នុងលោភមូល ៤ ដួង និងក្នុងមហាកុសលចិត្ត ៤ ដួង រួម ៨ ដួង ដូចដែលលោកដីកាចារ្យ សំដែងទុកថា " បុថុជ្ជនា ហសន្តេត្ថ (ចិត្តេ ហិ) បន (អដ្ឋ ហិ) (ឆ ហិ) សេក្ខា អសេក្ខា ច ចិត្តេ ហិ បន បញ្ច ហិ "

ប្រែ ការសើចរបស់បុថុជ្ជននោះ អាស្រ័យចិត្ត ៨ ដួង គឺ :

- លោភមូល សោមនស្ស៤ដួង និង
- មហាកុសល សោមនស្ស៤ដួង

---

រួម ៨ដួង

• សេក្ខបុគ្គល សើចដោយចិត្តជាសោមនស្ស ៦ ដួង គឺ :

- ទិដ្ឋិគតវិប្បយុត្ត ចិត្តជាសោមនស្សក្នុង លោភមូល ២ ដួង ។

- ក្នុងសោមនស្ស មហាកុសល ៤ ដួង រួម៦ ដួង ។

ព្រះអរហន្ត សើចក្នុង ៥ ដួងគឺ :

~ **ហសិតុប្បាទ ១ដួង**

~ **សោមនស្សក្នុងចិត្តជាមហាកិរិយា៤ដួង**

**រួម ៥ដួង**

* រួម សោមនស្សដែល ឱ្យញញឹមញញែម និង សើច បាន ១៣ដង ។

**សួរ** អាចារ្យខ្លះពោលថា ចិត្តជាអហេតុនោះ ចិត្តខ្លះក៏នៅ ប្រកបពិតចង់ជ្រាបថាអហេតុកចិត្តនោះ ដួងខ្លះមានហេតុប្រកប ឬទេ ?

**ឆ្លើយ** តាមដែលព្រះបរមសាស្តា សំដែងក្នុង ធម្មសង្គណី ថា ចិត្តបែងចែកជាពីរ គឺ :

- សហេតុកចិត្ត និង
- អហេតុកចិត្ត ។

ចិត្ត ដែលមានហេតុ ហៅថាសហេតុកចិត្ត បានដល់ចិត្តជា សហេតុកៈ ៧១ ដួង ចេតសិក ៥២ ។

ចិត្ត ដែលមិនមានហេតុ ហៅថា អហេតុកចិត្ត បានដល់ ចិត្តជា អហេតុកៈ ១៨ដួង ចេតសិក ១២ គឺ អញ្ញសមានា ១២ (វៀរ ឆន្ទៈ) ព្រោះហេតុដូច្នេះក្នុង អហេតុកចិត្ត ១៨ដួង គ្មានហេតុទេ ។

**សួរ** សម័យនេះអាចារ្យខ្លះ ពោលថា ចិត្តជាអកុសល ១២ ដួង និង អហេតុកចិត្ត ១៨ ដួង រួមចិត្ត ៣០ ដួង ហើយថាជា អសោភណចិត្ត ។

រឿងនេះ មិនឃើញក្នុងអភិធម្មត្ថសង្គហៈ ចង់ពិបាកជ្រាប ថា សេចក្តីពិត ហៅយ៉ាងណាទើបប្រាកដ ។

**ឆ្លើយ** ព្រះអនុរុទ្ធាចារ្យ បានពោលដល់ចិត្ត មិនបានពោលដល់ ចិត្តជាអសោភណៈ ពោលតែថាក្នុងចិត្ត ៨៩ ដួង នៅមានចិត្ត ៥៩ ដួង ហៅថាសោភណចិត្ត ព្រោះហេតុដូច្នោះ យើងក៏គប្បីដឹងថា ចិត្ត ៣០ដួង ទៀតនេះ ត្រូវហៅថា អសោភណចិត្ត ដូចគាថា ដែលនឹងពោលតទៅនេះ

**បាបា ហេតុកមុត្តានិ សោភណានីតិ វុច្ចរេ ឯកូនសដ្ឋី ចិត្តានិ អដ្ឋេកនវុតីបិ វា**

**ប្រែ** វៀរលែងអកុសលចិត្ត និង អហេតុកចិត្ត ហើយចិត្តចំនួន ៥៩ដួង ហៅថាសោភណចិត្ត ។

ន័យម្យ៉ាងទៀតថា ចំនួនចិត្ត ៩១ ដួង ហៅថាសោភណ ចិត្ត ដូចនេះ ។

# វិធីរាប់ចំនួន សោភណចិត្ត និង អសោភណចិត្ត

| | | |
|---|---|---|
| ន័យទី ១ | កាមាវចរសោភណចិត្ត | ២៤ដួង |
| | រូបាវចរចិត្ត | ១៥ដួង |
| | អរូបាវចរចិត្ត | ១២ដួង |
| | លោកុត្តរចិត្ត | ៨ដួង |
| | រួមសោភណចិត្ត | ៥៩ដួង |

| | | |
|---|---|---|
| ន័យទី ២ | កាមាវចរសោភណចិត្ត | ២៤ដួង |
| | រូបាវចរចិត្ត | ១៥ដួង |
| | អរូបាវចរចិត្ត | ១២ដួង |
| | លោកុត្តរចិត្ត | ៤០ដួង |
| | រួមសោភណចិត្ត | ៩១ដួង |

- អកុសលចិត្ត ១២ដួង
- អហេតុកចិត្ត ១៨ដួង

រួមអសោភណៈចិត្ត ៣០ដួង

# សំដែងមហាកុសលចិត្ត ៨ដួង

តាមបាលី

សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំមេកំ(1) សសង្ខារិកំមេកំ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំមេកំ សសង្ខារិកំមេកំ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំមេកំ សសង្ខារិកំមេកំ ឧបេក្ខាសហគតំ ញាណសម្បយុតំ អសង្ខារិកំមេកំ

(1) គួរតែជា អសង្ខារិកមេកំ < អសង្ខារិកំ + ឯកំ

**ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ-
មេកំ ឥមានិ អដ្ឋបិ កាមាវចរកុសលចិត្តានិ
នាម**

**ប្រែថា** ចិត្តកើតព្រមដោយសោមនស្ស ប្រកបដោយបញ្ញា ជាអសង្ខារិក ១ដួង ជាសសង្ខារិក ១ ដួង

ចិត្តកើតព្រមដោយ សោមនស្សប្រាសចាកបញ្ញាជាអសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង

ចិត្តកើតព្រមដោយ ឧបេក្ខា ប្រាកចាកបញ្ញាជាអសង្ខារិក ១ដួង ជាសសង្ខារិក ១ ដួង

ចិត្តកើតព្រមដោយ ឧបេក្ខា ប្រកបដោយបញ្ញាជាអសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង

* ចិត្ត ៨ ដួងដែលពោលមកហើយនេះ មាននាមថា **កាមាវចរកុសលចិត្ត ៨ ដួង**

## ពាក្យអធិប្បាយ -

* មហាកុសលចិត្ត ៨ ដួង

ពាក្យថា**មហាកុសល** ញែកបាន ២ បទគឺ

**មហា** + **កុសល**

**មហា** ប្រែថា ធំសំបើម ឬ ធំច្រើន

**កុសល** ប្រែថា កុសល

**មានន័យថា**

កុសលដែលធំ ឬ កុសលដែលច្រើន ជាងកុសលទាំងឡាយសំរាប់សោមនស្សឧបេក្ខា អសង្ខារិក សសង្ខារិក នោះ ក៏ ទំនងជាមួយគ្នា និង ពាក្យអធិប្បាយមកហើយក្នុងអកុសល ចិត្ត ។

**ពាក្យថា - ញាណសម្បយុត្ត និង ញាណវិប្បយុត្ត** នោះ ញែកបានពីរបទ :

- **ញាណ និង សម្បយុត្ត ឬ វិប្បយុត្ត**

ញាណ ប្រែថា ប្រាជ្ញា

សម្បយុត្ត ប្រែថា ប្រកប

វិប្បយុត្ត ប្រែថា មិនប្រកប

មានន័យថា

មានបញ្ញា ឬ មិនមានបញ្ញានេះឯង ។

# ព្រះអភិធម្ម ពិស្តារ

សំដែងមហាវិបាកចិត្ត ៨ ដួង តាមបាលី

សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ សោមនស្សសហគតំ វិប្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឧបេក្ខា

**សហគតំ ញាណសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឥមានិ អដ្ឋបិ អហេតុក-កាមាវចរវិបាកចិត្តានិ នាម**

**ប្រែ** ចិត្តកើតព្រមដោយ សោមនស្សប្រកបដោយបញ្ញា ជាអសង្ខារិក ១ដួង ជាសសង្ខារិក ១ដួង ។

- ចិត្តកើតព្រម និង សោមនស្ស ប្រាសចាកបញ្ញា ជាអសង្ខារិក ១ដួង ជាសសង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយ ឧបេក្ខា ប្រកបដោយបញ្ញា ជា អសង្ខារិក ១ដួង ជាសសង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយឧបេក្ខា ប្រាសចាកបញ្ញា ជា អសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង ។ ចិត្ត ៨ដួង ដែលពោល មកហើយនេះ មាននាមថា ជាសហេតុក-កាមាវចរវិបាកចិត្ត ។

សំដែងមហាកិរិយាចិត្ត ៨ដួង តាមបាលី

សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ សសង្ខារិកំ ឥមានិ អដ្ឋបិ សហេតុកកាមាវចរកិរិយា ចិត្តានិ នាម

ប្រែ - ចិត្តកើតព្រមដោយសោមនស្ស ប្រកបដោយបញ្ញា ជាអសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយសោមនស្ស ប្រាសចាកបញ្ញា ជា អសង្ខារិក ១ដួង ជាសសង្ខារិក ១ដួង ។

- ចិត្តកើតព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា ជា អសង្ខារិក ១ដួង ជាសសង្ខារិក ១ដួង ។

Page 81 missing

Page 82 missing

- ចិត្តកើតព្រមដោយ ឧបេក្ខា ប្រាសចាកបញ្ញា ជាអសង្ខារិក ១ ដួង ជាសសង្ខារិក ១ដួង

ចិត្ត ៨ ដួង ដែលពោលមកហើយនេះ មាននាមថា សហេតុកកាមាវចរកិរិយា ។

**ពាក្យអធិប្បាយ មហាវិបាកចិត្ត និង កិរិយា**

**ពាក្យថា** មហាវិបាក ញែកបាន ២ បទគឺ :

| | | |
|---|---|---|
| **មហា** | + | វិបាក |
| **មហា** | ប្រែថា | ធំ ឬ ច្រើន |
| **វិបាក** | ប្រែថា | ផល ផលធម៌ |

**មានន័យថា** ជាផលដែលធំធេង ច្រើនជាងផលដទៃ ឬជា ផលរបស់ មហាកុសលក៏បាន ។

**ពាក្យថា** មហាកិរិយា ញែកបានជា ២ បទ

| | | |
|---|---|---|
| **មហា** | + | **កិរិយា** |
| **មហា** | ប្រែថា ធំសំបើម ឬ ច្រើន | |

ចិត្តចេតនាអ្នកធ្វើកុសល និង អកុសល មានន័យថា ចេតនាទាំងបីប្រការ ។

### ៣. កម្មសម្ប័ត្តិ បានដល់

កុសលកម្ម និង អកុសលកម្ម ដែលកើតព្រោះសេចក្តីព្យាយាម និង ចេតនារួម សម្ប័ត្តិ ៣ ប្រការនេះ ប្រាកដឡើងក្នុងបច្ចុប្បន្ននោះ គឺ ខណៈកំម្លាំងដែលធ្វើ ឬ ធ្វើហើយក្នុងខណៈនោះ ។

### ៤. ឧបដ្ឋានសម្ប័ត្តិ បានដល់

កម្ម កម្មនិមិត្ត និង គតិនិមិត្ត ទាំង៣ ដែលប្រាកដខណៈដែលជិត ចុតិទៅនុះ ។ សម្ប័ត្តិ អង្គនេះក៏នៅជាតិបច្ចុប្បន្ន នេះដូចគ្នា ។

### ៥. វិបាកសម្ប័ត្តិ បានដល់

ផលរបស់សម្ប័ត្តិ ៤ ប្រការដែលពោលមកហើយ ជា ផលដែលកើតតទៅរហូតជាតិអនាគត តាមគួរដល់ហេតុ ។

ទំ: 81-82

**មានន័យថា** មហាកុសលជាបែបសោមនស្ស កាលបាន ផល ក៏ជាផលសោមនស្ស ។ បើជាឧបេក្ខាក៏បានផលជា ឧបេក្ខា ។ បើញាណសម្បយុត្ត វិប្បយុត្ត អសង្ខារិក សសង្ខារិក យ៉ាងណាក៏ បានជាផលយ៉ាងនោះ ។

ព្រោះហេតុដូច្នោះ ចំនួនមហាកុសលចិត្ត និង ចំនួនមហា វិបាកចិត្ត ទើបមានចំនួនចិត្តស្មើគ្នា ដូច្នេះ ។

មហាកិរិយាចិត្ត ក៏មានចំនួន ប្រហែលមហា-កុសលចិត្ត ដូចគ្នា ព្រោះការធ្វើរបស់ព្រះអរហន្តក៏មាន **សោមនស្ស ឧបេក្ខា ញាណសម្បយុត្ត ញាណវិប្បយុត្ត អសង្ខារិក សសង្ខារិក** ដូច បុថុជ្ជនធ្វើកុសល ព្រោះហេតុដូច្នេះ មហាកិរិយា ទើបមាន ចំនួន ៨ ដួង ប្រហែលនិង មហាកុសល ចិត្ត ផ្សេងគ្នា តែថាមិនមានផលដូចបុថុជ្ជន ប៉ុណ្ណោះ ។

**ឥច្ចេវំ សព្វថាបិ ចតុវីសតិ សហេតុក-កាមាវចរកុសលវិបាកកិរិយាចិត្តានិ សមត្តានិ**

ប្រែសេចក្តី

ដូចនេះចិត្តជា សហេតុកាមាវចរកុសល សហេតុក កាមាវចរវិបាក សហេតុកកាមាវចរកិរិយា រួមទាំងអស់ ២៤ ដួង ដោយបរិបូណ៌ ។ ( ឬ ហៅថា មហាកុសល មហាវិបាក មហាកិរិយា ដូច្នេះវិញក៏បាន ) ។

## គាថាសង្គហៈ

វេទនាញាណសង្ខារភេទេន ចតុវីសតិ សហេតុកកាមាវចរបុញ្ញបាកក្រិយា មតា កាមេ តេវីស បាកានិ បុញ្ញា បុញ្ញានិ វីសតិ ឯកាទស ក្រិយា ចេតិ ( ចតុ បញ្ញាស ) សព្វថា

ប្រែសេចក្តី គាថាទី ១

ចិត្តជាកាមាវចរកុសល សហេតុកកាមាវចរវិបាក សហេតុកកាមាវចរកិរិយា ទាំងអម្បាលនេះ រាប់ដោយ

វេទនា ញាណសង្ខារទាំង ៣ នេះហើយមានវេទនា ៦ ញាណ ១២ និង សង្ខារ ២៤ ដូច្នេះ ។

**គាថាទី ២**

~ ក្នុងកាមភូមិ ១១ ភូមិនោះមានវិបាកចិត្ត ២៣ ដួង មហាកុសលចិត្ត ៨ និង អកុសលចិត្ត ១២ = ២០ ដួង កិរិយា ១១ដួង រួមទាំងអស់បានដល់ចិត្ត ជាកាមាវចរ ៥៤ ដួង ដូច្នេះនេះ ។

**អធិប្បាយគាថាទី I**

មហាកុសលចិត្ត មហាវិបាកចិត្ត មហាកិរិយា រួម ៣ យ៉ាង គុណ និង វេទនា២ គឺ ឧបេក្ខា នឹង សោមនស្ស បាន ៦ ដួង ។ ៦ដួងនេះគុណ នឹង ញាណសម្បយុត្ត នឹង ញាណវិប្បយុត្ត បាន ១២ដួង ។ ១២ដួងនេះ គុណ នឹង សង្ខារទាំងពីរ បាន ២៤ ដួង ។

**អធិប្បាយគាថាទី II**

* កាមាវចរវិបាកចិត្ត ២៣ ដួងនោះ គឺ :

- អកុសលវិបាកចិត្ត ៧ ដួង
- កុសលវិបាកចិត្ត ៨ ដួង
- មហាវិបាកចិត្ត ៨ ដួង

រួម ២៣ ដួង

* កុសលចិត្ត អកុសលចិត្ត ២០ដួងនោះ គឺ :

- មហាកុសលចិត្ត ៨ដួង
- អកុសលចិត្ត ១២ដួង

រួម ២០ដួង

* ចិត្តជាមហាកិរិយា ឬកិរិយាចិត្ត ១១ ដួងនោះគឺ :

- អហេតុកកិរិយា ៣ដួង
- មហាកិរិយាចិត្ត ៨ដួង

រួម ១១ដួង

រួមទាំងអស់ ២៣ + ២០ + ១១ = ៥៤ដួង

ឞឞឞឞឞឞ

## តារាងសំដែងភាពមហាកុសលចិត្ត ៨ ដួង

សំដៅហេតុ ភាពមហាវិបាក ៨ ដួង និង មហាកិរិយា ៨ ដួង ក៏ទំនងជាមួយគ្នា ។

| សោមនស្សវេទនា | | ឧបេក្ខាវេទនា | |
|---|---|---|---|
| ញាណសម្បយុត្ត | ញាណវិប្បយុត្ត | ញាណសម្បយុត្ត | ញាណវិប្បយុត្ត |
| អសង្ខារិក<br>សសង្ខារិក | អសង្ខារិក<br>សសង្ខារិក | អសង្ខារិក<br>សសង្ខារិក | អសង្ខារិក<br>សសង្ខារិក |
| ២ | ២ | ២ | ២ |

រួម + ២ + ២ + ២ + ២ = ៨ដួង

**សួរ** ក្នុងអភិធម្មត្ថសង្គហ នេះសំដែងចិត្តទុកថា ជាអកុសលច្រើនយ៉ាង ដូចជារូបកុសល អរូបកុសល និង លោកុត្តរកុសល

អ្នកលោកក៏រមែងដឹងថា កុសលទាំងអម្បាលនេះមាន អំណាចច្រើនជាង កាមាវចរកុសលទាំងនេះ ហេតុដូច ម្តេច កាមាវចរកុសលទើបហៅថា មហាកុសល ?

**ឆ្លើយ** រូបាវចរកុសល អរូបាវចរកុសល លោកុត្តរកុសល មានអំណាចច្រើនជាង មហាកុសលដោយ សភាពនោះ ពិតមែន ។ តែមិនបានទូលំទូលាយ ដូចមហាកុសលហើយ មិនជាសាធារណៈ ដល់បុគ្គលទូទៅ ។

**មានន័យថា**

មហាកុសលចិត្តនោះរមែងជាសធារណៈ ដល់បុគ្គល ៣១ ភូមិ ។ សូម្បីព្រះសម្មាសម្ពុទ្ធ ទាំងឡាយ ក៏ត្រូវ អាស្រ័យ មហាកុសលចិត្ត មហាវិបាកចិត្ត មហាកិរិយាចិត្ត ទាំងអម្បាលនេះ ទើបអាចារ្យហៅថា មហាកុសលចិត្ត មហាវិបាកចិត្ត មហាកិរិយាចិត្ត ។

**សួរ** ក្នុងអភិធម្មត្ថសង្គហៈ ក្នុងបាលីដែលសំដែងពីចិត្ត ជាកាមាវចរនេះ មហាវិបាកកិរិយាចិត្ត ប្រកបដោយពាក្យ

(ស័ព្ទ) សហេតុកទាំងពីរបទ ចំណែកមហាកុសលចិត្ត ដូចម្ដេចមិនមាន សហេតុកៈ ?

**ឆ្លើយ** កាលដែលលោកសំដែង ប្រកបដោយពាក្យ (ស័ព្ទ) សហេតុកៈចំពោះ ក្នុងមហាវិបាកចិត្ត និង មហាកិរិយាចិត្តនោះ ព្រោះក្នុងចិត្តជាកាមាវចរ ៥៤ ដួងនេះ មានវិបាក ២ យ៉ាង កិរិយា ២ យ៉ាងដូចគ្នា គឺ អហេតុកកុសលវិបាក ៨ ដួង កិរិយា ២ ដួង ជាអហេតុកវិបាកនោះ ជាធម្មជាតិដែលប្រាសចាកហេតុ ។

ចំណែកមហាវិបាកចិត្ត ជាចិត្តដែលប្រកបដោយហេតុ ដូនេះ ទើបត្រូវសំដែង ប្រកបដោយពាក្យ (ស័ព្ទ ) សហេតុកជាពិសេស ។

កិរិយាចិត្តក៏ដូចគ្នា មានអហេតុកកិរិយា និង មហាកិរិយា ដើម្បីការពារសេចក្ដីចូលចិត្តខុសថា មហាកិរិយាមិនមានហេតុ ដូចអហេតុកកិរិយា សំដែងមកហើយ ទើបត្រូវប្រកបជាមួយ សហេតុកៈ

ចំណែកកុសល មិនដែលមាន ២ ដូចវិបាក និង កិរិយា ហើយថា ធម្មតាកុសល មានហេតុ ប្រកប ទាំងនោះ ព្រោះដូច្នោះ លោកអនុរុទ្ធាចារ្យ ទើបមិនបាន ដោយពាក្យ (ស័ព្ទ) សហេតុកៈទៀត ។

**សួរ** ការដែលថា មហាកិរិយាចិត្ត ជាចិត្តសំដែងអាការៈ ការធ្វើរបស់ព្រះអរហន្តនោះ ស្តាប់មិនបាន ម្នាក់ៗក៏ដឹង ដែរថា ព្រះអរហន្តអស់កិលេសហើយ ហេតុដូចម្តេច ចិត្តជាកាមាវចរ ទើបត្រឡប់ជាចិត្តរបស់ព្រះអរហន្ត ទៀត ? ។

**ឆ្លើយ** ការកាត់កាម ( កិលេស ) របស់ព្រះអរហន្តនោះ គ្មាន កាត់ចិត្តជាកាមាវចរទាំងអស់ទេ សេចក្តីពិត លោក កាត់តែ តណ្ហា រាគៈ ដែលត្រេកអរ ចំពោះសេចក្តីប្រាថ្នា ក្នុងកាម និង អវិជ្ជាដែលបិទបាំងទុក្ខប៉ុណ្ណោះ ។

ការសម្លាប់ធម៌ទាំងពីរនេះបានហើយរមែង ប្រហារ អកុសលចិត្ត និង អកុសលចេតសិកមួយចំណែក ដែល

ប្រកបដោយ កុសល និង អកុសលនោះ បានទាំងអស់ ដែលជាហេតុឱ្យលោក រំលត់ខន្ធទាំង ៥ បានក្នុងជាតិនេះ តែកាលមុនដែលរលត់ខន្ធ នោះចិត្តជាអហេតុកៈ ដូចនៅ បញ្ចទ្វារាវជ្ជនៈ មនោទ្វារាវជ្ជនៈ សម្បដិច្ឆន្នៈ ( ក៏នៅដើរ បាន) ហើយវិបាករបស់អតីតកាលក៏នៅ ដំណើរជានិច្ច ឧទាហរណ៍ ដូចជា ព្រះសិវលី អាស្រ័យផល របស់ មហាកុសល ដែលធ្វើមកពីអតីតកាល លោកមានលាភ ជានិច្ច និង មហាមោគ្គល្លាន នោះផងដែរ ព្រោះអកុសល ចាស់ក្នុង អតីតកាល ទើបត្រូវមហាចោរសម្លាប់ ដូច្នេះ ។

ជាការសំដែងច្បាស់លាស់ហើយថា ព្រះអរហន្ត មិនបាន សម្លាប់ចិត្តជាកាមាវចរទាំងអស់ ដូចពាក្យសួរទេ

**សួរ** ពាក្យថាញាណសម្បយុត្ត ញាណវិប្បយុត្ត ?

**ប្រែ** ប្រកបដោយបញ្ញា និង ប្រាសចាកបញ្ញានោះ បញ្ញា និង ញាណរផ្សេងគ្នា យ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា បញ្ញា និង ញាណ មិនផ្សេងអ្វីពីគ្នាទេ ពាន

បញ្ហោពោបរិត្តហ ថា

**បការេន ជានាតីតិ បញ្ញា**

**ពាក្យថា តាមវិគ្គហ ថា**

**ជានាតីតិ ញាណំ**

ទាំងពីរស័ព្ទនេះ មានន័យដល់សភាពដែលដឹង តែ ម្យ៉ាងព្រោះហេតុដូច្នោះ បដិសម្ភិទា បាលីថា **តំ ញាណដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា**

**ប្រែ** សភាពធម៌នេះព្រោះមានអត្ថ ដែលដឹងបាន ដូច្នេះ ហៅថា ញាណ ព្រោះមានអត្ថដែលដឹង ប្រការទាំងពួង ដូច្នេះហៅថា បញ្ញា ។ ជួនកាលក៏ថាចក្ខុ ជួនកាល ក៏ថា អាលោក ( ភ្លឺ ) ជួនកាលក៏ថាវិជ្ជា តែស័ព្ទទាំងអម្បាល នេះ ជាឈ្មោះរបស់ បញ្ញាទាំងអស់ ។

**សួរ** មហាវិបាកកុសលចិត្ត មហាកិរិយាចិត្ត នេះកើតបាន មិនចំពោះតែក្នុងកាមភូមិ សូម្បីក្នុងរូបភូមិ អរូបភូមិ ក៏ប្រាកដបាន ដូច្នេះដែរ ដូចម្តេចបានតាំងនៅក្នុងឈ្មោះ

កាមាវចរ ។

**ឆ្លើយ** មហាវិបាកកុសលចិត្ត

មហាកិរិយាចិត្តទាំងអម្បាលនេះ កកើតបាននៅក្នុងរូបភូមិ អរូបភូមិបានពិតប្រាកដមែន តែ មិនជាទីទូលំទូលាយដូច កាមភូមិ ឬ មិនមានច្រើនប្រហែល ក្នុងកាមភូមិទេ ។

ដូច្នេះ ព្រះបរមសាស្ដាទ្រង់សំដែងក្នុង ធម្មហទយ-វិភង្គ ព្រះបាលីថា " **កតមេ ធម្មា កាមាវចរា ហេដ្ឋតោ អវីចិនិរយំ បរិយន្តំ ករិត្វា ឧប្បរិម-តោ បរនិម្មិតវសវត្តី ទេវេ អន្តោ ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថា វចរា ឯត្ថ បរិយា បន្នា ខន្ធា ធាតុ អាយតនា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ ឥមេ ធម្មា កាមាវចរា** "

**ប្រែ** តាំងពីអវីចីមហានរក រហូតដល់ បរនិមិត្តទេវលោក ចំនួនសភាពធម៌ដែលកើត ឬ ឆ្វៃលទៅមកក្នុង ១១ ភូមិ គឺ

ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ
ទាំងអម្បាល នេះហៅថា កាមាវចរ ដែលបានដល់រូប
ទាំងអស់ ចិត្តទាំង ៥៤ ដួង និង ចេតសិក ៥២ ប៉ុណ្ណោះ
ជាដើម ។ សូម្បីនឹងមានក្នុងរូប អរូបក៏ដោយ តែក៏នៅ
មានចិត្ត ដែលចាំបាច់ប៉ុណ្ណោះជាដើមថា

**ចក្ខុវិញ្ញាណ សោតវិញ្ញាណ** ចំណែកកាម
ភូមិ ត្រូវបរិបូរណ៍ដោយគ្រប់បែបគ្រប់យ៉ាង ព្រោះបើអ្នក
ណាមួយខ្វះកាម ( សេចក្តីប្រាថ្នា ) ទៅហើយក៏ប្រកាន់ត្បា
ថា ជាអ្នក មិនមានបុណ្យវាសនា ។

ចំណែកក្នុងរូប និង អរូបភូមិគ្មានដូច្នេះទេ ព្រហ្ម
ណាមាន កាមច្រើន ព្រហ្មនោះមិនមានរិទ្ធិ មិនមាន
វាសនា ។ ព្រហ្មណា មានកាមតិច ជាទីបំផុត ព្រហ្មនេះ
រមែងមានរិទ្ធិ អំណាចធំដុំ ។

ដូច្នេះកាមាវចរចិត្ត ៥៤ ដួង ជាប្រយោជន៍
ចំពោះកាមភូមិដោយពិតប្រាកដ ។ .

**សួរ** មហាកុសលចិត្ត ប្រកបដោយសោមនស្ស និង មហាកុសលចិត្ត ដែលប្រកបដោយឧបេក្ខា ទាំងពីរយ៉ាង នេះ ណាមួយមានផលអានិសង្សច្រើនជាង ?

**ឆ្លើយ** មហាកុសលចិត្ត ដោយសោមនស្ស មានផលច្រើន ជាងការធ្វើដោយឧបេក្ខា ។ ធម្មតាការធ្វើកុសលក្នុងកាម-ភូមិ រមែងអាស្រ័យសោមនស្ស ហើយកាត់ផលអានិសង្ស ច្រើន ឬ តិច បាន ។

**មានន័យថា** មានសោមនស្សច្រើនប៉ុណ្ណា ផលអានិ-សង្សក៏មានច្រើនប៉ុណ្ណោះ ។ អ្នកធ្វើដោយចិត្តជាឧបេក្ខា នោះមិនមាន សេចក្តីត្រេកអរ ចំពោះកុសលដែលខ្លួនធ្វើ កាលដែលមិនត្រេកអរដូចនេះក៏ហៅថាមានចិត្តព្រងើយ ៗ រមែងមានន័យថាមាន ចេតនាសទ្ធាទន់ទៅ ដូច្នេះក្នុង កាមាវចរចិត្ត ទើបរាប់ថា សោមនស្ស កុសលមានកម្លាំង ច្រើនជាងឧបេក្ខាបាន ។

**សួរ** កុសលវិបាកចិត្តមានពីរយ៉ាងគឺ កុសលវិបាកចិត្ត

៨ដួង និង មហាវិបាក៨ដួង តើវិបាកទាំងពីរយ៉ាងនេះ ផ្សេងៗគ្នាយ៉ាង ណាខ្លះ ?

**ឆ្លើយ** កុសលចិត្ត និង អកុសលចិត្ត រមែងឱ្យផលពីរយ៉ាង គឺ បដិសន្ធិផល និង ប្រវត្តិផល ផលទាំងពីរយ៉ាងនេះ ហៅថាវិបាក នៃអកុសលវិបាកចិត្ត សន្តីរណៈ ដែលធ្វើឱ្យ បដិសន្ធិ ក្នុងអបាយ ទាំង ៤ នោះ ហៅថា ទុគតិបុគ្គល ។

កុសលវិបាកចិត្ត សន្តីរណៈ ធ្វើឱ្យបដិសន្ធិ ក្នុង មនុស្ស ឬ ធាតុមហារាជភូមិ នេះហៅថា សុគតិបុគ្គល ។

មហាវិបាក ជាញាណវិប្បយុត្ត ធ្វើឱ្យបដិសន្ធិមនុស្ស និង ទេវតា ៦ ជាន់ នេះហៅថា ទុហេតុកបុគ្គល ។

មហាវិបាក ជាញាណសម្បយុត្ត ធ្វើឱ្យបដិសន្ធិក្នុង កាមភូមិ ៧ ជាន់នោះ ហៅថា តិហេតុកបុគ្គល ។

ព្រោះហេតុដូច្នេះ កុសលវិបាក មហាវិបាក ផ្សេងគ្នា ដោយ បដិសន្ធិផល ( មើលបរិច្ឆេទទី ៥ ) ។

ចំណែកប្រវត្តិផល ប្រសិនបើមិនមាន អកុសលកម្មទេ នោះ មហាវិបាកចិត្ត ក៏សោយសេចក្តីសុខ ច្រើនជានិច្ច ឬ នឹង ពោលថា កុសលវិបាកចិត្ត មានជាតួនាទីជួយមហាវិបាកចិត្ត គ្រប់ពេលវេលាក៏ថាបាន ។

**សួរ** ពាក្យថា មហាកុសលចិត្ត ទូលំទូលាយច្រើនជាងកុសល ដទៃៗទៀត មហាកុសលចិត្តទូលំទូលាយត្រឹមណាហើយមាន ចំនួនប៉ុន្មាន ?

**ឆ្លើយ** តាមដែលព្រះអដ្ឋកថាចារ្យ ពោលទុកថា :

**សត្តរស សហស្សានិ ទ្វេសតានិ អសីតិ ច កាមាវចរបុញ្ញានិ ភវន្តីតិ វិនិទ្ទិសេ ។**

**ប្រែ** កាមាវចរកុសលចិត្ត បានដល់ ១៧២៨០ ដួង វិធីគិតគឺ ដូចនេះ :

ចិត្តជាគុណដោយបុញ្ញវត្ថុ × កិរិយាវត្ថុ ១០ = ៨០ដួង

កាមាវចរចិត្ត ៨០ដួង × អារម្មណ៍ ៦ = ៤៨០ដួង

កុសល ៨ដួង ៤៨០ដួង × អធិបតី ៤ = ១៩២០ដួង

កាមាវចរចិត្ត ១៩២០ដួង ×កម្ម ៣ = ៥៧៦០ដួង

កាមាវចរចិត្ត៥៧៦០ដួង × ហីនមជ្ឈិមបណីត ៣ = ១៧២៨០ដួង

វាទ (ការសំដែង) របស់អាចារ្យម្នាក់ទៀតនោះ គឺ :

កាមាវចរកុសលចិត្ត ៨ ដួង × កិរិយាវត្ថុ ១០ = ៨០ដួង

គុណ និង អារម្មណ៍ ៦ បាន = ៤៨០ ដួង

ចែកជាពីរចំណែក គឺ ញាណសម្បយុត្ត និង

ញាណវិប្បយុត =២៤០ដួង

ចំណែកញាណសម្បយុត្ត ២៤០ គុណ និង អធិបតី ៤ = ៩៦០ដួង

( ២៤០ដួង × ៤ = ៩៦០ដួង )

ចំណែកញាណវិប្បយុត្ត ២៤០ដួង × អធិបតី ៣ = ៧២០ដួង

រួមទាំងពីរចំណែក ( ៩៦០ដួង + ៧២០ដួង ) បាន = ១៦៨០ដួង × កម្ម៣ = ៥០៤០

គុណនឹង ហីន មជ្ឈិម បណីត ៣ = ១៥១២០ដួង ។

ព្រោះហេតុដូច្នេះ ទើបពោលថា មហាកុសលទូលំទូលាយ ច្រើន មានចំនួន ១៥១២០ ដួង ឬ ១៧២៨០ដួង ហើយឱ្យផលរហូតដល់ អសង្ខតធាតុ ឬ មហានិព្វាន ដោយប្រការដូច្នេះ

**សួរ** ពាក្យថាកម្ម

កម្មនោះមានចិត្តជាមហាកុសលឬ ?

**ឆ្លើយ**ពាក្យថាកម្មនោះ គឺ ចេតនាចេតសិត ដែលប្រកបដោយ **មហាកុសលចិត្ត** ឬ **កុសលចិត្ត** គ្មាន **មហាកុសលចិត្ត** ឬ **កុសលចិត្ត** (១) **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ**

**សួរ** ការធ្វើកុសលបានប្រកបដោយ ចេតសិកមានប៉ុន្មាន?

**ឆ្លើយ** ការធ្វើកុសលណាក្តី បើជាសោមនស្សញ្ញាណ សម្បយុត្តចេតសិកប្រកប ៣៨ បើជាញ្ញាណវិប្បយុត្ត ចេតសិកប្រកប ៣៧ ។ ថាបើជាឧបេក្ខាញ្ញាណសម្បយុត្ត ចេតសិកប្រកប ៣៧ បើជាឧបេក្ខាញ្ញាណវិប្បយុត្ត ចេតសិក ប្រកប ៣៦ ដួង ។

# សំដែង រូបាវចរកុសលចិត្ត ៥ ដួង

តាមបាលី

~ វិតក្ក វិចារ បីតិ សុខេកគ្គតា ហសិតំ បឋមជ្ឈានកុសលចិត្តំ

~ វិចារ បីតិ សុខេកគ្គតាសហិតំ ទុតិយជ្ឈាន កុសលចិត្តំ

~ បីតិសុខេកគ្គតាសហិតំ តតិយជ្ឈាន~ កុសលចិត្តំ

~ សុខេកគ្គតាសហិតំ ចតុត្ថជ្ឈាន~ កុសលចិត្តញ្ចេតិ

~ ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈាន~ កុសលចិត្តំ

ឥមានិ បញ្ចាបិ រូបាវចរកុសលចិត្តានិ នាម

ប្រែសេចក្ដីថា ព្រមដោយវិតក្ក វិចារ បីតិ សុខ ឯកគ្គតា ចិត្តជាបឋមជ្ឈានកុសល ១ដួង ។

~ ព្រមដោយ វិចារ បីតិ សុខ ឯកគ្គតា ចិត្តជាទុតិយជ្ឈានកុសល ១ដួង ២

~ ព្រមដោយ បីតិ សុខ ឯកគ្គតា ចិត្តជា តតិយជ្ឈានកុសល ១ដួង

~ ព្រមដោយ សុខ ឯកគ្គតា ចិត្តជាចតុត្ថជ្ឈានកុសល ១ដួង

~ ព្រមដោយ ឧបេក្ខា ឯកគ្គតា ចិត្តជា បញ្ចមជ្ឈានកុសល ១ដួង

រួមទាំង ៥ដួង ដែលពោលមកហើយនេះ មាននាមថា ចិត្តជារូបាវចរកុសល ឬ រូបាវ~ចរកុសលចិត្ត ២

---

(១) ព្រះសាស្ដាទ្រង់ត្រាស់ថា

# ពាក្យអធិប្បាយ រូបាវចរកុសលចិត្ត ៥ដួង

ពាក្យថា បឋមជ្ឈានកុសល ញែកបាន ៣ បទគឺ :

~ **បឋម** + **ឈាន** + **កុសល**

**បឋម** ប្រែ ចិត្តជាដំបូង

**ឈាន** ប្រែ ការជាប់អារម្មណ៍

**កុសល** ប្រែ ចាក់ចូលសេចក្តីល្អ

**មានន័យថា** កុសលចិត្ត ១ដួង ដែលហៅថា បឋមជ្ឈាន កើត ព្រមជាមួយ និង ចេតសិក ៥ ដួង គឺ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា** ។ ( អង្គរបស់ឈានមាន ៥)

**ពាក្យថា វិតក្ក**

**វិតក្ក** ជាចេតសិក ១ដួង ក្នុងអញ្ញសមានាចេតសិក ១៣ដួង ។

**សេចក្តីថា** សេចក្តីត្រិះរិះតែក្នុងទីនេះ ប្រែថា ការបង្អាប់ចិត្ត កាន់អារម្មណ៍របស់កម្មដ្ឋាន ។

**ពាក្យថា វិចារៈ**

វិចារៈ ជាចេតសិក ១ដួង ក្នុងអញ្ញសមានាចេតសិក ១៣ ដួង ។

**សេចក្តីថា** ការពិចារណា តែក្នុងទីនេះប្រែថា រក្សាចិត្តដែល នៅជាមួយ វិតក្កៈ ដើម្បីមិនឱ្យធ្លាក់អារម្មណ៍ ។

**ពាក្យថា បីតិ**

បីតិ ជាចេតសិក ១ដួង ក្នុងអញ្ញសមានាចេតសិក ១៣ ដួង ។

**សេចក្តីថា** សេចក្តីត្រេកអររបស់ចិត្ត មានន័យថា សេចក្តីត្រេកអរ ព្រោះការស្ងប់រម្ងាប់ចិត្ត ។

**ពាក្យថា សុខ**

សុខ ជាវេទនាចេតសិក ១ដួង ក្នុងអញ្ញសមានា ចេតសិក ១៣ដួង ។

**សេចក្តីថា** សេចក្តីត្រេកអរ ក្នុងអារម្មណ៍ សំដៅដល់សុខវេទនា

ពាក្យថា ឯកគ្គតា ញែកបានពីរបទគឺ :

**ឯក** + **គតា** ⟶ **ឯកគ្គតា** ( ប្រែ គតា បានដល់ឋានដែលនៅជាមួយគ្នា )

**មានន័យថា** បានដល់ឋានៈដែលចិត្តតែមួយ ។ ខាងក្រោយ កាលព្រះយោគាវចរ បានទទួល បដិភាគនិមិត្តហើយវេលាណា ចិត្តជាសមាធិ ដែលប្រកបដោយអង្គ ៥ ប្រការ ដែលពោល មកហើយ វេលានោះ ហៅថាបឋមជ្ឈានកុសលចិត្ត គឺ បាន ទទួលបឋមជ្ឈានហើយ ។

**ពាក្យថា ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន** ទាំងអម្បាលនេះ ក៏ទំនងជាមួយគ្នា ផ្សេងៗគ្នាត្រឹមតែ

**បឋមជ្ឈាន មានចេតសិកប្រកប ៥ ជួន**

**ទុតិយជ្ឈាន មានចេតសិកប្រកប ៤ ជួន**

តតិយជ្ឈាន មានចេតសិកប្រកប ៣ ដួង

ចតុត្ថជ្ឈាន មានចេតសិកប្រកប ២ ដួង

បញ្ចមជ្ឈាន មានចេតសិកប្រកប ២ ដួង

## សំដែង រូបាវចរវិបាកចិត្ត៥ដួង

តាមបាលី - វិតក្ក វិចារ បីតិ សុខេកគ្គតា សហិតំ បឋមជ្ឈានវិបាកចិត្តំ

- វិចារ បីតិ សុខេកគ្គតា សហិតំ ទុតិយជ្ឈានវិបាកចិត្តំ

- បីតិ សុខេកគ្គតាសហិតំ តតិយ-ជ្ឈានវិបាកចិត្តំ

- សុខេកគ្គតាសហិតំ ចតុត្ថជ្ឈាន-វិបាក ចិត្តំ

~ ឱបេក្ខាកគ្គតាសហិតំ បញ្ចម~
ជ្ឈានវិបាក

ចិត្តានិ ឥមានិ បញ្ចបិ រូបាវចរវិបាក
វិត្តានិ នាម

ប្រ ~ សេចក្តីកើតព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ជាចិត្តបឋមជ្ឈានវិបាកចិត្ត ១ ដួង ។

~ សេចក្តីកើតព្រមដោយ វិចារៈ បីតិៈ សុខៈ ឯកគ្គតា ចិត្តជាទុតិយជ្ឈានវិបាកចិត្ត ១ដួង ។

~ សេចក្តីកើតព្រមដោយ បីតិ សុខៈ ឯកគ្គតា ចិត្តជាតតិយជ្ឈានវិបាកចិត្ត ១ដួង ។

~ សេចក្តីកើតព្រមដោយ សុខៈ ឯកគ្គតា ចិត្តជាចតុត្ថជ្ឈាន វិបាកចិត្ត ១ដួង ។

~ សេចក្តីកើតព្រមដោយ ឧបេក្ខា ឯកគ្គតា ចិត្តជាបញ្ចមជ្ឈានវិបាកចិត្ត ១ដួង ។

រូបទាំង ៥ ដួងនេះ ដែលបានពោលមកហើយនេះ មាន នាមថា រូបាវចរវិបាកចិត្ត ។

## សំដែង រូបាវចរកិរិយាចិត្ត ៥ ដួង

តាមបាលី

~ វិតក្កវិចារបីតិ សុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយា ចិត្តំ

~ វិចារបីតិ សុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ

~ បីតិ សុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ

**~ សុខេកគ្គតាសហិតំ តតិយជ្ឈាន~**
**កិរិយាចិត្តំ**

**~ ឧបេក្ខាកគ្គតាសហិតំ បញ្ចមជ្ឈាន~**
**កិរិយាចិត្តញ្ចេតិ ឥមានិ បញ្ចបិ**
**រូបាវចរកិរិយាចិត្តានិ នាម**

**ប្រែ** - ព្រមដោយ វិតក្កៈ វិចារៈ បីត សុខៈ ឯកគ្គតា ចិត្តជា បឋមជ្ឈានកិរិយាចិត្ត ១ ដួង

- ព្រមដោយ វិចារៈ បីតិ សុខៈ ឯកគ្គតា ចិត្តជា ទុតិយជ្ឈាន កិរិយាចិត្ត ១ដួង

- ព្រមដោយ បីតិ សុខៈ ឯកគ្គតា ចិត្តជា តតិយជ្ឈាន កិរិយាចិត្ត ១ដួង

- ព្រមដោយ សុខៈ ឯកគ្គតា ចិត្តជាចតុត្ថជ្ឈាន កិរិយាចិត្ត ១ដួង

- ព្រមដោយ ឧបេក្ខា ឯកគ្គតា ចិត្តជាបញ្ចម-ជ្ឈាន កិរិយាចិត្ត ១ដួង

រូបទាំងប្រាំដួង (៥ដួង) ដែលពោលមកហើយ មាននាម ថា ជាចិត្ត រូបាវចរកិរិយាចិត្ត ៥ ដួង ។

# ពាក្យអធិប្បាយរូបាវចរវិបាកចិត្ត និង រូបាវចរកិរិយាចិត្ត

**ពាក្យថា**

វិតក្ក វិចារ បីតិ សុខ ឯកគ្គតា រូមចេតសិក ៥ ដួង នេះ ក៏ទំនងដូចគ្នា និង រូបាវចរកុសលចិត្ត គ្រប់៧ដួង ។

**ពាក្យថា** រូបាវចរវិបាកចិត្តនោះ ជាផលរបស់ចិត្ត ដែលជា រូបាវចរកុសលចិត្ត តាមលំដាប់ចិត្ត ជាផលរបស់កុសល ចំណែក កិរិយាចិត្តនោះ សំរាប់រូបព្រះអរហន្តបុគ្គល ដោយចំពោះ ( សំរាប់ ពាក្យអធិប្បាយ សុំមើលតាម កិរិយាចិត្ត )

## បាលី

ឥច្ចេវំ សព្វថាបិ បណ្ណរស រូបាវចរកុសល-

វិបាកកិរិយាចិត្តានិ សមត្តានិ

ប្រែ ដូចនេះ ចិត្តជា

រូបាវចរកុសលចិត្ត ៥ + រូបាវចរវិបាក

ចិត្ត ៥ + រូបាវចរកិរិយា ៥ រួម ១៥ដួង

(ចប់ដោយបរិបូរណ៍ហើយដោយប្រការទាំងពួង)

# គាថាសង្គហ

បញ្ចធា ឈានភេទេន រូបាវចរមានសំ បុញ្ញ-
បាកក្រិយាភេទា តំ បញ្ច ទសធា ភវេ

រូបាវចរចិត្ត រាប់ដោយប្រភេទឈាន ហើយ រមែង មាន ៥ ប្រការ : បើដោយកុសលវិបាកចិត្ត កិរិយាចិត្តនោះ រូប ទាំងអស់ ១៥ ដួង ។

## សំដែងការរាប់ រូបាវចរចិត្ត ១៥ ដួង

រូបាវចរកុសលចិត្ត ៥ ដួង រូបាវចរវិបាកចិត្ត ៥ ដួង រូបាវចរកិរិយា ៥ ដួង រួមជា ១៥ ដួង

| | |
|---|---|
| រូបាវចរកុសលចិត្ត | ៥ដួង |
| រូបាវចរវិបាកចិត្ត | ៥ដួង |
| រូបាវចរកិរិយាចិត្ត | ៥ដួង |
| រួម | ១៥ដួង |

ចិត្តជាសោមនស្ស ១២

ចិត្តជាឧបេក្ខា ៣

---

រួម ១៥

បឋមជ្ឈានចិត្ត កុសល + វិបាក + កិរិយា ៣ដួង

ទុតិយជ្ឈានចិត្ត កុសល + វិបាក + កិរិយា ៣ដួង

តតិយជ្ឈានចិត្ត កុសល + វិបាក + កិរិយា ៣ដួង

បញ្ចមជ្ឈានចិត្ត កុសល + វិបាក + កិរិយា ៣ដួង

រួម ១៥ដួង

# តារាងសំដែងភាព រូបាវចរចិត្ត ១៥ដួង

✧✧✧✧✧✧

| | | | | | | |
|---|---|---|---|---|---|---|
| | | | | អង្គធាតុ ២ | ឧបេក្ខា | ឯកគ្គតា | បញ្ចមជ្ឈាន |
| | | | | អង្គធាតុ ២ | សុខ | ឯកគ្គតា | ចតុត្ថជ្ឈាន |
| | | | អង្គធាតុ ៣ | បីតិ | សុខ | ឯកគ្គតា | តតិយជ្ឈាន |
| | | អង្គធាតុ ៤ | វិចារ | បីតិ | សុខ | ឯកគ្គតា | ទុតិយជ្ឈាន |
| អង្គធាតុ ៥ | វិតក្ក | វិចារ | បីតិ | សុខ | ឯកគ្គតា | បឋមជ្ឈាន |

# ពាក្យសួរ-ឆ្លើយ រូបាវចរចិត្ត ១៥ដួង

**សួរ** ពាក្យថាឈាន នោះមានន័យយ៉ាងណា ?

**ឆ្លើយ** ពាក្យថាឈាន នោះតាមវិគ្គហរបស់សព្ទថា

**កសិណាទិ អារម្មណំ ឈាយតិឧបនិជ-**

**ឈាយតីតិ ឈានំ**

**មានន័យម្យ៉ាងទៀត**

**បច្ចនិកធម្មេ ឈាបេតីតិ ឈានំ**

**ប្រែវិគ្គហៈ ទី១** ធម្មជាតិដែលជាប់អារម្មណ៍របស់កម្មដ្ឋាន ឈ្មោះថា " **ឈាន** " ។

**ប្រែវិគ្គហៈ ទី២** ធម្មជាតិដែលដុតធម៌ ផ្ទុយគ្នាដូច្នេះហៅ ថា " **ឈាន** " ។

## អធិប្បាយក្នុងវិគ្គហៈ ទី ១

**សេចក្ដីថា** កាលដែលព្រះយោគាវចរ បានទទួលបដិភាគ-និមិត្តហើយ អង្គទាំង ៥ គឺ **វិតក្កៈ វិចារៈ បីតិៈ**

**សុខៈ ឯកគ្គតា** ក៏រមែងកើតឡើង ។ តាំងពីខណៈនោះ ចិត្តរបស់ព្រះ យោគាវចរ ហៅថា **បឋមជ្ឈាន** ។

កាលអ្នកដល់បឋមជ្ឈាន ព្រះយោគាវចរ កាលចុតិនោះ បានទទួលល្អ បដិសន្ធិរូបភូមិ តាមកម្លាំងរបស់ឈាន ដែលខ្លួន បានធ្វើហើយ ជាបឋមជ្ឈានវិបាកចិត្ត ដូចនេះ ។

## អធិប្បាយក្នុងវិគ្គហៈ ទី ២

កាលបើខណៈដែលព្រះយោគាវចរ បានទទួលបឋមជ្ឈាន នោះ អកុសលនីវរណៈ ទាំង ៥ រមែងរត់ចេញ ឬ គេចចេញ ឬ ចេញចាកអំពីចិត្តទៅអស់រលីង ដោយ វិក្ខម្ភនៈ ( គ្របសង្កត់ ) ដូច្នេះ ហៅថាឈាន ។

**សួរ វិតក្កៈ វិចារៈ** ទាំងអម្បាលនេះ មិនមែនជារូបាវចរចិត្តពិតមែនឬ ?

**ឆ្លើយ វិតក្កៈ វិចារៈ** មិនមែនជារូបាវចរចិត្តទេ គឺជាអង្គ របស់ឈាន ឧបមា ជើង ដៃ ត្រចៀក ច្រមុះ ទាំងអម្បាលនេះ មិនមែនជារាងកាយទេ ត្រឹមតែ

ជាចំណែករាងកាយ ។ ពាក្យថារាងកាយនោះរូមទាំងអស់ហៅថាកាយ ឧបមេយ្យ យ៉ាងណា ពាក្យថា វិតក្កៈ វិចារៈ ក៏ដូច្នេះដែរ ។ គឺជាអង្គ ទាំង៥ មាន វិតក្ក វិចារ ជាដើម ហៅថា ជាអង្គរបស់ឈាន តែថា ឈាននោះ ត្រូ.បរិបូណ៌ដោយអង្គទាំង ៥ ដូច្នេះ ។

**ស្នួរ** បើដូច្នេះពាក្យថាឈាន គឺរូបាវចរចិត្តមែន ឬទេ ?

**ឆ្លើយ** ពាក្យថាឈានក៏មិនមែនជារូបាវចរចិត្តទេ គ្រាន់តែរូបាវចរចិត្ត ប្រកបដោយឈាន ដែលបរិបូណ៌ដោយ អង្គទាំង ៥ ប៉ុណ្ណោះ ។

( មេត្តាមើលរូបភាព នៃរូបាវចរចិត្ត ប្រកបផង )

**ស្នួរ** ចេតសិក មានដល់ ៥២ដួង ហេតុណាទើបមានត្រឹម ៥ ដួង គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ដែលមកប្រកបក្នុងចិត្តជារូបាវចរបានប៉ុណ្ណោះ ?

**ឆ្លើយ** កាលដែលយកតែចេតសិក ៥ដួង បកប្រកប ជាមួយរូបាវចរចិត្តនោះ ព្រោះ វិតក្ក អាចសម្លាប់ **ថីនំមិទ្ធំ នីវរណៈ** បាន ។ វិចារអាចប្រហារ វិចិកិច្ឆានីវរណៈ បាន ។ បីតិ អាចប្រហារ ព្យាបាទនីវរណៈបាន ។ សុខវេទនា អាចនឹង សម្លាប់ ឧទ្ធច្ច កុក្កុច្ចៈ នីវរណ បាន ។ ឯកគ្គតា អាចសម្លាប់កាមឆន្ទនីវរណបាន ដែលចេតសិកដទៃៗ មិនមានសេចក្តី អង់អាច នឹងរំលាយ នីវរណទាំង ៥ ដែលជាសត្រូវរបស់ឈានបាន ព្រោះហេតុដូច្នេះ ទើបចាំបាច់ត្រូវយកតែចេតសិក ៥ ដួង ដែលពោលមកហើយនេះ ។

**សួរ** មនុស្សគ្រប់គ្នា នឹង មានឈានឬទេ ?

**ឆ្លើយ** បុគ្គលមាន ៤ ជំពូក គឺ

- ទុគតិបុគ្គល
- សុគតិបុគ្គល
- តិហេតុកបុគ្គល

- ទិហេតុកបុគ្គល

រួមក្នុង បួនជំពូក នេះមានតែ តិហេតុកបុគ្គល ប៉ុណ្ណោះ ដែលអាចបានដល់ឈាន ដោយមិនកំណត់ថា បុគ្គលទាប ឬ ខ្ពស់ ។ ចំណែកបុគ្គលដទៃ ៧ នោះ មិនអាចដល់ឈាន បានឡើយ ។

**សួរ** សម័យនេះមានបុគ្គល ដែលបានដល់ឈានឬទេ ?

**ឆ្លើយ** បុគ្គលដែលបានឈាន ឬ មិនបាន ប្រាកដក្នុងសម័យនេះ សូម្បីក្រៅព្រះពុទ្ធសាសនា ក៏នៅមានបុគ្គលដែលបានដល់ឈាន មានចំនួនច្រើន ហើយឥឡូវនេះព្រះពុទ្ធសាសនា ក៏នៅមាន ប្រាកដ នៅឡើយ ក៏ រមែងជាឱកាសរបស់ឈាន ឬ មានលាភី ឈានបុគ្គល ដូច្នេះជាភាពមិនគួរសង្ស័យ ឡើយ ថាអ្នកដល់ ឈាន ឬ ឈានលាភីបុគ្គលនឹងមិនមាន។

**សួរ** ថាបើមានអ្នកដល់នូវឈានខ្លះហើយនោះ ហេតុដូច

ម្តេច ក៏បិនសំដែងឱ្យមនុស្សទាំងឡាយឃើញ ( ជ្រែកទឹក ជ្រែកដី ) ព្រោះអាចប្រព្រឹត្តទៅមកបានខ្លះ ?

**ឆ្លើយ** ការជ្រែកទឹក ជ្រែកដី គឺ ពុំមែនជាឈានទេ ប៉ុន្តែ អភិញ្ញាទាំង ៥ ដោយឡែក ។ ពាក្យថាឈាននោះ គឺ អាការ ជាប់អារម្មណ៍ដោយ ឧបចារសមាធិ ( អប្បនា ) សមាធិ ប៉ុណ្ណោះ

ចំណែកអភិញ្ញានោះ កាលដល់ឈាននោះ រមែងជា អ្នកមានឈានលាភីបុគ្គល អ្នកដែលមាន អធិការនៅមាន មុន ហើយនោះសេចក្តីនេះ នឹងមាន ទាក់ទងមកអំពី ឈាន ដែល ខ្លួនសំឡឹងពិនិត្យ កើតឡើង នោះ សេចក្តីចេះដឹងនេះ ហៅថា អភិញ្ញាមាន ៥ ប្រការ គឺ :

❶ ឥទ្ធិ វិធី និម្មិត រិទ្ធីផ្សេងៗបាន ដូចជាមនុស្សម្នាក់ ធ្វើជាច្រើននាក់ ឬ ច្រើនរយនាក់ ធ្វើជាមនុស្សតែ មួយនាក់ ជាដើម ។

- ទិព្វសោត ត្រចៀក ដូចត្រចៀកទិព្វ
- បរចិត្តវិជ្ជា សេចក្ដីដឹងចិត្តអ្នកដទៃ
- បុព្វេ និវាសានុស្សតិ ការដឹងជាតិដែលកន្លង ផុតទៅហើយ
- ទិព្វចក្ខុ ភ្នែកដូចភ្នែកទិព្វ ។ រូម ៥ប្រការ កាលដែលបុគ្គលមាន ឈានហើយ មិនសំដែងបាដិហារិយ៍ ក៏ព្រោះព្រះវិន័យក្ដោបក្ដាប់ទុកថា ហាមព្រះសង្ឃមិនឱ្យសំដែងឥទ្ធិបាដិហារិយ៍ ដល់ពួកមហាជន វៀរលែងតែកន្លែង ដែលនឹងចាំបាច់ ។ ព្រះបរមសាស្ដា ទ្រង់ឃើញទៅហើយថាបើព្រះសង្ឃអង្គឯណាមួយ ដែលដល់ឈាន សំដែង ឥទ្ធិបាដិហារិយ៍ ដល់ក្រុម មហាជន ហើយព្រះសង្ឃដែលមិនដល់ឈានទាំងនោះ ក៏ នឹងអត់អាហារជាប្រាកដ ។

**សួរ** ពាក្យថា រូបាវចរចិត្តនោះ ជាចិត្តរបស់មនុស្ស ឬជាចិត្តរបស់ ព្រហ្ម ?

ឆ្លើយ ពាក្យថារូបាវចរចិត្ត នោះ មាន ៣ ប្រការ គឺ :

កុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ជារូបាវចរកុសលចិត្ត គឺ ជាចិត្តរបស់មនុស្ស ដែលដល់ឈាន ។

រូបាវចរវិបាកចិត្ត ជាចិត្តរបស់ព្រហ្ម ។

រូបាវចរកិរិយាចិត្ត ជាចិត្តរបស់ព្រហ្ម ដែលបានដល់អរហត្តមគ្គ ឬ អរហត្តផល ជាព្រះអរហន្ត ព្រហ្មក៏ថាបាន ។

ដូច្នេះព្រះបរមសាស្តា ទើបទ្រង់ទេសនាទុកក្នុង ពូកព្រះ វិភង្គបាលីថា :

**កតមេ ធម្មា រូបាវចរា ហេដ្ឋតោ ព្រហ្មលោកំ បរិយន្តំ ករិត្វា ឧបរិតោ អកនិដ្ឋេ ទេវេ អន្តំ ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថបរិយាបន្នា សមា-បន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខ-**

**វិហារវិស្សុ វា ចិត្តចេតសិកា ធម្មា ឥមេ ធម្មា រូបាវចរ ។**

**ប្រែ** ក្នុង ៤ ជំពូកនេះ ពាក្យថារូបាវចរ បានដល់អ្វី ? តាំងអំពី ព្រហ្មបឋមជ្ឈានភូមិ រហូតដល់សុទ្ធាវាស ៥ ភូមិ ចិត្តរបស់អ្នក ដល់សមាបត្តិ ឬ ចិត្តរបស់អ្នកដែលទៅកើតទីនោះ ឬ ចិត្តរបស់ ព្រះអរិយបុគ្គល ព្រមនិងចេតសិកទាំងឡាយ ដែលជា សាធារណ ១៦ភូមិ ហៅថារូបាវចរ ។ ក្នុងទីនេះពាក្យថា សមាបន្នស្ស បានដល់រូបាវចរកុសលចិត្ត ។ ពាក្យថា ឧបន្នស្ស បាន ដល់រូបាវចរវិបាកចិត្ត ។ ពាក្យថា **ទិដ្ឋធម្ម សុខ វិហារិស្ស** បានដល់រូបាវចរកិរិយាចិត្ត ដោយលំដាប់ ។

**សួរ** ពាក្យសួរ សរុបក្នុងចិត្តជារូបាវចរនេះថា កាលបើ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ចេតសិក ៥ ដូងនេះ កើតព្រមហើយ ចិត្តជាបឋមជ្ឈាន កកើតឡើង ។

បរិច្ឆេទទី ១

ការកើតឡើងនៃចេតសិកទាំង ៥ ដូចនេះ ត្រូវក្នុង ខណៈជាមួយគ្នា ឬ កើតឡើងមួយខណៈ ១ ?

**សុំឱ្យអធិប្បាយ ផង**

**ឆ្លើយ** ធម្មតាប្រកបដោយចេតសិក ឬ ចិត្តដួងណាមួយនោះ សូម្បីលោកអដ្ឋកថាចារ្យ ដែលនឹងសំដែង ចំពោះចេតសិកទុក ប៉ុណ្ណា ក៏ដោយ រមែងមានទាំងចេតសិកដែលកើតព្រមគ្នា នឹង មិនកើតព្រមគ្នា ជាតួយ៉ាង ។

ចិត្តជាលោភមូលនោះ កើតព្រម នឹង វេទនាចេតសិក ប្រកបដោយ ទិដ្ឋិចេតសិក ។

**ពាក្យថា កើតព្រមគ្នាភាសាបាលីថា សហគតំ**

**ពាក្យថា ប្រកបជាមួយនោះបាលីថា សម្បយុត្តំ**

**មានន័យថា** មានចេតសិកពីរបែបគឺ :

- មួយបែបជាសហគតំ ១បែប. និង

- ចេតសិកដែលជាសម្បយុត្តំ ១បែប ។

ចិត្ត ១ដួង មានចេតសិកសម្បយុត្តច្រើន១ដួង ។

ចិត្ត និង ចេតសិកទាំងអម្បាលនេះ សូម្បីកើតដោយ មានលក្ខណៈ ៤ ប្រការក៏ដោយ រមែងប្រកប គ្នាបានតាម សភាពរបស់ចិត្តនោះឯង ។

**មានន័យថា** ចិត្ត ១ដួង ៗ មានចេតសិក សាធារណៈកើតច្រើនក្តី គ្មានចេតសិកកើតក្នុងខណៈជា មួយគ្នាក្តី មិនរមែង កើតម្តងមួយខណៈ ដូច្នេះ

**សួរ** រូបាវចរចិត្តនោះ មានចេតសិក កើតប៉ុន្មាន ?

**ឆ្លើយ** រូបាវចរកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ចេតសិកមាន ៣៥ដួងគឺ :

អញ្ញសមានចេតសិក ១៣ដួង

សោភណចេតសិក ២២ដួង ( វៀរវិរតិទាំង ៣ដួង )

---

រួម ៣៥ដួង

---

# បរិច្ឆេទទី ១

## សំដែងអំពីអរូបាវចរកុសលចិត្ត

តាមបាលី

អាកាសានញ្ចាយតនកុសលចិត្តំ

វិញ្ញាណញ្ចាយតនកុសលចិត្តំ

អាកិញ្ចញ្ញាយតនកុសលចិត្តំ

នេវសញ្ញានាសញ្ញាយតនកុសលចិត្តញ្ចេតិ

ឥមានិ ចត្តារិ បិ អរូបាវចរកុសលចិត្តានិ នាម

ប្រែ អាកាសានញ្ចាយតនកុសលចិត្តំ ចិត្តជាអាកាសានញ្ចាយតនកុសល ១ ដួង ។

វិញ្ញាណញ្ចាយតនកុសលចិត្តំ ចិត្តជាវិញ្ញាណញ្ចាយតនកុសល ១ ដួង ។

អាកិញ្ចញ្ញាយតនកុសលចិត្តំ ចិត្តជា អាកិញ្ចញ្ញាយ-តនកុសល ១ដួង ។

នេវ សញ្ញានាសញ្ញាយតនកុសលចិត្តំ ចិត្តជានេវ-សញ្ញានាសញ្ញាយតនកុសល ១ដួង ។

រួម ៤ ដួងនេះ ដែលពោលហើយ គឺ អរូបាវចរ-កុសលចិត្ត ។

## ពាក្យថា អរូបាវចរកុសលចិត្ត

**ពាក្យថា អាកាសានញ្ចាយតនះ** ញែកបាន ៣ បទ

**អាកាសះ + អនញ្ចះ + អាយតនះ**

**ប្រែ អាកាសះ** អាកាស

**អាយតនះ** ដែលតាំងនៅ

**អនញ្ចះ** មិនមានទីបំផុត

**មានន័យថា** អាយតនះ នៃកន្លែង មួយដែលមាន អាកាស មិនមានទីបំផុត ។ បានដល់ ឈានរបស់ព្រះ យោគាបុគ្គល ដែល សំម្លឹង អាកាសសោ អនន្តោ ។

ដូចនេះ អាកាសោ អាកាស អនន្តោ មិនមានទីបំផុត ។

**ពាក្យថា ឧប្បាទ ឋិតិ ភង្គ** បានសេចក្តីថាអាកាសរមែង មិនមានកើតរលត់ ។

**វិញ្ញាណញ្ចាយតន** ញែកបាន បីបទ

**វិញ្ញាណ** + **អានញ្ច** + **អាយតន**

**ប្រែ** **វិញ្ញាណ** វិញ្ញាណ

**អានញ្ច** មិនមានទីបំផុត

**អាយតន** ដែលតាំងនៅ

**មានន័យថា** ជាអាយតនតែមួយ ដែលវិញ្ញាណមិនមានទីបំផុត បានដល់ឈានទី ២ របស់ ព្រះយោគាបុគ្គល ដែលសំឡឹងវិញ្ញាណ ថា វិញ្ញាណំ អនន្តំ ។

ដូចនេះ វិញ្ញាណ អាកាសានញ្ចាយតន រមែងមិនមាន កើតរលត់

**ពាក្យថា**

**អាកិញ្ចញ្ញាយតន** ញែកបាន ៣ បទ

**ន** + **អាកិញ្ច** + **អាយតន** ជាទីតាំង

**ប្រែ** **ន** មិនមាន

**អាកិញ្ច** បន្តិចបន្តួច

**មានន័យថា** ជាអាយតនតែមួយ ដែលវិញ្ញាណមិនមាន សូម្បី តែបន្តិចបន្តួច

បានដល់ឈានទី III របស់ព្រះយោគាបុគ្គល ដែលសំឡឹង នត្ថិភាវៈ ( ភាវមិនមាន) ឬ សេចក្តី មិនមាន វិញ្ញាណថា នត្ថិកិញ្ចិ នត្ថិកិញ្ចិ ដូចនេះ

**ប្រែ - នត្ថិ** **មិនមានតែម្តង**

**ប្រែ - កិញ្ចិ**

**មានន័យថា**

វិញ្ញាណរមែង មិនមានសូម្បីតែបន្តិចបន្តួច

ពាក្យថា នេវសញ្ញានាសញ្ញាយតន ញែកបាន ៦បទ

**នេវ** + **សញ្ញា** + **ន** + **ន** + **សញ្ញា** + **អាយតនៈ**

**ប្រែ នេវ សញ្ញា** សញ្ញាគ្រោតគ្រាត មិនមាន

**ន សញ្ញា** មិនមាន និង សញ្ញាល្អិតអាយតនជាទីតាំង ។

**មានន័យថា** ជាអាយតនៈមួយដែលរមែងមិនមាន សញ្ញាគ្រោតគ្រាត តែថាមានសញ្ញា ដ៏ល្អិត បានដល់ឈានទី ៤ របស់ព្រះយោគាបុគ្គល សំម្លឹង ពិនិត្យសញ្ញាថា **ឯតំ សន្តំ ឯតំ បណីតំ**

**ប្រែ ឯតំ** ចតុត្ថជ្ឈាននេះ **សន្តំ** មានសេចក្ដីស្ងប់ល្អ បណីតំ ប្រសើរល្អ

# សំដែងអំពីអរូបាវចរវិបាកចិត្ត ៤ដួង

តាមបាលី អាកាសានញ្ចាយតនវិបាកចិត្តំ

វិញ្ញាណញ្ចាយតនវិបាកចិត្តំ

អាកិញ្ចញ្ញាយតនវិបាកចិត្តំ

នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត~

ញ្ចេតិ ឥមានិ ចត្តា រិបិ អរូបាវចរ

វិបាកចិត្តានិ នាម

ប្រែ ចិត្តជាអាកាសានញ្ចាយតនវិបាក ១ដួង

ចិត្តជាវិញ្ញាណញ្ចាយតនវិបាក ១ដួង

ចិត្តជាអាកិញ្ចញ្ញាយតនវិបាក ១ដួង

ចិត្តជានេវ សញ្ញានាសញ្ញាយតនវិបាក

១ដួង

រួមទាំង ៤ ដួង ដែលពោលមកហើយនេះ

មានទាមថា អរូបាវចរវិបាកចិត្ត ។

# ពាក្យអធិប្បាយ អរូបាវចរវិបាកចិត្ត និង កិរិយាចិត្ត

តាមបាលី

~ អាកាសានញ្ចាយតនកិរិយា ចិត្តំ

~ វិញ្ញាណញ្ចាយតនកិរិយា ចិត្តំ

~ អាកិញ្ចញ្ញាយតនកិរិយា ចិត្តំ

~ នេវសញ្ញានាសញ្ញាកិរិយា ចិត្តញ្ចេតិ

ឥមានិ ចត្តារិបិ អរូបាវចរកិរិយា ចិត្តានិ នាម

ប្រែ : ចិត្តជាអាកាសានញ្ចាយតនកិរិយា ១ដួង

ចិត្តជាវិញ្ញាណញ្ចាយតនកិរិយា ១ដួង

ចិត្តជាអាកិញ្ចញ្ញាយតនកិរិយា ១ដួង

ចិត្តជានេវសញ្ញានាសញ្ញាយតនកិរិយា ១ដួង

រួម ៤ដួងដែលបានពោលមកហើយនេះ មាននាមថា

# ពាក្យអធិប្បាយអរូបាវចរចិត្ត និង កិរិយាចិត្ត

អរូបាវចរឈានទាំង៤ប្រការនេះក៏ទំនង ជាមួយគ្នា និង អរូបាវចរកុសលចិត្ត ដែលបាន អធិប្បាយមកហើយគ្រប់ប្រការ ។

**ពាក្យថា** អរូបាវចរវិបាកនោះ ជាផលរបស់ចិត្ត ជាអរូបាវចរកុសលចិត្ត ដោយលំដាប់ចិត្តជាកុសល ។

**មានន័យថា** ជាចិត្តរបស់អរូបព្រហ្ម ដែលប្រាកដនៅក្នុងអរូបភូមិ ៤ នោះ ។

**ពាក្យថា** អរូបាវចរកិរិយា ជាចិត្តរបស់ព្រះអរហន្តព្រហ្ម ៤ សំខាន់នោះ អរូបាវចរចិត្តទាំងអស់ ធ្លាក់ទៅក្នុងបញ្ចមជ្ឈាន ប៉ុណ្ណោះ ( មេត្តាមើលរូបភាព អរូបាវចរចិត្តផង ) ។

**ឥច្ចេវំ សព្វថាបិ ទ្វាទសារូបាវចរកុសល-វិបាកកិរិយាចិត្តានិ សមត្តានិ**

**ប្រែ** ដូចនេះឯង ចិត្តជាអរូបាវចរកិរិយា កុសលវិបាក-កិរិយា រួម ១២ដួង បរិបូណ៌ ដោយប្រការទាំងពួង ។

---

# គាថាសង្គហ

**(អាលម្ពណប្ប ភេទេន)ចតុធា រុប្បមានសំ ( បុញ្ញបាកកិរិយា ភេទា ) បុន ទ្វាទសធា ឋិតំ** **ប្រែ** ចិត្តជាអរូបាវចរ ទាំងអម្បាលនេះ ថាបាន ដោយអារម្មណ៍ ហើយមាន ៤ ប្រការ ថា ដោយកុសលចិត្ត

វិបាកចិត្ត កិរិយាចិត្ត ហើយមានកុសលចិត្ត ៤ វិបាកចិត្ត ៤ កិរិយាចិត្ត ៤

រួម ១២ ដួងប៉ុណ្ណោះ ។

## សំដែងវិធីរាប់ចិត្ត ជាអរូបាវចរ

| | | | |
|---|---|---|---|
| អរូបាវចរកុសលចិត្ត | ៤ដួង | អាកាសានញ្ចាយតន | ៣ដួង |
| អរូបាវចរវិបាកចិត្ត | ៤ដួង | វិញ្ញាណញ្ចាយតន | ៣ដួង |
| អរូបាវចរកិរិយាចិត្ត | ៤ដួង | អាកិញ្ចញ្ញាយតន | ៣ដួង |
| | | នេវសញ្ញានាសញ្ញាយតន | ៣ដួង |
| រួម | ១២ដួង | រួម | ១២ដួង |

# តារាងចិត្តជាអរូបាវចរ ឬ អរូបាវចរ

| ឈ្មោះឈាន | កុសលចិត្ត | វិបាកចិត្ត | កិរិយាចិត្ត | រូប |
|---|---|---|---|---|
| អាកាសានញ្ចាយតន | ១ | ១ | ១ | ៣ |
| វិញ្ញាណញ្ចាយតន | ១ | ១ | ១ | ៣ |
| អាកិញ្ចញ្ញាយតន | ១ | ១ | ១ | ៣ |
| នេវសញ្ញានាសញ្ញាយតន | ១ | ១ | ១ | ៣ |
| រូប | ៤ | ៤ | ៤ | ១២ |

# ពាក្យសួរ ឆ្លើយ អរូបាវចរចិត្ត១២ដួង

**សួរ** ពាក្យថា អរូប និង នាម ផ្សេងគ្នាយ៉ាងណា ?

**ឆ្លើយ** ពាក្យថា អរូប

**ប្រែ** មិនមែនរូប សំដៅដល់សេចក្ដីថា នាមនោះឯង ។

ពាក្យថានាម

**ប្រែ** នាមធម៌

ដូច្នេះ អរូប និង នាម ក៏មានន័យជាមួយឬ ដូចគ្នាដែរ ។

**សួរ** ពាក្យថា អរូប និង នាម មានន័យសេចក្ដីដូចគ្នា គឺ នាមធម៌ ដូចគ្នា ហើយ ដូចម្ដេចក៏មិនហៅ អរូបាវចរ ថា នាមចិត្ត ?

**ឆ្លើយ** ពាក្យថាចិត្ត ជាអរូប ហៅថា នាមក៏គង់មិនខុស តែពាក្យថានាមនោះ បានដល់នាមធម៌ទាំងអស់ គឺ ចិត្ត ៨៩ ដួង ឬ ១២១ដួង ព្រមទាំងចេតសិក ៥២ ដួង រហូតដល់ និព្វានធាតុមួយប្រការទៀត ។

ពាក្យដែលហៅ អរូបព្រហ្មក៏បាន

ដូច្នេះក្នុងទីនេះ ទើបត្រូវប្រើស័ព្ទអរូបដោយត្រង់ ១

**សួរ** ពាក្យថា អាកាសានញ្ចាយតនៈ នេះប្រែថាជា អាយតននៃអាកាស

ពាក្យអាកាស ( កសិណ ) ក៏ជាអាកាសនៃកសិណ

ទៀត អាកាស ២ យ៉ាងនេះ ផ្សេងគ្នាយ៉ាងណា ?

**ឆ្លើយ** ពាក្យអាកាសានញ្ចាយតន បានដល់អាកាសរបស់សិណា ទាំង៩ គឺ ក្នុងកសិណទាំង ១០ ប្រការនោះ (វៀរលែងអាកាសកសិណ) ។

ពាក្យថា អាកាសកសិណនោះ បានដល់អាកាសកសិណ ដែលវៀរ អំពីអាកាសានញ្ចាយតន ។

អាកាសពីរយ៉ាងនេះ ផ្សេងៗគ្នាដូច្នេះឯង ។

អាកាសមាន ៤ ប្រការគឺ :

**១-អជដាកាស**

**២-បរិច្ឆិន្នាកាស**

**៣-កសិណុគ្ឃាដិមាកាស**

**៤-បរិច្ឆេទាកាស**

- អជ្ជដាកាស បានដល់អាកាសទាំងអស់ រហូតដល់ផ្ទៃមេឃ បរិច្ឆិន្នាកាស បានដល់អាកាសកសិណរបស់

ព្រះយោគាវចរ គឺ រូបអាកាសដែលសំដៅទុកជាចន្លោះទ្វារ បង្អួចអ្វីក៏បាន ។

កសិណុគ្ឃាដិមាកាស បានដល់អាកាស ដែលទាក់ទងមកអំពីកសិណ ៩ ( គឺ វៀរលែងអាកាសកសិណ ) ។ បរិច្ឆេទាកាស បានដល់អាកាស គឺ បរិច្ឆេទរូបនោះឯង ។

ព្រោះហេតុដូច្នេះ ពាក្យថា អាកាសានញ្ចាយតន ទើបបានដល់ កសិណុគ្ឃាដិមាកាស ប៉ុណ្ណោះ មិនបាន សំដៅដល់អាកាសរបស់ អាកាសកសិណផងទេ ។

**សួរ** ការសំម្លឹងពិនិត្យ វិញ្ញាណតាមន័យ របស់វិញ្ញាណញ្ចាយតន នោះជាវិបស្សនាបានទេ ?

**ឆ្លើយ** ការសំម្លឹងពិនិត្យ វិញ្ញាណ គឺសំម្លឹងនាមធម៌ ដោយព្រែលក្ខណ៍នោះ គ្មានដូច្នេះទេ ព្រោះការសំម្លឹង វិបស្សនា សំម្លឹងពិនិត្យ តាមន័យ វិបស្សនាញាណ ១០ ប្រការ ។

ចំណែកក្នុង វិញ្ញាណញ្ចាយតន នោះ សំម្លឹងពិនិត្យ វិញ្ញាណដែល ជារឿយៗ មកអំពីអាកាសានញ្ចាយតន

នោះឯង ។

**មានន័យថា**

វិញ្ញាណញ្ចាយតន រមែងមានអារម្មណ៍ រូប-នាម ។

វិញ្ញាណញ្ចាយតន រមែងមានអារម្មណ៍ អាកាសានញ្ចាយតនវិញ្ញាណ ហេតុដូច្នេះ ការសំម្លឹងពិនិត្យ វិញ្ញាណនេះមិនមែនជាវិបស្សនាទេ ។

សួរ ក្នុងអរូបាវចរចិត្ត ១២ដួងនេះ ពាក្យថាអាកាសានញ្ចាយតន វិញ្ញាណញ្ចាយតន ពីរបទនេះមានសព្ទ អនញ្ច ប្រកបដោយពីរបទ

**ពាក្យថា** **អនញ្ច** ប្រែថា យ៉ាងណា ?

**ឆ្លើយ** **អនញ្ច** ប្រែថា មិនមានទីបំផុត

ជាពាក្យជាមួយគ្នា **អនន្ត** (**ន** + **អន្ត** )

**ប្រែ** **ន** : មិនមាន

**អន្ត** : ទីបំផុត

**អនន្ត** **ប្រែថា** មិនមានទីបំផុត ។

# គាថាវិគ្គហថា

**នត្ថិ អនន្តោ ឯតស្សាតិ (គួរ)**

**អនន្តោ ប្រែថា** ធម្មជាតិយ៉ាងនេះមិនមាន

ទីបំផុត ព្រោះហេតុដូច្នោះ ព្រះយោគី ទើបដល់ឈាន អរូប ត្រូវពិនិត្យសំម្លឹងថា អាកាសោ អនន្តោ ។

**~ វិញ្ញាណំ អនន្តំ**

**ប្រែ** អាកាសមិនមានទីបំផុត ហើយ វិញ្ញាណ មិនមានទីបំផុត ។

**សួរ** ពាក្យថាអាយតន ប្រែថាទីតាំង

ពាក្យថាអរូប ប្រែថា មិនមានរូប

កាលមិនមានរូបយ៉ាងនេះ នឹងមានទីតាំងយ៉ាងណា ?

**ឆ្លើយ** ពាក្យប្រែអាយតនៈនោះសេចក្ដីពិត ក៏បានដល់ទីតាំង ហើយទីតាំងមិនមានចំពោះតែរូបទេ សូម្បីជានាមធម៌ក៏មានទីតាំងដូចគ្នា ដូចជា :

ធម្មាយតនេ បានដល់ទីតាំងរបស់ចេតសិក និង ព្រះនិព្វាន ។

ជួនកាលអាយតនបាន ដល់ ទីតាំងរបស់ សិប្បដូចជា **សិប្បាយតនំ កម្មាយតនំ** ជាដើម ។

ព្រោះហេតុដូច្នោះ អរូបចិត្តនោះ ពាក្យថាអាយតនបានដល់ជាទីតាំង របស់ចិត្តជាអរូបឈាន ។ អរូបឈានទាំងអស់ ជាអាយតនទាំងអស់ ។

**សួរ** អរូបវិបាក ជាផលរបស់អរូបកុសលនោះជាផលយ៉ាងណាខ្លះ ? សុំឱ្យលើកជាតួយ៉ាង ឧទាហរណ៍ផង ?

**ឆ្លើយ** អរូបវិបាក ជាផលរបស់អរូបកុសលនោះ គឺ :

ព្រះយោគី ដែលដល់អរូបឈាន ៤ ប្រការ កាលចុតិអំពីកាមភូមិ អរូបាវចរវិបាក ៤ ដួងនាំទៅដល់អរូបភូមិ ៤ ដោយលំដាប់ ដូច្នេះអរូបាវចរ ៤ ដួងនេះហៅថា ចិត្តអរូបបដិសន្ធិបាន ឧទាហរណ៍ ដូចជា :

អសិត តាបសដែលជាអាចារ្យនៃព្រះជនក របស់ព្រះបរមសាស្តា នៃយើង និង ឧទកតាបស អាឡារតាបស ដែលព្រះបរមសាស្តាទៅរៀន អរូបកម្មដ្ឋាន មុនដែលលោក នឹងសំរេចបឋមសម្ពោធិញ្ញាណនោះ ។

ព្រះឥសីទាំងបីនេះ សុទ្ធតែជាអ្នកបានទទួល អរូបាវចរកុសល និង ជាអ្នកដែលបាន ទៅកើតក្នុងអរូបភូមិទាំងអស់ ។

ដូចនេះ អរូបាវចរវិបាក ធ្វើឱ្យកើតជាព្រហ្មដូច្នេះ ។

**សួរ** អរូបាវចរកិរិយា ជាចិត្តរបស់ព្រះអរហន្តព្រហ្មនោះ ព្រះអរូបព្រហ្ម មានឬទេ ?

**ឆ្លើយ** ក្នុងអរូបព្រហ្ម ៤ ភូមិ មានព្រះអរិយបុគ្គល ៧ ពួកប្រាកដនៅផង គឺ

ព្រះសោតាបត្តិផលបុគ្គល ១
ព្រះសកទាគាមិមគ្គ ១
ព្រះសកទាគាមិផល ១

ព្រះអនាគាមិមគ្គ ១

ព្រះអនាគាមិផល ១

ព្រះអរហត្តមគ្គ ១

ព្រះអរហត្តផល ១

រួមព្រះអរិយបុគ្គល ៧ ចំពូក ។

ដូច្នេះព្រះអហន្តអរូបព្រហ្ម និង មានជាប្រាកដ

**សួរ** អរូបាវចរចិត្ត ១២ដួង មានចេតសិកប្រកបប៉ុន្មាន ?

**ឆ្លើយ** អរូបបាវចរចិត្ត ១២ដួង មានចេតសិកប្រកប ៣០ ដួង គឺ :

អញ្ញសមានាចេតសិក ១០ ដួង ( វៀរ វិតក្ក វិចារ បីតិ )

សោភណសាធារណចេតសិក ២០ដួង ( វៀរ វិរតិ ៣ និង អប្បមញ្ញា ២ )

**រួម ៣០ដួង**

**សួរ** អរូបាវចរចិត្ត ១២ដួង មានចេតសិកប្រកប ៣០ដួង ( វៀរ វីរតិ ៣ ករុណា មុទិតា ) នោះសំដៅសេចក្ដីថា អរូប

ព្រហ្ម មិនមាន ករុណា មុទិតា ឬ ?

**ឆ្លើយ** ការដែលវៀរលែង វិរតិ ព្រោះក្នុងព្រហ្មលោកក៏មិនមាន វិរមិតព្វវត្ថុ សំដៅសេចក្ដីថាក្នុងព្រហ្មលោក វត្ថុដែលត្រូវវៀរ មិនមានឡើយ ។ ការដែលវៀរ ករុណា មុទិតានោះ ព្រោះចិត្តជាអរូប ជាធម្មជាតិឧបេក្ខា គឺ មិនមានត្រេកអរ មិនជាប់ជំពាក់ជានិច្ច ។

ដូច្នេះការរាប់ចេតសិក ដែលប្រកបចាំបាច់វៀររបស់ទាំងនេះចេញផង ។

## សំដែង លោកុត្តរចិត្ត ៤ដួង

**តាមបាលី**

**សោតាបត្តិមគ្គចិត្តំ សកទាគាមិមគ្គចិត្តំ អនាគាមិមគ្គចិត្តំ អរហត្តមគ្គចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរចិត្តានិ នាម**

ប្រែ សោតាបត្តិមគ្គ ១ដួង

សកទាគាមិមគ្គចិត្ត ១ដួង

| | |
|---|---|
| អនាគាមិមគ្គចិត្ត | ១ដួង |
| អរហត្តមគ្គចិត្ត | ១ដួង |
| រួម | ៤ដួង |

ហៅថាលោកុត្តរចិត្ត (លោកុត្តរកុសលចិត្ត )

# អធិប្បាយ លោកុត្តរកុសលចិត្ត៤ដួង

ពាក្យថា សោតាបត្តិមគ្គ ញែកបាន ៣ បទ គឺ

| | | | | |
|---|---|---|---|---|
| សោត | + | អាបត្តិ | + | មគ្គ |
| សោត | | ប្រែថា | | ក្រសែទឹក |
| អាបត្តិ | | ប្រែថា | | បានដល់ហើយ |
| មគ្គ | | ប្រែថា | | ជាផ្លូវ |

**មានន័យថា**

ជាមគ្គចិត្ត ១ដួង ដែលបានដល់ក្រសែទឹក ដែលហូរទៅកាន់ ព្រះនិញ្វនធាតុ បានដល់មគ្គចិត្តរបស់ ព្រះអរិយ-បុគ្គលដំបូង ដែលមានបដិសន្ធិ យ៉ាងច្រើនត្រឹម ៧ជាតិទៀត ក្នុងលោកប៉ុណ្ណោះ ។

**ពាក្យថា សកទាគាមិមគ្គ ញែកបាន ៣បទ**

| | | |
|---|---|---|
| **សក** + | **អាគាមិ** + | **មគ្គ** |
| **សក** | ប្រែ | បួយគ្រា |
| **អាគាមិ** | ប្រែ | ត្រឡប់មក |
| **មគ្គ** | ប្រែ | ផ្លូវ |

**មានន័យថា** ជាមគ្គចិត្ត ១ដួង ដែលធ្វើឱ្យបុគ្គលត្រឡប់មកកាន់កាមលោក មួយគ្រាទៀត ប៉ុណ្ណោះ ។

ការដល់មគ្គចិត្ត របស់ព្រះអរិយបុគ្គលទី ២ ដែលត្រឡប់មកបដិសន្ធិ ក្នុងកាមភូមិ ១ គ្រាទៀត ប៉ុណ្ណោះ ។

**ពាក្យថា អនាគាមិមគ្គ ញែកបាន ៣ បទគឺ**

**អន + អាគាមិ + មគ្គ**

**អន** ប្រែថា មិនមាន

**អគាមិ** ប្រែថា ត្រឡប់មក

**មគ្គ** ប្រែថា ផ្លូវ

**មានន័យថា** ជាមគ្គចិត្តមួយដួង ដែលធ្វើឱ្យបុគ្គលត្រូវត្រឡប់មកកាន់ កាមលោក សូម្បីតែមួយគ្រាមិនមាន ។

បានដល់មគ្គចិត្ត របស់ព្រះអរិយបុគ្គលទី ៣ ដែលមិន ត្រូវត្រឡប់មកកាន់កាមលោក ។

**ពាក្យថា អរហត្តមគ្គ ញែកបាន ២ បទ**

**អរហត្ត + មគ្គ**

**អរហត្ត** ប្រែថា អរហត្ត

**មគ្គ** ប្រែថា ផ្លូវ

**មានន័យថា** ជាមគ្គ ១ដួង

**អរហត្ត** សេចក្ដីជាអ្នកបានទទួលបូជា ពិសេស

**មានន័យថា** ជាមគ្គចិត្តមួយដួង ដែលធ្វើឱ្យបុគ្គលបាន ទទួលការបូជាពិសេស បានដល់មគ្គចិត្តរបស់ ព្រះអរិយបុគ្គលទី ៤ ដែលរមែងបានទទួលការបូជា ពិសេសរបស់ទេវតា មនុស្ស ទាំងឡាយ ។

## សំដែងលោកុត្តរចិត្ត ៤ដួង

**តាមបាលី**

សោតាបត្តិផលចិត្តំ សកទាគាមិផលចិត្តំ
អនាគាមិផលចិត្តំ អរហត្តផលចិត្តញ្ចេតិ
ឥមានិ ចត្តារិបិ លោកុត្តរចិត្តានិ នាម

ប្រែ ជាចិត្ត សោតាបត្តិផល ១ដួង

| | | |
|---|---|---|
| ជាចិត្ត | សកទាគាមិផល | ១ដួង |
| ជាចិត្ត | អនាគាមិផល | ១ដួង |
| ជាចិត្ត | អរហត្តផល | ១ដួង |
| | រួម | ៤ដួង |

ហៅថាចិត្តជាលោកុត្តរវិបាក

## ពាក្យអធិប្បាយ លោកុត្តរវិបាកចិត្ត ៤ដួង

ពាក្យថា

សោតាបត្តិ សកទាគាមិ អនាគាមិ អរហត្ត នោះ

ទំនងជាមួយគ្នា នឹង លោកុត្តរកុសលចិត្តនោះគ្រប់ប្រការ

ពាក្យថា លោកុត្តរវិបាកចិត្ត

**មានន័យថា** ជាផលរបស់លោកុត្តរកុសលចិត្ត ប៉ុណ្ណោះ

**ឥច្ចេវំ សព្វថាបិ អដ្ឋលោកុត្តរកុសលវិបាក-**

**ចិត្តានិ សមត្តានិ**

ប្រែ ចិត្តទាំងនេះ លោកុត្តរកុសលចិត្ត ៤ ដួង លោកុត្តរ-

វិបាកចិត្ត ៤ ដួង រួម ៨ ដួងនេះដោយបរិបូណ៌ ។

## គាថាសង្គហ

ចតុមគ្គប្បភេទេន ចតុធា កុសលន្តថា

បាកន្តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ

ប្រែសេចក្តីថា លោកុត្តរកុសលចិត្ត ចាដោយប្រភេទរបស់មគ្គ មាន ៤ ប្រភេទ លោកុត្តរវិបាកចិត្តមាន ៤ ដូចគ្នា ព្រោះជាផលរបស់កុសល ដូច្នេះដឹងបានថា លោកុត្តរចិត្តមានចំនួន ៨ ដួងប៉ុណ្ណោះ ។

## គាថាសង្គហ

ទ្វាទសាកុសលានេវំ កុសលានេកវីសតិ

ឆត្តឹសេវ វិបាកានិ កិរិយា ចិត្តានិ វីសតិ

ចតុបញ្ញាសធា កាមេ រូបេ បន្នរសី រយេ

**ចិត្តានិទ្វាទសារុប្បេ អដ្ឋធា នុត្តរេ តថា**

ប្រែ សេចក្តីដូចដែលបរិយាយមកខាងដើមនេះ អកុសលចិត្ត ១២ដួង កុសលចិត្ត ២១ដួង វិបាកចិត្ត ៣៦ដួង កិរិយាចិត្ត ២០ដួង ។

ចិត្តជាសាធារណៈ បានដល់កាមភូមិនោះអ្នកប្រាជ្ញត្រូវពោលថា មាន ៥៤ដួង ។

ចិត្តជាសាធារណៈបានដល់រូបភូមិ នោះអ្នកប្រាជ្ញត្រូវពោលថាមាន ១៥ដួង ។

ចិត្តជាសាធារណៈបានដល់អរូបភូមិនោះ អ្នកប្រាជ្ញត្រូវពោលថា មាន ១២ដួង ។

ចិត្តជាលោកុត្តរនេះអ្នកប្រាជ្ញ ត្រូវពោលថា មានចំនួន ៨ ដួង ។

## សេចក្តីអធិប្បាយគាថា ២បទនេះ

| | | | |
|---|---|---|---|
| អកុសលចិត្ត | ១២ដួង | កាមាវចរចិត្ត | ៥៤ដួង |
| កុសលចិត្ត | ២១ដួង | រូបាវចរចិត្ត | ១៥ដួង |
| វិបាកចិត្ត | ៣៦ដួង | អរូបាវចរចិត្ត | ១២ដួង |
| កិរិយាចិត្ត | ២០ដួង | លោកុត្តរចិត្ត | ៨ដួង |
| រួម = | ៨៩ដួង | រួម = | ៨៩ដួង |

................................

## គាថាសង្គហ

**ឥត្ថមេកូននវុតិប្បភេទំ បន មានសំ**

**ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា**

ប្រែ សំដែងបទជូន ទីបំផុត តាមដែលពោលមកហើយ

ចិត្តទាំងអស់ អ្នកប្រាជ្ញទាំងឡាយ រមែងពោលថា មានពីរ

ប្រការគឺ ៨៩ដួង និង ១២១ដួង ដូច្នេះឯង ។

✲ ✲ កតមេកូននវុតិ វិធំ ចិត្តំ ឯកវីសសតំ ហោតិ វិតក្កវិចារបីតិ សុខេកគ្គតាសហិតំ បឋមជ្ឈានសោតតាបត្តិមគ្គចិត្តំ វិចារបីតិ-សុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គ-ចិត្តំ បីតិសុខេកគ្គតាសហិតំ តតិយជ្ឈាន-សោតាបត្តិមគ្គចិត្តំ សុខេកគ្គតាសហិតំ ចតុត្ថ-ជ្ឈានសោតាបត្តិមគ្គចិត្តំ ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្តញ្ចេតិ ឥមានិ សមវីសតិ មគ្គចិត្តានិ តថា ផលចិត្តានិ ចេតិ សមចត្តាឡីស លោកុត្តរចិត្តានិ ភវន្តីតិ ។

ប្រែ ចិត្ត ៨៩ដួង កើតជាមួយចិត្ត ១២១ដួង ឬ យ៉ាងណា ?

-ព្រះសោតាបត្តិមគ្គចិត្ត ១ដួង ដែលប្រកបដោយបឋមជ្ឈានដែលកើតព្រមគ្នា នឹង គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ( អង្គទាំង ៥ ) ។

- ព្រះសោតា បត្តិមគ្គចិត្ត ១ដួង ដែលប្រកបដោយទុតិយជ្ឈាន កើតជាមួយអង្គទាំង ៤ គឺ វិចារ បីតិ សុខ ឯកគ្គតា ។

- ព្រះសោតាបត្តិមគ្គចិត្ត ១ដួង ដែលប្រកបដោយតតិយជ្ឈាន សឹងកើតជាមួយអង្គទាំង ៣ គឺ បីតិ សុខ ឯកគ្គតា ។

- ព្រះសោតាបត្តិមគ្គចិត្ត ១ដួង ដែលប្រកបដោយចតុត្ថជ្ឈាន កើតជាមួយអង្គទាំង ២ គឺ សុខ ឯកគ្គតា

- ព្រះសោតាបត្តិ មគ្គចិត្ត ១ដួង ដែលប្រកបដោយបញ្ចមជ្ឈាន កើតជាមួយអង្គទាំង ២ គឺ ឧបេក្ខា ឯកគ្គតា

រួមសោតបត្តិមគ្គចិត្ត ៥ យ៉ាង ដែលប្រកបដោយឈានទាំង ៥

ចំណែកព្រះសកទាគាមិ ព្រះអនាគាមិ ព្រះអរហន្ត ក៏ទំនងគឺ១ម្យ៉ាង សោតាមានឈាន ៥ រួម ៤ យ៉ាង មានឈាន ២០ដួង ។

ផលចិត្តម្យ៉ាង១មានឈាន ៥ បានផល ២០ដួង រួម មគ្គ ២០ ផល ២០ ដូច្នេះ ឈានចិត្តរបស់ ចិត្ត ជាលោកុត្តរ ៨ ដួង បាន ៤០ ដួង ហៅថាលោកុត្តរចិត្ត ៤០ដួង ដូច្នេះឯង ។

# សំដែងវិធីរាប់ចិត្ត ១២១ដួង

| | | | |
|---|---|---|---|
| កាមាវចរចិត្ត | ៥៤ដួង | ចិត្តជាលោកិយ៍ | ៨១ដួង |
| រូបាវចរចិត្ត | ១៥ដួង | លោកុត្តរចិត្ត | ៤០ដួង |
| អរូបាវចរចិត្ត | ១២ដួង | រួម | ១២១ដួង |
| លោកុត្តរចិត្ត | ៤០ដួង | | |
| រួម | ១២១ដួង | | |
| អសោភណចិត្ត | ៣០ដួង | កុសលចិត្ត | ៣៧ដួង |
| សោភណចិត្ត | ៩១ដួង | អកុសលចិត្ត | ១២ដួង |
| រួម | ១២១ដួង | អព្យាកតចិត្ត | ៧២ដួង |
| | | រួម | ១២១ដួង |

# តារាងលោកុត្តរៈ ៤០ដួង

| មគ្គចិត្ត.ផលចិត្ត | បឋមឈាន | ទុតិយជ្ឈាន | តតិយជ្ឈាន | ចតុត្ថជ្ឈាន | បញ្ចមជ្ឈាន | រូប |
|---|---|---|---|---|---|---|
| សោតាបត្តិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| សកទាគាមិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| អនាគាមិមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| អរហត្តមគ្គ | ១ | ១ | ១ | ១ | ១ | ៥ |
| សោតាបត្តិផល | ១ | ១ | ១ | ១ | ១ | ៥ |
| សកទាគាមិផល | ១ | ១ | ១ | ១ | ១ | ៥ |
| អនាគាមិផល | ១ | ១ | ១ | ១ | ១ | ៥ |
| អរហត្តផល | ១ | ១ | ១ | ១ | ១ | ៥ |
| រូប | ៨ | ៨ | ៨ | ៨ | ៨ | ៤០ |

## គាថាសង្គហ

**ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា**

**វុច្ចតានុត្តរំ ចិត្តំ ចត្តាឡីសវិធន្តិ ច ។**

ប្រែ បានដោយសង្ខេបនោះ លោកុត្តរចិត្ត កាលចំណែក មួយដូងៗ ប្រាំតាមប្រភេទរបស់ឈានហើយ និង ជា លោកុត្តរចិត្ត មាន ៤០ដួង ។

# គាថាសង្គហ

**យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា បឋមា-ទិជ្ឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ឯកាទស វិធំ តស្មា បឋមាទិក មីរិតំ ឈានមេកេ កម្មន្តេ តុ តេវិសតិ វិធំ ភវេ**

**ប្រែ** រូបាវចរចិត្ត រាប់ដោយឈានថា បឋមជ្ឈាន ទុតិយ-ជ្ឈាន មានឧបមាយ៉ាងណា លោកុត្តរចិត្ត ក៏រាប់ឧបមាដូច្នេះដែរ

សំរាប់អរូបាវចរចិត្ត ត្រូវរាប់ជាបញ្ចមជ្ឈាន ព្រោះហេតុដូច្នោះ ទើបជាបឋមជ្ឈាន ១១ ទុតិយជ្ឈាន ១១ ដូចនេះជាដើមទៅ ចំណែកបញ្ចមជ្ឈាន នេះមាន ២៣ ដួង

អធិប្បាយថា លោកុត្តរចិត្ត ៨ដួង បានបឋមជ្ឈាន ៨ដួង ក្នុងរូបាវចរកុសល បឋមជ្ឈាន ១ វិបាកបឋមជ្ឈាន ១ កិរិយាបឋមជ្ឈាន រួមលោកិយ លោកុត្តរ

ក្នុងបឋមជ្ឈាន ១១ដួង ទុតិយជ្ឈាន ១១ដួង ក៏ ដូចគ្នា តតិយជ្ឈាន ១១ដួង ចតុត្ថជ្ឈាន ១១ដួង

រួមសោមនស្ស ក្នុងឈានទាំង ៤ មាន ៤៤ដួង

ចំណែកបញ្ចមជ្ឈាននោះ ក្នុង រូបាវចរ ៣ ដួង + អរូបាវចរ ១២ដួង + លោកុត្តរ ៨ ដួង រួម ២៣ដួង រួមទាំងអស់ ១១ + ១១ + ១១ + ១១ = ២៣ឈានចិត្ត ៦៧ដួង

## គាថាសង្គហ

**សត្តតឹសវិធំ បុញ្ញំ ទ្វេបញ្ញាស វិធំ តថា បាក**

**មិច្ចាហុ ចិត្តានិ ឯកវីសសតំ ពុធា**

**ប្រែ** ចិត្តជាបុណ្យ ( កុសល ) មាន ៣៧ដួង

ចិត្តជាវិបាកមាន ៥២ដួង

រួមជាមួយនិង អកុសល និង កិរិយាចូលគ្នា អ្នកប្រាជ្ញ រមែងពោលថា បានដល់ចិត្ត ១២១ដួង ។

# សំដែងភាពចិត្តជាព្រះបរមត្ថ

| ឈ្មោះចិត្ត | កុសលធម្មា | អកុសលាធិម្មា | | | អព្យាកតធម្មា | | រួម |
|---|---|---|---|---|---|---|---|
| | | លោភ | ទោស | មោហ | វិបាក | កិរិយា | |
| កាមាវចរ | ៨ | ៨ | ២ | ២ | ២៣ | ១១ | ៥៤ |
| រូបាវចរ | ៥ | × | × | × | ៥ | ៥ | ១៥ |
| អរូបាវចរ | ៤ | × | × | × | ៤ | ៤ | ១២ |
| លោកុត្តរ | ២០ | × | × | × | ២០ | × | ៤០ |
| រួម | ៣៧ | ៨ | ២ | ២ | ៥២ | ២០ | ១២១ |

# ពាក្យសួរឆ្លើយ លោកុត្តរចិត្ត ៨ដួង

**សួរ** ពាក្យថា លោកុត្តរគឺជាអ្វី ?

**ឆ្លើយ** ពាក្យលោកុត្តរ ប្រែថា ធម្មជាតិដែលបានផុតអំពីលោកទាំង ៣ គឺ កាមលោក រូបលោក អរូបលោក ។

**មានន័យថា**

បានឆ្លងផុតចាកពី ៣១ភូមិ បានដល់ លោកុត្តរធម៌ ៩ ប្រការ គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ និង ព្រះនិព្វានធាតុ ១ ។

**សួរ៖** ពាក្យថាលោកុត្តរ ប្រែថា ផុតចាកលោកទាំងបី នោះចិត្ត ឬ អ្វីដែលផុតអំពីលោកទាំង ៣ ?

**ឆ្លើយ** តាមពុទ្ធភាសិតថា :

**កតមេ ធម្មា លោកុត្តរា ចត្តារោ ច អរិយមគ្គា ចត្តារិ ច សាមញ្ញផលានិ អសង្ខតា ច ធាតុ ឥមេ ធម្មា លោកុត្តរា**

**ប្រែ** ចិត្តជាមគ្គ ៤ ប្រការ ( មគ្គចិត្ត ៤ ប្រការ ) ចិត្តជាផលឬ ផលចិត្ត ៤ ប្រការ ។

( មគ្គចិត្ត ៤ ប្រការ + ផលចិត្ត៤ ប្រការ ) = រួម ៨ ប្រការ

នេះមានអារម្មណ៍ជាព្រះនិព្វាន ព្រោះហេតុដូច្នេះ លោកុត្តរ ពិត១នោះ គឺ និព្វានតែ ១ តែចិត្ត៨ ប្រការ នោះ គឺ និព្វានតែ ១ តែ ចិត្ត ៨ ប្រការនោះក៏ជាហេតុផល ដែលនាំទៅកាន់ព្រះនិព្វានបាន ។

ដូច្នេះរូបទាំង ៨ ប្រការ និង ព្រះនិព្វាន ទើបរាប់ជាលោកុត្តរបាន តែមគ្គផល ៨ ប្រការនេះ នៅជាសង្ខតធម៌នៅឡើយ ។

ចំណែកនិព្វានជាអសង្ខតធម៌ គឺ គ្មានចិត្ត ឬចេតសិក ឡើយ ។

**សួរ** កាមាវចរវិបាក រូបាវចរវិបាក អរូបាវចរវិបាកទាំងនេះកាលអ្នកធ្វើកុសល ស្លាប់ទៅហើយ បានទទួលផលក្នុងជាតិមុខ ចំណែកលោកុត្តរវិបាកនេះបានទទួលផលកាលណា ?

**ឆ្លើយ** លោកុត្តរវិបាកនោះ គ្មានដូចវិបាកដទៃៗទេព្រោះលោកុត្តរវិបាកជាធម្មជាតិ ដែលបានទទួលផលរហ័សជាទីបំផុត គឺ ព្រមជាមួយដែលបានដល់លោកុត្តរកុសល ហើយក៏បានទទួលជាលោកុត្តរវិបាក ក៏យ៉ាងនោះដែរ គឺ ជាអកាលិកធម៌ពិតៗ ដូច្នេះទើបបានផល មួយរំពេច ។

**ស្នួរ** ការសោយវិបាករបស់ព្រះអរហន្ត ដូចព្រះសីវលី មានលាភច្រើន ព្រះពាកុល មានអាយុវែង ព្រះមោគ្គល្លាន ត្រូវមហាចោរ សម្លាប់ជាដើម ។ ទាំងនេះ ជាលោកុត្តរវិបាកឬទេ ?

**ឆ្លើយ** តាមការពិត ព្រះអរហន្តមិនមានកុសល និង អកុសល ចំពោះតែក្នុងអនាគតរបស់ជាតិ តែកុសល និង អកុសលដែលលោកបានធ្វើមកហើយ ក្នុងអតីតកាល គឺ ក្នុងជាតិមុនៗនោះ នៅជំពាក់បំណុលចាស់ ព្រោះដូច្នេះ កាលដែលព្រះអរហន្តសោយសុខ ឬ ទុក្ខនោះ ព្រោះ កាមាវចរវិបាកចាស់ គ្មានលោកុត្តរវិបាកទេ ?

**ស្នួរ** អ្នកដល់លោកុត្តរកុសល បានទទួលគុណយ៉ាងណា ខ្លះ ?

**ឆ្លើយ** អ្នកដែលបានទទួលអរិយមគ្គទាំង ៤ ប្រការនោះ បានផុតអំពីវដ្តសំសារ តាមថ្នាក់ជានិច្ចគឺ ព្រះសោតាបត្តិ -

បុគ្គល យ៉ាងច្រើនទៀត ៧ ជាតិប៉ុណ្ណោះ និង បានផុតពីវដ្តសំសារ ។

- ព្រះសកទាគាមិ មួយជាតិក្នុងកាមភូមិ ។
- ព្រះអនាគាមិ មិនត្រឡប់មក និង
- ព្រះអរហន្ត នោះរំលត់ខ្លួនក្នុងជាតិនេះ ។

ដូច្នេះ អ្នកដែលបានទទួលលោកុត្តរកុសល ទើបមានគុណច្រើន ។

**សួរ** ចំណែកការប្រហារ កិលេសនោះ លោកុត្តរកុសលទាំង ៤ ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ការសម្លាប់កិលេសរបស់ព្រះសោតាបត្តិមគ្គប្រហារចិត្តជាអកុសល បាន ៥ ដួង គឺ : ទិដ្ឋិគត សម្បយុត្ត ៤ដួង

វិចិកិច្ឆា សម្បយុត្ត ១ដួង

អាការៈដែលសម្លាប់នោះ ព្រះបរមសាស្តាត្រាស់ទុកថា វិជ្ជូបមា ធម្មា ប្រដូចផ្លេកបន្ទោរ ។ ដូច្នេះ បានដល់ញាណរបស់ព្រះសោតាបត្តិមគ្គ ។

ការសម្លាប់របស់ព្រះសកទាគាមិមគ្គ ក៏ប្រហែលគ្នា តែអាចនិងធ្វើឱ្យកាមរាគ និងបដិឃៈ ស្រាលស្តើងចុះបានខ្លះ ។ [1]

ការសម្លាប់របស់ព្រះអនាគាមិមគ្គ គឺ :

- ទិដ្ឋិគតសម្បយុត្ត ៤ដួង

វិចិកិច្ឆា ១ដួង ទោសមូល ២ដួង រួម ៧ដួង

ព្រះអរហន្តនោះសម្លាប់ចិត្តជាអកុសល ១២ដួង ដោយពេញបរិបូណ៌ និង អាការដែលសម្លាប់នោះ ព្រះបរបសាស្តាព្រាល់ថា :

វជិរូបមា ដូចនេះ

ប្រែ ប្រដូច វជិរៈ គឺអាវុធរបស់ព្រះឥន្ទ

**មានន័យថា** មគ្គទាំង ៣ នេះកាត់ផ្តាច់បានដាច់ខាតដូចរំលាយដោយវជិរាវុធ គឺ អាវុធរបស់ព្រះឥន្ទ្រ ។

**សួរ** ការប្រហារ ( សម្លាប់ ) កិលេសនោះ លោកុត្តរកុសលប្រហារកិលេស អតីត អនាគត ឬ បច្ចុប្បន្ន ?

**ឆ្លើយ** ការប្រហារកិលេស របស់ព្រះអរិយមគ្គនោះ និងថា ដោយកាលឯណានិមួយៗក្នុងកាលទាំងបី ក៏មិនមាន ព្រោះ កិលេស ចំណែកអតីត ក៏រលត់ទៅហើយមុន ប្រហារ កិលេស ចំណែកអនាគតក៏នៅមិនកើត ប្រហារមិនបាន នោះឯង ( ក៏ដូច្នេះឯង ) សំរាប់បច្ចុប្បន្ន កិលេស ទាំងអស់ មិនបានកើតព្រមគ្នា ។

កាលលោភចិត្តកើត ទោសចិត្តក៏មិនកើត កាល ទោសកើត លោភក៏មិនកើត ដូច្នេះការប្រហារកិលេសនេះ ទើបជាការលំបាក ។

ដែលនឹងអធិប្បាយថា សម្លាប់ ឬ ប្រហារកិលេស ១៥០០ ព្រមគ្នាអស់រលីង ដែលអធិប្បាយមកហើយ ។

នេះជាវាទៈរបស់ព្រះអដ្ឋកថាចារ្យ តែយ៉ាងណាក្តី ការប្រហារកិលេសនេះ ការពិចារណាមើលតាំងពីមគ្គចិត្ត ប្រាកដឡើង កិលេសដែលនឹងប្រាកដទៀតក៏រមែងមិនមាន ឱកាសឡើយ ដូច្នេះក៏មានសេចក្តីថា អរិយមគ្គកាត់មិន

ឱ្យកិលេសកើតបាន ក្នុងអនាគតទៀត ជាដាច់ខាត ។ ឧបមាដូចដើមឈើ ដែលមានផ្លែមួយដើមមានមនុស្សបេះស៊ីជានិច្ច នៅមានបុរសមួយនាក់មកកាត់ឫសកែវចេញ ទោះបីដើមឈើនោះនៅប្រាកដជាដើមក្តី ក៏មិនអាចនឹងឱ្យផលបានឡើយ ។ ក្នុងទីនេះការកាត់ដើមឈើរបស់បុរសនោះនឹង ថាវំលាយផលក្នុងអតីតក៏មិនបាន ព្រោះផលអតីតនោះ អ្នកស្រុកបេះស៊ីទៅហើយ នឹងអនាគតក៏មិនមាន និង ថាវំលាយផល បច្ចុប្បន្នក៏មិនមាន តែថាអស់ទៅព្រមនឹងជាមួយកាត់ឫសផល ក្នុងអនាគតក៏មិនអាចដែលនឹងផលកើតទៀតបាន មានឧបមាយ៉ាងណា ការប្រហារកិលេសរបស់ព្រះអរិយមគ្គ ដូច្នេះដែរ ។

ថាដោយកាលទាំង ៣ ក៏មិនបាន ត្រឹមតែថា កិលេសរបស់អនាគតនោះ រមែងមិនប្រាកដច្បាស់ ។

ក្នុងកថាវត្ថុ អត្ថកថា ពោលថា :

**និព្វានារម្មណេ បន អរិយមគ្គេ បវត្តិតេ កិលេសា អនុប្បន្នា យេវ អនុប្បជ្ជនតីតិ បហីនា នាម ហោន្តីតិ**

**ប្រែ** កាលអរិយមគ្គដែលមាន ព្រះនិព្វានជាអារម្មណ៍ កើតឡើងនោះ កិលេសនៅមិនទាន់កើត ក៏រមែងមិនកើត ដូច្នេះ ការប្រហារកិលេសនោះ នឹងរាប់ថា ប្រហារកិលេស អនាគតក៏បាន ។

**សួរ** ក្នុងកាមាវចរ រូបាវចរ អរូបាវចរ ទាំង ៣ នោះមាន ចិត្តជា កិរិយាចិត្តបាន ចំណែកលោកុត្តរចិត្តនោះ ធ្វើដូច ម្តេចមិនមានកិរិយាចិត្តទេ ។

**ឆ្លើយ** ពាក្យថា កាមាវចរ រូបាវចរ កិរិយា អរូបាវចរ គឺជា កាមាវចរកុសល រូបាវចរកុសល និង អរូបាវចរកុសល នោះឯង ឧបមាដូចមានមនុស្សម្នាក់ ដែលធ្វើកាមាវចរកុសលមកពីដំបូង ខាងក្រោយអ្នកនោះក្លាយជាព្រះអរហន្តទៅ ។ តាំងពីខណៈដែលបានជាព្រះអរហន្តទៅ

ការធ្វើកុសលរបស់អ្នកនោះ ក៏រមែងក្លាយទៅជាកិរិយាទៅ និងមិនបានផលទេឡើយ ។ មានន័យថា ការធ្វើកុសលរបស់អ្នកនោះ ដែលនិងបានជាព្រះអរហន្តហៅថា មហា-កុសលប្រែថា មហាកុសលនៅមានផល សំរាប់ទៅអនាគតបើនឹងត្រូវ បដិសន្ធិទៀត មហាកុសលនេះឯង តែងសំរេចជាព្រះអរហន្ត ហើយក៏ក្លាយទៅជាកិរិយាទៅមួយរំពេច មានសេចក្តីថា មិនបានផល ព្រោះមិនមានការ បដិសន្ធិទៀតឡើយ ពោលដោយសង្ខេបគឺ កាមាវចរកុសលកើតបាន គ្រប់រយៈ ( ខណៈ ) រហូតដល់រំលត់ខន្ធទាំង ៥ ។ តែមុននឹងបានសំរេច ព្រះអរហន្តនោះ ហៅថាកាមាវចរកុសលតាំងតែខណៈ ដែលជាជាតិអរហន្តនេះ ហៅថាកាមាវចរកិរិយា ចំណែកមគ្គរបស់លោកុត្តរនោះគ្មានដូច្នេះទេ ។

អរិយមគ្គកើតតែ១ម្តង (១គ្រា) ហើយរលត់ចុះមួយរំពេច មិនបានកើតតទៅដូចលោកិយកុសល ដែល

កើតញយៗដូច្នេះក្នុងលោកុត្តរ . ទើបមិនចាំបាច់ ត្រូវមាន

កិរិយា

**សួរ** លោកុត្តរចិត្ត ៨ដួង ? មានចេតសិកប្រកបជាមួយ

ប៉ុន្មាន?

**ឆ្លើយ** លោកុត្តរចិត្ត ៨ដួង មានចេតសិកប្រកប ៣៦ដួងគឺ

អញ្ញសមានាចេតសិក ១៣ដួង

សោភណសាធារណចេតសិក ២៣ ( វៀរ អប្បមញ្ញា ២ )

រួម ៣៦ ដួង ។

**សួរ** ការដែលវៀរលែង អប្បមញ្ញាចេតសិកនោះ ព្រោះ

ក្នុងលោកុត្តរចិត្ត មិនមានករុណា ឬ មុទិតា ? ។

**ឆ្លើយ** គ្មានដូច្នេះទេ ការដែលវៀរ អប្បមញ្ញាទាំងពីរ

ព្រោះអារម្មណ៍ផ្សេងគ្នា គឺ អប្បមញ្ញាមានសត្វទាំងឡាយ

ជាអារម្មណ៍ ចំណែកលោកុត្តរមានព្រះនិព្វានជាអារម្មណ៍

ព្រោះអារម្មណ៍ផ្សេងគ្នា ដូច្នេះឯង ទើបធ្វើឱ្យអប្បមញ្ញា

ទាំងពីរ វៀរ ។

បរិច្ឆេទទី ១

# សង្គហន័យរបស់លោកុត្តរ

ឥតិ អភិធម្មត្ថសង្គហេ ចិត្ត សង្គហវិភាគោ

នាម បឋមោ បរិច្ឆេទោ

ប្រែ ក្នុងគម្ពីរ ព្រះអភិធម្មត្ថសង្គហៈនេះ ឈ្មោះថា ចិត្តសង្គហវិភាគ ជាបឋមបរិច្ឆេទ ចប់ត្រឹមតែប៉ុណ្ណោះ ។

*បរិច្ឆេទទី II*

# ចេតសិក គឺចេតសិកបរិច្ឆេទ

## គាថាសង្គហ ខាងដើម

ឯកុប្បាទនិរោធា ច ឯកាលម្ពណវត្ថុកា

ចេតោយុត្តាទ្វិបញ្ញាស ធម្មាចេតសិកាមតា

ប្រែ នៅមានធម្មជាតិ ៥២ដូង ដែលកើតព្រមនឹងចិត្ត រលត់ព្រមជាមួយចិត្ត មានអារម្មណ៍តែ១ ជាមួយគ្នានឹងចិត្ត មានវត្ថុតែមួយជាមួយនឹងចិត្ត និង ប្រកបចូលជាមួយចិត្តសំបូណ៌ដោយលក្ខណ ៤ ប្រការនេះ ហៅថាចេតសិក

## ពាក្យអធិប្បាយ ចេតសិក

ពាក្យថាចេតសិក តាមវិគ្គហថា

ចេតសិនិយុត្តំ ចេតសិកំ

**ប្រែ** ធម្មជាតិដែលប្រកបជាមួយចិត្ត ដូច្នេះហៅថា ចេតសិក ។

**មានន័យថា** មានលក្ខណៈ ៤ យ៉ាងគឺ :

| | |
|---|---|
| ១- ឯកុប្បាទ | កើតព្រមចិត្តជា១ចិត្ត |
| ២- ឯកនិរោធ | រលត់ប្រមជាមួយចិត្ត |
| ៣- ឯកលម្ពណ | មានអារម្មណ៍ជាមួយគ្នានិងចិត្ត |
| ៤- ឯកវត្ថុក | ដែលអាស្រ័យវត្ថុជាមួយគ្នានិងចិត្ត |

រួម ៤ យ៉ាង មានចេតសិក ៥២ដួងគឺ :

| | |
|---|---|
| I អញ្ញសមានាចេតសិក | ១៣ដួង |
| II អកុសលចេតសិក | ១៤ដួង |
| III សោភណសាធារណចេតសិក | ២៥ដួង |
| រួម | ៥២ដួង |

អញ្ញសមានាចេតសិក ១៣ដួង ញែកចេញ ២យ៉ាង

| | |
|---|---|
| សព្វចិត្តសាធារណចេតសិក | ៧ដួង |
| បកិណ្ណចេតសិក | ៦ដួង |

រួម ១៣ដួង

## សំដែងអញ្ញសមានាចេតសិក ១៣ដួង

តាមបាលី

ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោ ចេតិ សត្តមេ ចេតសិកា សព្វចិត្តសាធារណា នាម ។ វិតក្កោ វិចារោ អធិមោក្ខោ វីរិយំ បីតិ ឆន្ទោ ចេតិ ឆយិមេ ចេតសិកា បកិណ្ណកា នាម ឯវមេតេរស ចេតសិកា អញ្ញសមានាតិ វេទិតព្វ

ប្រែ ក្នុងចេតសិក ៥២ដួងនោះ គឺ :

ផស្ស វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រីយ៍ មនសិការ រួមចេតសិក ៧ ដួង ហៅថាសព្វចិត្តសាធារណចេតសិក ។

វិតក្ក វិចារ អធិមោក្ខ វិរិយ បីតិ ឆន្ទ រួមចេតសិក ៦ ដួង ហៅថា បកិណ្ណកចេតសិក ចំនួន ១៣ ដួង ហៅថា អញ្ញសមានាចេតសិក ។

**អធិប្បាយ** អញ្ញសមានា ១៣ដួង

សព្វចិត្តសាធារណចេតសិកនោះ គឺ :

១- **ផស្ស ប្រែថា** ជាចេតសិកដែលទាក់ទងមកអំពីការប៉ះទង្គិចអារម្មណ៍ទាំង ៦ដូចជាភ្នែក រូប ប៉ះទង្គិចគ្នាហើយ ជាផស្សកើត ន័យថា ការប៉ះទង្គិច ។

២- **វេទនា ប្រែថា** ជាចេតសិកដែលសោយអារម្មណ៍ គឺសេចក្តីទុក្ខ សុខ មានន័យថា ខាងក្រោយដែលត្រូវប៉ះទង្គិចអារម្មណ៍ នៅមានការសោយអារម្មណ៍ទៀត ។

៣- **សញ្ញា ប្រែថា** ជាចេតសិកដែលចាំអារម្មណ៍ គឺចាំ **ពណ៌ ស ក្រហម** ជាដើម ។

៤- **ចេតនា** ជាចេតសិក ដែលស្វែងរកអារម្មណ៍តាម

បំណងគឺ ធ្វើការវត្ថុណាក្តី មានចេតនាក្នុងកាល ទាំង ៣

**អ . ប . អនា ៥**

៥- **ឯកគ្គតា** ជាចេតសិកដែលទទួលអារម្មណ៍តែមួយ គឺ សមាធិនោះឯង មានន័យថា តាំងមាំនៅក្នុងអារម្មណ៍តែមួយ ។

៦- **ជីវិតិន្ទ្រីយ៍** ជាចេតសិកដែលរក្សានាមធម៌ ទាំងអស់ឱ្យរៀបរយ តែជីវិតិន្ទ្រីយ៍ នោះមានពីរយ៉ាងគឺ រូបជីវិតិន្ទ្រិយ៍ នាមជីវិតិន្ទ្រីយ៍ ក្នុងទីនេះបានដល់នាមជីវិតិន្ទ្រីយ៍នោះឯង ។

៧- **មនសិការៈ** ជាចេតសិកធ្វើចិត្ត ឱ្យត្រិះរិះអារម្មណ៍ គឺការត្រិះរិះថា ល្អ ឬ ទេ ដូច្នេះជាដើម ។

រួមចេតសិក ៧ដួង ដែលពោលមកហើយនេះ ហៅថាសព្វចិត្តសាធារណ ព្រោះ ជាចេតសិកដែល សាធារណដល់ចិត្តទាំងអស់ ។

**បកិណ្ណកចេតសិក ៦ ដួង គឺ :**

១ **វិតក្កៈ ប្រែថា** ជាចេតសិក ដែលធ្វើឱ្យរិះរក អារម្មណ៍ គឺ ធ្វើឱ្យលើកចិត្តឡើង កាន់អារម្មណ៍ជានិច្ច មានន័យថា ចេតសិកដែលគិតផ្សេងៗ នានា ។

២ **វិចារៈ** ជាចេតសិកដែលពិចារណា គឺ ការពិចារណាអារម្មណ៍ដើម្បី មិនឱ្យវិតក្កគេចចេញចាក អារម្មណ៍ ឬ ជាការរក្សាវិតក្កៈក៏បាន ។

៣ **អធិមោក្ខោ** ជាចេតសិកចុះស៊ប់ក្នុងអារម្មណ៍មិនងាករេ ឬ ការកាត់សេចក្ដីដាច់ខាតថាល្អ ឬ អាក្រក់ជាដើម ។

៤ **វីរិយំ** ជាចេតសិក ដែលមានសេចក្ដីព្យាយាម គឺ ការមិនរុញរាថយក្រោយនៃសេចក្ដីព្យាយាម ។

៥ **បីតិ** ជាចេតសិក ដែលត្រេកអរចំពោះអារម្មណ៍ គឺ សេចក្ដីចូលចិត្តអារម្មណ៍ បានដល់បីតិ៥យ៉ាងគឺៈ **ខុទ្ទកាបីតិ ខណិកាបីតិ ឱក្កន្តិកាបីតិ ឧព្វេង្គាបីតិ ផរណាបីតិ** រួមបីតិ ទាំង៥

៦ **ឆន្ទៈ** ជាចេតសិកដែលត្រូវការអារម្មណ៍ ឬ ពេញចិត្តក្នុងអារម្មណ៍ ដែលត្រូវការអារម្មណ៍ក៏បាន ឬ ប៉ុនប៉ងក្នុងអារម្មណ៍

រួមចេតសិក ៦ យ៉ាង ដែលពោលមកហើយនេះ ហៅថាបកិណ្ណកចេតសិក ព្រោះសាធារណៈបានដល់ចិត្តចំណែកខ្លះដោយម្តងមួយកាល ។

រួមទាំងអស់គឺ សព្វចិត្តសាធារណចេតសិក ៧ដួង និង បកិណ្ណកចេតសិក ៦ ដួងជា ១៣ ដួង ហៅថា អញ្ញសមានាចេតសិក ។

**ចប់អញ្ញសមានាចេតសិក ១៣ដួង**

បរិច្ឆេទទី ២

# សំដែងអកុសលចេតសិក ១៤ដួងតាមបាលី

មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចំ លោភោ ទិដ្ឋិ មានោ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ ថីនំ មិទ្ធំ វិចិកិច្ឆា ចេតិ (ចុទ្ទសមេ) (ចេតសិកា) អកុសលា នាម

ប្រែ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ លោភោ ទិដ្ឋិ មានោ ទោសោ ឥស្សា មច្ឆរិយ កុក្កុច្ចៈ ថីនៈ មិទ្ធៈ វិចិកិច្ឆា

រួមចេតសិក១៤ដួងនេះហៅថាអកុសលចេតសិក ។

# អធិប្បាយអកុសលចេតសិក ១៤ដួង

១ មោហៈ ប្រែ ជាចេតសិកដែលមួម៉ៅ វង្វេងក្នុងអារម្មណ៍ មានន័យថា មិនដឹងសេចក្ដីពិតនៃសភាវធម៌ដែលពិតប្រាកដ

**២ អហិរិកៈ** ជាចេតសិកដែលមិនមានសេចក្ដីខ្មាស់-អៀន ចំពោះអកុសលគ្រប់បែបយ៉ាង ។

**៣ អនោត្តប្បៈ** ជាចេតសិកដែលមិនមានសេចក្ដីខ្លាច ឬ តក់ស្លុតចំពោះការធ្វើបាប អកុសលគ្រប់បែបយ៉ាង

**៤ ឧទ្ធច្ចៈ** ជាចេតសិកដែលរាយមាយ រវើរវាយក្នុងវត្ថុគ្រប់បែបយ៉ាង ។

**៥ លោភៈ** ជាចេតសិកដែលមានសេចក្ដីជាប់ពាន់អារម្មណ៍ទាំង ៦ កាលខណៈដែលអារម្មណ៍ប៉ះទង្គិច វៀរលែងតែព្រះនិព្វាន ។

**៦ ទិដ្ឋិ** ជាចេតសិកដែលមានសេចក្ដីឃើញខុស គឺ ប្រកាន់ឧបាទានក្ខន្ធទាំង ៥ ជាអត្តា(ខ្លួន) ឬ ជួនកាលហៅថា សក្កាយទិដ្ឋិ ។

**៧ មានៈ** ជាចេតសិកដែលមានសេចក្ដីប្រកាន់ខ្លួនជា ធំ ឬ ខ្ពស់ជាងអ្នកដទៃ ជាដើម ។

៨ **ទោសៈ** ជាចេតសិកដែលមានសេចក្តីប្រទូស្តរាយ គឺសេចក្តីក្រោធនោះឯង ។

៩ **ឥស្សា** ជាចេតសិកដែលមាន សេចក្តីច្រណែននិងអ្នកដទៃ គឺ សេចក្តីហួងហែង ។

១០ **មច្ឆរិយៈ** ជាចេតសិកដែលមានសេចក្តីកំណាញ់ក្នុងសម្បត្តិរបស់ខ្លួន គឺ មិនមានចេតនាឱ្យទានដល់អ្នកដទៃ

១១ **កុក្កុច្ចៈ** ជាចេតសិកដែលមានសេចក្តីខូចចិត្ត ក្តៅក្រហាយក្នុងអកុសលដែលបានធ្វើហើយ និង កុសលដែលនៅមិនទាន់បានធ្វើ ។

១២ **ថីនៈ** ជាចេតសិកដែលធ្វើឱ្យចិត្តងោកងុយ គឺ ស្វែងរកអារម្មណ៍មិនបាន ។

១៣ **មិទ្ធៈ** ជាចេតសិកដែលញ៉ាំងរួមនូវខន្ធ ឱ្យងោកស្ងាប់ចង់ដេក និងមិនស្វែងរកអារម្មណ៍ មិនបាន ឬភាពរួញរា

១៤ **វិចិកិច្ឆា** ជាចេតសិកធ្វើឱ្យកើតសេចក្តីសង្ស័យ

ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឬ ក្នុងមគ្គបដិបទា ចំពោះព្រះពុទ្ធសាសនា ឬ ការកាត់អារម្មណ៍មិនបាន ។

រួមចេតសិក ១៤ដួងនេះ ដែលពោលមកហើយជា អកុសលចេតសិក ។ អកុសលទាំងអម្បាលនេះ ជាសាធារណដល់អកុសលចិត្ត ១២ដួង ដោយចំពោះ ។

(ចប់អកុសលចិត្ត ១៤ដួង)

¤ ¤ ¤ ¤ ¤ ¤ ¤

# សំដែងសោភណសាធារណចេតសិក២៥ដួង

## តាមបាលី

សទ្ធា សតិ ហិរិ ឱត្តប្បំ អលោភ អទោស តត្រមជ្ឈត្តតា កាយបស្សទ្ធិ ចិត្តបស្សទ្ធិ កាយលហុតា ចិត្តលហុតា កាយមុទុតា ចិត្តមុទុតា កាយកម្មញ្ញតា ចិត្តកម្មញ្ញតា កាយបាគុញ្ញតា ចិត្តបាគុញ្ញតា កាយុជុកតា ចិត្តុជុកតា

រូម ចេតសិក ១៩ ដួង ដែលពោលមកហើយ ហៅថា សោភណសាធារណចេតសិក

**សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ** ចេតសិក ៣ ដួងនេះ ហៅថា វិរតិចេតសិក ។

**ករុណា មុទិតា** ចេតសិក ២ ដួងនេះហៅថា អប្បមញ្ញាចេតសិក និង បញ្ញិន្ទ្រីយ៍ចេតសិក ១ ដួង រួមទាំងអស់ហៅថា សោភណចេតសិក ២៥ ដួង ។

ប្រែ សេចក្តីអធិប្បាយ សោភណសាធារណចេតសិក២៥ដួង :

១ **សទ្ធា** ជាចេតសិកដែលមានសេចក្តីជឿប្រកាន់ក្នុងអារម្មណ៍

២ **សតិ** ជាចេតសិកដែលរឭកបាន ពី រឭកអារម្មណ៍ព្រមជាមួយសម្បយុត្តធម៌ ។

៣ **ហិរិ** ជាចេតសិកដែលមានសេចក្តីខ្មាស់ ចំពោះការធ្វើអកុសល ។

៤ **ឱត្តប្បៈ** ជាចេតសិកដែលមានសេចក្តីខ្លាច ចំពោះការធ្វើអកុសល ។

៥ **អលោភៈ** ជាចេតសិកដែលមិនមានចេតនាប្រាថ្នាក្នុងអារម្មណ៍

៦ **អទោសៈ** ជាចេតសិកដែលមិនមានប្រទូសរ៉ាយ ឬខឹង

៧ **តត្រមជ្ឈត្តតា** ជាចេតសិកដែលធ្វើជាកណ្តាល គឺប្រងើយៗ

៨ **កាយបស្សទ្ធិ** ជាចេតសិកដែលធ្វើឱ្យមានសេចក្តីស្ងប់របស់ចេតសិក ដែល ប្រព្រឹត្តទៅក្នុងកាយ

៩ **ចិត្តបស្សទ្ធិ** ជាចេតសិកដែលធ្វើឱ្យមានសេចក្តីស្ងប់ប្រព្រឹត្តទៅក្នុងចិត្ត

១០ **កាយលហុតា** ជាចេតសិក ដែលមានសេចក្តីស្រាលស្តើងរបស់កាយ ។

១១ **ចិត្តលហុតា** ជាចេតសិកដែលមានសេចក្តីស្រាលស្តើងរបស់ចិត្ត ។

១២ **កាយមុទុតា** ជាចេតសិកទន់ភ្លន់ ដែលគួរដល់ការងាររបស់កាយ

១៣ **ចិត្តមុទុតា** ជាចេតសិកទន់ភ្លន់ ដែលគួរដល់ការងាររបស់ ចិត្ត ។

១៤ **កាយកម្មញ្ញតា** ជាចេតសិកដែលគួរ ដល់កាយកម្ម ។

១៥ **ចិត្តកម្មញ្ញតា** ជាចេតសិកដែលគួរដល់ ការងារនៃចិត្ត គឺ មនោកម្ម

១៦ **កាយបាគុញ្ញតា** ជាចេតសិកដែលធ្វើឱ្យ ចេតសិកទាំងឡាយ រហ័សរហួនតាមផ្លូវកាយ ។

១៧ **ចិត្តបាគុញ្ញតា** ជាចេតសិកដែលធ្វើឱ្យចិត្តទាំងឡាយ រហ័សរហួនតាមផ្លូវចិត្ត ។

១៨ **កាយុជុកតា** ជាចេតសិកដែលស្លូតត្រង់ចំពោះកាយ ។

១៩ **ចិត្តុជុកតា** ជាចេតសិកដែលស្លូតត្រង់ចំពោះចិត្ត

រូម ១៩ដួង ដែលពោលមកហើយ ហៅថាសោភណសាធារណចេតសិក ។

**២០ សម្មាវាចា** ជាចេតសិក ដែលបានវៀរចាកវិរតទុច្ចរិត ទាំង ៤ ប្រការ : **មុសាវាទ បិសុណវាទ ផរុសវាចា សម្ផប្បលាបា** រួម ៤ ប្រការនេះ ដោយមិន ទាក់ទងជាមួយវាទ ជាមុខរបរ ។

**២១ សម្មាកម្មន្តោ** ជាចេតសិកដែលវៀលែងអំពីកាយទុច្ចរិត ៣ ប្រការគឺ បាណាតិបាត អទិន្នាទ កាមេសុមិច្ឆាចារ ដែលទាក់ទង និង មុខរបរ ។

**២២ សម្មាអាជីវោ** ជាចេតសិក ដែលវៀរចាកអំពីកាយទុច្ចរិត ៣ វចីទុច្ច ៤ រួម ៧ ប្រការដែលទាក់ទងដល់មុខរបរ ឬ វៀរចាកជំនួញខុស ៥ ប្រការ

**២៣ ករុណា** ជាចេតសិកដែលមានសេចក្តីស្រណោះសត្វទាំងពួងដែលកើតទុក្ខ ឬ លើកលែង ឬ មិនយកទោសពៃចំពោះសត្វ ។

**២៤ មុទិតា** ជាចេតសិកដែល មានសេចក្ដីត្រេកអរចំពោះសត្វទាំងឡាយដែលជាសុខ ឬ មិនច្រណែន ចំពោះលាភ យស សរសើរសុខ របស់អ្នកដទៃ

**២៥ បញ្ញិន្ទ្រិយ** ជាចេតសិកដែលមានបញ្ញា ជាឥន្ទ្រិយ៍ រួមទាំងអស់ ១៩ + ៣ + ២ + ១ = ២៥ ហៅថាសោភណចេតសិក ។

## គាថាសង្គហ

**ឯកូនវីសតិ ច តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា សោភណបញ្ចវីសតិ ទ្វេបញ្ញាសបវុច្ចរេ ៗ**

ប្រែ សេចក្ដីដែលបរិយាយមកនេះ សំដែងថាចេតសិកជាអញ្ញសមានា ១៣ដួង ជាអកុសលចេតសិក ១៤ដួង និងសោភណចេតសិក ២៥ដួង ដូចនេះទើបពោលថាមានចេតសិក ៥២ ដួង ។

# ពាក្យសួរ ឆ្លើយតាមចេតសិក៥២ដួង

**សួរ** ពាក្យថាចេតសិក ប្រែត្រង់ៗ បានដល់អ្វី ?

**ឆ្លើយ** ពាក្យថា ចេតសិកនោះប្រែត្រង់ៗ តាមវិគ្គហថា ចេតសិនិយុត្តំ ចេតសិកំ ប្រែថា សភាពដែលប្រកបជាមួយចិត្តហៅថាចេតសិក តែពាក្យថា ប្រកបជាមួយចិត្តនោះ មាន ៤ ប្រការគឺ :

ឯកុប្បាទ កើតព្រមជាមួយចិត្ត ។

ឯកនិរោធ រលត់ចុះព្រមជាមួយចិត្ត ។

ឯការម្មណា កាលចេតសិកទទួលអារម្មណ៍តែ១ក៏ជាមួយគ្នានិងចិត្ត ។

ឯកវត្ថុក ដែលអាស្រ័យក៏ជាវត្ថុតែ១ជាមួយគ្នានឹងចិត្តរួម ៤ យ៉ាងនេះហៅថា ចេត្តោ យុត្ត ឬ ប្រកបជាមួយ ។

**សួរ** ក្រៅអំពីចេតសិក ៥២ដួង ដែលពោលមកហើយ សភាពដែលកើតព្រមជាមួយចិត្ត នៅមានទៀតឬទេ ?

**ឆ្លើយ** ក្រៅអំពីចេតសិក សភាពធម៌ដែលកើតព្រមជាមួយចិត្ត នៅមានទៀតដូចជា ចិត្តជរូប និង កម្មជរូបទាំងពីរនេះក៏កើតព្រមជាមួយចិត្ត តែថា ចិត្តរលត់មុនរូប ចំណែកចេតសិកនោះរលត់ព្រមគ្នា ព្រោះហេតុដូច្នេះ ពាក្យថា ឯកនិរោធ ក៏បដិសេធថា រូបដែលកើតព្រមជាមួយចិត្ត តែមិនបានរលត់ព្រមជាមួយគ្នា និង ចិត្តទេ (ចិត្ត-ជរូប និង កម្មជរូប មិនមានចេតសិកទេ ទើបមិនរលត់ព្រមជាមួយចិត្ត)

- សភាពដែលកើតរលត់ព្រមជាមួយចិត្ត ក៏នៅមានទៀត គឺ វិញ្ញត្តិរូប ។ វិញ្ញត្តិរូបនោះកើតរលត់ប្រមជាមួយចិត្ត តែថាគ្មានអារម្មណ៍តែមួយជាមួយចិត្តដូចចេតសិកទេ ។ ចំណែកចេតសិកនោះកើតរលត់ ព្រមគ្នាដែលមានអារម្មណ៍តែមួយជាមួយគ្នានិងវត្ថុជាមួយគ្នា ព្រោះហេតុដូច្នេះសរុប-ធម៌ទាំងអស់ សូម្បីរូបខ្លះ និង កើតរលត់ព្រមគ្នាពិតតែគ្មានចេតសិក ។

**សួរ** ពាក្យថាអញ្ញសមានា ប្រែត្រង់ៗ បានដល់អ្វី ?

**ឆ្លើយ** តាមវិគ្គហថា

**អញ្ញេសំ សមានា អញ្ញសមានា**

**ប្រែ** ដូចជាមួយសភាពដទៃបាន ដូច្នេះហៅថាអញ្ញសមានា ។

# អធិប្បាយថា

- កាលបើប្រកបជាមួយកុសល ក៏ជាកុសល
- កាលបើប្រកបជាមួយអកុសល ក៏ជាអកុសល

**មានន័យថា**

ប្រកបផ្នែកណាក៏បាន ឬ មានសេចក្តីអង់អាច ដែលជាសាធារណដល់កុសល អកុសល ឬ អព្យាកតបានគ្រប់បែប ។

ឧបមាដូចទឹកធម្មតា រមែងជាប្រយោជន៍ ដល់សត្វ និង មនុស្សគ្រប់ៗគ្នាបានដូច្នេះ។

**សួរ** ក្នុងចេតសិក ១៣ដួងនោះ មានពាក្យមនសិការ ប្រែថាការពិចារណាអារម្មណ៍

ពាក្យថាវិចារ ក៏ប្រែថាការពិចារណាអារម្មណ៍ ។ ការពិចារណាអារម្មណ៍ទាំងពីរនេះផ្សេង១យ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាមនសិការ តាមវិគ្គហថា :

**មនសិ ករោតីតិ មនសិការោ**

ប្រែ សភាពដែលធ្វើឱ្យចិត្តតអារម្មណ៍ កាលធ្វើឱ្យចិត្តត អារម្មណ៍ហើយ ធ្វើឱ្យអារម្មណ៍តចិត្តដូចគ្នា ក្នុងទីនេះនៅ មានមនសិការ ៣ ប្រការទៀត គឺ :

១- វិថីបាដិបាទិកមនសិការ

២- ជវន បាដិបាទិកមនសិការ

៣- អារម្មណបាដិបាទិកមនសិការ

រួម ៣ ប្រការ ។

-វិថីបាដិបាទកមនសិការ បានដល់បញ្ចទ្វារាវជ្ជនៈ

ព្រោះធ្វើឱ្យចក្ខុវិញ្ញាណ សម្បដិច្ឆន្ន កើតខាងក្រោយដែលខ្លួនរលត់ចុះ ។

- ជវនបាដិបាទិកមនសិការ បានដល់មនោទ្វារាវជ្ជន ព្រោះធ្វើឱ្យជវនកើត ។

- អារម្មណ៍បាដិបាទិកមនសិការ បានដល់មនសិការចេតសិក ព្រោះអារម្មណ៍ប្រាកដនូវឋិតិខណៈ ។ ព្រោះហេតុដូច្នោះ តាមពាក្យប្រែ មនសិការថា ការពិចារណាអារម្មណ៍គឺ ធ្វើឱ្យចិត្តតចំពោះអារម្មណ៍ ហើយធ្វើឱ្យអារម្មណ៍ប្រាកដនូវចិត្តដោយត្រង់ ។

ពាក្យថា វិចារនោះ តាមវិគ្គហថា :

**វិចរតិ វិចារេតីតិ វា វិចារោ**

ប្រែ ការពិចារណាអារម្មណ៍ ខាងក្រោយដែលវិតក្កគិតហើយ ដូច្នេះហៅថាវិចារ ។

វិចារមានន័យថា អារម្មណ៍ចាស់ដែលវិតក្កគិតទុកហើយដើម្បីមិនឱ្យបាត់សូន្យទៅអំពីអារម្មណ៍ ឬ មិនឱ្យ

ចាកពីរអារម្មណ៍ ។

**សួរ** ក្នុងបរិច្ឆេទទី ១ សំដែងពីចិត្តពោលថា សោមនស្ស សហគតំ ប្រែថាព្រមដោយសេចក្តីត្រេកអរ ក្នុងចេតសិកបរិច្ឆេទថា បីតិ ប្រែថា សេចក្តីត្រេកអរយ៉ាងនោះ ពាក្យថា សោមនស្សជាមួយបីតិខុសគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា សោមនស្សសេចក្តីត្រេកអរនោះ ជាវេទនាចេតសិក ១ដួង ពាក្យថា បីតិនោះជាបីតិចេតសិកដោយឡែក គឺ វេទនានោះជាវេទនាខន្ធ បានដល់សេចក្តីសោយសុខ ទុក្ខជាដើម មានន័យថា សេចក្តីត្រេកអរដែលទាក់ទងមកអំពី សេចក្តីសោយអារម្មណ៍ ។

ពាក្យថាបីតិ ត្រេកអរនោះ គឺសេចក្តីត្រេកអររបស់ឥដ្ឋារម្មណ៍ បានដល់បីតិទាំង ៥ គឺ **:ខុទ្ទកាបីតិ ខណិកាបីតិ ឱក្កន្តិកាបីតិ ឧព្វេង្គាបីតិ ផរណាបីតិ** រួម ៥ ប្រការ ហៅថាបីតិ ។

បីតិចេតសិកនេះ រាប់ជាសង្ខារខន្ធ ដូច្នេះ បីតិ និង សោមនស្សផ្សេងគ្នាគឺ

- សោមនស្សជាវេទនាខន្ធ
- បីតិជាសង្ខារក្ខន្ធ

( សូមមើល សម្បយោគន័យ នៃបកិណ្ណក ចេតសិក ៦ដួង ) ។

**សួរ** ពាក្យថាតត្រមជ្ឈត្តតា ចេតសិក និង ឧបេក្ខាវេទនា ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាឧបេក្ខា ជាវេទនាចេតសិក ១ដួងដែលចូលបានទាំងពីរចំណែក ដូច · និង អញ្ញសមានាចេតសិក គឺ សាធារណៈដល់សុខ ទុក្ខបានទាំង២ ចំណែកតត្រមជ្ឈត្តតា គ្មានដូច្នេះទេ គឺ នៅកណ្តាលសុខ និង ទុក្ខទាំងពីរ មាន សេចក្តីថា តត្រមជ្ឈត្តតា មិនជាសុខ ឬ ទុក្ខ ថាបើនិយាយ ជាខន្ធក៏ជាសង្ខារក្ខន្ធ ។

**សួរ** កាយបស្សទ្ធិ និង ចិត្តបស្សទ្ធិ នោះសព្ទកាយ ប្រែថា រាងកាយស្ងើ ។ ចិត្តបស្សទ្ធិ ប្រែថារាងចិត្តស្ងើ ក្នុងទីនេះ ដូចម្តេច ប្រែថាចិត្តស្ងើសោត ?

**ឆ្លើយ** កាយបស្សទ្ធិ ប្រែថាជាចេតសិក ព្រោះកាយប្រែបានពីរយ៉ាង គឺ នាមកាយ និង រូបកាយ ។

ពាក្យថារាងកាយនោះបានដល់រូបកាយ គឺ រូបធម៌ ក្នុងទីនេះពាក្យថា កាយបស្សទ្ធិនោះ ជានាម មិនមែនរូប ព្រោះហេតុដូច្នោះ ត្រូវប្រែជានាមកាយ គឺ ចេតសិក ដោយត្រង់បាន ។

**សួរ** ក្នុងវិរតិ ទាំងបី ប្រែថាការវៀរចាកកាយ ទុច្ចរិត វចីទុច្ចរិត តាមធម្មតា សម្មាវាចាគឺ វាចាដែលល្អ សម្មាកម្មន្តោ គឺ ការងារល្អ ការធ្វើល្អ សម្មាអាជីវ គឺការចិញ្ចឹមជីវិតដោយល្អ ។

ប៉ុណ្ណោះក៏ល្មមបានសេចក្តីដល់ពាក្យ (សព្ទ) ហើយ ដូច្នេះត្រូវប្រែថា វៀរចាកវិរតិផង ?

**ឆ្លើយ** ពាក្យថាវិរតិនេះ គឺជាសីល ពាក្យថាសីលនោះបាន ដល់ចេតនា ដែលនឹងលះបង់ វៀរលែងការទុច្ចរិត ទោះបីថា សម្មាវាចា និង ជាវាចាដែលល្អ យ៉ាងណា ក៏ដោយ ។

សម្មាអាជីវ និងជា ( សព្វ) ការចិញ្ចឹមជីវិត មុខរបរដែលល្អក៏ដោយ បើមិនវៀរចាកទុច្ចរិតហើយ មិនហៅថាសីល ។ ហើយមិនជាជីវិតល្អឡើយ ។

ន័យមួយទៀត សម្មាវាចាមាន ៣ យ៉ាងគឺ

កថា សម្មាវាចា ចេតនា សម្មាវាចា និង វិរតិសម្មាវាចាក្នុងទីនេះ ពាក្យថា កថា សម្មាវាចា បានដល់វាចាដែលល្អ គឺ វាចាសីល វាចាធម៌ទាំងអស់ ។

ពាក្យថា ចេតនា សម្មាវាចានោះ និយាយ ឬ មិននិយាយ ក៏ដោយព្រោះវៀរចាកវចីទុច្ចរិត ៤ ប្រការហើយហៅថាសម្មាវាចាវិរតិ ។

សម្មាកម្មន្តក៏មាន ៣យ៉ាង គឺ : កិរិយាសម្មាកម្មន្ត ចេតនាសម្មាកម្មន្ត វិរតិសម្មាកម្មន្ត ។

១ កិរិយាសម្មាកម្មន្ត បានដល់ ការធ្វើល្អ ពីការប្រតិបត្តិល្អគ្រប់យ៉ាង ។

២ ចេតនាសម្មាកម្មន្ត បានដល់ចេតនាដែលធ្វើសេចក្តីល្អ គ្រប់យ៉ាង ។

៣ វិរតិសម្មាកម្មន្ត បានដល់ការវៀរចាកកាយ ទុច្ចរិត ៣ ប្រការហើយហៅថា វិរតិសម្មាកម្មន្ត .សម្មាអាជីវ មាន ២យ៉ាងគឺ :

១-វិរិយ សម្មាអាជីវ បានដល់សេចក្តីព្យាយាមដែលល្អក្នុងការចិញ្ចឹមជីវិត បានដល់ការធ្វើចំការ ធ្វើស្រែជាដើម ។

២-វិរតិ សម្មាអាជីវ បានដល់មុខរបរការចិញ្ចឹមជីវិត ដែលវៀរចាក ទុច្ចរិត ៧ ប្រការ ហៅថា វិរតិសម្មាអាជីវ ។

វិរតិទាំងអម្បាលនេះ ក្នុងមគ្គទាំង ៨ ហៅថា សម្មាអាជីវមគ្គង្គ សម្មាកម្មន្តមគ្គង្គ សម្មាអាជីវមគ្គង្គដូច្នេះ ។

**សួរ** តាមការដែលដឹងគ្រប់ៗគ្នាមកហើយថា អប្បមញ្ញា មាន ៤ ប្រការគឺ មេត្តា ករុណា មុទិតា ឧបេក្ខា

ក្នុងចេតសិកបរិច្ឆេទ ហេតុដូចម្តេចបានជាលោកសំដែង អប្បមញ្ញាតែ ពីរយ៉ាងប៉ុណ្ណោះ ?

**ឆ្លើយ** អប្បមញ្ញា ឬ ព្រហ្មវិហារធម៌មាន ៤ ប្រការជានិច្ច តែ ចេតសិកបរិច្ឆេទនោះ លោកសំដែងត្រឹមតែ ២ដួង ព្រោះ មេត្តាបានដល់អទោសចេតសិក ដែលបានសំដែង មកហើយដូចគ្នា ។ ព្រោះហេតុដូច្នោះ ទើបសំដែងក្នុង ទីនេះ ត្រឹមតែ២យ៉ាងប៉ុណ្ណោះ ក៏ប្រហែលនឹងសំដែងទាំង ៤ ប្រការដោយបរិបូណ៌ហើយដូចគ្នា ។

សួរ ពាក្យថា បញ្ញិន្ទ្រិយ បានដល់បញ្ញាជាឥន្ទ្រីយ៍នោះ បានដល់បញ្ញាអ្វី ?

**ឆ្លើយ** ពាក្យថាបញ្ញាក្នុងទីនេះ បានដល់បញ្ញាដែលប្រកប ជាមួយចិត្ត ៤៧ដួង គឺចិត្តជាញាណសម្បយុត្ត ១២ដួង រូបាវចរ ១៥ ដួង អរូបាវចរ ១២ដួង លោកុត្តរ ៨ដួង ។

រួមលោកិយ និង លោកុត្តរ = ៤៧ដួង បញ្ញានេះ ហៅថា សម្មាទិដ្ឋិ ( ក្នុងមគ្គទាំង ៨បាន )

## គាថាសង្គហៈ

តេសំ ចិត្តា វិប្បយុត្តានំ យថា យោគមិតោ

បរំ ចិត្តុប្បាទេសុ បច្ចេកំ សម្បយោគោ បវុច្ចតិ

ប្រែ តាំងពីនេះតទៅ និង សំដែងសម្បយោគន័យ របស់ចេតសិក ៥២ដួងគឺ : ចេតសិកដែលប្រកបចូលជាមួយចិត្តម្តងមួយដួងៗ ប៉ុណ្ណោះ ។

## គាថាសង្គហ

សត្តសព្វត្ថយុជ្ជតិ យថា យោគំ បកិណ្ណកា

ចុទ្ទសាកុសលេស្វេវ សោភណេស្វេវសោភ-

ណា

ប្រែ សព្វចិត្តសាធារណចេតសិក ៧ដួង ប្រកបដោយចិត្តទាំងអស់ ៨៩ដួង ឬ ១២១ដួង ។

- បកិណ្ណកចេតសិក ៦ដួង នោះប្រកបដោយចិត្តខ្លះមិនប្រកបដោយចិត្តខ្លះ ។

- អកុសលចេតសិក ១៤ដួង ប្រកបនិង ( ដោយ ) ចិត្តជាអកុសល ១២ដួង ( អកុសលចិត្ត ១២ដួង )

- សោភណចេតសិក ២៥ដួងនោះ ប្រកបជាមួយនិងចិត្តជាសោភណ ( សោភណចិត្ត ) ៥៩ដួង ឬ ៩១ដួង ។

កថំ ពាក្យដែលថាចេតសិក ដែលប្រកប និង ចិត្តនេះប្រកបយ៉ាងណាខ្លះ ?

**សព្វចិត្តសាធារណា តាវ សត្តមេ ចេតសិកា សព្វេសុបិ ឯកូននវុតិ ចិត្តុប្បាទេសុ លព្ភន្តិ**

ប្រែ ជាដំបូង ចេតសិកជា សព្វចិត្តសាធារណ ៧ ដួង ប្រកបចូល និងចិត្ត ៩១ដួង ។

**បកិណ្ណកេសុ បន វិតក្កោ តាវ ទ្វិបញ្ច-វិញ្ញាណវជ្ជិតកាមាវចរចិត្តេសុ ចេវ ឯកាទសសុ បឋមជ្ឈានចិត្តេសុ ចេតិ បញ្ចបញ្ញាស ចិត្តេសុ ឧប្បជ្ជតិ ។**

ប្រែ ចំណោកបកិណ្ណកចេតសិក ៦ ដួង ចេតសិកដំបូងគឺ : វិតក្កចេតសិកប្រកបចូល និង ចិត្ត ៥៥ដួង គឺ ក្នុងចិត្ត កាមាវចរចិត្ត ៤៤ដួង ( វៀរលែងទ្វិបញ្ចវិញ្ញាណ ១០ដួង ) + បឋមជ្ឈានចិត្ត ១១ ដួង រួម ៥៥ដួង ( ៤៤ + ១១ = ៥៥ដួង ) ។

**វិចារោ បន តេសុ ចេវ ឯកាទសសុ ទុតិយជ្ឈានចិត្តេសុ ចាតិ ឆសដ្ឋី ចិត្តេសុ ឧប្បជ្ជតិ**

ប្រែ វិចារចេតសិកនោះ ប្រកបចូលជាមួយចិត្ត ៦៦ដួង គឺចំនួនចិត្ត ដែលវិតក្ក ប្រកបនោះបូកជាមួយចិត្តជាទុតិយ-ជ្ឈាន ១១ ដួង ត្រូវជា ៦៦ ដួង ( ៥៥ ១១ + ៦៦=ដួង )

**អធិមោក្ខោ ទ្វិបញ្ចវិញ្ញាណវិចិកិច្ឆា សហគតវជ្ជិតចិត្តេសុ ឌ**

ប្រែ អធិមោក្ខចេតសិក ប្រកបចូលនិង ចិត្ត ៧៨ដួង ( គឺ ៨៩នោះ វៀរលែង ទ្វិបញ្ចវិញ្ញាណ ១០ដួង និង វិចិកិ-

ប្លា ១ដួង នៅសល់ចិត្ត ៧៨ដួង ) ។

**វីរិយំ បន បញ្ចទ្វារាវជ្ជន-ទ្វិបញ្ចវិញ្ញាណសម្បដិច្ឆនសន្តីរណាវជ្ជិត ចិត្តេសុ**

ប្រែ វិរិយ ចេតសិកប្រកបចូលជាមួយ ចិត្ត ៧៣ដួង (គឺចិត្ត ៨៩នោះ វៀរលែង បញ្ចទ្វារាវជ្ជន ១ ទ្វិបញ្ចវិញ្ញាណ ១០ ដួង សម្បដិច្ឆន្នៈ ២ ដួង សន្តីរណ ៣ ដួង នៅសល់ ៧៣ដួង ) ។

**បីតិ ទោមនស្សុបេក្ខាសហគត-កាយវិញ្ញាណចតុត្ថជ្ឈានវជ្ជិតចិត្តេសុ**

ប្រែ បីតិ ចេតសិក (វៀរលែងចិត្ត ៧០ដួង )គឺ = ទោសមូល ២ដួង ចិត្តដែលកើតព្រម និង ឧបេក្ខា វេទនា ៥៥ និង ចិត្តជាកាយវិញ្ញាណ ២ ចិត្តជាចតុត្ថជ្ឈាន ១១ សល់ ៥១ ដួង ។ (ចិត្តទាំង១២១ ដួង - ៧០ ដួង = ៥១ ដួង )

**ឆន្ទោ អហេតុក មោហមូលវជ្ជិតចិត្តេសុ**

៧ែប្រ. ឆន្ទ ចេតសិកប្រកបជាមួយចិត្ត ៦៩ ដួង គឺក្នុងចិត្ត ៨៩ ( វៀរលែង អហេតុក ១៨ និងមោហមូល ២ សល់ ៦៩ ដួង) ។

# ពាក្យអធិប្បាយសម្បយោគន័យ

## អញ្ញសមានាចេតសិក

ក្នុងអញ្ញសមានាចេតសិក ១៣ ដួងនោះ សម្បយោគបាន ៧ ន័យគឺ :

១-សព្វចិត្តសាធារណចេតសិក ៧ ន័យ ប្រកបគ្រប់ចិត្តទាំងអស់

២-វិតក្កចេតសិក ប្រកបនឹងចិត្ត ៥៥ ដួង

៣-វិចារចេតសិក ប្រកបនឹងចិត្ត ៦៦ ដួង

៤-អធិមោក្ខចេតសិក ប្រកបនឹងចិត្ត ៧៨ ដួង

៥-វិរិយចេតសិក ប្រកបនឹងចិត្ត ៧៣ ដួង

៦-បីតិចេតសិក ប្រកបនឹងចិត្ត ៥១ ដួង

៧-ឆន្ទចេតសិក ប្រកបនឹងចិត្ត ៦៩ ដួង

សម្បយោគន័យរបស់អញ្ញសមានាចេតសិក ១៣ ដួងនោះ បាន ៧ ន័យ ដូចដែលបរិយាយមកហើយ ។

**គាថាសង្គហ**

**តេ បន ចិត្តុប្បាទា យថាក្កមំ ឆសដ្ឋី បញ្ចបញ្ញាស ឯកាទសចសោឡស សត្តតិ វីសតិ ចេវ បកិណ្ណកវិវជ្ជិតា បញ្ចបញ្ញាស ឆសដ្ឋី អដ្ឋសត្តតីតិ សត្តតិ ឯកបញ្ញាសចេក្ខនសត្តតិ សប្បកិណ្ណកា**

**ប្រែ** - ចិត្តដែលរមែងប្រកបចូលជាមួយចេតសិក ទាំ៦ អម្បាលនេះគឺ ចំណែកវៀរលែងជាចំនួនដោយលំដាប់ :

≠ ៥៥ ≠ ១១ ≠ ១៦ ≠ ៧០ ≠ ២០ (១)

ភាគលំដាប់ទទួល ឬ ប្រកប

≠ ៦៦ ≠ ៧៨ ≠ ៧៣ ≠ ៥១ ≠ ៦៩ (២)

ដោយលំដាប់

បរិច្ឆេទទី ២

# ចប់សម្បយោគន័យរបស់អញ្ញសមានា ចេតសិក ១៣ ដួង

(១) និង (២) ក្នុងអភិធម្មត្ថសង្គហ រៀបរៀងដោយ ឧត្តមមុនី អ៊ុម ស៊ូរ អាចារ្យព្រះរាជបណ្ឌិតយកម្ពុជា ទំព័រ ៤៣ បន្ទាត់ទី ៦ អធិប្បាយថា :

វិតក្កចេតសិកវៀរចាកចិត្ត ៦៦ កើតក្នុងចិត្ត ៥៥

វិចារចេតសិកវៀរចាកចិត្ត ៥៥ កើតក្នុងចិត្ត ៦៦

អធិមោក្ខចេតសិកវៀរចាកចិត្ត ១១ កើតក្នុងចិត្ត ៧៨

វិរិយចេតសិក វៀរចាកចិត្ត ១៦ កើតក្នុងចិត្ត ៧៣

បីតិចេតសិកវៀរចាកចិត្ត ៧០ កើតក្នុងចិត្ត ៥១

# សំដែងសម្បយោគន័យរបស់អកុសល ចេតសិក១៤ដួង

## តាមបាលី

អកុសលេសុ បន មោហោ អហិរិកំ អនោត្តប្បំ ឧទ្ធច្ចញ្ចាតិ ចត្តារោមេ ចេតសិកា សព្វាកុសលសាធារណា នាម សព្វេសុបិ ទ្វាទសាកុសលេសុ លព្ភន្តិ

ប្រែ ក្នុងអកុសលចេតសិកនោះ មោហ អហិរិក អនោត្តប្ប ឧទ្ធច្ច រួមចេតសិកទាំង ៤ ដួងនេះ ហៅថា សព្វាកុសលសាធារណ ( មោចតុក) ។

មានន័យថា សាធារណបានដល់ចិត្តជាអកុសល ១២ដួង ។

លោភោ អដ្ឋសុ លោភសហគតចិត្តេស្វេវ លព្ភតិ ៗ

ទិដ្ឋិ ចតូសុ ទិដ្ឋិគតសម្បយុត្តេសុ ៗ

មានោ ចតូសុ ទិដ្ឋិគតវិប្បយុត្តេសុ ៗ

ប្រែ លោភចេតសិក ប្រកបចូលជាមួយចិត្ត ជាលោភ-មូលទាំង ៨ដួង ។

ទិដ្ឋិចេតសិក ប្រកបចូលជាមួយចិត្តជាទិដ្ឋិគតសម្បយុត្ត ៤ដួង ក្នុងលោភមូល ៨ដួង ។

មានះចេតសិក ប្រកបចូលទិដ្ឋិគតវិប្បយុត្ត ៤ ដួង

(ទោស ឥស្សា ទិដ្ឋិ មច្ឆរិយ កុក្កុច្ចញ្ចាតិ ទ្វីសុ បដិឃសម្បយុត្ត ចិត្តេសុ ថីនំ មិទ្ធិ បញ្ចសុ សសង្ខារិកចិត្តេសុ វិចិកិច្ឆា វិចិកិច្ឆាសហគតចិត្តេ យេវ លព្ភតីតិ) ៤ដួងប្រកបចូលនឹងចិត្ត ជាទោសមូល ២ដួង ។

ថីនំ និង មិទ្ធំ ២ដួងនេះ ប្រកបចូលនិងចិត្ត ជាសសង្ខារិក ៥ដួង វិចិកិច្ឆាចេតសិក ប្រកបចូលក្នុងចិត្តជាវិចិកិច្ឆា ១ដួង ។

## ពាក្យអធិប្បាយសម្បយោគន័យរបស់ អកុសលចេតសិក ១៤ដួង

ក្នុងអកុសលចេតសិក ១៤ដួង មានសម្បយោគន័យ ៥ន័យ គឺ :

១- **មោហ អហិរិក អនោត្តប្ប ឧទ្ធច្ច** (មោហចតុក) ៤ដួងប្រកបចូលជាមួយចិត្ត ជាអកុសលចិត្ត ១២ដួង ។

២- **លោភ ទិដ្ឋិ** មាន៣ដួងនេះប្រកបចូលជាមួយចិត្តជាលោភមូល ៨ដួង គឺ លោភប្រកបចូលជាមួយចិត្ត និង លោភមូល ៨ដួងទិដ្ឋិក្របជាមួយទិដ្ឋិគតសម្បយុត្ត ៤ដួង ។

មានៈប្រកបនឹង ទិដ្ឋិគតវិប្បយុត្ត ៤ ដួង ។

៣- **ទោស ឥស្សា មច្ឆរិយ កុក្កុច្ច** (ទោចតុកៈ) ប្រកបចូលជាមួយនឹង ទោសមូល ២ដួង ។

៤- **ថីនំ និង មិទ្ធំ** ប្រកបចូលនឹងចិត្តជាសសង្ខារិក ៥ដួងគឺ ក្នុងចិត្តជាលោភមូល ៤ដួង និង ក្នុងទោសមូល ១ដួងរួម ៥ដួង ។

៥- **វិចិកិច្ឆាចេតសិក** ប្រកបចូលក្នុងចិត្តជាវិចិកិច្ឆា ១ដួងប៉ុណ្ណោះ រួមសម្បយោគន័យរបស់ចេតសិកជា

អកុសល ៥ន័យ ។

# គាថាសង្គហ

សព្វ បុញ្ញេសុ ចត្តារោ លោភមូលេ តយោ គតា ទោសមូលេសុ ចត្តារោ សសង្ខារេ ទ្វយំ តថា ៕

វិចិកិច្ឆា វិចិកិច្ឆា ចិត្តេចាតិ ចតុទ្ទសា ទ្វាទសា កុសលេ ស្វេវ សប្បយុជ្ជនតិ បញ្ចធា ៕

ចេតសិក ៤ដួងនេះរមែង កើតក្នុងចិត្តជាអកុសល ១២ ដួង ។ ចេតសិក ៣ដួងនេះរមែងកើតក្នុងចិត្តជាលោភមូល ៨ដួង ។ចេតសិក ៤ដួងទៀត រមែងកើតក្នុងចិត្តជាទោសមូល ២ដួង ។ ចេតសិក ២ដួងទៀតក៏រមែងកើត

សសង្ខារិកទាំង ៥ ។ វិចិកិច្ឆា ចេតសិក រមែងកើតក្នុងចិត្ត ជា វិចិកិច្ឆា ១ ដួង ដូចនេះឯង អកុសលចេតសិក ១៤ដួង រមែងកើតក្នុងអកុសលចិត្ត ១២ដួង ដោយ ៥ ន័យ ។

**ចប់សម្បយោគន័យរបស់អកុសលចេតសិក ១៤ ដួង**

បរិច្ឆេទទី ២

# សំដែងសម្បយោគន័យរបស់សោភណ
# ចេតសិក ២៥ដួង

## តាមបាលី

សោភណេសុ បន សោភណសាធារណា តាវ ឯកូនវីសតិមេ ចេតសិកា សព្វេសុបិ ឯកូនសដ្ឋី សោភណចិត្តេសុ សំវិជ្ជន្តិ ៗ

ប្រែ សោភណសាធារណចេតសិក ១៩ដួង នេះរមែងប្រកបចូលជាមួយចិត្ត ជាសោភណ ៥៩ ដួង បានទាំងអស់

វិរតិយោ បន តិស្សោបិ អដ្ឋសុ លោកុត្តរ-ចិត្តេសុ សព្វថាបិ និយតា ឯកតោវលព្ភន្តិ ។

លោកិយេសុ បន កាមាវចរកុសលេ-ស្វេវ កទាចិ សន្ទិស្សន្តិ វិសុំ វិសុំ ៗ

ប្រែ  វិរតិចេតសិក ៣ដួងនេះរមែង ប្រកបជាមួយចិត្តជាលោកុត្តរ ៨ ដួងដោយព្រមៗគ្នា ក្នុងលោកិយចិត្ត នោះរមែងកើតបានក្នុង កាមាវចរកុសលចិត្ត ៨ដួង បានដោយគ្រាខ្លះ ហើយម្តងមួយដួងៗ ។

**អប្បមញ្ញា យោ បន ទ្វាទសសុ បញ្ចមជ្ឈានវជ្ជិតមហគ្គតចិត្តេសុ ចេវ កាមាវចរកុសលេសុ ច សហេតុកកាមាវចរ-កិរិយាចិត្តេសុ ចាតិ អដ្ឋវីសតិ ចិត្តេស្វេវ កទាចិ នានាហុត្វា ជាយន្តិ ។**

**ឧបេក្ខាសហគតេសុ បនេត្ថ ករុណា មុទិតា នសន្តីតិ កេចិ វទន្តិ ។**

ប្រែ  អប្បមញ្ញាចេតសិក ទាំង២ដួង ប្រកបចូលជាមួយចិត្ត ២៨ដួង គឺ រូបាវចរចិត្ត ១២ដួង ( វៀរលែងបញ្ចម-ជ្ឈាន ) និង កាមាវចរកុសលចិត្ត ៨ដួង កាមាវចរកិរិយាចិត្ត ៨ដួង រួម ២៨ដួង ម្តងមួយគ្រាៗ និងម្តងទៀត ។

តែអាចារ្យពួកខ្លះពោលថា : អប្បមញ្ញាចេតសិកទាំងពីរនេះ រមែងមិនកើតក្នុងចិត្ត ដែលប្រកបចូលជាមួយនឹង ឧបេក្ខាវេទនាឡើយ ។

**បញ្ញា បន ទ្វាទសសុ ញាណសម្បយុត្ត-កាមាវចរចិត្តេសុ ចេវ សព្វេសុបិ បញ្ចវីស មហគ្គតលោកុត្តរចិត្តេសុ ចាតិ សត្តចត្តាឡីស ចិត្តេសុ សម្បយោគំ គច្ឆតីតិ ។**

ប្រែ បញ្ញាចេតសិកនោះ ប្រកបចូលជាមួយចិត្ត ៤៧ដួង ពី - កាមាវចរចិត្ត ញាណសម្បយុត្ត ១២ដួង ។

- មហគ្គតលោកុត្តរចិត្តទាំង ៣៥ដួង រួម ៤៧ដួង

( មហគ្គតចិត្ត ២៧ + លោកុត្តរចិត្ត ៨ = ៣៥ដួង )

# គាថាសង្គហ

**ឯកូនវីសតិ ធម្មា ជាយន្តេកូនសដ្ឋិសុ តយោ សោឡស ចិត្តេសុ អដ្ឋវីសតិយំ ទ្វយំ ។**

បញ្ញាបកាសិតា សត្តចត្តាឡីស ធម្មា ចិត្តុប្បាទេសុ ចតុវីស រាសី សោភណសេដ្ឋ (?)

**បញ្ញាបការសិតា សត្តចត្តាឡីស វិធេសុបិ សម្បយុត្តា ចតុវីសំ សោភណសេវ សោភណា ។**

ប្រែ សភាពធម៌ ១៩ដួងនេះ រមែងកើតក្នុងចិត្តជាសោភណ ៥៩ដួង ។ ចេតសិក ៣ដួង រមែងកើតក្នុងចិត្ត ១៦ដួង ។ ចេតសិក ២ដួង រមែងកើតក្នុងចិត្ត ២៨ដួង និងបញ្ញាចេតសិក រមែងកើតក្នុងចិត្ត ៤៧ដួង ដូចនេះឯង ។

សោភណចេតសិក រមែងកើតក្នុងចិត្តជាសោភណ (ឬសោភណចិត្ត) បានដោយសម្បយោគ ៤ន័យ ។

# ពាក្យអធិប្បាយសម្បយោគន័យរបស់សោភណចេតសិក ២៥ដួង

ក្នុងសោភណចេតសិក ២៥ដួង សម្បយោគន័យបាន ៤ន័យគឺ :

១- សោភណសាធារណចេតសិក១៩ដួង ប្រកប

ចូលជាមួយចិត្តជាសោភណា ៥៩ដួង ឬ ៩១ដួង ។

២- វិរតិចេតសិក ៣ដួង ប្រកបចូលជាមួយលោកុត្តរចិត្ត ៨ដួងជានិច្ច ។ ចំណែកក្នុងកាមាវចរកុសល-ចិត្ត ៨ដួងនោះ រមែងកើតម្តង១ ហើយម្តង១ដួង១ មានន័យថា មិនបានកើតព្រម១គ្នាទេ ។

៣- អប្បមញ្ញាចេតសិកទាំងពីរដួងនោះ ប្រកបចូលជាមួយចិត្ត ២ ដួង គឺ រូបាវចរចិត្ត ១២ដួង ( វៀរលែងបញ្ចមជ្ឈាន ) និងកាមាវចរកុសលចិត្ត ៨ដួង កិរិយាចិត្ត ៨ដួង រួមទាំងអស់ ២៨ដួង មួយគ្រាមួយដង និងម្តងមួយដួង១តែអាចារ្យពួកខ្លះថា : ករុណា មុទិតា ទាំងពីរនេះកើតក្នុងចិត្ត ដែលប្រកបនឹងឧបេក្ខាមិនបាន ។

៤- បញ្ញាចេតសិក ប្រកបចូលជាមួយចិត្ត ៤៧ ដួងគឺ កាមាវចរចិត្ត ញាណសម្បយុត្ត ១២ដួង រូបាវចរចិត្ត ១៥ដួង អរូបាវចរចិត្ត ១២ដួង និង លោកុត្តរចិត្ត ៨ដួង រួម ៤៧ដួង

រូបសម្បយោគន័យរបស់សោភណចេតសិក ៥ដួង នេះបាន ៧ + ៥ + ៤ = ១៦ន័យ ដូចដែលបរិយាយមកហើយ ។

## ពាក្យសួរឆ្លើយ សម្បយោគន័យ ១៦ ន័យ

សួរ ពាក្យថាសម្បយោគន័យ មានន័យយ៉ាងណា ?

ឆ្លើយ ពាក្យថាសម្បយោគន័យ ប្រែថា ប្រកបចូលគ្នា គឺ ចេតសិកមួយដួង ៗ ប្រកបចូលជាមួយនឹងចំនួនចិត្តប៉ុន្មាន ដូចជា វិតក្ក ចេតសិក ១ដួង ប្រកបចូលជាមួយចិត្ត ចំនួន ៥៥ដួង ។

ដូចនេះហៅថា សម្បយោគន័យ ។

សួរ ពាក្យថាប្រកបចិត្ត និង ចេតសិកផ្សេងៗ ដូចជាវិតក្ក វិចារនោះ ប្រកបគ្នាយ៉ាងណា ហើយមានន័យយ៉ាងណា ?

ឆ្លើយ ពាក្យថាចេតសិកប្រកប និង ចិត្តនោះ គឺ ចេតសិក

រមែងកើតព្រោះចិត្ត ឬ ចេតសិកដួងណាមួយ រមែងកើតក្នុងចិត្តចំនួន ប៉ុណ្ណេះ ប៉ុណ្ណោះ ឧទាហរណ៍ ដូចជា វិតក្កប្រែថាគិត និង គិតអ្វីក៏ដោយ គិតបានក្នុងចំនួនចិត្ត ៥៥ ដួងដែលពោលមកហើយ ក្រៅអំពី ៥៥ដួងនេះ មិនមានវិតក្ក ឬ ប្រើវិតក្កមិនបាន ដូចជាក្នុងទ្វិបញ្ចវិញ្ញាណ ១០ដួងជាដើម ចិត្តទាំងនេះគិតមិនបាន ឬ មិនមានសេចក្តីពិតតែម្តង ព្រោះហេតុដូច្នោះ ចិត្តដែលវិតក្កគិតបាន មានចំនួន ៥៥ដួង ដូចនេះហៅថា សម្បយោគន័យវិតក្កចេតសិក ។

**ស្នូរ** ក្នុងបកិណ្ណកចេតសិក ៦ន័យ នៃសម្បយោគន័យនោះ គឺ : វិរិយចេតសិកប្រកបជាមួយ និងចិត្ត ៧៣ដួង វៀរលែងទ្វិបញ្ចវិញ្ញាណ ១០ សម្បដិច្ឆន្ន ២ សន្តីរណ ៣ បញ្ចទ្វារាវជ្ជន ១ ។

វិរិយមាន ២យ៉ាងគឺ :

១- កាយិកវិរិយ

២-វិរិយចេតសិក

កាលវិរិយចេតសិក វៀរលែងកាយវិញ្ញាណចេញហើយ ពាក្យថា កាយិកវិរិយ រាប់ចូលក្នុងវិរិយណា ?

**ឆ្លើយ** ពាក្យថា កាយវិញ្ញាណ និង កាយវិរិយ ផ្សេងគ្នាច្រើនព្រោះកាយវិញ្ញាណ គឺ សេចក្តីដឹងដែលកើតមួយរំពេចដែលផោដ្ឋព្វារម្មណ៍ ប៉ះទង្គិចនិងកាយ មិនមានធុរៈដទៃលាយឡំ ក្រៅអំពីសេចក្តី ដឹង ចំណែកកាយិកវិរិយនោះ កាលចិត្តមានសេចក្តីព្យាយាមចំពោះ អារម្មណ៍ណាមួយហើយ ទើបកើតជាកាយិកវិរិយឡើង ប្រាកដជាកាយវិញ្ញត្តិតទៅ ដូច្នេះវិរិយទើបមិនមានឱកាសកើតក្នុងកាយវិញ្ញាណធាតុពិតប្រាកដ ។

**សួរ** បីតិចេតសិកប្រកបចូលនិង សោមនស្សចិត្ត ចំណែកខ្លះនោះ បីតិ និង សោមនស្សនៅជាមួយគ្នាឬ ?

**ឆ្លើយ** បីតិ និង សោមនស្សគ្មាននៅជាមួយគ្នាទេ ព្រោះបីតិប្រែថា ចូលចិត្ត សោមនស្សប្រែថា ត្រេកអរ

មានន័យថា សោមនស្សមានការសោយអារម្មណ៍ ។ បីតិនោះជាសេចក្ដីចូលចិត្តមុន ដែលសោមនស្សសោយអារម្មណ៍ ព្រោះហេតុដូច្នោះ បីតិគ្មានសោមនស្សទេ តែចិត្តដែលសោមនស្សទើបកើតបីតិបាន ឯកាយវិញ្ញាណ និងចតុត្ថជ្ឈាននោះមិនមានបីតិ ព្រោះកាយវិញ្ញាណជាកាយិក-សុខវេទនា និង ហេតុដែលវៀរលែង ចតុត្ថជ្ឈាននេះព្រោះបីតិរមែងសម្លាប់ដោយភាវនា ទៅហើយ ព្រោះហេតុនេះបីតិទើបមិនបានប្រកបជាមួយចិត្តជាចតុត្ថជ្ឈាន ។

**សួរ** បីតិចេតសិក បានដល់បីតិ ៥យ៉ាងនេះ សុំឱ្យអធិប្បាយ ?

**ឆ្លើយ** បីតិមាន ៥យ៉ាង គឺ :

១- ខុទ្ទកាបីតិ សេចក្ដីចូលចិត្តល្មមសមគួរ តែធ្វើឱ្យព្រឺរោម ព្រឺស្បែកបាន ។

២- ខណិកាបីតិ សេចក្ដីចូលចិត្តច្រើនដងៗ ដូចផ្លេកបន្ទោរ

៣- ឧក្កន្តិកាបីតិ សេចក្តីចូលចិត្តដែលធ្វើឱ្យដឹងខ្លួន ព្រឺរោម ព្រឺស្បែក ពេញទាំងកាយ ដូចជារលកទឹក ក្នុងមហាសមុទ្ទ

៤- ឱពេង្គាបីតិ សេចក្តីចូលចិត្តច្រើន អ្នកមានបីតិ ឱ្យអណ្តែតខ្លួនទៅបាន ។

៥- ផរណាបីតិ សេចក្តីចូលចិត្តដែលធ្វើឱ្យត្រជាក់ជ្រួតជ្រាបសព្វរាងកាយ ដូចប្រេងក្នុងគ្រាប់ល្ង ។

រួម ៥ប្រការនេះ ហៅថា បីតិចេតសិកទាំងអស់ ។

**សួរ** ក្នុងអកុសលចេតសិក ១៤ដួងនោះសុំឱ្យញែកចេញជាចេតសិក ដែលប្រកបក្នុងលោភប៉ុន្មាន ទោសៈ មោហៈប៉ុន្មាន ?

**ឆ្លើយ** ចេតសិកដែលកើតជាមួយលោភមាន ៩ ដួងគឺ :

**មោហ អហិរិក អនោត្តប្ប ឧទ្ធច្ច លោភ ទិដ្ឋិ មាន ថីន មិទ្ធ** រួម ៩ ដួង ។

ចេតសិកដែលកើតក្នុង ទោស មាន ៦ដួង គឺ :

**ទោស ឥស្សា មច្ឆរិយ កុក្កុច្ច ថីន មិទ្ធ** រួម៦ដួង ។

ចេតសិកដែលកើតក្នុងមោហ មាន ៥ដួង គឺ :

**មោហ អហិរិក អនោត្តប្ប ឧទ្ធច្ច វិចិកិច្ឆា** រួម ៥ដួង ។

**សួរ** ក្នុងសម្បយោគន័យរបស់ អកុសលចេតសិកនេះ មច្ឆរិយ ប្រែថា មានចិត្តកំណាញ់ ក្នុងទ្រព្យសម្បត្តិរបស់ខ្លួនប្រកប និង ទោសៈបានយ៉ាងណា ? មច្ឆរិយ និង ទោសៈជាមួយគ្នាឬ ?

**ឆ្លើយ** មច្ឆរិយ មានចិត្តកំណាញ់ស្វិត ក្នុងសម្បត្តិរបស់ខ្លួន គឺ មិនចង់ឱ្យអ្នកដទៃមកទាក់ទងក្នុងសម្បត្តិរបស់ខ្លួន បើមានអ្នកណានិមួយចូលមកទាក់ទង ទោមនស្ស សេចក្តីខូចចិត្តកកើតឡើងមួយរំពេច ។ កាលដែលទោមនស្សកើតឡើងដូច្នេះនេះ ជាទោសៈដោយត្រង់ ព្រោះហេតុដូច្នេះ

ទើបលោកយកមច្ឆរិយរាប់ចូលក្នុងចិត្តជាទោសមូល ២ដួង ដូចដែលពោលមកហើយ ក្នុងអកុសលចេតសិក ១៤ដួង ។

**សួរ** ពាក្យថា ថីន មិទ្ធ ប្លែកគ្នាថាជាធម្មជាតិដែលធ្វើឱ្យចិត្ត ចេតសិកញ៉ូររន្ធត់ ញាប់ញ៉ូរ ងោកងុយ ប្រកបចូលនិងសសង្ខារិក ទាំង ៥ គឺ លោភៈ៤ និង ទោស ១ រួមចិត្ត៥ដួង សូមជ្រាបថា ថីន និង មិទ្ធ ជាលោភ ជាទោសបានយ៉ាងណាខ្លះ ?

**ឆ្លើយ** ថីនំ និង មិទ្ធំ ជាធម្មជាតិដែលត្រូវការឈប់សំរាកពីអារម្មណ៍ឈប់សំរាក គឺ អំពីវិរិយរបស់ចិត្ត និង ចេតសិកទាំងពីរ ដូច្នេះជាចេតសិកដែលផ្ទុយគ្នា និង វិរិយចេតសិក កាលដែលឈប់សំរាក ពីអារម្មណ៍ ក៏មានពីរយ៉ាង : លោភៈ និង ទោមនស្ស ឬ ក្នុងលោភៈ និង ទោមនស្ស យ៉ាងណាមួយក៏បាន ។ ក្នុងបាតិយអត្ថកថា និង (សង្គីតំអត្ថកថាបាតេយ្យ) នេះថា :

**ឯត្ថ ច ចិត្តគេលញ្ញំ ចិត្តស្សេវ អកល្យតា ខន្ធត្តយគេលញ្ញំ បន រូបកាយស្សបិ ថីន មិទ្ធស្ស និទ្ធា ហេតុត្តា**

**ប្រែ** ក្នុងទីនេះ សេចក្តីមិនស្ទូវសប្បាយចិត្ត ហៅថា : **ចិត្តកម្មញ្ញតា អកម្មញ្ញតា** គឺ មិនគួរដល់ចិត្ត ព្រោះជាហេតុរបស់ ថីនៈ ។ ថីនៈ និង មិទ្ធៈនោះ ចង់ដេក ចង់លក់ ឬ ចង់ឈប់ សម្រាកអំពីចិត្តដែលធ្វើការក្នុងអារម្មណ៍ផ្សេងៗ ។

កាលចិត្ត ចេតសិកថយពីវិរិយដូច្នេះនេះ ប្រសិនណាបើមិនមានអ្វីមកដឹកនាំ ទេក៏នៅក្នុងថីនៈ មិទ្ធៈ ជានិច្ច មិនដាច់ដដែល ។ ដូច្នេះថីនៈ មិទ្ធៈ ទាំងពីរនេះ ត្រូវអាស្រ័យការដឹកនាំ ហៅថាសសង្ខារិក ដោយហេតុដែលពោលមកហើយ ។

ព្រះអនុរុទ្ធាចារ្យ សំដែងថា ថីនៈ មិទ្ធៈ ទាំងពីរនេះប្រកបចូលជាមួយចិត្តជាសសង្ខារិក ៥ដួង ដូចនេះឯង ។

**សួរ** អប្បមញ្ញាទាំងពីរ ប្រកបចូលនិង ចិត្ត ២៨ គឺ :

សោមនស្ស រូបាវចរកុសល ១២ ដួងកាមាវចរ កុសល ៨ដួង មហាកិរិយា ៨ដួង រួម ២៨ដួង ។

**ករុណា** ប្រែថា សេចក្តីអាណិតសត្វទាំងឡាយ ដែលកើតទុក្ខ ។

**មុទិតា** ប្រែថាសេចក្តីត្រេកអរ ចំពោះសត្វទាំងឡាយដែលជាសុខ ក្នុងទីនេះចិត្តត្រូវប្រកបក្នុងកុសល និង កិរិយារបស់កាមាវចរនោះ ឧបេក្ខាប្រែថា ព្រងើយ១ កាល បើដូច្នេះ **ករុណា មុទិតា**ប្រកបនិងឧបេក្ខាបានយ៉ាងណា ទៀត ?

**ឆ្លើយ** ពាក្យថាឧបេក្ខា តាមធម្មតាប្រែថា: សេចក្តីព្រ-ងើយ១ នេះបានដល់ ( វេទនូបេក្ខា) មានសេចក្តីថា សេចក្តីព្រងើយនៃការសោយអារម្មណ៍ គឺ មិនទៅផ្លូវផ្អែក សេចក្តីសុខ និង ទុក្ខ ឬ នៅក្នុងលំដាប់កណ្តាលនោះឯង ។ តែថា ឧបេក្ខាមាន ១០ប្រការ គឺ :

១- ឆឡង្គុបេក្ខា

២- ព្រហ្មវិហារុបេក្ខា

៣- ពោជ្ឈង្គុបេក្ខា

៤- វីរិយុបេក្ខា

៥- សង្ខារុបេក្ខា

៦- វេទនូបេក្ខា

៧- វិបស្សនូបេក្ខា

៨- តត្រមជ្ឈត្តុបេក្ខា

៩- ឈានុបេក្ខា

១០- បារិសុទ្ធុបេក្ខា រួម១០ប្រការដូច្នេះឯង ។

១- ពាក្យថាឆឡង្គុបេក្ខា បានដល់ឧបេក្ខារបស់ព្រះអរហន្ត ក្នុងកាលដែលប៉ះទង្គិចអារម្មណ៍ ជាឥដ្ឋារម្មណ៍ អនិដ្ឋារម្មណ៍ នោះ ធ្វើឱ្យចិត្តនៅព្រងើយៗបាន ។

២- ព្រហ្មវិហារុបេក្ខា បានដល់ឧបេក្ខាភាវនាក្នុងព្រហ្មវិហារ ៤ គឺ ការធ្វើសេចក្តីព្រងើយៗ ចំពោះសត្វ

ទាំងពួងដែលជាសុខ និង ទុក្ខ ។

៣- ពោជ្ឈង្គុបេក្ខា បានដល់ឧបេក្ខាពោជ្ឈង្គ ៧ ប្រការគឺ : ការធ្វើសេចក្តីព្រងើយ១ក្នុងធម៌ ដែលកើតព្រម១គ្នា ។

៤- វីរិយុបេក្ខា បានដល់សេចក្តីព្រងើយ១របស់វីរិយគឺ : សេចក្តីព្យាយាម ដែលល្មមសមគួរ ឬ សេចក្តីព្យាយាមយ៉ាងកណ្តាល ក្នុងការប្រតិបត្តិនេះ ហៅថា មជ្ឈិមាបដិបទាក៏បាន ។

៥- សង្ខារុបេក្ខា បានដល់ឧបេក្ខារបស់ព្រះយោ-គិបុគ្គលក្នុងការសំឡឹងពិនិត្យ វិបស្សនា ធ្វើឱ្យចិត្តព្រងើយ-១ចំពោះរូបនាមទាំងពីរ ខាងក្រោយ ដែលបានទទួល វិបស្សនាញាណ ៨ ប្រការ ។

៦- វេទនុបេក្ខា បានដល់ឧបេក្ខាវេទនា ទាំង ៣ ឬ ៥ គឺ នៅក្នុងរវាងកណ្តាល សុខ ទុក្ខ វេទនា ។

៧- វិបស្សនូបេក្ខា បានដល់ឧបេក្ខាវិបស្សនា គឺសេចក្តីព្រងើយៗ ចំពោះវិបស្សនូបកិលេស ។

៨- តត្រមជ្ឈត្តុបេក្ខា បានដល់ឧបេក្ខានៃ តត្រ-ជ្ឈត្តតាចេតសិក គឺ អនុលោមតាមសុខ ទុក្ខទាំងពីរ ។

៩- ឈានុបេក្ខា បានដល់ឧបេក្ខារបស់ព្រះយោគី ដែលបានទទួល ចតុត្ថជ្ឈាន គឺ សេចក្តីព្រងើយៗក្នុងសុខ

១០- បារិសុទ្ធុបេក្ខា បានដល់ ឧបេក្ខារបស់បញ្ចម-ជ្ឈាន លាភីបុគ្គល គឺ ធ្វើសេចក្តី ព្រងើយៗ ចំពោះសេចក្តីសុខរបស់ឈាន ។

ក្នុងឧបេក្ខា ១០ប្រការនេះ ពាក្យថាឧបេក្ខារបស់ចិត្តជាកាមាវចរកុសល និង កិរិយានោះ ត្រង់គ្នានឹងវេទនូបេក្ខាគឺមិនមែនសុខ ទុក្ខ ឬ រវាងកណ្តាលរបស់សុខ ទុក្ខទាំងពីរ ។ ពង្រីកសេចក្តីតទៅទៀតថាអ្នកធ្វើបាបឬបុណ្យក៏ដោយ ធ្វើបានដោយឧបេក្ខាវេទនាក៏មានឧបមាយ៉ាងណាក្នុងការធ្វើករុណា មុទិតា កម្មដ្ឋានដែលនឹងដល់អប្បនា

គង់នឹងធ្វើបានដោយសោមនស្ស ឧបេក្ខា ដូច្នេះឯង ព្រោះហេតុដូច្នេះ អប្បមញ្ញាទាំងពីរ ទើបប្រកប នឹង ចិត្តជាកាមាវចរកុសល និង កិរិយាបាន ។

**សួរ** បញ្ញាដែលប្រកបជាមួយនឹងចិត្តមាន ៤៧ដួង ។

ពាក្យបញ្ញាមានន័យថាអ្វី ? ហើយលោកិយបញ្ញាផ្សេងៗក្នុងសម័យនេះ គឺ វិជ្ជាដែលធ្វើយន្តហោះ ធ្វើបរមាណូ គ្រាប់បែកជាដើមនោះ មិនមែនបញ្ញាឬ ?

**ឆ្លើយ** បញ្ញាក្នុងទីនេះ ប្រកបជាមួយនឹងចិត្តជាញាណសម្បយុត្ត និង ចិត្តជាមហគ្គត លោកុត្តរ ទាំងអស់រួម ៤៧ដួង ។

ពាក្យថាញាណនេះ មិនមែនចិត្ត សេចក្ដីពិតជាចេតសិកគឺ បញ្ញានោះឯង. បញ្ញានេះបានដល់បញ្ញាទាំង ៣ គឺ : សុតមយបញ្ញា ចិន្តាមយបញ្ញា និង ភាវនាមយបញ្ញា ។

ការធ្វើគ្រឿងយន្តហោះ គ្រាប់បែកបរមាណូ នោះមនុស្សដែលសាងជាដំបូង បានដល់ចិន្តាមយបញ្ញា មនុស្ស

ដែលបានរៀនអំពីអ្នកមានវិជ្ជាគឺ នាយជាងធ្វើកបាល់ហោះនោះបានដល់ សុតមយបញ្ញា តែមនុស្សទាំងពីរនាក់នេះប្រាសចាក ភាវនាមយបញ្ញា ។ ភាវនាមយបញ្ញានេះមានក្នុងព្រះពុទ្ធសាសនា គឺ ការធ្វើវិបស្សនា ឬ សេចក្តីចេះដឹងក្នុងខន្ធ អាយតន ធាតុជាដើម ។

បញ្ញាទាំងអម្បាលនេះ ហៅថា ភាវនាមយបញ្ញា តែយ៉ាងណាក្តី បញ្ញាមាន ២យ៉ាងទៀតគឺ : លោកិយបញ្ញា និង លោកុត្តរបញ្ញា ។

ការធ្វើយន្តហោះគ្រាប់បែកបរមាណូនោះ នៅក្នុងលក្ខខ័ណ្ឌ ចិន្តាមយ សុតមយ របស់លោកិយបញ្ញាផង ។ ចំណែកភាវនាបញ្ញានោះនៅក្នុងលក្ខខ័ណ្ឌលោកុត្តរបញ្ញា ព្រោះហេតុដូច្នេះ ពាក្យថា បញ្ញាបានដល់បញ្ញាលោកិយ និង លោកុត្តរទាំងអស់ ។ ចិត្តដែលប្រកបនោះ ៤៧ដួង ដូចដែលពោលមកហើយ ។

# គាថាសង្គហ

ឥស្សា មច្ឆេរិយ កុក្កុច្ច វិរតិ ករុណាទយោ
នានា កទាចិ មានោ ច ថីនមិទ្ធំ តថាសហ
យថា វុត្តានុសារេន សេសានិយត យោគិនោ
សង្គហញ្ច បវក្ខាមិ តេសំទានិ យថារហំ ។

ប្រែ តាមន័យផ្សេងៗ ដែលមិនបានពោលមកហើយខាងដើម ។

ឥស្សា មច្ឆរិយ កុក្កុច្ច វិរតិ ទាំង ៣ ករុណា មុទិតា មានៈ ទាំងអម្បាលនេះ ក្នុងការប្រកបជាមួយ និង ចិត្ត នោះមិនកំណត់ ។ ថីន មិទ្ធ ក៏ដូចគ្នាដែរ ចេតសិកដែលសល់ទាំងអស់ប្រកបចូលជាមួយនឹងចិត្ត ដែលកំណត់ពីនេះតទៅនឹងសំដែងសង្គហន័យតាមចំនួនចិត្តដែលបាន :

## ពាក្យអធិប្បាយគាថាសង្គហន័យ ២

## បទ

ឥស្សា មច្ឆរិយ កុក្កុច្ច វិរតិទាំង ៣ អប្បមញ្ញា២ ថីន មិទ្ធ មានៈ រួមចេតសិក ១១ដួងនេះ រមែងកើតក្នុង ចិត្តដែលប្រកប ដោយមិនកំណត់ ដូច្នេះហៅថាអនិយត យោគី មានសេចក្ដីថា ជួនកាលក៏រមែងកើត ជួនកាល ក៏មិនកើតសល់ ១១ដួង ដែលពោលមកហើយ នៅមានសល់ចេតសិក ៤១ដួង ហៅថានិយត យោគី មានសេចក្ដីថា រមែងកើតក្នុងចិត្តដែល ប្រកបជានិច្ច តាំងពីឥឡូវនេះជាដើម ទៅចប់

សំដែងសង្គហន័យ គឺ ចំនួនចិត្តនីមួយៗ មានចេតសិកប៉ុន្មានទៀត ។

## គាថាសង្គហ

ឆត្តឹសា នុត្តរេ ធម្មា បញ្ចត្តឹស មហគ្គតេ
អដ្ឋត្តឹសាបិ លព្ភន្តិ កាមាវចរសោភណេ ។
សត្តវីសតិ បុញ្ញម្ហិ ទ្វាទសា ហេតុកេតិ ច
យថា សម្ភវយោគេន បញ្ចធា តត្ថ សង្គហោ

**ប្រែសេចក្ដីថា:**

- ចិត្តជាលោកុត្តរ ៨ដួង ប្រកបជាមួយចេតសិក ៣៦ដួង

- ចិត្តជាមហគ្គត ២៧ដួង ប្រកបជាមួយចេតសិក ៣៥ដួង

- ចិត្តជាកាមាវចរ ២៤ដួង ប្រកបជាមួយចេតសិក ៣៨ដួង

- ចិត្តជាអកុសល ១២ដួង ប្រកបជាមួយចេតសិក ២៧ដួង

- ចិត្តជាអហេតុក ១៨ដួង ប្រកបជាមួយចេតសិក ១២ដួង គឺ : អញ្ញសមានា ១២ ( វៀរឆន្ទៈ )

- ចិត្ត ៨៩ដួង ឬ ១២១ដួង ប្រកបជាមួយចេតសិក ៥២ដួង

តាមន័យនៃសង្គហន័យ ៥ ន័យ

**សួរ** កលំ ក្នុងទីនេះ សង្គហ ៥ន័យ គឺយ៉ាងណាខ្លះ ?

# សំដែងសង្គហន័យរបស់ចិត្តជាលោកុត្តរ តាមបាលី

លោកុត្តរេសុ តាវ អដ្ឋសុ បឋមជ្ឈានិកចិត្តេសុ អញ្ញសមានា តេរស ចេតសិកា អប្បមញ្ញា វជ្ជិតា តេវីសតិ សោភណចេតសិកា ចេតិ ឆត្តឹស ធម្មា សង្គហំ គច្ឆន្តិ ។

តថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។

តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។

ចតុត្ថជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា ។

បញ្ចមជ្ឈាននិកចិត្តេសុបិ ឧបេក្ខាសហគតា តេ ឯវ សង្គយ្ហន្តីតិ ។

សព្វថាបិ អដ្ឋសុ លោកុត្តរចិត្តេសុ

## បញ្ចកឈានទសេន បញ្ចធាទ សង្គហោ ហោតីតិ ៥

**សេចក្ដីថា** ក្នុងលោកុត្តរចិត្តនេះ

១- បឋមជ្ឈានិកចិត្ត ៨ដួងនោះ បានដល់ចេតសិក ៣៦ដួងគឺ : អបញ្ញសមានា ១៣ដួង សោភណចេតសិក ២៣ ( វៀរលែង អប្បបញ្ញា ២ )

រួម ៣៦ដួង

២- ទុតិយជ្ឈានិកចិត្ត ៨ ដួង បានដល់ចេតសិក ៣៥ដួងគឺ : អញ្ញសមានា ១២ដួង ( វៀរលែងវិតក្ក ) សោភណចេតសិក ២៣ដួង ( វៀរលែងអប្បមញ្ញា ២ )

រួម ៣៥ដួង

៣- តតិយជ្ឈានិកចិត្ត ៨ដួង បានដល់ចេតសិក ៣៤ដួង គឺ : អញ្ញសមានា ១១ដួង ( វៀរលែង វិតក្ក វិចារ ) សោភណចេតសិក ២៣( វៀរលែងអប្បមញ្ញា ២ )

រួម ៣៤ដួង

៤- ចតុត្ថជ្ឈានិកចិត្ត ៨ ដួង បានដល់ចេតសិក ៣៣ដួង គឺ : អញ្ញសមានា ១០ ( វៀរលែងវិតក្ក វិចារ បីតិ ) សោភណចេតសិក ២៣ ( វៀរលែងអប្បមញ្ញា ២)

រួម ៣៣ដួង

៥- បញ្ចមជ្ឈានិកចិត្ត ៨ដួង បានដល់ចេតសិក ៣៣ដួងគឺ : អញ្ញសមានា ១០ ( វៀរលែងវិតក្ក វិចារ បីតិ ) សោភណចេតសិក ២៣ ( វៀរលែង អប្បមញ្ញា ២) រួម ៣៣ដួង

ដូចនេះលោកុត្តរចិត្ត ៨ ដួង ពង្រីកចេញដោយឈានទាំង ៥ ហើយមានសង្គហន័យ ៥ន័យ ដូចដែលបានពោលមកហើយ ។

# គាថាសង្គហ

ឆត្តឹស បញ្ចធា ច ចតុត្តឹឆស យថាក្កមំ

តេត្តឹស ទ្វយមិច្ចេវំ បញ្ចធា នុត្តរេ ឋិតា

ប្រែ  លោកុត្តរចិត្ត ៨ ដួងនេះ មានសង្គហន័យ គឺ :

១- ឆត្តឹស សង្គហន័យ

២- បញ្ចត្តឹស សង្គហន័យ

៣- ចតុត្តឹស សង្គហន័យ

៤- នឹង ៥ តេត្តឹស សង្គហន័យទាំងពីរ

រួម៥ន័យដូចនេះ

សំដែងសង្គហន័យរបស់ មហគ្គតចិត្ត ២៧ដួង

( ជាលោកិយ )

តាមបាលី

មហគ្គតេសុ បន តីសុ បឋមជ្ឈានិក-

ចិត្តេសុ តាវ អញ្ញសមានា តេរស ចេតសិកា

វិរត្យទិជ្ជិតា ទ្វាវិសតិ សោភណចេតសិកា ចេតិ បញ្ចត្តឹស ធម្មា សង្គហំ គច្ឆន្តិ ។

ករុណា មុទិតា បនេត្ថ បច្ចេកមេវ យោជេតព្វា ។

កថា ទុតិយជ្ឈានិកចិត្តេសុ វិតក្កវជ្ជា ។

តតិយជ្ឈានិកចិត្តេសុ វិតក្កវិចារវជ្ជា ។

ចតុត្ថជ្ឈានិកចិត្តេសុ វិតក្កវិចារបីតិវជ្ជា។

បញ្ចមជ្ឈានិកចិត្តេសុ បន បណ្ណារសសុ អប្បមញ្ញាយោ លព្ភន្តីតិ ។

សព្វថាបិ សត្តវីសតិ មហគ្គតចិត្តេសុ បញ្ចកឈានវសេន បញ្ចធាវ សង្គហោ ហោតីតិ ។

ប្រែ ក្នុងមហគ្គតចិត្ត ២៧ ដួង :

១- បឋមជ្ឈានិកចិត្ត ៣ដួង បានដល់ចេតសិក ៣៥ដួង គឺ : អញ្ញសមានាចេតសិក ១៣ដួង សោភណចេតសិក ២២ដួង ( វៀរលែងវិរតិ ៣ ) រួម ៣៥ដួង ។

២- ទុតិយជ្ឈានិកចិត្ត ៣ដួង បានដល់ចេតសិក ៣៤ដួងគឺ អញ្ញសមានាចេតសិក១២ដួង (វៀរលែង វិតក្ក ) សោភណចេតសិក ២២ ដួង ( វៀរលែង វិរតិ ៣ ) រួម ៣៤ដួង ។

៣- តតិយជ្ឈានិកចិត្ត ៣ដួង បានដល់ចេតសិក ៣៣ដួង អញ្ញសមានាចេតសិក ១១ដួង (វៀរលែង វិតក្ក វិចារ ) សោភណចេតសិក ២២ដួង ( វៀរលែង វិតរតិ ៣) រួម ៣៣ដួង ។

៤- ចតុត្ថជ្ឈានិកចិត្ត ៣ដួង បានដល់ចេតសិក ៣២ដួង អញ្ញសមានា ១០ ( វៀរលែង វិតក្ក វិចារ បីតិ ) សោភណចេតសិក ២២ ( វៀរលែង វិតក្ក ៣) រួម ៣២ដួង

៥- បញ្ចមជ្ឈានិកចិត្ត ១៥ដួង បានដល់ចេតសិក ៣០ដួង គឺ : អញ្ញសមានាចេតសិក ១០ដួង ( វៀរលែង វិតក្ក វិចារៈបីតិ ) សោភណចេតសិក ២០ដួង ( វៀរ វិរតិ ៣ + អប្បមញ្ញា ២ ) រួម ៣០ដួង ។

ដូចនេះ ចិត្តជាមហគ្គត ២៧ ដួង ថាដោយបញ្ចកន័យ មានសង្គហន័យ ៥ន័យ ។

## គាថាសង្គហ

បញ្ចត្តឹស ចតុត្តឹស តេត្តឹស ច យថាក្កមំ ពាត្តឹស ចេវ តឹសេតិ បញ្ចធាវ មហគ្គតេ ។

ប្រែ ចិត្តជាមហគ្គត ២៧ដួងនោះមានសង្គន័យ គឺ :

១- បញ្ចត្តឹស សង្គហន័យ

២- ចតុត្តឹស សង្គហន័យ

៣- តេត្តឹស សង្គហន័យ

៤- ពាត្តឹស សង្គហន័យ

៥- តឹស សង្គហន័យ

រួម ៥ ន័យដោយលំដាប់ ។

# សំដែងសង្គហន័យរបស់កាមាវចរចិត្ត ២៤ដួង

## តាមបាលី

កាមាវចរសោភណេសុ បន កុសលេសុ តាវ បឋមទ្វយេ ញាណសម្បយុត្តេ អញ្ញសមានា តេរស ចេតសិកា បញ្ចវីសតិ សោភណចេតសិកា ចេតិ អដ្ឋតឹស បញ្ចបិ បច្ចេកមេវ យោជេតព្វា ៗ

តថា ទុតិយទ្វយេ ញាណវជ្ជិតា ៗ

តតិយទ្វយេ ញាណសម្បយុត្តេ បីតិវជ្ជិតា ៗ

ចតុត្ថទ្វយេ ញាណសម្បយុត្តេ បីតិ

វចីតា ៗ

តេ ឯវ សង្គយ្ហន្តិ ៗ

ប្រែ ក្នុងកាមាវចរសោភណសាធារណចិត្ត ២៤ដួងនោះ ក្នុងចិត្តជាកុសល ៨ ដួង គូទី១ បានដល់ចេតសិក ៣៨ ដួងគឺ : អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៥ដួង រួម = ៣៨ដួង ។

គូទី ២ បានដល់ចេតសិក ៣៧ដួងគឺ :
អញ្ញសមានាចេតសិក ១៣ សោភណចេតសិក ២៤ ( វៀរបញ្ញិន្ទ្រីយ៍ ) រួម ៣៧ដួង ។

គូទី ៣ បានដល់ចេតសិក ៣៧ ដួង គឺ :

អញ្ញសមានាចេតសិក ១២ ( វៀរលែងបីតិ ) សោភណចេតសិក ២៥ដួង រួម ៣៧ដួង ។

គូទី ៤ បានដល់ចេតសិក ៣៦ដួង គឺ :

អញ្ញសមានាចេតសិក ១២ដួង ( វៀរលែង បីតិ ) សោភណចេតសិក ២៤ ( វៀរលែងបញ្ញិន្ទ្រីយ៍)

រួម=៣៦ដួង

រួមសង្គណើ ក្នុងចិត្តជាកាមាវចរកុសល ៨ដួង

# សំដែងសង្គហន័យ កិរិយាកាមាវចរ-
# ចិត្ត ៨ដួង

## តាមបាលី

កិរិយា ចិត្តេសុ បិ វិរតិ វជ្ជិតា តថេ
ចតូសុ បិ ទុកេសុ ចតុធាវ សង្គយ្ហន្តិ ៗ

ប្រែ ក្នុងកាមាវចរកិរិយាចិត្ត ៨ ដួងនោះ

គូទី ១- បានដល់ចេតសិក ៣៥ដួងគឺ :

អញ្ញសមានាចេតសិក ១៣ដួង សោភណចេតសិក ២២ដួង ( វៀរ វិរតិ ៣ ) រួម ៣៥ដួង ។

គូទី ២- បានដល់ចេតសិក ៣៤ដួង គឺ :

អញ្ញសមានាចេតសិក ១៣ដួង សោភណចេតសិក ២១ដួង ( វៀរ វិរតិ ៣ បញ្ញិន្ទ្រីយ៍ ១ ) រួម ៣៤ដួង ។

គូទី ៣- បានដល់ចេតសិក ៣៤ដួង គឺ :

អញ្ញសមានាចេតសិក ១២ ( វៀរ បីតិ ) សោភណ ចេតសិក ២២ដួង ( វៀរ វិរតិ ៣ ) រួប ៣៤ដួង ។

គូទី ៤- បានដល់ចេតសិក ៣៣ដួង គឺ :

អញ្ញសមានាចេតសិក ១២ ( វៀរ បីតិ ) សោភណចេតសិក ២១ ដួង ( វៀរ វិរតិ ៣ បញ្ញិន្ទ្រិយ៍ ១ ) រួម ៣៣ដួង ។

រួមសង្គហន័យ ក្នុងចិត្តជាកាមាវចរ ៨ដួង ចប់

## សំដែងសង្គហន័យ កាមាវចរវិបាក ៨ដួង តាមបាលី

តថា វិបាកេសុ ច អប្បមញ្ញា វិរតិ វជ្ជិតា ។ តេ ឯវ សង្គយ្ហន្តិ ។ សព្វថាបិ ។

**ចតុវីសតិ កាមាវចរសោភណចិត្តេសុ**

**ឱ្យកវសេន ទ្វានវសធា ច សង្គហោ ហោតីតិ**

**ប្រែ** ក្នុងកាមាវចរវិបាកចិត្ត ៨ដួង ក៏តាមទំនងដើម គឺ :

គូទី ១- បានដល់ចេតសិក ៣៣ដួង គឺ :

អញ្ញសមានាចេតសិក ១៣ដួង សោភណចេតសិក ២០ដួង ( វៀវ វិរតិ ៣ អប្បមញ្ញា ២ ) រួម ៣៣ ដួង ។

គូទី ២- បានដល់ចេតសិក ៣២ដួង គឺ :

អញ្ញសមានាចេតសិក ១៣ដួង សោភណចេតសិក ១៩ដួង ( វៀវ វិរតិ ៣ អប្បមញ្ញា ២ បញ្ញិន្ទ្រិយ៍ ១) រួម ៣២ដួង ។

គូទី ៣- បានដល់ចេតសិក ៣២ដួង គឺ :

អញ្ញសមានាចេតសិក ១២ ដួង (វៀវ បីតិ ) សោភណចេតសិក ២០ដួង (វៀវ វិរតិ ៣ អប្បមញ្ញា ២ ) រួម ៣២ដួង ។

គូទី ៤- បានដល់ចេតសិក ៣១ដួង គឺ :

អញ្ញសមានាចេតសិក ១២ដួង (វៀរ បីតិ ) សោភណចេតសិក ១៩ដួង ( វៀរ វិរតិ ៣ អប្បមញ្ញា២ បញ្ញិន្រ្ទីយ៍ ១ ) រួម ៣១ដួង ។

រួមសង្គហន័យក្នុង កាមាវចរវិបាកចិត្ត ៨ដួងរួមទាំងអស់ ។

សង្គហន័យក្នុង កាមាវចរចិត្ត ២៤ ដួងនោះ បាន ១២សង្គហន័យគឺ ចំណែកកុសលចិត្ត ៤ កិរិយាចិត្ត ៤ វិបាកចិត្ត ៤ ដូច្នេះនេះ ។

## គាថាសង្គហ

អដ្ឋត្តឹស សត្តតឹស ទ្វយំ ឆត្តឹសកំ សុភេ
បញ្ចត្តឹស ចតុត្តឹស ទ្វយំ តេត្តឹសកំ ក្រិយេ
តេត្តឹសសបាកេ ពាត្តឹស ទ្វយេកត្តឹសកំ ភវេ
សហេតុកាមាវចរ បុញ្ញបាកក្រិយាមនេ ។

ប្រែសេចក្តីថា

ក្នុងកាមាវចរកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ទាំង ៣នេះ ក្នុងកុសលចិត្ត ៨ ដួង បានសង្គហន័យ គឺ អដ្ឋតឹស សង្គហន័យ សត្តតឹសសង្គហន័យ ទាំងគូរ និង ឆត្តឹសសង្គហ ន័យ រួមបាន ៤ ន័យ ។

ក្នុងកាមាវចរចិត្ត កិរិយាចិត្ត ៨ ដួង មានសង្គហន័យ គឺ បញ្ចត្តឹសន័យ ចតុត្តឹសសង្គហន័យទាំងគូរ និង តេត្តឹស សង្គហន័យ រួមមានសង្គហន័យ ៤ ន័យ ។

ក្នុងកាមាវចរវិបាកចិត្ត ៨ ដួង មានសង្គហន័យ គឺ តេត្តឹសសង្គហន័យ ពាត្តឹសសង្គហន័យទាំងគូរ និង ឯកត្តឹស សង្គហន័យ រួម ៤ ន័យ ។

## គាថាសង្គហៈ

ន វិជ្ជន្តេត្ថ វិរតី កិរិយេសុ ច មហគ្គតេ
អនុត្តរេ អប្បមញ្ញា កាមបាកេ ទ្វយំ តថា ។
អនុត្តរេ ឈានធម្មា អប្បមញ្ញា ច

**មជ្ឈិមេ វិរតិ ញាណបីតិ ច បរិត្តេសុ វិសេសកា ។**

ប្រែ ក្នុងទីនេះកិរិយាចិត្ត ៨ដួង និង មហគ្គតចិត្ត ២៧ ដួង រមែងមិនមានវិរតិ ។

- ក្នុងលោកុត្តរចិត្ត រមែងមិនមាន អប្បមញ្ញា ។

- ក្នុង កាមាវចរវិបាកចិត្ត ៨ ដួង រមែងមិនមាន ទាំងពីរ គឺ វិរតិ ៣ និង អប្បមញ្ញា ២ ។

- ក្នុងលោកុត្តរចិត្ត ឈានទាំង ៥ ធ្វើឱ្យផ្សេងគ្នា អប្បមញ្ញាផ្សេងគ្នា ក្នុងមហគ្គតចិត្ត តែ

- ក្នុងកាមាវចរចិត្តនោះ បីតិ វិរតិ បញ្ញា និង បីតិ ធ្វើឱ្យផ្សេងគ្នាទៅ ឬ ធ្វើឱ្យចិត្ត ១ ដួង និង ចិត្ត ១ ដួង ទៀត ពិសេសជាងគ្នា ប៉ុណ្ណោះ ។

## សំដែងសង្គហរបស់អកុសលចិត្ត ១២ ដួង

# តាមបាលី

អកុសលេសុ បន លោភមូលេសុ តាវ បឋមេ អសង្ខារិកេ អញ្ញសមានា តេរស ចេតសិកា អកុសលសាធារណា ចត្តារោ ចាតិ សត្តរស លោភទិដ្ឋីហិ សទ្ធឹ ឯកូនវីសតិ ធម្មា សង្គហំ គច្ឆន្តិ ។

តថេវ ទុតិយេ អសង្ខារិកេ លោភមានេន សទ្ធឹ ។ តតិយេ តថេវ បីតិ វជ្ជិតា លោភទិដ្ឋីហិ សហ អដ្ឋារស ។

ចតុត្ថេ តថេវ លោភមានេន ។

ប្រែ ក្នុងអកុសលចិត្ត ១២ដួងនេះ មានលោភមូល ៨ ដួងបានជាសង្គហន័យ ៨ ន័យ ។

តែនឹងសំដែង អសង្ខារិក ៤ ន័យ មុន គឺ :

- បឋមអសង្ខារិក បានដល់ចេតសិក ១៩ដួង :

អញ្ញសមានាចេតសិក ១៣ដួង អកុសលសាធារណចេតសិក ៤ ដួង និង លោភ ទិដ្ឋិ រួម ១៩ដួង ។

- ទុតិយអសង្ខារិក បានដល់ចេតសិក ១៩ដួង:
អញ្ញសមានា ១៣ដួង អកុសលសាធារណចេតសិក ៤ដួង និង លោភ មានះ រួម ១៩ដួង ។

- តតិយ អសង្ខារិក បានដល់ចេតសិក ១៨ដួង គឺ អញ្ញសមានា ១២ដួង ( វៀរ បីតិ ) អកុសលសាធារណចេតសិក ៤ដួង និង លោភ ទិដ្ឋិ រួម ១៨ដួង ។

- ចតុត្ថអសង្ខារិក បានដល់ចេតសិក ១៨ដួង គឺ អញ្ញសមានាចេតសិក ១២ដួង ( វៀរ បីតិ ) អកុសលសាធារណចេតសិក ៤ដួង និង លោភៈ មានះ រួម ១៨ដួង

## សំដែងសង្គហន័យរបស់ទោសមូលចិត្ត ២ដួង តាមបាលី

បញ្ចមេ បន បឋមសម្បយុត្តេ អសង្ខា-
រិកេ ទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចញ្ចាតិ
ចតូហិ សទ្ធឹ បីតិ វជ្ជិតា

-តេ ឯវ វីសតិ ធម្មា សង្គយ្ហន្តិ ។

-ឥស្សា មច្ឆេរកុក្កុច្ចានិ បនេត្ថ
បច្ចេកមេវ យោជេតព្វានិ ។

ប្រែ (បញ្ចម អសង្ខារិក) ក្នុងទោសមូលចិត្ត ២ ដួង នោះបានដល់ចេតសិក ២០ដួង គឺ អញ្ញសមានា ១២ដួង (វៀរ បីតិ) អកុសលសាធារណចេតសិក ៤ ដួង និង ទោសៈ ឥស្សា មច្ឆរិយ កុក្កុច្ច រួម ២០ដួង ។

តែក្នុងទីនេះ សូមឱ្យចូលចិត្តថា : ឥស្សា មច្ឆរិយ កុក្កុច្ចនោះ ប្រកបជាមួយនឹងចិត្តម្តង ១ដួង ៗ ។

# សំដែងសង្គហន័យរបស់សសង្ខារិក ៥ ដួងតាមបាលី

~ សសង្ខារិក បញ្ចកេបិ តថេវ ថីនមិទ្ធេន វិសេសេត្វា យោ ជេតព្វ ៗ

ប្រែ~ សសង្ខារិកទាំង ៥ មាន ថីន មិទ្ធ ជាពិសេស ហើយប្រកបចូលជាមួយនឹងចេតសិកបាន គឺ : ក្នុងលោភមូលចិត្ត

- បឋមសសង្ខារិក បានដល់ចេតសិក ២១ ដួង គឺ : អញ្ញសមានា ១៣ដួង អកុសលសាធារណចេតសិក ៤ ដួង និង លោភ: ទិដ្ឋិ ថីន មិទ្ធ រួម ២១ដួង ។

- ទុតិយសសង្ខារិក បានដល់ចេតសិក ២១ដួង គឺ : អញ្ញសមានាចេតសិក ១៣ដួង អកុសលសាធារណចេតសិក ៤ដួង និង លោភ: មាន: ថីន មិទ្ធ រួម ២១ដួង ។

- តតិយសសង្ខារិក បានដល់ចេតសិក ២០ ដួង គឺ : អញ្ញសមានាចេតសិក ១២ដួង ( វៀរ បីតិ ) អកុសល

សាធារណចេតសិក ៤ដួង និង លោភៈ ទិដ្ឋ ថីនៈ មិទ្ធ ២០ដួង

- ចតុត្ថសសង្ខារិក បានដល់ចេតសិក ២០ដួង គឺ អញ្ញសមានាចេតសិក ១២ ( វៀរ បីតិ ) អកុសលសធារណចេតសិក ៤ដួង និង លោភៈ មានៈ ថីន មិទ្ធ រូប ២០ដួង ។

- បញ្ចមសសង្ខារិក បានដល់ចេតសិក ២២ដួង គឺ អញ្ញសមានាចេតសិក ១២ដួង ( វៀរ បីតិ ) អកុសល សាធារណចេតសិក ៤ដួង និង ទោសៈ ឥស្សាមច្ឆរិយ កុក្កុ ថីន មិទ្ធ រូប ២២ដួង ។

## សំដែងសង្គហន័យរបស់មោហមូលចិត្ត ២ដួង តាមបាលី

ឆន្ទបីតិ វជ្ជិតា បន អញ្ញសមានៈ ឯកាទស អកុសលសាធារណា ចត្តារោ ចាតិ

បណ្ណរស ធម្មា

- ឧទ្ធច្ចសហគតចិត្តេ សម្បយុជ្ជន្តិ ។

- វិចិកិច្ឆា សហគតចិត្តេ ច អធិមោក្ខ-វិរហិតា

- វិចិកិច្ឆា សហិតា តថេវ បណ្ណរស ធម្មា សមុបលព្ភន្តីតិ ។ សព្វថាបិ ទ្វាទស អកុសលចិត្តុប្បាទេសុ បច្ចេកំ យោជិយ-មានាបិ គណនវសេន សត្តរស វ សង្គហិតា ភវន្តីតិ ។

ប្រែ ក្នុងមោហមូលចិត្ត ២ ដួង :

- ឧទ្ធច្ចសហគតចិត្ត បានដល់ ចេតសិក ១៥ដួង គឺ: អញ្ញសមានាចេតសិក ១១ដួង ( វៀរ បីតិ ឆន្ទ ) អកុសលសាធារណចេតសិក ៤ ដួង រួម ១៥ដួង ។

- វិចិកិច្ឆាសហគតចិត្ត បានដល់ចេតសិក ១៥ដួងគឺ: អញ្ញសមានាចេតសិក ១០ ដួង ( វៀរ បីតិ ឆន្ទ

អធិមោក្ខ) អកុសលសាធារណចេតសិក ៤ដួង និង វិចិកិច្ឆា រួម ១៥ដួង ។

អកុសលចិត្ត ១២ដួង ថា : ដោយសង្គហន័យ ៧ ន័យ ដូចពោលមកហើយ ។

---

## គាថាសង្គហ

- ឯកូនវីសដ្ឋារស វីសេកវីស វីសតិ
- ទ្វាវីស បន្នរ សេតិ សត្តធា កុសលេ ឋិតា ។

**សាធារណា ច ចត្តារោ សមានា ច ទសាបរេ ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសល-យោគិនោ ។**

ប្រែ ក្នុងអកុសលចិត្ត ១២ដួង មានសង្គហន័យ គឺ : ឯកូនវិស សង្គហន័យ អដ្ឋារសសង្គហន័យ វិសសង្គហន័យ

ឯកវិសតីសង្គហន័យ ទ្វាវិសសង្គហន័យ បន្នរសសង្គហន័យ រួម សង្គហន័យ ៧ ន័យ ។

---

## គាថាសង្គហៈ

**សាធារណា ច ចត្តារោ សមានា ច ទសាបរេ**

**ចុទ្ទសេតេ បវុច្ចន្តិ សព្វាកុសលយោគិនោ**

ប្រែ សព្វាកុសល សាធារណចេតសិក ៤ដួង និង អញ្ញសមានាចេតសិក ១០ដួង ( វៀរ ឆន្ទ បីតិ អធិមោក្ខ ) រួម ចេតសិក ១៤ ដួង នេះហៅថា សព្វាកុសលយោគី ចេតសិក ឬ ជាចេតសិក ដែលជាសាធារណដល់ចិត្តជា អកុសល ១២ដួង បាន ។

---

## សំដែងសង្គហន័យរបស់អហេតុកចិត្ត ១៨ដួង តាមបាលី

អហេតុកេសុ បន ហសន ចិត្តេ តាវ ឆន្ទ-
វជ្ជិតា អញ្ញសមានា ទ្វាទស ធម្មា សង្គហំ
គច្ឆន្តិ ។ តថា វោដ្ឋព្វនេ ឆន្ទបីតិ វជ្ជិតា
សុខសន្តីរណេ ឆន្ទវីរិយវជ្ជិតា
មនោធាតុត្តិកាហេតុកបដិសន្ធិ យុគលេ ឆន្ទ-
បីតិ វីរិយវជ្ជិតា ។
ទ្វិបញ្ចវិញ្ញាណេសុ បកិណ្ណកវជ្ជិតា តេ យេវ
សង្គយ្ហន្តីតិ ។

- សព្វថា បិ អដ្ឋារសសុ

អហេតុកេសុ គណនវសេន ចតុធា វ
សង្គហោ ហោតីតិ ។

ប្រែ ក្នុងអហេតុកចិត្ត ១៨ដួង ចិត្តជាហសិតុប្បាទ បាន
ដល់ចេតសិក ១២ដួង គឺ អញ្ញសមានាចេតសិក ១២ដួង
( វៀរ ឆន្ទៈ )

- ចិត្តជាវោដ្ឋព្វន បានដល់ចេតសិក ១១ ដួង គឺ :

អញ្ញសមានាចេតសិក ១១ ដួង ( វៀរ ឆន្ទ បីតិ )

- មនោធាតុ ៣ ដួង និង បដិសន្ធិចិត្តទាំង២ ដួង បានដល់ចេតសិក ១០ដួង គឺ អញ្ញសមានាចេតសិក ១០ ដួង ( វៀរ ឆន្ទ បីតិ វិរិយ )

- សោមនស្សសន្តីរណ បានដល់ចេតសិក ១១ដួង គឺ អញ្ញសមានាចេតសិក ១១ ដួង ( វៀរ ឆន្ទ វិរិយ )

- ទ្វិបញ្ចវិញ្ញាណ ១០ ដួង បានដល់ចេតសិក ៧ ដួង គឺ សព្វចិត្តសាធារណចេតសិក ៧ ដួង នេះឯង ។

- **ទ្វាទសេកាទស សត្តចាតិ ចតុព្វិធោ ( អដ្ឋារស ហេតុកេសុ ) ចិតុប្បាទេសុ សង្គហោ ។**

**អហេតុកេសុ សព្វត្ថ សត្ត សេសា យថារហំ ឥតិ វិត្ថារតោ វុត្តោ ( តេត្តឹស វិធសង្គហោ ) ។**

ប្រែ ក្នុងអហេតុកចិត្ត ១៨ដួងនេះ មានសង្គហន័យ គឺ :

**ទ្វានស សង្គហន័យ ឯកានស សង្គហន័យ ឧសសង្គហន័យ សត្តសង្គហន័យ** រូម ៤ ន័យ

ក្នុងសព្វចិត្តសាធារណចេតសិក ៧ ដួង រមែងប្រកបចូលក្នុងអហេតុកចិត្តជានិច្ច ។

ចំណែកបកិណ្ណកចេតសិក ៦ ដួងនោះ តាមតែប្រកបបាន ។

ចប់សង្គហន័យ ៣៣ ន័យ ដូចដែលពោលមកហើយ ដោយពិស្តារ ។

---

## គាថាសង្គហ

**ឥត្ថំ ចិត្តាវិយុត្តានំ សម្បយោគញ្ច សង្គហំ ញត្វា ភេទំ យថា យោគំ ចិត្តេន សមមុទ្ទិសេ ។**

ប្រែ តាមន័យដែលបានបរិយាយមក កាលដឹងសម្បយោគន័យ ហើយសង្គហន័យរបស់ចេតសិក ៥២ដួង ត្រូវប្រកបចូលជាមួយនឹងចិត្ត តាមដែលប្រកបចូលជាមួយគ្នា

បាន ឬ ត្រូវសំដែងចំនួនចិត្តតាមដែលនឹងប្រកបចូលបាន ។

**ចប់សង្គហន័យ ៣៣ ន័យតែប៉ុណ្ណោះ**

**ឥតិ អភិធម្មត្ថសង្គហេ ចេតសិក-សង្គហវិភាគោ នាម ទុតិយោ បរិច្ឆេទោ**

ក្នុងគម្ពីរ អភិធម្មសង្គហនេះ មាននាមថា ចេតសិកសង្គហវិភាគ ។ ក្នុងបរិច្ឆេទទី ២ ចប់តែ ប៉ុណ្ណោះ ។

## សំដែងអធិប្បាយសង្គហន័យ ៣៣ដួង

ពាក្យថាសង្គហន័យ ផ្សេងគ្នាពីសម្បយោគន័យ គឺសម្បយោគន័យ មានសេចក្តីថា ចេតសិកប្រកបចូលជាមួយចិត្ត ។

ឧទាហរណ៍ វិតក្កចេតសិក១ដួង ប្រកបចូលជាមួយ

ចិត្ត ឬ សាធារណដល់ចិត្ត ៥៥ដួង ដូចដែលអធិប្បាយមក ជាដើម ។

តែចំណែកសង្គហន័យនោះ ចិត្តត្រឡប់ប្រកបចូល ជាមួយនឹង ចេតសិកទៀត ឧទាហរណ៍ ក្នុងលោកុត្តរចិត្ត បឋមឈាន ១ដួង ប្រកបចូលជាមួយចេតសិក ៣៦ដួង ដូចដែលបានអធិប្បាយមកហើយ ដូច្នេះកាលដែលចេតសិក ប្រកបជាមួយចិត្ត ហៅថាសម្បយោគន័យ ចិត្តប្រកបជា មួយចេតសិក ហៅថា សង្គហន័យ ។ ន័យទាំងពីរនោះ រមែងអាស្រ័យដល់គ្នា និង គ្នាបាន ហើយចំនួនចិត្តប្រកប ចូលបានប៉ុណ្ណោក៏ត្រូវហៅឈ្មោះ ចេតសិកប៉ុណ្ណោះ ដូចជា សព្វចិត្តសាធារណចេតសិក ៧ ដួង ប្រកប ឬ សាធារណ ដល់ចិត្តទាំងអស់ ដូច្នេះត្រូវថាផស្សមានចំនួន ៨៩ ឬ ១២១ ដួង វេទនាមាន ៨៩ ឬ ១២១ ដួង ។ សញ្ញាចេតនា ឯកគ្គតា ជីវិតិន្ទ្រីយ៍ មនសិការ ទាំងនេះក៏ទំនងដូចគ្នា ទាំង អស់ ។

ចំណែកសង្គហន័យក៏គឺ បឋមជ្ឈានិកចិត្តជា លោកុត្តរចិត្ត ៨ ដួង និង ( បានដល់ ) ចេតសិក ៣៦ ដួង ។

មានន័យថាបឋមជ្ឈានរមែងមានចេតសិក ៣៦ដួង ព្រោះហេតុដូច្នោះ ចេតសិក ៣៦ ដួង ដែលប្រកបជាមួយចិត្តដួងនេះត្រូវហៅថា បឋមជ្ឈានទាំងអស់ សង្គហន័យដទៃៗទៀតក៏មានទំនងដូចគ្នាដែរ ។

## ពាក្យសួរឆ្លើយក្នុងសង្គហន័យ៣៣ន័យ

**សួរ** ក្នុងសង្គហន័យ ៣៣ ន័យ លោកុត្តរចិត្ត ៨ ដួង ប្រកបចូលជាមួយចេតសិក វៀរលែងអប្បមញ្ញា ចិត្តជាលោកុត្តររបស់ព្រះអរិយបុគ្គល ហេតុដូចម្ដេចមិនមានករុណា មុទិតា ?

**ឆ្លើយ** គ្មានដូច្នោះទេ ក្នុងលោកុត្តរធម៌ និង ព្រះអរិយបុគ្គលគ្រប់ៗព្រះអង្គ រមែងមានករុណា មុទិតានៅជានិច្ច

ករុណារបស់ព្រះពុទ្ធអង្គ ហៅថាមហាករុណា គឺ ជាករុណាដ៏ធំក្រៃលែងជាងករុណាទាំងពួង ។ ការដែលអភិធម្មត្ថសង្គហ បានវៀរចាក ករុណា មុទិតានោះ ព្រោះមានអារម្មណ៍ផ្សេង១គ្នា គឺ :

**ករុណា មុទិតា** មានអារម្មណ៍បញ្ញត្តិ គឺ ជាអារម្មណ៍ដែលមានចំពោះសត្វទាំងឡាយ ។ ចំណែកលោកុត្តរនោះមាននិព្វានជាអារម្មណ៍ ដោយត្រង់ដូច្នេះទើបត្រូវវៀរចាកអប្បមញ្ញាទាំងពីរ ។

**សួរ** ក្នុងបាលីអភិធម្មត្ថសង្គហ សំដែងពាក្យថា បឋមជ្ឈានិក ទុតិយជ្ឈានិក ។ ពាក្យថាឈានិកនេះ មានសេចក្តីដូចម្តេច គឺ បុគ្គល ឬ ចិត្ត ?

**ឆ្លើយ** ពាក្យថាបឋមជ្ឈានិកចិត្ត ទុតិយជ្ឈានិកចិត្ត មានសេចក្តីថា " ចិត្ត " ជួនកាលមានសេចក្តីថា "បុគ្គល " ។ បុគ្គលដែលបានដល់ឈាន ដូចជាបឋមជ្ឈានិកបុគ្គល ឬជួនកាលក៏ហៅថា បឋមជ្ឈានលាភីបុគ្គល ។ តែពាក្យ

ចាឈានិក ច្រើនសំដែង ធម្មាធិដ្ឋាន ដូចជា : អដ្ឋសុបឋម ជ្ឈានិកចិត្តេសុ ជាដើម ។

សេចក្តីថា លោកុត្តរចិត្តដែលបរិបូណ៌ ដោយបឋម ជ្ឈាននេះឯង ។

**សួរ** ការវៀរលែងវិរតិក្នុងសង្គហន័យ របស់មហគ្គតចិត្ត ២៧ដួងនោះ វៀរលែងធ្វើអ្វី ?

**ឆ្លើយ** ការវៀរលែង វិរតិទាំងបីក្នុងមហគ្គតចិត្ត ២៧ដួង ព្រោះធម្មតា មហគ្គតបុគ្គលនោះ ត្រូវបរិបូណ៌ដោយសីល ដែលបរិសុទ្ធសិន ទើបអាចដល់មហគ្គតចិត្តបាន ដូច្នេះ ការដល់មហគ្គតចិត្ត ទើបមិនចាំបាច់ នឹងមិនត្រូវនិយាយថា រក្សាវិរតិទៀត ឬ មានន័យថា ការវៀរលែងវិរតិ តព្វត្ថុ មិនមាន ព្រោះហេតុដូច្នេះក្នុងមហគ្គតចិត្ត ២៧ ដួង ទើបវៀរលែងវិរតិចេញបានដូច្នេះ ។

**សួរ** ក្នុងការសំដែងសង្គហន័យ របស់កាមាវចរចិត្ត ២៤ ដួង នោះតាមបរិច្ឆេទ "ចិត្ត " សំដែងតាមលំដាប់កុសល

វិបាក កិរិយា តើហេតុអ្វីក្នុងបរិច្ឆេទ "ចេតសិក" ទើបសំដែងកុសលវិបាកកិរិយា ?

**ឆ្លើយ** ក្នុងការសំដែងតាមលំដាប់ កុសល វិបាក កិរិយា នោះ លោកអាស្រ័យកុសល កុសលកម្ម ទើប វិបាកទាក់ទងគ្នា តែកាលដែល ចេតសិកសំដែងកុសល វិបាក កិរិយា នោះ អាស្រ័យលំដាប់ចំនួនរបស់ ដើម្បីឱ្យអ្នកសិក្សាកត់ចំណាំបានងាយ ។ ដូចជា : កាមាវចរកុសលចិត្ត ប្រកបនឹង ចេតសិក ៣៨ដួង ៣៧ដួង ៣៧ដួង ៣៦ដួង ហើយតកាមាវចរកិរិយាចិត្ត បានចេតសិក ៣៥ ដួង ៣៤ ដួង ៣៤ដួង ៣៣ដួង ។

កាលតកាមាវចរវិបាកចិត្តបាន ចេតសិក ៣៣ ដួង ៣២ ដួង ៣២ ដួង និង ៣១ ដួង ។ ចំនួនលេខតាមលំដាប់ដូចនេះ អ្នកសិក្សា អភិធម្មត្ថសង្គហ ក៏នឹងកត់ចាំបានងាយល្អ ដូច្នេះទើបលោកសំដែងតាមលំដាប់លេខ ។

**សួរ** តាមគាថាសង្គហថា :

**អនុត្តរេ ឈានធម្មា អប្បមញ្ញា ច មជ្ឈិមេ វិរតិ ញាណបីតិ ច បរិត្តេសុ វិសេសិកា**

ឈានទាំង ៥ ជាពិសេសក្នុងលោកុត្តរ អប្បមញ្ញា ជាពិសេសក្នុងមហគ្គត វិរតិ ញាណបីតិ ច ជាពិសេសក្នុងកាមាវចរចិត្តនោះ ពិសេសយ៉ាងណាខ្លះ ?

**ឆ្លើយ** តាមគាថាសង្គហដែលសំដែងមកហើយមានន័យថា

ឈានទាំង៥ ធ្វើឱ្យលោកុត្តរចិត្ត ប្លែកគ្នា ឬ ផ្សេងគ្នាគឺ វិតក្កធ្វើឱ្យបឋមជ្ឈាន និង ទុតិយជ្ឈានផ្សេងគ្នា វិចារធ្វើឱ្យទុតិយជ្ឈាន និង តតិយជ្ឈានផ្សេងគ្នា ដូចនេះជាដើម អប្បមញ្ញាទាំងពីរ ធ្វើឱ្យមហគ្គតផ្សេងគ្នា គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន និង ចតុត្ថជ្ឈាន ឈានទាំង ៤នេះ មានអប្បមញ្ញាប្រកបបាន ចំណែកបញ្ចមជ្ឈាននោះ មិនមានអប្បមញ្ញា ។ បីតិ វិរតិ បញ្ញា ធ្វើឱ្យកាមាវចរចិត្តផ្សេងគ្នាគឺ : វិរតិប្រកប និង ចិត្តជាកាមាវចរកុសលចិត្ត

បាន ក្នុងវិបាក និង កិរិយានោះ មិនមានប្រកបទេ ដូច្នេះ វិរតិ ធ្វើឱ្យកុសលផ្សេងគ្នា និង វិបាក កិរិយា ។

បញ្ញាធ្វើឱ្យញាណសម្បយុត្តផ្សេងគ្នាគឺ ចិត្តដែលបញ្ញា ហៅថាញាណសម្បយុត្ត ។ ចិត្តប្រាសចាកបញ្ញា ហៅថា ញាណវិប្បយុត្ត ។

បីតិ ធ្វើឱ្យសោមនស្ស និង ឧបេក្ខាផ្សេងគ្នា គឺ ចិត្តដែលមានបីតិ ហៅថាសោមនស្ស ។ ចិត្តប្រាសចាកបីតិហៅថា ឧបេក្ខា ព្រោះហេតុដូច្នេះ តាមដែលគាថាសង្គហៈសំដែងមកហើយថា : ឈាន អប្បមញ្ញា វិរតិ បញ្ញា បីតិ ទាំងនេះ ធ្វើឱ្យចិត្តផ្សេងគ្នា ហៅថា ធ្វើឱ្យពិសេស ដូច្នេះឯង ។

**សួរ** ក្នុងបរិច្ឆេទ "ចេតសិក" ខាងដើមអធិប្បាយអញ្ញសមានាថា ជាសាធារណដល់កុសល អកុសលបាន ដូចនេះ ក្នុងសង្គហន័យអកុសលមានគាថាសង្គហៈថា សាធារណា ច ចិត្តារោ សមានា ច ទសា បរិរេ សេចក្ដីថា

អញ្ញសមានាចេតសិក ១០ ដួង ប៉ុណ្ណោះ សាធារណ ដល់អកុសលចិត្ត ១២ដួង បានជាក្បសំដីពីរវារៈឃើញមិន ចុះសំរុងគ្នា ដូចម្តេចឆន្ទ បីតិ និង អធិមោក្ខ បានវៀរលែង អំពីអញ្ញសមានាទៀត ?

**ឆ្លើយ** កាលដែលឆន្ទៈ បីតិ អធិមោក្ខៈ ដែលវៀរលែងអំពី អញ្ញសមានាចេតសិក ព្រោះឆន្ទៈមិនអាច និង ប្រកបចិត្ត ជាមោហមូលចិត្តបាន សុំឱ្យពិចារណាសម្បយោគន័យ របស់ឆន្ទៈ ដែលអធិប្បាយមកហើយពីខាងដើម បរិច្ឆេទ នេះហើយ ។

ការវៀរលែង បីតិព្រោះបីតិផ្ទុយគ្នា និងទោសមូល ហើយឧបេក្ខា សហគតដល់ចិត្តទាំងអស់ ដូច្នេះទើបត្រូវ វៀរបីតិចេញ ។

ការវៀរលែង អធិមោក្ខនោះ ព្រោះអធិមោក្ខ ផ្ទុយគ្នា និងវិចិកិច្ឆាបាន ព្រោះហេតុដូច្នេះ ចិត្ត ៣ ដួងដែល ពោលមកហើយនេះ មិនបានឈ្មោះថា សព្វកុសលយោគី

ចេតសិកទេ។

**សួរ** សង្គហន័យរបស់អកុសលចិត្តនោះ មានសង្គហន័យ ១២ន័យ គឺ ក្នុងលោភមូលចិត្ត ៨ ន័យ ទោសមូលចិត្ត ២ ន័យមោហមូលចិត្ត ២ ន័យ រួម ១២ន័យ ដូចម្តេចក្នុងគាថាសង្គហៈថា **សត្តធា កុសលេ ឋិតា** មានសេចក្តីថា មានតែ សង្គហន័យ ៧ ន័យ ?

**ឆ្លើយ** កាលដែលមានសង្គហន័យ ១២ន័យ ហើយមាន៧ ន័យតាមបាលី **សត្តធា ឋិតា** នោះ **សត្តធា** ប្រែថា ៧ ប្រការ គឺ :

- ប្រភេទទី ១ មានចំនួន ១៩ដួង
- ប្រភេទទី ២ មានចំនួន ១៨ដួង
- ប្រភេទទី ៣ មានចំនួន ២០ដួង
- ប្រភេទទី ៤ មានចំនួន ២១ដួង
- ប្រភេទទី ៥ មានចំនួន ២០ដួង
- ប្រភេទទី ៦ មានចំនួន ២២ដួង

- ប្រភេទទី ៧ មានចំនួន ១៥ដួង

រួម ៧ ប្រភេទ ( មេត្តាមើលសង្គហន័យរបស់អកុសលចិត្ត ដែលបរិយាយមកហើយផង ) គឺ :

- ក្នុងលោភមូលចិត្ត ៨ដួង មាន ៤ ប្រភេទ ។
- ក្នុងទោសមូលចិត្ត ២ដួង មាន ២ប្រភេទ ។
- ក្នុងមោហមូលចិត្ត ២ដួង មាន ១ ប្រភេទ ។

រូក ៧ ទ័ករ

ដូច្នេះព្រះអនុរុទ្ធាចារ្យ បំណងយកតែចំនួន ប្រភេទ លេខ មើបពោលថា សត្តធា កុសលេ បិតា

ដូចនេះ សេចក្ដីពិតមាន សង្គហន័យ ១២ន័យពេញបរិបូណ៌ ។

**សួរ** តាមដែលយើងគ្រប់ៗគ្នាថា ការប្រកបរបស់អញ្ញសមានាចេតសិកនោះ ដូច្នេះក្នុងសង្គហន័យរបស់អហេតុកចិត្ត ១៨ដួង ប្រកបបានជាមួយ អញ្ញសមានាចេតសិក ម្យ៉ាងប៉ុណ្ណោះ មិនមានកុសលចេតសិក ឬអកុសលចេតសិក

សូម្បីតែ ១ ដួងនោះទេ ហើយពាក្យថាអហេតុកចិត្តក៏ជាអព្យាកតប៉ុណ្ណោះ ដូចម្ដេចទើបប្រកបជាមួយតែ អញ្ញសមានាចេតសិក ប៉ុណ្ណោះ ?

**ឆ្លើយ** តាមដែលយល់ថា អញ្ញសមានាចេតសិក សាធារណដល់ចិត្ត ដែលជាកុសលចិត្ត និង អកុសលចិត្តនោះមិនពិតទេ អញ្ញសមានាចេតសិក សាធារណបានដល់ចិត្តទាំងអស់ គឺ កុសលចិត្ត អកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ក្នុងព្រះបរមត្ថ ៤ ប្រការនោះ ។

ក្រៅពីព្រះនិព្វាន ហើយនិង រូប អញ្ញសមានាចេតសិកអាចប្រកបបាន ព្រោះហេតុដូច្នេះ អហេតុកចិត្ត ១៨ដួង ដែលជាអព្យាកតធម៌ ទើបប្រកបជាមួយអញ្ញសមានាចេតសិកបាន ។

**សួរ** ចិត្តជាហសិតុប្បាទ បានដល់អញ្ញសមានាចេតសិក ១២ដួង ( វៀរ ឆន្ទៈ ) ដូចម្ដេចបានជាវៀរឆន្ទៈ ?

**ឆ្លើយ** ការដែលវៀរ ឆន្ទៈចេញចាកពីអញ្ញសមានាចេតសិក

ដែលប្រកបចូលជាមួយនិង ចិត្តជាហសិតុប្បាទនេះ ព្រោះ ឆន្ទៈ-ចេតសិក មិនអាចប្រកបជាមួយ អហេតុកចិត្តបាន និង មោហ-មូលចិត្តបានទេ ( មេត្តាមើល ឆន្ទចេតសិក ប្រកបជា មួយចិត្តក្នុងសម្បយោគន័យ ដែលពោលមកហើយពីខាងដើមផង )

**សួរ** មនោធាតុតិក បដិសន្ធិ យុគលេ ប្រែថា មនោធាតុ ៣ និង បដិសន្ធិ ២ នោះ បានដល់ចិត្តអ្វីខ្លះ ?

**ឆ្លើយ** បញ្ចទ្វារាវជ្ជន ចិត្ត ១ ដួង សម្បដិច្ឆន្ន ២ ដួង រួម ៣ដួង ហៅថា មនោធាតុតិក ។

ឧបេក្ខាសន្តីរណ ២ដួង ហៅថា បដិសន្ធិចិត្ត២ដួង ។

អប្បមញ្ញា ក្នុងកាមាវចរវិបាកចិត្ត ៨ ដួងរមែងមិនមាន ទាំងពីរ គឺ វិរតិ និង អប្បមញ្ញា ។

ក្នុងលោកុត្តរចិត្ត ឈានទាំង ៥ ធ្វើឱ្យផ្សេងគ្នា អប្បមញ្ញាផ្សេងៗគ្នា ក្នុងមហគ្គតចិត្ត ប៉ុន្តែក្នុងកាមាវចរ នោះ វិរតិ បីតិ និង បញ្ញា ធ្វើឱ្យផ្សេងគ្នា ឬ ធ្វើឱ្យចិត្ត ១ ដួង និង ចិត្ត ១ ដួងទៀត ពិសេសជាងគ្នាប៉ុណ្ណោះ ។

# បរិច្ឆេទ ទី ៣

# បកិណ្ណកសង្គហ

## គាថាសង្គហ ខាងដើម

សម្បយុត្តា យថា យោគំ តេបញ្ញាស សភាវតោ ចិត្តចេតសិកា ធម្មា តេសំ ទានិ យថារហំ ។

វេទនាហេតុតោ កិច្ចទ្វារាលម្ពណវត្ថុតោ ចិត្តុប្បាទវសេនេវ សង្គហោ នាម និយតេ

សភាពធម៌ ៥៣ ដួង ប្រែសេចក្ដីថា ដែលសឹងជា ចិត្ត និង ចេតសិក មានលក្ខណៈដែលប្រកបនូវគ្នា នឹងគ្នា នោះ បានបរិយាយមកពិស្ដារហើយ ។

ឥឡូវនេះនឹងសំដែងបកិណ្ណកៈ សង្គហៈ ឬ សង្គហៈ ដែលចិត្ត និង ចេតសិកទាំងពីរលាយឡំគ្នា ដោយប្រភេទ

របស់វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ វត្ថុ រួមទាំង ៦ ប្រការ តាមដែលនឹងកើតបាន ។

អធិប្បាយថា : សភាវធម៌ ៥៣ ដួង ដែលជាចិត្ត និង ចេតសិក នោះបានបរិយាយមកហើយ ។ សភាវធម៌ ៥៣ដួងនេះ ហៅថា នាមធម៌ ៥៣ដួង ។

ឥឡូវនេះ នឹងសំដែងបកិណ្ណកសង្គហ ឬ ជាបរិច្ឆេទ ដែលចិត្តនិងចេតសិកទាំងពីរ លាយឡំគ្នាដោយអាស្រ័យ ប្រភេទទាំង ៦ ពី :

១- វេទនាសង្គហៈ

២- ហេតុសង្គហៈ

៣- កិច្ចសង្គហៈ

៤- ទ្វារសង្គហៈ

៥- អាលម្ពណសង្គហៈ

៦- វត្ថុសង្គហៈ

រួម ៦ សង្គហរបស់ប្រភេទ ដូចតទៅ

# សំដែងវេទនា សង្គហតាមបាលី

តត្ថ វេទនាសង្គហេ តាវ តិវិធា វេទនា សុខំ ទុក្ខំ អទុក្ខមសុខាចេតិ ។ សុខំ ទុក្ខំ សោមនស្សំ ទោមនស្សំ ឧបេក្ខាតិ ច ភេទេន បន បញ្ចធា ហោតិ ។ តត្ថ សុខសហគតំ កុសលវិបាកំ កាយវិញ្ញាណមេកមេវ ។ តថា ទុក្ខសហគតំ អកុសលវិបាកំ កាយវិញ្ញាណំ ។ សោមនស្សសហគតចិត្តានិ បន លោភមូលានិ ចត្តារិ ទ្វាទស កាមាវចរសោភណានិ សុខសន្តីរណហសិតានិ ច ទ្វេតិ អដ្ឋារស កាមាវចរសោមនស្សសហគតចិត្តានិ ចេវ បឋមជ្ឈានទុតិយជ្ឈានតតិយជ្ឈានចតុត្ថជ្ឈាន-សង្ខាតានិ ចតុត្តាឡីស មហគ្គតលោកុត្តរ-ចិត្តានិ ចេតិ ទ្វាសដ្ឋីវិធានិ ភវន្តិ ។

**ទោមនស្សសហគតចិត្តានិ បន ទ្វេ បដិឃ-សម្បយុត្តចិត្តានេវ**

**សេសានិ សព្វានិ បិ បញ្ចបញ្ញាស ឧបេក្ខាស-ហគតចិត្តានេវាតិ ។**

**ប្រែ** ខាងដើមក្នុងវេទនាសង្គហមានវេទនា ៣ គឺ :

១- សុខវេទនា ២- ទុក្ខវេទនា

៣- អទុក្ខមសុខវេទនា រួមវេទនាទាំង៣ដោយ អនុភ-វនលក្ខណា ។

ន័យមួយទៀតថា : វេទនាមាន ៥ គឺ :

១- សុខវេទនា ២- ទុក្ខវេទនា ៣- សោមនស្សវេទនា ៤- ទោមនស្សវេទនា ៥- ឧបេក្ខាវេទនា រួមវេទនាទាំង ៥ ប្រភេទឥន្ទ្រិយ ។

ក្នុងទីនេះ សុខវេទនា បានដល់ចិត្តជា សុខសហគតកុសលវិបាក កាយវិញ្ញាណ ១ ដួង ប៉ុណ្ណោះ ។

ពាក្យថា ទុក្ខវេទនា បានដល់ចិត្តជាទុក្ខសហគត

អកុសលវិបាក កាយវិញ្ញាណ ១ដួង ប៉ុណ្ណោះ ។

សោមនស្សវេទនានោះ បានដល់ចិត្តជា សោមនស្សសហគត ៦២ដួង គឺ : សោមនស្សក្នុងលោភមូលចិត្ត ៤ដួង ក្នុងកាមាវចរសោភណចិត្ត ១២ ដួង សោមនស្សសន្តីរណ ១ដួង ហសិតុប្បាទ ១ដួង ហើយក្នុងមហគ្គតចិត្ត លោកុត្តរចិត្ត ៤៤ដួង គឺជា : បឋមជ្ឈាន ១១ដួង ទុតិយ-ជ្ឈាន ១១ដួង តតិយជ្ឈាន ១១ ចតុត្ថជ្ឈាន ១១ រួម ៤៤ ដួង រួមទាំងអស់ សោមនស្សវេទនា ៦២ដួង

ពាក្យថា ទោមនស្សវេទនា បានដល់ ទោសមូលចិត្ត ២ ដួង ។

ពាក្យថា ឧបេក្ខាវេទនា បានដល់ចិត្តដែលសល់អំពី សោមនស្សវេទនា ទោមនស្សវេទនា គឺ ចិត្តជាឧបេក្ខាវេទនាទាំងអស់ មានចំនួន ៥៥ ដួង ។ អធិប្បាយតទៅទៀតថា :

ក្នុងវេទនាសង្គហនេះ សំដែងដោយវេទនាទាំងពីរ

ន័យ គឺ អនុភវនន័យ និង ឥន្ទ្រិយ ប្រភេទន័យ

១- អនុភវនន័យ : ជាន័យនៃលំដាប់របស់ការសោយអារម្មណ៍ បានដល់វេទនា ៣ ដួង គឺ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ។

២- ឥន្ទ្រិយប្រភេទ : ប្រភេទរបស់ឥន្ទ្រិយបានដល់សុខ វេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា ឧបេក្ខាវេទនា ។

សុខវេទនាបានដល់ចិត្ត ១ ដួងគឺ សុខសហគត-កុសលវិបាក កាយវិញ្ញាណ ១ ដួង ។

ទុក្ខវេទនាបានដល់ចិត្ត ១ ដួង គឺ ទុក្ខសហគត-អកុសលវិបាក កាយវិញ្ញាណ ១ដួង ។

សោមនស្សវេទនាមាន ៦២ ដួងគឺ : ក្នុងលោភមូលចិត្ត ៨ដួងនោះសោមនស្ស ៤ ដួង

ក្នុងអហេតុកកុសលវិបាកចិត្ត មានសោមនស្សសន្តីរណ ១ដួង

ក្នុងអហេតុកកិរិយាចិត្ត មានហសិតុប្បាទ ១ដួង

ក្នុងកាមាវចរសោភណចិត្ត ២៤ ដួង មានសោមនស្ស ១២ដួង រួម កាមាវចរសោមនស្ស ១៨ ដួង

ក្នុងរូបាវចរចិត្ត ១៥ ដួង មាន បឋមជ្ឈាន. ៣ ដួង ទុតិ .៣ ដួង តតិយ. ៣ដួង ចតុត្ថ. ៣ដួង រួម ១២ដួង

ក្នុងលោកុត្តរចិត្ត ៤០ដួង មាន បឋមជ្ឈាន ៨ ដួង ទុតិ .៨ដួង តតិយ. ៨ដួង ចតុត្ថ. ៨ដួង រួម ៣២ដួង

រួមទាំងអស់ កាមាវចរសោមនស្ស ១៨ដួង

រូបាវចរចិត្ត ១២ដួង

លោកុត្តរសោមនស្ស ៣២ដួង

---

រួម ៦២ដួង

ទោមនស្សវេទនានោះ បានដល់ទោមនស្សបដិឃសម្បយុត្ត ២ដួង ចិត្តជាឧបេក្ខាវេទនា ទាំងអស់ ៥៥ ដួង គឺ :

-ក្នុងអកុសលចិត្ត ៦ដួង

- ក្នុងអហេតុកចិត្ត ១៤ដួង
- ក្នុងកាមាវចរសោភណចិត្ត ១២ដួង

រួមកាមាវចរឧបេក្ខា ៣២ដួង

- ក្នុងចិត្តមហគ្គត ១៥ដួង គឺ បញ្ចមជ្ឈាន ៣ដួង
- ក្នុងអរូបឈានជាឧបេក្ខាទាំងអស់ ១២ដួង
- ក្នុងលោកុត្តរចិត្ត ៤០ ដួងមានឧបេក្ខាបញ្ចមជ្ឈាន ៨ដួង

រួម ៣២ដួង + ៣ដួង + ១២ដួង + ៨ដួង = ៥៥ដួង ដូចនេះ

## គាថាសង្គហៈ

សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថ វេទនា
សោមនស្សំ ទោមនស្សំ ឥតិ ភេទេន បញ្ចធា

សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ
ឋិតំ ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា

បានសេចក្ដីថា ក្នុងវេទនាសង្គហនេះ នៅវេទនា ៣ គឺ : សុខវេទនា ទុក្ខវេទនា និង ឧបេក្ខាវេទនា ។

ន័យមួយទៀត មានវេទនា ៥ គឺ វេទនាទាំង ៣ ដែលពោលមកហើយ រួមចូលជាមួយ សោមនស្សវេទនា និងទោមនស្សវេទនាផង រួម ៥ ដួង ។

សុខវេទនា ១ដួង ទុក្ខវេទនា ១ដួង ទោមនស្សវេទនា ២ដួង សោមនស្សវេទនា ៦២ដួង និង ឧបេក្ខាវេទនា ៥៥ដួង

---

## ពាក្យសួរឆ្លើយ វេទនាសង្គហ

**សួរ** ពាក្យថា វេទនាប្រែថាអ្វី ហើយមានសេចក្ដីដូចម្ដេច?

**ឆ្លើយ** ពាក្យថាវេទនា ប្រែថា ការសោយអារម្មណ៍ទាំង ៦ បានដោយត្រង់ដល់វេទនាចេតសិក ១ដួង និង ចិត្តជាវេទនាចេតសិកប្រកបជាចិត្ត ដូចជាសុខវេទនា បានដល់សុខសហគតកុសលវិបាកចិត្ត កាយវិញ្ញាណ ដូចនេះជាដើម

មានន័យថា កាយវិញ្ញាណ ចិត្តដែលសុខវេទនារមែង ប្រកប ហៅថា សុខវេទនា ។

**ស្ងួរ** សុខវេទនា និង សោមនស្សវេទនា ផ្សេងគ្នា យ៉ាងណាខ្លះ ?

**ឆ្លើយ** សុខវេទនា និង សោមនស្សវេទនា ផ្សេងគ្នាគឺ :

-សុខវេទនា បានដល់កាយវិញ្ញាណ

-ចំណែកសោមនស្សវេទនា រមែងកើតក្នុង វិញ្ញាណដទៃ មានន័យថា សុខវេទនារមែងកើត កាលប៉ះទង្គិចឥដ្ឋារម្មណ៍ របស់ផោដ្ឋព្វារម្មណ៍ ប៉ុណ្ណោះ ។ ចំណែកសោមនស្សវេទនា រមែងកើតដោយ ការប៉ះទង្គិចអារម្មណ៍ដទៃៗ គឺ **រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និង ធម្មារម្មណ៍** ។ សុខវេទនា សោមនស្សវេទនាផ្សេងគ្នា ដូច្នេះឯង ។

**ស្ងួរ** ក្នុងវេទនាទាំង ៣ ពាក្យថា អទុក្ខមសុខវេទនា មានសេចក្តីថាដូចម្តេច ?

**ឆ្លើយ** ពាក្យថា អទុក្ខមសុខវេទនាមានសេចក្តីថា អទុក្ខ + អសុខ ប្រែថា មិនមែនទុក្ខវេទនា មិនមែនសុខវេទនា គឺ ឧបេក្ខាវេទនា នោះឯង ន័យម្យ៉ាងទៀតថា ពាក្យអទុក្ខម-សុខ ហៅឈ្មោះដោយការអាស្រ័យ ការសោយអារម្មណ៍ និង ពាក្យឧបេក្ខាវេទនា ហៅឈ្មោះដោយអាស្រ័យ ឥន្ទ្រិយ៍ គឺ ក្នុងឥន្ទ្រិយ៍ទេសនាសំដែងថា **សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ** ដូច្នេះជាដើម ។

**សួរ** ពាក្យថាឧបេក្ខាពិចារណាមើល ក៏មានច្រើនយ៉ាង ដូចជា ឧបេក្ខាបារមី ក៏មានមេត្តា ករុណាមុទិតា ក៏បាន ក្នុងវិបស្សនូប កិលេស ១០ប្រការ ក៏មាន ។

ពាក្យថាឧបេក្ខាក៏មានក្នុង វិបស្សនាញាណអង្គ ១០ ថា សង្ខារុបេក្ខា ក៏មានក្នុងបកិណ្ណកសង្គហ ដែលជា ឧបេក្ខានោះតើមានឧបេក្ខាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាឧបេក្ខាប្រែថា សេចក្តីព្រងើយៗ តែសេចក្តី

ព្រងើយៗនោះមានអារម្មណ៍ផ្សេងៗគ្នាច្រើនមានសេចក្ដីថា សេចក្ដីព្រងើយៗនោះ ជាអារម្មណ៍ព្រងើយៗបានច្រើនយ៉ាង ព្រោះហេតុដូច្នោះ និង អធិប្បាយឧបេក្ខា ១០យ៉ាងតទៅ ÷

១- **ឆឡង្គុបេក្ខា** បានដល់ឧបេក្ខា របស់ព្រះអរហន្តគឺ សេចក្ដីព្រងើយៗ ចំពោះអារម្មណ៍ទាំង ៦ អធិប្បាយថា មិនត្រេកអរ មិនជាប់ជំពាក់កាលប៉ះទង្គិចអារម្មណ៍

២- **ព្រហ្មវិហារុបេក្ខា** បានដល់ឧបេក្ខារបស់ព្រះយោគីបុគ្គល គឺសេចក្ដីព្រងើយៗចំពោះសត្វទាំងឡាយ អធិប្បាយថា មិនស្រណោះ មិនត្រេកអរ ចំពោះសត្វទាំងពួង ។

៣- **ពោជ្ឈង្គុបេក្ខា** បានដល់ឧបេក្ខារបស់ព្រះអរិយបុគ្គល គឺ សេចក្ដីព្រងើយៗ ចំពោះសហជាតិធម៌ដែលកើតព្រមគ្នា ក្នុងការធ្វើវិបស្សនា ។

៤- **វីរិយុបេក្ខា** បានដល់មជ្ឈិមាបដិបទា គឺសេចក្ដីព្យាយាមយ៉ាងកណ្ដាល ក្នុងការធ្វើបដិទានៃមគ្គ ៨ ប្រការ ។

៥- **សង្ខារុបេក្ខា** បានដល់សេចក្ដីព្រងើយៗ ចំពោះសង្ខារទាំងពួង គឺ ព្រងើយៗក្នុងអាការកើតរលត់ ។

៦- **វេទនុបេក្ខា** បានដល់វេទនាចេតសិក ដែលមិនសុខ មិនទុក្ខ គឺ វេទនាដែលនៅក្រៅសុខ-ទុក្ខ គឺឧបេក្ខាវេទនា ក្នុងវេទនា ៣ ឬ ៥ ក្នុងបរិច្ឆេទនេះ ។

៧- **វិបស្សនុបេក្ខា** បានដល់ឧបេក្ខារបស់ព្រះយោគី គឺ សេចក្ដីព្រងើយៗ ចំពោះរូបនាម ដែលខ្លួនសំឡឹង ពិនិត្យ មានន័យថា ឈប់នៅត្រង់នោះ ( បានដល់បញ្ញាចេតសិកដែលជាកណ្ដាល ក្នុងការពិចារណា អារម្មណ៍ដែល កើតតាមហេតុបច្ច័យ ) ។

៨- **តត្រមជ្ឈត្តុបេក្ខា** បានដល់ឧបេក្ខា របស់តត្រមជ្ឈត្តតាចេតសិក គឺ សង្គ្រោះចំពោះសុខ និង ទុក្ខទាំងពីរ ចំណែកតែ តត្រមជ្ឈត្តតា គ្មានជាសុខ ឬ ទុក្ខទេ ។

៩- **ឈានុបេក្ខា** បានដល់ឧបេក្ខារបស់ឈានលាភីបុគ្គលដែលមិនត្រេកអរ ជាប់ជំពាក់ ចំពោះសេចក្ដីសុខ ក្នុងទីនេះពាក្យថាសុខ បានដល់ សុខេកគ្គតា របស់ចតុត្ថជ្ឈាន ។

១០- **បារិសុទ្ធុបេក្ខា** បានដល់ឧបេក្ខារបស់ ចតុត្ថជ្ឈាន ឬ បញ្ចមជ្ឈានក៏បាន ។

ឧបេក្ខាដូចនេះ ក្នុងចិត្តជាបញ្ចមជ្ឈាន ក្នុងឧបេក្ខា ១០ប្រការនេះ ។

ពាក្យថាអទុក្ខមសុខ ឬ ឧបេក្ខានោះ បានដល់វេទនូបេក្ខាគឺវេទនាមួយ៉ាង ដែលក្រៅអំពី សុខវេទនា និង ទុក្ខវេទនា ទាំងពីរនោះឯង ។

**សួរ** តាមដែលបរិច្ឆេទចិត្តថា ចិត្តជាវិញ្ញាណ ១០ដួង ក្នុង ១០ដួងនោះ សុខវេទនា ទុក្ខវេទនា ប្រកបចូលបាន ជាមួយនិងកាយវិញ្ញាណទាំងពីរ ។ ពាក្យថាកាយវិញ្ញាណ ទាំងពីរហៅថា សុខវេទនា ទុក្ខវេទនាបានឬទេ ?

**ឆ្លើយ** គ្មានដូច្នេះទេ វេទនាចេតសិក អាចដែលជា សាធារណបានដល់ចិត្តទាំងអស់ ។

ពាក្យថាកាយវិញ្ញាណនេះ ជាចិត្តដែលកើតព្រមនឹង វេទនាក្នុងខណៈដែលប៉ះទង្គិចផោដ្ឋព្វារម្មណ៍នោះ សេចក្តី ដឹងខ្លួនថាជាសុខ ឬ ទុក្ខ ហៅថា សុខវេទនា ឬ ទុក្ខវេទនា វេទនាជាចេតសិក កាយវិញ្ញាណជាចិត្ត វេទនាកើតព្រម និង កាយវិញ្ញាណប៉ុណ្ណោះឯង ។

**សួរ** តាមវោហារថា ឈឺភ្នែក ឈឺត្រចៀក ជាដើមនោះ ទុក្ខវេទនាកើត ក្នុងចក្ខុវិញ្ញាណ មិនមែនទេឬ កាលបើ ដូច្នេះចក្ខុវិញ្ញាណ សោតវិញ្ញាណ ទាំងអស់នេះមិនគួរ ហៅទុក្ខវេទនា ឬ ?

២៤ មុទិតា ជាចេតសិកដែល មានសេចក្ដីត្រេកអរ ចំពោះសត្វទាំងឡាយដែលជាសុខ ឬ មិនច្រណែន ចំពោះលាភ យស សរសើរសុខ របស់អ្នកដទៃ

២៥ បញ្ញិន្ទ្រិយ ជាចេតសិកដែលមានបញ្ញា ជាឥន្ទ្រិយ រួមទាំងអស់ ១៩ + ៣ + ២ + ១ = ២៥ ហៅថាសោភណចេតសិក ។

## គាថាសង្គហ

ឯត្តាវតា ច តេរសញ្ញសមានា ច ចុទ្ទសាកុសលា តថា សោភណាបញ្ចវីសតិ ទ្វេបញ្ញាស បវុច្ចរេ ១

ប្រែ សេចក្ដីដែលបរិយាយមកនេះ សំដែងថាចេតសិកជាអញ្ញសមានា ១៣ដួង ជាអកុសលចេតសិក ១៤ដួង និងសោភណចេតសិក ២៥ដួង ដូចនេះទើបពោលថាមានចេតសិក ៥២ ដួង ។

2៖ 289. 290

# ពាក្យសួរ ឆ្លើយតាមចេតសិក៥២ដួង

**សួរ** ពាក្យថាចេតសិក ប្រែត្រង់ៗ បានដល់អ្វី ?

**ឆ្លើយ** ពាក្យថា ចេតសិកនោះប្រែត្រង់ៗ តាមវិគ្គហថា ចេតសិនិយុត្តំ ចេតសិកំ ប្រែថា សភាពដែលប្រកបជាមួយចិត្តហៅថាចេតសិក តែពាក្យថា ប្រកបជាមួយចិត្តនោះ មាន ៤ ប្រការគឺ :

ឯកុប្បាទ កើតព្រមជាមួយចិត្ត ។

ឯកនិរោធ រលត់ចុះព្រមជាមួយចិត្ត ។

ឯការម្មណា កាលចេតសិកទទួលអារម្មណ៍តែ១ក៏ជាមួយគ្នានិងចិត្ត ។

ឯកវត្ថុក ដែលអាស្រ័យក៏ជាវត្ថុតែ១ជាមួយគ្នានឹងចិត្តរួម ៤ យ៉ាងនេះហៅថា ចេតោ យុត្ត ឬ ប្រកបជាមួយ ។

**សួរ** ក្រៅអំពីចេតសិក ៥២ដួង ដែលពោលមកហើយសភាពដែលកើតព្រមជាមួយចិត្ត នៅមានទៀតឬទេ ?

ដួង ( វៀរ វេទនាប៉ុណ្ណោះ ) ។

**សួរ** ឧបេក្ខាវេទនា ចេតសិកប្រកបប៉ុន្មាន ?

**ឆ្លើយ** ឧបេក្ខាវេទនា មានចំនួន ៥៥ដួង ចេតសិកប្រកប ៤៦ដួង ប្រហែលសោមនស្សវេទនា គឺ វៀរ ទោស ឥស្សា មច្ឆរិយ កុក្កុច្ច វិចិកិច្ឆា និង វេទនា រួមវៀរលែងចេតសិក ៦ដួង សល់ចេតសិក ៤៦ដួង នោះ ប្រកបចូលនិង ឧបេក្ខាវេទនាបាន ។

---

## សំដែងសង្គហតាមបាលី

ហេតុសង្គហេ ហេតូនិ នាម លោភោ ទោសោ

មោហោ អលោភោ អទោសោ អមោហោ

ចាតិ ឆព្វិធានិ ភវន្តិ ។

តត្ថ បញ្ចទ្វារាវជ្ជនទ្វិបញ្ចវិញ្ញាណ-

សម្បដិច្ឆនសន្តីរណវោដ្ឋព្វនហសនវសេន

អដ្ឋារស អហេតុកចិត្តានិ នាម ។

សេសានិ សព្វានិ បិ ឯកសត្តតិ ចិត្តានិ សហេតុកានេវ ។

តត្ថាបិ ទ្វេ មោហមូលចិត្តានិ ឯកហេតុកានិ ។ សេសានិ ទស អកុសលចិត្តានិ ចេវ ញាណវិប្បយុត្តានិ ទ្វាទស កាមាវចរសោភណានិ ចេតិ ទ្វាវីសតិ ទ្វិហេតុកចិត្តានិ ។

ទ្វាទស ញាណសម្បយុត្តា កាមាវចរ-សោភណានិ ចេតិច (0)សត្តចត្តាឡីស តិហេតុក ចិត្តានិ ។

ក្នុងហេតុសង្គហនេះ មានហេតុ៦ ប្រការគឺ :

១-លោភហេតុ ២-ទោសហេតុ ៣-មោហហេតុ

៤-អលោភហេតុ ៥-អទោសហេតុ ៦-អមោហហេតុ

រួម ៦ ប្រការ ។

ប្រែ ក្នុងទីនេះចិត្តជា **បញ្ចទ្វារាវជ្ជន ១ដួង**

**ទ្វិបញ្ចវិញ្ញាណ ១០ដួង សម្បដិច្ឆន្ន ២ដួង សន្តីរណ ៣ដួង វោដ្ឋព្វន ១ដួង ហសន ១ដួង** រួម ១៨ដួង ហៅថា **អហេតុកចិត្ត** សល់ចិត្ត ៧១ដួង ហៅថា **សហេតុកចិត្ត** ។

- ចិត្តជាមោហមូល២ ដួង ហៅថា ឯកហេតុកចិត្ត ។
- អកុសលចិត្តដែលសល់១០ដួងទៀត និងចិត្តជាញាណ-វិប្បយុត្ត ១២ដួង រួម ២២ដួង ហៅថា ទ្វិហេតុកចិត្ត ។
- ចិត្តជាញាណសម្បយុត្ត ១២ដួង មហគ្គតចិត្ត លោកុត្តរចិត្ត ៣៥ដួង រួម៤៧ដួងនេះ ហៅថា តិហេតុកចិត្ត ។

---

# សំដែងអធិប្បាយហេតុសង្គហតាមបាលី

ក្នុងហេតុកសង្គហនេះ មានហេតុ ៦ប្រការគឺ :

**លោភហេតុ ទោសហេតុ មោហហេតុ**

---

០) បញ្ចត្តឹស មហគ្គត លោកុត្តរចិត្តានិ ចេតិ

អលោភហេតុ អទោសហេតុ អមោហហេតុ រួម ៦ប្រការ ។ កាលសំដែងហេតុ ៦ប្រការហើយ អហេតុក ក៏នៅមានទៀត ។

ពាក្យថា អហេតុក មានន័យថា មិនមានហេតុ ចិត្តដែលមិនមានហេតុមាន ១៨ដួង គឺ : បញ្ចទ្វារាវជ្ជន ១ ដួង ទ្វិបញ្ចវិញ្ញាណ ១០ ដួង សម្បដិច្ឆន្ន ២ ដួង សន្តីរណ ៣ដួង មនោទ្វារាវជ្ជន ១ដួង ហសិតុប្បាទ ១ដួង រួម ១៨ ដួងនេះហៅថា អហេតុកចិត្ត ឬ ចិត្តដែលមិនមានហេតុ សល់ចិត្ត ៧១ដួង ហៅថាសហេតុកចិត្ត ឬ ចិត្តដែលមានហេតុ ។

ក្នុងសហេតុកចិត្ត ៧១ដួងនេះ មានចិត្តជាមោហមូលចិត្ត ២ ដួង ហៅថាឯកហេតុក ឬ ចិត្តដែលមានហេតុតែ ១ គឺ មោហហេតុ សល់អកុសលចិត្ត ១០ដួង និងចិត្តជាញាណវិប្បយុត្ត ១២ដួង រួម២២ដួងហៅថាទ្វិហេតុក ឬ ចិត្តដែលមានហេតុ ២ហេតុ គឺ លោភ ទោស មោហ ឬ

អលោភ អទោស អមោហ

- ចិត្តជាញាណសម្បយុត្ត ១២ដួង រូបាវចរចិត្ត និង អរូបាវចរចិត្ត ២៧ដួង លោកុត្តរចិត្ត ៨ ដួង រួមទាំងអស់ ៤៧ដួង ហៅថា តិហេតុក ឬ ចិត្តដែលមានហេតុ ៣ គឺ អលោភ អទោស អមោហ ។

---

## គាថាសង្គហ

លោភោ ទោសោ ច មោហោ ច ហេតូ អកុសលា តយោ អលោភាទោសាមោហា ច កុសលាព្យាកតា តថា ។ អហេតុកាដ្ឋារសេកហេតុកា ទ្វេ ទ្វាវីសតិ ទ្វិហេតុកា មតាសត្ត ចត្តាឡីស តិហេតុកា ។

ប្រែ ហេតុដែលជាអកុសល ៣ គឺ លោភៈ ទោសៈ មោហៈ ហេតុដែលជាកុសល និង អព្យាកតមាន ៣ គឺ អលោភៈ អទោសៈ អមោហៈ។

អហេតុកចិត្ត ១៨ដួង ឯកហេតុកចិត្ត ២ដួង ទ្វិហេតុកចិត្ត ២២ដួង និង តិហេតុក ៤៧ដួង ។

# ស្នួរ-ឆ្លើយ ក្នុង ហេតុសង្គហ

**ស្នួរ** ពាក្យថាហេតុ ប្រែថាយ៉ាងណា ហើយបានសេចក្តីថាយ៉ាងណា ?

**ឆ្លើយ** ពាក្យហេតុ តាមវិគ្គហថា ហិនោតិ ផលំ បវត្តតីតិ ហេតុ ប្រែ សភាវធម៌ដែលធ្វើឱ្យ ផលកើត ហៅថា ហេតុ មានន័យថា កុសល និង អកុសលដោយត្រង់ តែថាជាចេតសិក ។

**ស្នួរ** កុសលមានហេតុប៉ុន្មាន អកុសលមានហេតុប៉ុន្មាន ?

**ឆ្លើយ** កុសលមានហេតុ ៣ គឺ : **អលោភៈ អទោសៈ** អមោហៈ ។ អកុសលមានហេតុ ៣គឺ : **លោភៈ ទោសៈ មោហៈ** ។ រួម៦ ហេតុ

**សួរ** ពាក្យថាអហេតុក ប្រែថា មិនមានហេតុបានដល់ចិត្តជាអហេតុកចិត្ត១៨ដួង ។ កាលបើដូច្នេះ កុសលវិបាក-ចិត្ត អកុសលវិបាកចិត្ត ឧបេក្ខា សន្តីរណ ២ដួង បដិសន្ធិ-ចិត្តនោះ បើមិនមានហេតុហើយ និង បានយ៉ាងណាថា ទ្វិហេតុកបុគ្គល និង ត្រៃហេតុកបុគ្គល ?

**ឆ្លើយ** ឧបេក្ខា សន្តីរណ ២ដួង នេះ ដែលជាបដិសន្ធិចិត្ត ពិតមែន តែថាចិត្តទាំងពីរដួងនោះ អិនអាចដែលនឹងជាផលបាន ឬមានសេចក្តីថា មិនជាហេតុយ៉ាងណានិមួយៗ ដល់បដិសន្ធិចិត្តទេ វត្ថុដែលជាហេតុដល់បដិសន្ធិនោះ គឺ កុសល និង អកុសល ។ កាលខណៈដែលទទួលបដិសន្ធិ កុសលវិបាកចិត្ត ឬ អកុសលវិបាកចិត្ត ប្រាកដឡើង ចិត្តដួងនេះ ហៅថាបដិសន្ធិចិត្ត ដូច្នេះ ពាក្យសួរនេះមិនមានហេតុផលត្រង់នឹងសន្តីរណទាំងពីរឡើយ ។

**សួរ** ក្នុងអកុសលចិត្ត ១២ដួងនោះ មានឯកហេតុកចិត្ត គឺ មោហមូលចិត្ត២ដួង ដូចម្តេច ឯកហេតុកចិត្ត ក្នុងកុសលចិត្ត

មិនមានដូច អកុសលចិត្ត ?

**ឆ្លើយ** កាលដែលមាន ឯកហេតុកចិត្ត ឬ ទ្វិហេតុកចិត្ត ក៏ដោយមានជា ធម្មនិយាម គ្មានអ្នកណាមួយធ្វើឱ្យមានឡើងទេ ក្នុងចិត្ត ៨៩ដួង ឬ ១២១ដួងនោះមានចិត្តជាឯហេតុកចិត្ត២ដួងប៉ុណ្ណោះ ព្រោះហេតុដូច្នោះក្នុងចិត្តដទៃៗទើបមិនមានឯកហេតុកចិត្តឡើយ គឺ មានតែក្នុងអកុសលចិត្តប៉ុណ្ណោះ ។

**សួរ** តាមការដែលដឹងគ្រប់គ្នាទូទៅថា បុថុជ្ជន បុគ្គលមាន ៤ បុគ្គលគឺ **ទុគ្គតិអហេតុកបុគ្គល សុគតិអហេតុកបុគ្គល ទ្វិហេតុកបុគ្គល ត្រៃហេតុ បុគ្គល** រួម ៤ ពួក ។ ដូចម្ដេច ឯកហេតុកបុគ្គលទើបមិនមានក្នុងកាលឯកហេតុកចិត្តប្រាកដនៅផង ?

**ឆ្លើយ** ការហៅទ្វិហេតុកបុគ្គលនោះ អាស្រ័យហៅបដិសន្ធិចិត្តពាក្យថាឯកហេតុកចិត្ត គ្មានបដិសន្ធិទេ ព្រោះហេតុដូច្នោះ ទើបមិនមានទ្វិហេតុកបុគ្គល ។

**សួរ** ដែលហៅថាទ្វិហេតុកបុគ្គល មានហេតុទាំងពីរនោះ រាប់ចំនួនហេតុមាន ៤ ហេតុ គឺ លោភៈ ទោសៈ និង អលោភៈ អទោសៈ ដូចម្ដេចទើបហៅថាទ្វិហេតុក ?

**ឆ្លើយ** កាលដែលហៅថាទ្វិហេតុក រមែងមានហេតុទាំងពីរ មិនសំដៅយកចំនួនហេតុទាំងអស់ សេចក្ដីពិតសំដៅយក តែក្នុងអកុសលចិត្ត ១០ ដួង មានហេតុ ២ គឺ : លោភ ទោស និងក្នុងចិត្តជាញាណវិប្បយុត្ត ១២ដួង នោះ ក៏មានហេតុ ២ គឺ អលោភ អទោស ។ មានសេចក្ដីថា អកុសលហេតុ ២ ឬ កុសលហេតុ ២ ដូច្នេះ ទើបហៅថា ទ្វិហេតុក ប្រែថា ចិត្តដែលមានហេតុ ២ តែមិនបានកំណត់ ថាកុសល ឬ អកុសលទេ ។

**សួរ** ខាងដើមក្នុងហេតុសង្គហថា មានហេតុ ៦ ហេតុ ក្នុងគាថាសង្គហថា កុសលាព្យាកតតត្ថ ប្រែថាកុសល និង អព្យាកតហេតុ ពាក្យនិយាយខាងដើម និងខាងចុងមិន ត្រង់មិនត្រូវគ្នា ដូច្នេះនេះ និង អធិប្បាយយ៉ាងណា ?

**ឆ្លើយ** ការដែលសំដែងពីខាងដើមនោះ លោកមានបំណង នឹង សំដែងកុសលហេតុ ៣ និង អកុសលហេតុ ៣ រួប៦ ហេតុតាមបាលី ដែលលោកសំដែងមកខាងដើមហេតុ សង្គហនេះ ចំណែកដែលលោកថា ក្នុងគាថាសង្គហនោះ ព្រោះថា ហេតុធម៌មាន មិនចំពោះកុសល និង អកុសល ។

សូម្បីក្នុងវិបាក និង កិរិយាដែលជាអព្យាកតាក៏មាន. ព្រោះហេតុដូច្នេះ ទើបមានកុសលហេតុ ៣ អកុសលហេតុ ៣ និង អព្យាកតាហេតុ ៣ រួមមានហេតុធម៌ ៩ ដូច គាថាដែលសំដែងហើយ ។

**សួរ** ក្នុងអកុសលចិត្ត ១២ដួងនេះ ប្រកបចូលនឹងហេតុ ប៉ុន្មាន ?

**ឆ្លើយ** អកុសលចិត្ត ១២ដួង ប្រកបចូលនឹងហេតុ ២២ គឺ លោភហេតុ ៨ ទោសហេតុ ២ និង មោហហេតុ ១២រួម ២២ហេតុ ។ មោហហេតុ ១២គឺ មោចតុកៈ ៤ចំ ពោះខ្លួនឯង មោចតុកៈ ៤ ប្រកបជាមួយលោភហេតុ

មោចតុកៈ ៤ ទៀតប្រកបជាមួយទោសហេតុ ។

**ស្នួរ** ក្នុងកុសលចិត្ត ៣៧ដួងប្រកបជាមួយហេតុប៉ុន្មាន ?

**ឆ្លើយ** កុសលចិត្ត ៣៧ដួង ប្រកបជាមួយហេតុ ១០៧ គឺ មហាកុសលចិត្ត ញាណវិប្បយុត្ត ៤ដួងនោះ បានដល់អលោភ ៤ អទោស ៤ ចិត្តជាញាណសម្បយុត្ត ៤ បានដល់អលោភ ៤ អទោស ៤ និង អមោហ ៤ក្នុងមហគ្គតចិត្ត ៩ បានដល់ អលោភ ៩ អទោស ៩ អមោហ ៩ និង ក្នុងបត្តចិត្ត ២០ នោះបានដល់អលោភ ២០ អទោស ២០ អមោហ ២០ រួមទាំងអស់ ១០៧ហេតុ ។

**ស្នួរ** ក្នុងចិត្តមានហេតុប្រកប ដូច្នេះនេះ ហើយចំណែកចេតសិកនោះ មិនមានហេតុប្រកបទេឬ ?

**ឆ្លើយ** សភាពចិត្តមានហេតុប្រកបហើយ ចេតសិកក៏រមែងមានហេតុប្រកបដូចគ្នា ព្រោះហេតុដូច្នោះ ចិត្ត និងចេតសិកកើតរលត់ព្រមគ្នា ។

ចេតសិកដែល ប្រកបនិងហេតុនោះ មានដូចតទៅ

នេះគឺ ÷

១-ឯហេតុកចេតសិកបានដល់ លោភ ទោស និង វិចិកិច្ឆា

២-ទ្វិហេតុកចេតសិក បានដល់ **មោហ ឥស្សា មច្ឆរិយ កុក្កុច្ច ថិន្នំ មាន អលោភោ អទោសោ អមោហោ** រួម ៩ ដួង

៣-តិហេតុកចេតសិក បានដល់សោភណចេតសិក ២២ដួង ( វៀរ អលោភ អទោស អមោហ ) និង អហិរិក អនោត្តប្ប ឧទ្ធច្ច ថីនំ មិទ្ធំ រួម ២៧ដួង ។

៤-បញ្ចហេតុកចេតសិក បានដល់ចេតសិក បីតិ ១ដួង

៥-ឆហេតុកចេតសិក បានដល់អញ្ញសមានា ចេតសិក ១២ដួង ( វៀរ បីតិ ) ។

រួម ៥ន័យ ដែលពោលមកហើយនេះ. ហៅថាហេតុកចេតសិក ។

# សំដែងកិច្ចសង្គហតាមបាលី

កិច្ចសង្គហេ កិច្ចានិ នាម បដិសន្ធិ ភវង្គ-អាវជ្ជនទស្សនសវនឃាយនសាយនផុស្សន-សម្បដិច្ឆនសន្តីរណវោដ្ឋព្វនជវនតទាលម្ពណចុតិវសេន ចុទ្ទសវិធានិ ភវន្តិ

បដិសន្ធិ ភវង្គាវជ្ជនបញ្ចវិញ្ញាណ-ដ្ឋានាទិវសេន បន តេសំ ទសធា ឋានភេទោ វេទិតព្វោ ។

ក្នុងកិច្ចសង្គហនេះ មាន ១៤ កិច្ចគឺ :

១ បដិសន្ធិកិច្ច ២ ភវង្គកិច្ច

៣ អាវជ្ជនកិច្ច ៤ ទស្សនកិច្ច

៥ សវនកិច្ច ៦ ឃាយនកិច្ច

៧ សាយនកិច្ច ៨ ផុស្សនកិច្ច

៩ សម្បដិច្ឆនកិច្ច ១០ សន្តីរណកិច្ច

១១ វោដ្ឋវនកិច្ច ១២ ជវនកិច្ច

១៣ តទាលម្ពណកិច្ច . ១៤ ចុតិកិច្ច

រួម ១៤កិច្ច ។

នៅមានស្ថាន ១០ស្ថានទៀត គឺ :

| | | | |
|---|---|---|---|
| ១ | បដិសន្ធិស្ថាន | ២ | ភវង្គស្ថាន |
| ៣ | អាវជ្ជនស្ថាន | ៤ | បញ្ចវិញ្ញាណស្ថាន |
| ៥ | សម្បដិច្ឆន្នស្ថាន | ៦ | សន្តីរណស្ថាន |
| ៧ | វោដ្ឋវនស្ថាន | ៨ | ជវនស្ថាន |
| ៩ | តទាលម្ពណស្ថាន | ១០ | ចុតិស្ថាន |

រួម ១០ស្ថាន

## សំដែងបាលី (ត)

តត្ថ ទ្វេ ឧបេក្ខាសហគតសន្តីរណានិ ចេវ អដ្ឋ មហាវិបាកានិ ច នវ រូបារូបវិបាកានិ ចេតិ ឯកូនវីសតិ ចិត្តានិ បដិសន្ធិភវង្គចុតិ កិច្ចានិ នាម ។ អាវជ្ជនកិច្ចានិ បន ទ្វេ តថា

ទស្សនសវនឃាយនសាយនផុស្សនសម្បដិច្ឆន-
កិច្ចានិ ច ។

តីណិ សន្តីរណកិច្ចានិ ។ មនោទ្វារាវជ្ជន-
មេវ បញ្ចទ្វារេ វោដ្ឋព្វនកិច្ចំ សាធេតិ ។

អាវជ្ជនទ្វយវជ្ជិតានិ កុសលាកុសលផល-
កិរិយា ចិត្តានិ បញ្ចបញ្ញាស ជវនកិច្ចានិ ។

អដ្ឋ មហាវិបាកានិ ចេវ សន្តីរណត្តយ-
ញ្ចេតិ ឯកាទស តទាលម្ពណកិច្ចានិ ។

តេសុ បន ទ្វេ ឧបេក្ខាសហគត-
សន្តីរណចិត្តានិ បដិសន្ធិ ភវង្គចុតិតទាលម្ព-
ណសន្តីរណវសេន បញ្ច កិច្ចានិ នាម ។

- មហគ្គត វិបាកានិ នវ បដិសន្ធិភវង្គ
ចុតិវសេន តិកិច្ចានិ នាម ។ សោមនស្ស
សហគតសន្តីរណំ សន្តីរណតទាលម្ពណវសេន
ទុកិច្ចំ ។ តថា វោដ្ឋព្វនំ វោដ្ឋព្វនាវជ្ជវសេន

**សេសានិ បន សព្វានិ បិ ជវន-**
**មនោធាតុត្តិកទ្វិបញ្ចវិញ្ញាណានិ យថា**
**សម្ភវមេកកិច្ចានីតិ ។**

ចិត្តជាឧបេក្ខាសន្តីរណ ២ដួង មហាវិបាកចិត្ត ៨ដួង និង មហគ្គតវិបាកចិត្ត ៩ដួង រួម ១៩ដួងនោះមាន បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ចបានឬ ទើបបានឈ្មោះថាជាចិត្តដែលមានកិច្ច បដិសន្ធិ ភវង្គ និង ចុតិ ។

អាវជ្ជនចិត្ត ២ដួង មានជវនកិច្ច ២ ដូចនេះ ចិត្តដែលមានទស្សនកិច្ច ២ សវនកិច្ច ២ ឃាយនកិច្ច ២ សាយនកិច្ច ២ ផុស្សកិច្ច ២ ចិត្តដែលមានសម្បដិច្ឆន្នកិច្ច ២ ចិត្តដែលមានសន្តីរណកិច្ច ៣ មនោទ្វារាវជ្ជនចិត្តនោះ ធ្វើឱ្យវោដ្ឋវនកិច្ចក្នុងបញ្ចទ្វារ ។ វៀរលែង អាវជ្ជនទាំងពីរហើយ កុសលចិត្ត អកុសលចិត្ត ដល់កិរិយាចិត្តទាំងអស់ រួម ៥៥ដួងនេះហៅថា ចិត្តដែលមានឈ្មោះថា ជវនកិច្ច ។ មហាវិបាកចិត្ត ៨ដួង សន្តីរណចិត្ត ៣ដួង រួម ១១ដួងនេះ

រមែងមានតទាលម្ពណកិច្ច ក្នុងចិត្ត ១១ដួងនេះ ឧបេក្ខាសន្តីរណចិត្ត ២ ដួងរមែងមាន៥កិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ តទាលម្ពណ និង សន្តីរណ ។

មហាវិបាកចិត្ត ៨ ដួងនេះរមែងមាន ៤កិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ និង តទាលម្ពណ ។

មហគ្គតវិបាកចិត្ត ៩ដួង រមែងមាន ៣ កិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ ។

សោមនស្សសន្តីរណចិត្ត រមែងមាន ២កិច្ច គឺ សន្តីរណ និង តទាលម្ពណ ដូចនេះឯង ។

វោដ្ឋវនចិត្ត ក៏រមែងមានកិច្ច ២ គឺ វោដ្ឋវនកិច្ច និង អាវជ្ជនកិច្ច ។

ចិត្តដែលសល់ជវន ៥៥ដួង មនោធាតុ ៣ ទ្វិបញ្ច-វិញ្ញាណ ១០ ទាំងអស់នេះរមែងមានកិច្ចជាមួយគ្នា ។

# អធិប្បាយកិច្ច ១៤

ពាក្យថាកិច្ច បានដល់ការធ្វើរបស់ចិត្ត និង ចេតសិករូម ទាំងពីរ ការធ្វើរបស់ចិត្ត ចេតសិកនេះ មានកិច្ច ១៤ជាមួយគ្នាគឺ ១-បដិសន្ធិកិច្ច ២ -ភវង្គកិច្ច

៣- អាវជ្ជន ៤- ទស្សនកិច្ច ៥-សវនកិច្ច

៦- ឃាយនកិច្ច ៧-សាយនកិច្ច ៨-ផុស្សនកិច្ច

៩- សម្បដិច្ឆន្នកិច្ច ១០- សន្តីរណកិច្ច

១១-វោដ្ឋវនកិច្ច ១២- ជវនកិច្ច

១៣-តទាលម្ពណកិច្ច ១៤- ចុតិកិច្ច ។

ចិត្តដែលធ្វើឱ្យបន្តជាតិថ្មី១ ហៅថាបដិសន្ធិកិច្ច ចិត្តដែលធ្វើឱ្យចេញចាក ១ដួង ចំពោះចិត្ត ១ដួង ហៅថាភវង្គកិច្ច /ចិត្តដែលធ្វើឱ្យតាំងនៅក្នុងអារម្មណ៍ ហៅថាទស្សនកិច្ច ចិត្តដែលធ្វើឱ្យបានឮ ហៅថាសវនកិច្ច ចិត្តធ្វើឱ្យបានក្លិន ហៅថាឃាយនកិច្ច ចិត្តដែលធ្វើឱ្យភ្លក់រសជាតិ ហៅថាសាយនកិច្ច ចិត្តដែលធ្វើឱ្យទទួលសម្ផស្ស ហៅថា

ផុស្សនកិច្ច ចិត្តដែលទទួលអារម្មណ៍ជូនបន្តទៅ ហៅថា សម្បដិច្ឆន្នកិច្ច កាលដែលសម្បដិច្ឆន្នកិច្ច ចិត្តដែលទទួលកាត់សេចក្តីហៅថា វោដ្ឋវនកិច្ច សេចក្តីលឿនរហ័ស របស់ចិត្តហៅថា ជវនកិច្ច ចិត្តដែលទទួលបន្តអារម្មណ៍ ដែលជវនបណ្តោយមកហើយហៅថា តទាលម្ពណកិច្ច ចិត្ត ១ដួងចុងក្រោយ ដែលរលត់រអិលឃ្លាតចាកទី គឺ ភព ហៅថា ចុតិកិច្ច ។

ពាក្យថាស្ថាន មានន័យថាទីកន្លែង ដែលចិត្ត និងចេតសិកធ្វើកិច្ច បានដល់ស្ថាន ១០ស្ថាន គឺ :

| | |
|---|---|
| ១- បដិសន្ធិស្ថាន | ២- ភវង្គស្ថាន |
| ៣- អវជ្ជនស្ថាន | ៤- បញ្ចវិញ្ញាណស្ថាន |
| ៥- សម្បដិច្ឆន្នស្ថាន | ៦- សន្តីរណស្ថាន |
| ៧- វោដ្ឋវនស្ថាន | ៨- ជវនស្ថាន |
| ៩- តទាលម្ពណស្ថាន | ១០- ចុតិស្ថាន ។ |

រួមមានស្ថាន ១០ ស្ថាន ។

ក្នុងទីនេះ ចិត្ត ១៩ដួង គឺ ឧបេក្ខាសន្តីរណៈ ២ដួង មហាវិបាក ៨ដួង មហគ្គតវិបាក ៩ដួង រួម ១៩ដួងនេះមាននាទីធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ព្រោះហេតុដូច្នេះ ចិត្ត ១៩ដួងនេះ ហៅថា បដិសន្ធិចិត្ត ឬ ភវង្គចិត្ត ឬ ចុតិចិត្ត ក៏បាន ។

បញ្ចទ្វារាវជ្ជន និង មនោទ្វារាវជ្ជន រួម ២ ដួងនេះ ហៅថា អាវជ្ជន ដូចនេះជាដើម ។

កុសលវិបាកចិត្ត អកុសលវិបាកចិត្ត ចក្ខុវិញ្ញាណ ២ ដួង រមែងមានទស្សនកិច្ច ។

សោតវិញ្ញាណ ២ដួង រមែងមានសវនកិច្ច

ឃានវិញ្ញាណ ២ដួង រមែងមានឃាយនកិច្ច ។

ជិវ្ហាវិញ្ញាណ ២ដួង រមែងមានសាយនកិច្ច ។

កាយវិញ្ញាណ ២ដួង រមែងមានផុស្សនកិច្ច ។

សម្បដិច្ឆន្ន ២ដួង រមែងមានសម្បដិច្ឆន្នកិច្ច ។

សន្តីរណេ ៣ដួង រមែងមានសន្តីរណកិច្ច ។

និងមនោទ្វារាវជ្ជន ១ដួងនោះ ឯង ធ្វើឱ្យសំរេចវោដ្ឋវនកិច្ច ក្នុងទ្វារទាំង ៥ ជានិច្ច

កុសលចិត្ត ២១ អកុសលចិត្ត ១២ដួង កិរិយាចិត្ត ១៨ដួង ( វៀរ អាវជ្ជន ២ ) និង លោកុត្តរវិបាកចិត្ត ៤ ដួង រួម ៥៥ដួង រមែងមាជវនកិច្ច ។

ឧបេក្ខាសន្តីរណចិត្ត ២ដួង ហៅថាចិត្តដែលមានកិច្ច ៥គឺ បដិសន្ធិ ភវង្គ ចុតិ សន្តីរណ និង តទាលម្ពណ ។

មហាវិបាកចិត្ត ៨ដួង ដែលមានកិច្ច ៤ គឺ បដិសន្ធិ ភវង្គ ចុតិ តទាលម្ពណ ។

មហគ្គតវិបាកចិត្ត ៩ ដួង ជាចិត្តដែលមាន កិច្ច៣គឺ **បដិសន្ធិ ភវង្គ ចុតិ** ។

សោមនស្សសន្តីរណចិត្ត ១ដួង ជាចិត្តដែលមាន កិច្ច ២ គឺ **សន្តីរណកិច្ច តទាលម្ពណកិច្ច** ។

វោដ្ឋវន ក៏ដូចគ្នា ជាចិត្តដែលមានកិច្ចពីរ គឺ **វោដ្ឋវនកិច្ច អាវជ្ជនកិច្ច** ។

ចិត្តដែលសល់អំពី ពោលមកហើយនេះ ជវន ៥៥ មនោធាតុ ៣ និង ទ្វិបញ្ចវិញ្ញាណ ១០ដួង ទាំងអស់នេះហៅថា ចិត្តដែលមានកិច្ចតែ១៧ប៉ុណ្ណោះ ។

## គាថាសង្គហ

បដិសន្ធាទយោ នាម កិច្ចភេទេន ចុទ្ទ~សធា ឋានភេទេន ចិត្តុប្បាទា បកាសិតា ។

អដ្ឋសដ្ឋី តថា ទ្វេ ច នវាដ្ឋ ទ្វេ យថាក្កមំ ឯកទ្វិតិចតុប្បញ្ច កិច្ចឋានានិ និទ្ទិសេ ។

ប្រែ បដិសន្ធិចិត្ត ជាដើម អម្បាលនេះ ថាដោយកិច្ចនោះមានចំនួន ១៤ដួង ថាដោយស្ថាននោះ រមែងសំដែងថាមានចំនួន ១០ស្ថាន ។

ចិត្តដែលមានកិច្ច ១ និង ស្ថាន ១ ចិត្តដែលមានកិច្ច ២ និង ស្ថាន ២ ចិត្តដែលមានកិច្ច ៣ និង ស្ថាន ៣ ចិត្តដែលមានកិច្ច ៤ និង ស្ថាន ៤ ចិត្តដែលមានកិច្ច ៥ និង

ស្ថាន ៥ ទាំងអស់នេះ សំដែងលំដាប់ ៦៨ដួង ២ដួង ៩ដួង ៨ដួង និង ២ដួង ដូចនេះ ។

# ពាក្យសួរឆ្លើយក្នុងកិច្ចសង្គហ

**សួរ** ពាក្យថាកិច្ចមានន័យយ៉ាងណា ?

**ឆ្លើយ** ពាក្យថាកិច្ច តាមវិគ្គហថា : ករណំ កិច្ចំ

**ប្រែ** ការធ្វើរបស់ចិត្ត ចេតសិក ហៅថាកិច្ច បានដល់ការធ្វើរបស់ចិត្ត និង ចេតសិក ១៤កិច្ច បានន័យថាចិត្ត និង ចេតសិកក៏បាននាទីធ្វើការនៅរហូតសព្វកាល ។

**សួរ** ពាក្យថាស្ថាន មានន័យថាយ៉ាងណា ?

**ឆ្លើយ** ពាក្យថាស្ថាន តាមវិគ្គហថា :

**តិដ្ឋតិ បវត្តតិ ចិត្តំ ឯត្ថាតិ ឋានំ**

ទីកន្លែងដែលចិត្ត និង ចេតសិក ធ្វើការ ហៅថាស្ថាន មាន ១០ស្ថាន បានន័យថា ការដែលធ្វើការរបស់ ចិត្ត និង ចេតសិកទាំងពីរហៅថាស្ថាន ។

**សួរ** ក្នុង អហេតុកចិត្តនោះ មានសន្តីរណៈដល់ ៣ដួង ដូចម្តេច ក្នុងបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ទើបបានដល់ សន្តីរណកិច្ច ២ ដួងប៉ុណ្ណោះ ?

**ឆ្លើយ** ក្នុងការដែលលោកសំដែង ឧបេក្ខាសន្តីរណ ២ដួង ថាមានកិច្ច ៣ ព្រោះឧបេក្ខាសន្តីរណ ២ដួងនេះជាចិត្តដែល បដិសន្ធិពិតប្រាកដ គឺ អកុសលវិបាកសន្តីរណ ជាបដិសន្ធិចិត្ត ក្នុងទុគ្គតិភូមិបាន និង កុសលវិបាកចិត្តសន្តីរណ ជាបដិសន្ធិ ចិត្តក្នុងកាមសុគតភូមិ ១ដួងទៀត ដូច្នេះ ទើបលោកសំ- ដែងតែ ២ដួងប៉ុណ្ណោះ ។

ចំណែកសោមនស្សសន្តីរណនោះគ្មានបដិសន្ធិចិត្តទេ

**សួរ** ពាក្យថាកិច្ច និង ស្ថាន ផ្សេងគ្នាយ៉ាណា ?

**ឆ្លើយ** ពាក្យថាកិច្ច និង ស្ថានផ្សេងគ្នាគឺ ពាក្យថា កិច្ចមាន ន័យថា ការធ្វើ ។

ពាក្យថាស្ថាន មានន័យថា ទីកន្លែងដែលធ្វើការ ឧទាហរណ៍ទីកន្លែងដែលធ្វើការមួយកន្លែង ការងារដែល

ធ្វើនោះមួយចំណែក ហើយអ្នកដែលធ្វើការនោះក៏មួយចំណែក មានឧបមាយ៉ាងណាក្នុងកិច្ច និងស្ថាន ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។

ចិត្ត ដែលធ្វើជាតួនាទី ក៏មួយយ៉ាង ហើយចិត្តដែលធ្វើការក៏មួយយ៉ាងទៀតដោយឡែក ក្នុងរវាងចិត្ត ៣ ដួង ដួងកណ្តាលជាឈ្មោះរបស់ស្ថាន ។

**សួរ** ក្នុងបរិច្ឆេទទី ១ ពី ចិត្តបរិច្ឆេទ ឈ្មោះថា វោដ្ឋព្វនបានទេ ក្នុងបរិច្ឆេទទី ៣ ពាក្យថាវោដ្ឋព្វន (វោដ្ឋវន) មានន័យថាយ៉ាងណា ? ហើយជាចិត្តអ្វី ?

**ឆ្លើយ** ពាក្យថា វោដ្ឋវន បានដល់មនោទ្វារាវជ្ជនចិត្ត ចិត្តដួងនេះមានសេចក្តីអាចដែលនិងកាត់សេចក្តីជា ឥដ្ឋារម្មណ៍ និង អនិដ្ឋារម្មណ៍បាន តាមវិគ្គហថា : វវត្ថាបីយ តេតិ វោដ្ឋវនំ ប្រែថា មានសេចក្តីអង់អាចដែលនឹងញែកបំបែកអារម្មណ៍បាន ត្រូវហៅថា វោដ្ឋវន គឺជាមនោទ្វារាវជ្ជនចិត្តនោះឯង ។

**សួរ** ចិត្តជាវោដ្ឋវន មានកិច្ចពីរយ៉ាងគឺ វោដ្ឋវនកិច្ច និង អាវជ្ជនកិច្ចនោះ អធិប្បាយយ៉ាងណា ?

**ឆ្លើយ** វោដ្ឋវនចិត្ត មានកិច្ចពីរយ៉ាងនោះ អធិប្បាយថា កាលអារម្មណ៍ប៉ះទង្គិចទ្វារទាំង ៥នោះ ក៏មានសេចក្ដីអង់អាចដែលនិងអាចពិចារណាបាន ហើយកាលធម្មារម្មណ៍ប៉ះទង្គិចនូវមនោទ្វារនោះ អាចនិង កាត់សេចក្ដីថា ជាឥដ្ឋារម្មណ៍ ឬ អនិដ្ឋារម្មណ៍ បាន ដូច្នេះមនោទ្វាររមែងជាតួនាទីបាន ។

**សួរ** ចិត្តដែលជាតួនាទីតែមួយ មានប៉ុន្មាន ?

**ឆ្លើយ** ចិត្តដែលជាតួនាទីតែមួយ មាន ៦៨ដួង គឺ :

| | |
|---|---|
| ចិត្តជាមនោធាតុ ៣ដួង | ចិត្តជាទ្វិបញ្ចវិញ្ញាណ១០ដួង |
| ចិត្តជាជវន ៥៥ដួង | រួម ៦៨ដួង ។ |

**សួរ** ចិត្តដែលជាតួនាទី ២-៣-៤-៥ មានប៉ុន្មាន សុំឱ្យសំដែងសរុបផង ។

**ឆ្លើយ** ចិត្តដែលជាតួនាទី ២ នោះមានពីរគឺ វោដ្ឋវនចិត្ត និង

សោមនស្សចិត្ត សន្តីរណ ។ ចិត្តដែលជាតួនាទី ៣ មានប្រាំបួនគឺ មហគ្គតវិបាកចិត្ត ៩ដួង ។ ចិត្តដែលជាតួនាទី ៤ មានប្រាំបីគឺ មហាវិបាកចិត្ត ៨ដួង ។ ចិត្តដែលជាតួនាទី ៥ មានពីរ គឺ ឧបេក្ខាសន្តីរណ ២ដួង ។

**សួរ** ចិត្តដែលមានកិច្ច យ៉ាងនេះ បើប្រកបនិងស្ថានរបស់ចិត្តហើយ និងមានស្ថានប៉ុន្មាន ?

**ឆ្លើយ** ចិត្តដែលមានកិច្ច និង ចេតសិកធ្វើតាមតួនាទីនោះ លោកអធិប្បាយថាមាន ២៥ស្ថាន គឺ :

| | | |
|---|---|---|
| ១- | ស្ថានរបស់បដិសន្ធិ | ១ស្ថាន |
| ២- | ស្ថានរបស់ភវង្គ | ៦ស្ថាន |
| ៣- | ស្ថានរបស់អាវជ្ជន | ២ស្ថាន |
| ៤- | ស្ថានរបស់បញ្ចវិញ្ញាណ | ១ស្ថាន |
| ៥- | ស្ថានរបស់សម្បដិច្ឆន្ន | ១ស្ថាន |
| ៦- | ស្ថានរបស់សន្តីរណ | ១ស្ថាន |
| ៧- | ស្ថានរបស់តទាលម្ពណៈ | ២ស្ថាន |

៨- ស្ថានរបស់ជវន ៦ស្ថាន

៩- ស្ថានរបស់វោដ្ឋវន ២ស្ថាន

១០- ស្ថានរបស់ចុតិ ៣ស្ថាន

រួមទាំងអស់ ២៥ស្ថាន ។

I - ក្នុងរវាងចុតិ និងភវង្គ ហៅថា ស្ថានរបស់ចិត្តជាបដិសន្ធិ ។

II- ក្នុងរវាងបដិសន្ធិ និង អាវជ្ជន ១

- ក្នុងរវាងតទាលម្ពណ និង អាវជ្ជន ១

- ក្នុងរវាង ជវន និង អាវជ្ជន ១

- ក្នុងរវាងវោដ្ឋវន និង អាវជ្ជន ១

- ក្នុងរវាងតទាលម្ពណ និង ចុតិ ១

- ក្នុងរវាងជវន និង ចុតិ ១

រួម ៦ស្ថាន ហៅថាស្ថានរបស់ចិត្ត ជាភវង្គ ។

III - ក្នុងរវាង ភវង្គ និង បញ្ចវិញ្ញាណ ១

- ក្នុងរវាង ភវង្គ និង ជវន ១

រួមស្ថាននេះហៅថា ស្ថានរបស់ចិត្តជាអាវជ្ជន ៤ ។

IV - ក្នុងរវាងអាវជ្ជន និង សម្បដិច្ឆន្ន ហៅថា ស្ថានរបស់ចិត្តជាទ្វិបញ្ចវិញ្ញាណ ៥ ។

V - ក្នុងរវាងបញ្ចវិញ្ញាណ និង សន្តីរណស្ថានរបស់សម្បដិច្ឆន្ន ។

VI - ក្នុងរវាង សម្បដិច្ឆន្ន និង វោដ្ឋព្វន ហៅថាស្ថានរបស់ចិត្តជាសន្តីរណៈ ។

VII - ក្នុងរវាង សន្តីរណ និង ជវន ១

- ក្នុងរវាងសន្តីរណ និង ភវង្គ ១

រួម ២ ស្ថាននេះហៅថាស្ថានរបស់ចិត្តជាវោដ្ឋព្វន ។

VIII - ក្នុងរវាងវោដ្ឋវន និង តទាលម្ពណ ១

- ក្នុងរវាងអាវជ្ជន និង ភវង្គ ១

- ក្នុងរវាងអាវជ្ជនៈ និង ចុតិ ១

- ក្នុងរវាង មនោទ្វារាវជ្ជនៈ និង តទាលម្ពណ១

- ក្នុងរវាង មនោទ្វារាវជ្ជនៈ និង ភវង្គ ១

- ក្នុងរវាង មនោទ្វារាវជ្ជនៈ និង ចុតិ ១

រួម ៦ ស្ថាននេះ ហៅថាជាស្ថានរបស់ចិត្តជាជវន ។

IX - ក្នុងរវាងជវន និង ភវង្គ ១

- ក្នុងរវាងជវន និង ចុតិ ១

រួម២ស្ថាននេះហៅថាស្ថានរបស់ចិត្ត ជាតទាលម្ពណ

X - ក្នុងរវាង ជវន និង បដិសន្ធិ ១

- ក្នុងរវាង តទាលម្ពណ និង បដិសន្ធិ ១

- ក្នុងរវាង ភវង្គ និង បដិសន្ធិ ១

រួម៣ស្ថាននេះ ហៅថា ស្ថានរបស់ចិត្តជាចុតិ រួម ២៥ស្ថាន ។

**សួរ** កាលចិត្តជាបរមត្ថ មានកិច្ច និង ស្ថានយ៉ាងនេះ តើកិច្ច និងស្ថានរបស់ចេតសិកមានឬទេ ?

**ឆ្លើយ** -កិច្ចរបស់ចេតសិក ក៏មានដូចគ្នា គឺ ចេតសិកជាអកុសល ១៤ដួង វិរតិទាំង ៣ រួម ១៧ដួង មានជវនកិច្ច

- ជវនកិច្ច អប្បមញ្ញា ចេតសិកទាំង២ដួងមាន

៤កិច្ច គឺ ជវន បដិសន្ធិ ភវង្គ ចុតិ រួម ៤ កិច្ច ។

- សោភណ សាធារណចេតសិក ១៩ដួង បញ្ញា១ដួង ឆន្ទ១ដួង រួម ២១ដួង មាន ៥ កិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ ជវន តទាលម្ពណ រួម ៥ កិច្ច ។

- បីតិ ចេតសិក ១ដួង មាន ៦កិច្ចគឺ បដិសន្ធិ ភវង្គ ចុតិ សន្តីរណ ជវន តទាលម្ពណ រួម ៦ កិច្ច ។

- វីរិយ ចេតសិក ១ដួង មាន ៧ កិច្ចគឺ បដិសន្ធិ ភវង្គ ចុតិ អាវជ្ជន វោដ្ឋព្វន ជវន តទាលម្ពណ រួម ៧ កិច្ច ។

- វិតក្ក វិចារ អធិមោក្ខ ចេតសិក ៣ ដួងនេះមាន ៩កិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ អាវជ្ជន សម្បដិច្ឆន្ន សន្តីរណ វោដ្ឋព្វន ជវន តទាលម្ពណរួម ៩កិច្ច ។

- សព្វចិត្តសាធារណចេតសិក ៧ ដួង មាន ១៤កិច្ច មានន័យថាមានតួនាទីទាំងអស់ ។

# សំដែងទ្វារសង្គហតាមបាលី

**ទ្វារសង្គហេ ទ្វារានិ នាម ចក្ខុទ្វារំ សោតទ្វារំ ឃានទ្វារំ ជិវ្ហាទ្វារំ កាយទ្វារំ មនោទ្វារញ្ចេតិ ឆព្វិធានិ ភវន្តិ ។**

**តត្ថ ចក្ខុមេវ ចក្ខុទ្វារំ ។ តថា សោតាទយោ សោតទ្វារាទីនិ មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ**

**ប្រែ** ក្នុងទ្វារសង្គហនេះ នៅមានទ្វារ ៦ គឺ :

១- ចក្ខុទ្វារ ២- សោតទ្វារ ៣- ឃានទ្វារ

៤- ជិវ្ហាទ្វារ ៥- កាយទ្វារ ៦- មនោទ្វារ

រួមទ្វារមាន ៦ ទ្វារ ។

ក្នុងទីនេះចក្ខុទ្វារបសាទរូប ហៅថា ចក្ខុទ្វារ និង សោតបសាទរូប ហៅថា សោតទ្វារ ដូចនេះជាដើម ។

ចំណែកមនោទ្វារនោះគឺ ភវង្គុប្បច្ឆេទ ១៩ដួង ហៅថាមនោទ្វារ ។

**សំដែងបាលីតទៅ :**

តត្ថ បញ្ចទ្វារាវជ្ជនចក្ខុវិញ្ញាណសម្បដិច្ឆន្ន-
សន្តីរណវោដ្ឋវនកាមាវចរជវន
តទាលម្ពណវសេន ឆចត្តាឡីស ចិត្តានិ
ចក្ខុទ្វារេ យថារហំ ឧប្បជ្ជន្តិ ។ តថា
បញ្ចទ្វារាវជ្ជនសោតវិញ្ញាណាទិវសេន
សោតទ្វារាទីសុ បិ ឆចត្តាឡីសេវ ភវន្តីតិ ។
សព្វថាបិ បញ្ចទ្វារេ ចតុប្បញ្ញាស ចិត្តានិ
កាមាវចរានេវ ។

មនោទ្វារេ បន មនោទ្វារាវជ្ជន-
បញ្ចបញ្ញាស ជវនតទាលម្ពណវសេន សត្ត-
សដ្ឋី ចិត្តានិ ភវន្តិ ។

ឯកូនវីសតិ បដិសន្ធិ ភវង្គចុតិវសេន
ទ្វារវិមុត្តានិ ។

តេសុ បន ទ្វិបញ្ចវិញ្ញាណានិ ចេវ

មហគ្គតលោកុត្តរជវនានិ ចេតិ ឆត្តឹស យថារហមេកទ្វារិកចិត្តានិ នាម ។

មនោធាតុត្តិកំ បន បញ្ចទ្វារិកំ ។

សុខសន្តីរណវោដ្ឋវនកាមាវចរជវនានិ ឆទ្វារិកចិត្តានិ ។

ឧបេក្ខាសហគតសន្តីរណមហាវិបាកានិ ឆទ្វារិកានិ ចេវ ទ្វារវិមុត្តានិ ច មហគ្គតវិបាកានិ ទ្វារវិមុត្តានេវ ។

ក្នុងទីនេះ បញ្ចទ្វារាវជ្ជនចិត្ត ចក្ខុវិញ្ញាណចិត្ត សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត វោដ្ឋវនចិត្ត កាមាវចរជវនចិត្ត តទាលម្ពណចិត្ត រួមចិត្ត ៤៦ដួងនេះរមែងកើតក្នុងចក្ខុទ្វារ និងបញ្ចទ្វារាជ្ជន ។

សោតវិញ្ញាណ ជាដើម គឺ រួមចំនួនចិត្តទាំង ៤៦ ដួង នោះរមែងកើតក្នុងសោតទ្វារ ។

2; 325-326

Page 325 missing

Page 326 missing

៥- កាយទ្វារ បានដល់ ទ្វាររាងកាយ

៦- មនោទ្វារ បានដល់ ទ្វារចិត្ត

រួមទ្វារទាំង ៦ ហៅថា ទ្វារទាំង ៦ ក្នុងបាលីអភិធម្មត្ថសង្គហ អធិប្បាយថា :

១- ចក្ខុបសាទ ហៅថា ចក្ខុទ្វារ

២- សោតបសាទ ហៅថា សោតទ្វារ

៣- ឃានបសាទ ហៅថា ឃានទ្វារ

៤- ជិវ្ហាបសាទ ហៅថា ជិវ្ហាទ្វារ

៥- កាយបសាទ ហៅថា កាយទ្វារ

៦- ភវង្គ ហៅថា មនោទ្វារ

រួមសរុប បសាទរូប និង មនោ ហៅថាទ្វារទាំង ៦ តែសេចក្ដីបំណងនោះជាមួយគ្នា ។

ចិត្តដែលកើតក្នុង ចក្ខុទ្វារមាន ៤៦ដួងគឺ ចក្ខុទ្វារាវជ្ជនៈ ១ដួង ចក្ខុវិញ្ញាណ ២ ដួង សម្បដិច្ឆន្ន ២ដួង សន្តីរណ ៣ដួង វោដ្ឋវន ១ដួង កាមាវចរជវនចិត្ត ២៩ដួង

តទាលម្ពណ (មហាវិបាកចិត្ត ៨ដួង) រួម ៤៦ដួងនេះ រមែង កើតក្នុងចក្ខុទ្វារ ។

ក្នុងសោតទ្វារក៏មាន សោតទ្វារាវជ្ជន ១ដួង សោតវិញ្ញាណ ២ដួង សម្បដិច្ឆន្ន ២ដួង សន្តីរណ ៣ដួង វោដ្ឋវន ១ដួង កាមាវចរជវនចិត្ត ២៩ដួង តទាលម្ពណ (មហាវិបាក ៨ដួង) រួម ៤៦ប្រហែលគ្នា ។

ក្នុងឃានទ្វារ ជីវ្ហាទ្វារ កាយទ្វារក៏មានចំនួនដូច - គ្នាផ្លាស់តែ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ ប៉ុណ្ណោះមានចិត្តចំនួន ៤៦ដួង ប្រហែលគ្នា ។

- ក្នុងមនោទ្វារនោះ រមែងកើតបានចិត្ត ៦៧ដួង គឺ មនោទ្វារាវជ្ជន ១ដួង ជវនចិត្ត ៥៥ដួង តទាលម្ពណចិត្ត ១១ដួង រួម ៦៧ដួង ។

- បដិសន្ធិចិត្ត ១៩ដួង ដែលមានកិច្ចបដិសន្ធិ ភវង្គ ចុតិ នោះជាទ្វារវិមុត្តិ គឺ ផុតអំពីទ្វារទាំង ៦ ។

- ចិត្តដែលកើតក្នុងទ្វារទាំង ៦ នេះមាន៥ប្រការគឺ

១- ឯកទ្វារិក ២- បញ្ចទ្វារិក

៣-ឆទ្វារិក ៤- ជូនកាលក៏ជាឆទ្វា-

រិក ជូនកាលទៀតក៏ផុតចាកទ្វារ

៥- ផុតចាកទ្វារ រួម ៥ប្រការ ។

- បញ្ចវិញ្ញាណចិត្ត ១០ដួង មហគ្គតចិត្ត លោកុត្តរចិត្ត ជវន ចិត្ត ២៦ ដួង រួម ៣៦ ដួងនេះ ហៅថា ឯកទ្វារិកចិត្តមានន័យថា ចំនួនចិត្ត ដែលកើតក្នុងទ្វារ តែ១ដួងប៉ុណ្ណោះ ។ ( ទ្វិ . ១០ + មហ.កុ.កិ.១៨ លោកុ.៨ =៣៦ )

- មនោធាតុទាំង ៣ ហៅថាបញ្ចទ្វារិកចិត្ត ឬចិត្តដែលកើតក្នុងទ្វារទាំង ៥ ។

- សោមនស្ស សន្តីរណចិត្ត ១ដួង វោដ្ឋវនចិត្ត ១ដួង កាមាវចរចិត្ត ជវនចិត្ត ២៩ដួង រួម ៣១ដួងនេះ ហៅថាឆទ្វារិក ឬ ចំនួនចិត្ត ដែលកើតក្នុងទ្វារទាំង ៦ ។

-ឧបេក្ខាសន្តីរណចិត្ត ២ដួង មហាវិបាកចិត្ត ៨ ដួង រួម ១០ដួងនេះហៅថា " ជូនកាលកើតក្នុងទ្វារ ជូនកាល

កើតក្រៅទ្វារ" ។

- មហគ្គតវិបាកចិត្ត ៩ ដួងនេះហៅថា ទ្វារវិមុត្តិ មានន័យថា មិនបានកើតក្នុងទ្វារទាំង ៦ សូម្បីតែ ១ដួង ក៏មិនមានឡើយ ។

## គាថាសង្គហ

ឯកទ្វារិកចិត្តានិ បញ្ចឆទ្វារិកានិ ច
ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា ។
ឆត្តឹសតិ តថា តីណិ ឯកត្តឹស យថាក្កមំ
ទសធា នវធា ចេតិ បញ្ចធា បរិទីបយេ ។

ចិត្តដែលរមែងកើតក្នុងទ្វារមាន ៥ ប្រការគឺ :

១- ឯកទ្វារិកចិត្ត

២- បញ្ចទ្វារិកចិត្ត

៣- ឆទ្វារិកចិត្ត

៤- ជួនកាលក៏ឆទ្វារិកចិត្ត ជួនកាលទ្វារវិមុត្តិនិង

៥- ទ្វារវិមុត្តិ ជានិច្ច ។

ឯកទ្វារិកចិត្ត បានដល់ចិត្ត ៣៦ដួង បញ្ចទ្វារិកចិត្ត បានដល់ចិត្ត ៣ដួង ឆទ្វារិកចិត្ត បានដល់ចិត្ត ១០ ដួង ហើយឆទ្វារិកវិមុត្តិ ប្រចាំបានដល់ចិត្ត ៩ដួង ត្រូវសំដែង ដោយ ៥ ប្រការតាមលំដាប់ ។

## សួរ-ឆ្លើយក្នុងទ្វារសង្គហ

**សួរ** ពាក្យថាទ្វារ ប្រែថាអ្វី ? ហើយមានន័យថាជាអ្វី ?

**ឆ្លើយ** ពាក្យថាទ្វារតាមវិគ្គហៈថា :

ទ្វេ ជនា អវន្តិ គច្ឆន្តិ ឯតេនាតិ ទ្វារំ ប្រែថា មាន មនុស្ស ២ នាក់ ចេញចូលផ្លូវចន្លោះនេះបាន ដូច្នេះ ហៅ ថាទ្វារ តាមវិគ្គហ អវន្តិ ញែកចេញជា ២បទ គឺ

ទុ + អវទុ

ទុ ប្រែថា ពីរ

អវទុ ប្រែថា បានដល់ចូល និង ចេញ

មានន័យថា មនុស្សចូល មនុស្សចេញ ២នាក់ចូលចេញបាន ទ្វារំ វិយាតិ ទ្វារំ ប្រែថា ដូចទ្វារ ហៅថាទ្វារ បានដល់រូប

នាមទាំងពីរ មានន័យថា រូបនាមទាំងពីរនេះ ដូចទ្វារដែលមនុស្សចូល ចេញគ្នាបានស្រួល ព្រោះហេតុដូច្នេះ រូបនាមទាំងពីរនេះ ហៅថាទ្វារ បានដល់ទ្វារទាំង ៦ ។

**សួរ** កាមាវចរចិត្ត ៥៤ដួង ដែលកើតក្នុងបសាទរូប ៥ រូបនេះ ហៅថា បញ្ចទ្វារបានឬទេ ?

**ឆ្លើយ** កាមាវចរចិត្ត ៥៤ដួង ដែលរមែងកើតក្នុងទ្វារទាំង ៥ នោះមិនមែនជាទ្វារទេ ពាក្យសួរ ទ្វារនោះបានដល់រូបទ្វារ៥ នាមទ្វារមួយរួម ៦ទ្វារប៉ុណ្ណោះ ។ ចិត្តដែលកើតក្នុងទ្វារទាំង ៦ នេះ តាមវិគ្គហថា : ទ្វារេ បវុត្តោ ទ្វារិតោ ប្រែថា ចិត្តទាំងអស់នេះ ហៅថាទ្វារិក ព្រោះអាស្រ័យនិងទ្វារទាំង ៦ ហើយទើបកើតទ្វារ គឺ ចិត្តដែលកើតក្នុង ចក្ខុ-បសាទ ហៅថាចក្ខុទ្វារិកចិត្ត ចិត្តដែលកើតក្នុងសោតបសាទក៏រមែងហៅថា សោតទ្វារិក ដោយលំដាប់របស់វត្ថុទាំង ៦

**សួរ** តាមអភិធម្មត្ថសង្គហៈ មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ ប្រែ ភវង្គហៅថា មនោទ្វារ ក្នុងទីនេះ លោកអធិប្បាយថា

ភវង្គ ១៩ ដួងប៉ុណ្ណោះ ។

កាលលោកអធិប្បាយ ដូច្នេះនេះ ធម្មតាចិត្តរមែង មាន ៨៩ដួង ឬ ១២១ដួង បើថា មនោទ្វារបានតែ ១៩ដួង ប៉ុណ្ណោះ ហើយសល់ ៧០ដួង ឬ ១០២ដួងនោះ និង ហៅ ទ្វារអ្វី ?

**ឆ្លើយ** តាមដែលលោកអដ្ឋកថាចារ្យ អធិប្បាយថា :

សព្វោ មនោ មនោទ្វារំ ប្រែថា ចិត្តទាំងអស់គឺ ៨៩ ដួង ឬ ១២១ដួង ដោយមនោទ្វារទាំងនោះ ព្រោះហេតុ ដូច្នោះ ចិត្តដែលសល់ ៧០ ឬ ១០២ ដួងនោះជាមនោទ្វារ បាន និង ចិត្ត ៧០ ឬ ១០២ ដួងដែលពោលមកនេះបាន ទាំងទ្វារ និង ទ្វារិក តែចំណែកចិត្តជាភវង្គ ១៩ដួង កើត បានតែចំពោះទ្វារ ( គ្មានជាទ្វារិកទេ ) ព្រោះហេតុដូច្នេះ ព្រះអនុរុទ្ធាចារ្យ សំដែងថា **មនោទ្វារំ បន ភវង្គន្តិ បវុច្ចតិ** ដូចនេះ ។

មានន័យថា ភវង្គចិត្ត ១៩ដួងនេះឯងជាមនោទ្វារពិត។ ។

**ស្នូរ** កាលភវង្គចិត្ត ១៩ដួង នោះជាមនោទ្វារពិត។ ដូច្នេះសំដែងតទៅថា ឯកូនវីសតិ បដិសន្ធិ ភវង្គ-**ចុតិវសេន ទ្វារវិមុត្តានេវ** ។

**ប្រែថា** ចិត្ត ១៩ដួងនេះ ជាទ្វារវិមុត្តិទៀត ?

**ឆ្លើយ** កាលដែលលោកអធិប្បាយថា ចិត្ត ១៩ដួង ជាទ្វារវិមុត្តិតាមអត្ថកថា ថា **ទ្វារេ និប្បត្តតោ វិមុត្តានិ ទ្វារវិមុត្តានិ ប្រែថា** ជាធម្មជាតិដែលផុត អំពីការកើតទ្វារដូច្នេះមានឈ្មោះថា ទ្វារវិមុត្តិ មានន័យថា ធម្មជាតិ ១៩ដួង ជាទ្វារពិត តែគ្មានជាទ្វារវិមុត្តិចិត្ត ដូចនេះ ។

**ស្នូរ** តាមដែលលោក អត្ថកថាចារ្យ ពោលថាចិត្តទាំងអស់ជាមនោទ្វារ ហើយព្រះអនុរុទ្ធាចារ្យថា ភវង្គចិត្ត ១៩ដួង ហៅថា មនោទ្វារនោះក៏ប្រពៃហើយ តែក្នុងទ្វារ

សង្គហថា ចិត្តដែលរមែងកើតក្នុងមនោទ្វារមានចំនួន ៦៧ដួងនោះ មានន័យថាដូចម្តេចទៀត ?

**ឆ្លើយ** កាលដែលលោកពោលដល់ចិត្ត ៦៧ដួងនោះ គឺ មនោទ្វារាវជ្ជនចិត្ត ១ដួង អកុសលចិត្ត ១២ដួង កុសលចិត្ត ២១ដួង កិរិយាចិត្ត ១៨ដួង ( វៀរលែង អាវជ្ជន ២ ) លោកុត្តរវិបាកចិត្ត ៤ដួង តទាលម្ពណចិត្ត ១១ដួង រួម ៦៧ ដួងនេះ រមែងកើតក្នុងមនោទ្វារ ឬ ន័យម្យ៉ាងទៀត ហៅថា មនោទ្វារិកចិត្ត សល់ចិត្ត ១០ដួងនោះគឺ ទ្វិបញ្ច-វិញ្ញាណ ១០ដួង ហៅថាឯកទ្វារិកចិត្ត

ឧបេក្ខា សន្តីរណចិត្ត ២ដួង មហាវិបាកចិត្ត ៨ដួង និងមហគ្គតវិបាកចិត្ត ៩ ដួង រួម ១៩ដួងនេះហៅថា ទ្វារវិមុត្តិ ។

បញ្ចទ្វារាវជ្ជនចិត្ត ១ដួង សម្បដិច្ឆន្នចិត្ត ២ដួង ហៅថា បញ្ចទ្វារិកចិត្ត ព្រោះហេតុដូច្នេះ ចិត្តដែលសល់២២

ដួង មានចំនួន ៦៧ ដួងនោះរមែងកើតក្នុងមនោទ្វារពិត ប្រាកដហើយលោកហៅថាមនោទ្វារិកចិត្ត ដូច្នេះឯង ។

**សួរ** ពាក្យថាទ្វារ ឬ មនោទ្វារនេះ ក្នុងគម្ពីរព្រះពុទ្ធ សាសនា ហៅប៉ុន្មានយ៉ាង ? ហើយមានប៉ុន្មាន អធិប្បាយ ផ្សេងគ្នាខ្លះបានទេ ?

**ឆ្លើយ** ពាក្យទ្វារ ឬ មនោទ្វារ តាមគម្ពីរផ្សេងៗសំដែងទុក មានច្រើនយ៉ាងគឺ  គម្ពីរខ្លះថា កាយទ្វារ វចីទ្វារ និង មនោទ្វារគម្ពីរខ្លះសំដែងថា ទ្វារទាំង ៩ ។

ពាក្យ ២ បទនេះសង្គ្រោះគ្នាបាន ដូចគ្នា ពាក្យអធិ-ប្បាយ និង សេចក្តីបំណងនោះផ្សេងគ្នាគឺ ៖ ក្នុងបកិណ្ណក-សង្គហៈ សំដែងថាមនោទ្វារបានដល់វិមុត្តិ ១៩ដួង ក្នុងវិថី-សង្គហៈសំដែងថា មនោទ្វារបានដល់លោភមូលចិត្ត ៨ ដួង និង ទោសមូលចិត្ត ២ដួង រួម ១០ដួង ។

ក្នុងព្រះមហាបដ្ឋាន អដ្ឋកថាអធិប្បាយ មនោទ្វារថា ចិត្តទាំងអស់ ហៅថាមនោទ្វារ១ក្នុងអដ្ឋកថាមជ្ឈិមបណ្ណាស

ថាមនោទ្វារ បានដល់ចេតនារបស់កុសលចិត្ត និង អកុសលចិត្ត ទាំងអស់ មាន ២៩ដួង គឺ អកុសលចិត្ត ១២ដួង មហាកុសលចិត្ត ៨ដួង និង មហគ្គតកុសលចិត្ត ៩ដួងរួមទាំង អស់២៩ដួងប៉ុណ្ណោះ ។

តែយ៉ាងណាក្តី ពាក្យថា កាយទ្វារ វចីទ្វារ និង មនោទ្វារនោះ ហៅដោយសម្ពូហន័យ ឬ ដោយសង្ខេប ។ ពាក្យថាទ្វារទាំង ៩ នេះ ហៅដោយអវយវន័យ ឬ ថា ដោយពិស្តារប៉ុណ្ណោះ ។

**សួរ** ពាក្យថាមនោធាតុទាំង ៣ ហៅថាបញ្ចទ្វារិកចិត្ត នោះមានន័យដូចម្តេច ?

**ឆ្លើយ** បញ្ចទ្វារាវជ្ជនចិត្តនេះ ហៅថាចិត្តមួយក៏ពិត ដោយអវយវរបស់ចិត្តក៏ត្រូវចាត់តាមលំដាប់នៃទ្វារទាំង ៥ គឺ : ចក្ខុទ្វារាវជ្ជន សោតទ្វារាវជ្ជន ឃានទ្វារាវជ្ជន ជិវ្ហាទ្វារាវជ្ជន និង កាយទ្វារាវជ្ជន មានន័យថា អាវជ្ជនសភាពនេះ មានគ្រប់១ដួង ហើយការពិចារណាក្នុងទ្វារទាំង ៥នេះ

ហៅរូមគ្នាថាបញ្ចទ្វារាវជ្ជន ។

ចំណែកសម្បដិច្ឆន្ន ទាំងពីរនោះ ក៏មានគ្រប់១ដួង ដូចគ្នាកាលទ្វារទាំង ៥ ប៉ះទង្គិចអារម្មណ៍ទាំង ៥ ហើយ ខាងក្រោយដែលវិញ្ញាណកើតហើយ សម្បដិច្ឆន្នក៏រមែង កើតជានិច្ចព្រោះហេតុដូច្នេះលោកសំដែងថា អាវជ្ជន និង សម្បដិច្ឆន្ន ហៅថា បញ្ចទ្វារិកចិត្តដូច្នេះ ។

**សួរ** ពាក្យថា សុខសន្តីរណក្នុងបរិច្ឆេទ ១ និង ២ មិន ឃើញមាន សូម្បីតែ ១ដួង ហើយក្នុងទ្វារសង្គហថា សុខ សន្តីរណនោះ បានដល់ចិត្តដួងណា ?

**ឆ្លើយ** ពាក្យថាសុខសន្តីរណ បានដល់សោមនស្សសន្តីរណ ១ដួងក្នុងកុសលវិបាក ៨ដួងនោះឯង ។ កាលដែលលោក ហៅសោមនស្សសន្តីរណជាសុខសន្តីរណនោះ ព្រោះសោម-នស្សសន្តីរណ ទាក់ទងមកពីសុខសហគតកាយវិញ្ញាណ សុំ កុំចូលចិត្តជ្រាបថា សុខ និង សោមនស្សជាវេទនាជាមួយ គ្នា ។ គឺកាលផោដ្ឋព្វារម្មណ៍ប៉ះទង្គិចកាយទ្វារហើយ សុខ

សហគតកាយវិញ្ញាណ រមែងកើតតាមក្រោយមក និង សម្បដិច្ឆន្នៈ និង សន្តីរណកកើតតាមលំដាប់ដោយធម្មជាតិ

ព្រោះហេតុដូច្នេះ ទើបលោកហៅថា សុខសន្តីរណ ។

**សួរ** ឧបេក្ខាសន្តីរណ ២ដួង និង មហាវិបាកចិត្ត ៨ដួង រួម ១០ដួងនេះ ជួនកាលហៅថា ឆទ្វារិក ជួនកាលក៏ហៅថាទ្វារវិមុត្តិ មានន័យថាយ៉ាងណាខ្លះ ?

**ឆ្លើយ** ឧបេក្ខាសន្តីរណចិត្ត ២ដួង និង មហាវិបាកចិត្ត ៨ ដួង រួម ១០ដួងនេះ កាលខណៈដែលធ្វើតួនាទីជាកិច្ចរបស់សន្តីរណ និង តទាលម្ពណនោះ ហៅថាឆទ្វារិកចិត្ត ការធ្វើតួនាទីជាកិច្ចរបស់បដិសន្ធិ ភវង្គចុតិកិច្ច តាមខាងដើមនោះ ហៅថាទ្វារវិមុត្តិចិត្ត មានន័យថា ចិត្ត ១០ដួងនេះ ធ្វើការបានពីរផ្នែក ហើយមានឈ្មោះពីរដូច្នេះដែរ ។

**សួរ** មហគ្គតវិបាក ៩ដួង ជាធម្មជាតិមនោទ្វារទៅហើយ ដូចម្តេចលោកអធិប្បាយថា ទ្វារវិមុត្តិ ?

**ឆ្លើយ** មហគ្គតវិបាក ៩ដួងនេះ ជាធម្មជាតិមនោទ្វារពិត មែនតែគ្មានជាទ្វារិកចិត្តទេ ។

ពាក្យថាទ្វារ និង ទ្វារិក ផ្សេងគ្នាច្រើនគឺ :

- ទ្វារនេះបានដល់រូបទ្វារ និង នាមទ្វារទាំងពីរ

-ពាក្យថាទ្វារិកចិត្តនេះ មានន័យថា ចិត្តដួងណាមួយ អាស្រ័យទ្វារទើបកើតឡើង ចិត្តនោះត្រូវហៅថាទ្វារិកចិត្ត ព្រោះហេតុដូច្នេះ ទ្វារ និង ទ្វារិក ផ្សេងគ្នាច្រើនដូច្នេះ ។

## សំដែងអារម្មណ៍សង្គហតាមបាលី

អារម្មណសង្គហេ អារម្មណានិ នាម រូបារម្មណំ សទ្ទារម្មណំ គន្ធារម្មណំ រសារម្មណំ ផោដ្ឋព្វារម្មណំ ធម្មារម្មណញ្ចេតិ ឆព្វិធានិ ភវន្តិ ។ តត្ថ រូបមេវ រូបារម្មណំ តថា

**បន្នានយោ. សន្នារម្មណាទីនិ ៦ ធម្មារម្មណំ
រន បសាទសុខុមរូបចិត្តចេតសិកនិព្វាន
រញ្ញត្តិវសេន ឆធា សង្គយ្ហតិ**

ក្នុងអារម្មណ៍សង្គហនេះ នៅមានអារម្មណ៍ ៦ គឺ
បារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍
ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ រួមមានអារម្មណ៍ ៦
ារម្មណ៍ ។

ពាក្យថា រូបារម្មណ៍ បានដល់ពណ៌ ។

ពាក្យថា សទ្ទារម្មណ៍ បានដល់សំឡេងនេះជាដើម ។

ចំណែកធម្មារម្មណ៍ បានដល់ធម៌ទាំង ៦ គឺ :

| | | |
|---|---|---|
| ១- បសាទរូប | ២- សុខុមរូប | ៣- ចិត្ត |
| ៤- ចេតសិក | ៥- និព្វាន | ៦-បញ្ញត្តិ |

រួម ៦ប្រការនេះហៅថាធម្មារម្មណ៍ ។

## សំដែងបាលី (ត)

តត្ថ ចក្ខុទ្វារិកចិត្តានំ សព្វេសម្បិ រូបមេវ អារម្មណំ តញ្ច បច្ចុប្បន្នមេវ ។ តថា សោតទ្វារិកចិត្តាទីនំបិ សទ្ទាទីនិ តានិ ច បច្ចុប្បន្នានិយេវ ។

មនោទ្វារិកចិត្តានំ បន ឆព្វិធម្បិ បច្ចុប្បន្នមតីតំ អនាគតំ កាលវិមុត្តញ្ច យថារហមាលម្ពណំ ហោតិ ។

ទ្វារវិមុត្តានញ្ច បដិសន្ធិ ភវង្គចុតិ សង្ខាតានំ ឆព្វិធម្បិយថា សម្ភវំ យេភុយ្យេន ភវន្តរេ ឆទ្វារគ្គហិតំ បច្ចុប្បន្នមតីតំ បញ្ញត្តិភូតំ

វា កម្មកម្មនិមិត្តគតិ និមិត្តសម្មតំ អារម្មណំ ហោតិ ។

តេសុ ចក្ខុវិញ្ញាណាទីនិ យថាក្កមំ រូបាទិឯកេកាលម្ពណានេវ ។ មនោធាតុត្តិកំ បន រូបាទិបញ្ចារម្មណំ ។

សេសានិ កាមាវចរវិបាកានិ ហសន-
ចិត្តញ្ចេតិ សព្វថាបិ កាមាវចរាលម្ពណានេវ ។

អកុសលានិចេវ ញាណវិប្បយុត្ត-
កាមាវចរជវនានិ ចេតិ លោកុត្តរវជ្ជិត-
សព្វាលម្ពណានិ ។

ញាណសម្បយុត្តកាមាវចរកុសលានិ ចេវ
បញ្ចមជ្ឈានសង្ខាតំ អភិញ្ញាកុសលញ្ចេតិ
អរហត្តមគ្គផលវជ្ជិតសព្វាលម្ពណានិ ។

ញាណសម្បយុត្តកាមាវចរកិរិយានិ ចេវ
កិរិយាភិញ្ញា វោដ្ឋព្វនញ្ចេតិ ( សព្វថាបិ
សព្វាលម្ពណានិ ) ។ អរូបេសុ ទុតិយចតុត្ថានិ
មហគ្គតាលម្ពណានិ សេសានិ មហគ្គតាចិត្តានិ,
សព្វានិបិ បញ្ញត្តាលម្ពណានិ លោកុត្តរចិត្តានិ
និព្វានារម្មណានីតិ ។

**ប្រែសេចក្ដីថា**

ក្នុងចក្ខុទ្វារិកចិត្ត រូបទាំងអស់នោះឯងជាអារម្មណ៍ចំពោះតែអារម្មណ៍បច្ចុប្បន្នប៉ុណ្ណោះ និង សោតទ្វារិកចិត្តមានសំឡេងជាអារម្មណ៍ហើយជាអារម្មណ៍បច្ចុប្បន្ន ។

ចំណែកអារម្មណ៍របស់ មនោទ្វារិកចិត្តនោះជាបច្ចុប្បន្នអតីតអនាគត និងកាលវិមុត្តិ តាមតែនឹងជាអារម្មណ៍បាន ។

អារម្មណ៍ទាំង ៦ របស់ទ្វារវិមុត្ត ចិត្ត ១៩ដួង រមែងមានកិច្ច គឺ បដិសន្ធិ ភវង្គ ចុតិ នេះហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តសឹងជាអតីត បច្ចុប្បន្ន បញ្ញត្តិ ។

ទ្វារទាំង ៦ ដោយច្រើន រមែងបានទទួលមកអំពីភពមុនក្នុងទីនេះ ចក្ខុវិញ្ញាណជាដើមនោះ មានអារម្មណ៍តែមួយគឺ រូបារម្មណ៍ជាដើមតាមលំដាប់ ។

មនោធាតុទាំង ៣ នោះមានអារម្មណ៍ទាំង ៥ គឺមានរូបជាដើម ។

ចិត្តជាកាមាវចរវិបាក ដែល សល់១១ដួង និង ចិត្តជាហសិតុប្បាទ ១ដួង រួម ១២ដួងនោះជាកាមារម្មណ៍ ។

អកុសលចិត្ត ១២ដួងញាណវិប្បយុត្តជវនចិត្ត ៨ ដួង រួម ២០ដួងនេះជាអារម្មណ៍បានទាំងអស់ វៀរលែងតែលោកុត្តរចេញ ។

ញាណសម្បយុត្តកុសលចិត្ត ៤ដួង និង បញ្ចមជ្ឈានអភិញ្ញាកុសលចិត្ត ១ដួង រួម ៥ដួងនេះ ជាអារម្មណ៍បានក្នុងចិត្តទាំងអស់វៀរលែង អរហត្តមគ្គ១ និង អរហត្តផល ១ ។

ញាណសម្បយុត្តកិរិយាចិត្ត ៤ដួង និង កិរិយាអភិញ្ញាកុសលចិត្ត ១ដួង ហើយនឹងចិត្តជាវោដ្ឋព្វន ១ដួង រួម ៦ដួងនេះជាអារម្មណ៍របស់ចិត្តទាំងអស់បាន ។

ក្នុងអរូបចិត្តនេះ ទុតិយចិត្ត ៣ដួង និង ចតុត្ថអរូបចិត្ត ៣ដួង រួម ៦ដួងនេះជាអារម្មណ៍មហគ្គត ។ មហគ្គត-

ចិត្ត២១ដួង ដែលសល់៦ដួងដែលពោលមកហើយនេះ ជាអារម្មណ៍បញ្ញត្តិ ។

លោកុត្តរចិត្ត ៨ដួងមានព្រះនិព្វានជាអារម្មណ៍ ។

# អធិប្បាយក្នុងអារម្មណ៍សង្គហ

**ពាក្យថា អារម្មណ៍**ជាធម្មជាតិដែលចិត្ត និង ចេតសិក ទាំងពីរទទួលហើយ ធ្វើតួនាទីរបស់ខ្លួនបាន ដូច្នេះហៅថា អារម្មណ៍បានដល់អារម្មណ៍ទាំង ៦ប្រការ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ រួម ៦អារម្មណ៍ :

- រូបារម្មណ៍ បានដល់ វណ្ណ ឬ ពណ៌
- សទ្ទារម្មណ៍ បានដល់ សំឡេង
- គន្ធារម្មណ៍ បានដល់ ក្លិន
- រសារម្មណ៍ បានដល់ រស
- ផោដ្ឋព្វារម្មណ៍ បានដល់ វត្ថុដែលមាន

**បឋវី អាបោ តេជោ** ធាតុទាំង ៣នេះដែលប៉ះពាល់

រាងកាយ ។

- ធម្មារម្មណ៍ បានដល់ធម្មជាតិប៉ះទង្គិចចិត្ត ។

រួម ៦ អារម្មណ៍ ជាមួយគ្នា ។

តាមដែលទ្វារសង្គហអធិប្បាយមកហើយថា ចក្ខុទ្វារិកចិត្តទាំងអស់គឺ ចិត្ត ៤៦ដួងនេះ ទទួលរូបារម្មណ៍បច្ចុប្បន្នបាន ។ សោតទ្វារិកចិត្ត ៤៦ ដួង ក៏ទទួលសទ្ទារម្មណ៍បច្ចុប្បន្ន ។ ឃានទ្វារិកចិត្ត ៤៦ដួង ជិវ្ហាទ្វារិកចិត្ត ៤៦ដួង កាយទ្វារិកចិត្ត ៤៦ដួង ជាទំនងដូចគ្នាដែរ គឺទទួលអារម្មណ៍បច្ចុប្បន្នជានិច្ច ។

ចំណែកមនោទ្វារិកចិត្ត ៦៧ដួងនោះទទួលអារម្មណ៍ទាំង ៦ បច្ចុប្បន្ន អតីត អនាគត់ ឬ កាលវិមុត្តារម្មណ៍ក៏បាន ។

ទ្វារវិមុត្តិចិត្ត ១៩ដួងគឺ ឧបេក្ខាសន្តីរណ ២ដួង មហាវិបាក ៨ដួង និង មហគ្គតវិបាក ៩ដួង រួម១៩ដួង

ដែលមានកិច្ច បដិសន្ធិភវង្គ ចុតិ នោះទទួលអារម្មណ៍ទាំង ៦ របស់កម្ម **កម្មនិមិត្ត គតិនិមិត្ត** ដែលជាអារម្មណ៍អតីត បច្ចុប្បន្នបញ្ញត្តិ ដែលទទួលមកពីភពមុន ( ជាតិមុន ) មុនកាលជិតនឹងចុតិចុះ ។

ទ្វិបញ្ចវិញ្ញាណ ១០ដួង គឺ ចក្ខុ សោត ឃាន ជិវ្ហា កាយវិញ្ញាណ ទាំងអស់នេះ មានអារម្មណ៍ទាំង ៥គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ តាមលំដាប់ ។

ចំណែកបញ្ចទ្វារាវជ្ជន ១ដួង និង ឧបេក្ខាសម្បដិច្ឆន្ន ២ដួង រួម៣ដួងដែលជាមនោធាតុនោះ រមែងមានអារម្មណ៍ទាំង ៥ សល់ពី ទ្វិបញ្ចវិញ្ញាណ ១០ និង សម្បដិច្ឆន្ន ២ នឹងមានកាមាវចរវិបាក ១១ដួង និង ហសិតុប្បាទ ១ដួង រួម ១២ដួងនេះមានអារម្មណ៍ កាមាវចរ ។

អកុសលចិត្ត ១២ដួង និង ញាណវិប្បយុត្តជវនចិត្ត ៨ដួង រួម ២០ដួង ជាអារម្មណ៍ សព្វារម្មណ៍ ដែលវៀរចាក

ពីចិត្តជាលោកុត្តរ មានន័យថា ចិត្ត ២០ដួងនេះ អាចមាន អារម្មណ៍ទាំងអស់បាន វៀរលែងតែលោកុត្តរ ព្រោះ អារម្មណ៍លោកុត្តរ មិនមានតួនាទីរបស់អកុសល និង ញាណវិប្បយុត្តឡើយ ។

ចិត្តជាញាណសម្បយុត្តកុសល ៤ដួង បញ្ចមជ្ឈាន អភិញ្ញាកុសល១ដួង រួម ៥ដួងនេះជា សព្វារម្មណ៍ វៀរលែង អរហត្តមគ្គ ១ អរហត្តផល ១ ។

ចិត្តជា ញាណសម្បយុត្ត ៤ដួង បញ្ចមជ្ឈាន អភិញ្ញា កិរិយា១ដួង និង មនោទ្វារាវជ្ជន ១ដួង រួម ៦ដួងជាសព្វា-រម្មណ៍បាន ដោយប្រការទាំងពួង មិនបានវៀរលែងអ្វី ឡើយ ។

ក្នុងទីនេះ អភិញ្ញា២ដួង បានដល់បញ្ចមជ្ឈាន-ចិត្តក្នុងរូបាវចរកុសលចិត្ត ១ដួង បញ្ចមជ្ឈានរូបាវចរកិរិយា ចិត្ត១ដួង រួម ២ដួងនេះ ។ វិញ្ញាណញ្ចាយតនពាដួង នេវសញ្ញានាសញ្ញាយតន ៣ដួង រួម ៦ដួងនេះជាអារម្មណ៍

មហគ្គតចិត្ត នៅសល់មហគ្គតចិត្ត ២១ដួងជាអារម្មណ៍បញ្ញត្តិ ។

លោកុត្តរចិត្ត ៨ដួង មាននិព្វានជាអារម្មណ៍ ។

## គាថាសង្គហ

**បញ្ចវីសបរិត្តម្ហិ ឆ ចិត្តានិ មហគ្គតេ ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ វិសានុត្តរមុត្តម្ហិ អគ្គមគ្គផលុជ្ឈិតេ បញ្ច សព្វត្ថ ឆច្ចេតិ សត្តធា តត្ថ សង្គហោ ។**

ក្នុងកាមារម្មណ៍ មានចិត្ត ២៥ដួង ក្នុងអារម្មណ៍មហគ្គត ឬ មហគ្គតារម្មណ៍ មានចិត្ត ៦ដួង ក្នុងអារម្មណ៍-បញ្ញត្តិ ឬ បញ្ញត្តារម្មណ៍ មានចិត្ត ២១ដួង ក្នុងអារម្មណ៍និព្វានមានចិត្ត ៨ដួង ក្នុងសព្វារម្មណ៍ដែលវៀរលែងអំពីអរហត្តមគ្គ អរហត្តផល មានចិត្ត ៥ដួង ក្នុងសព្វារម្មណ៍ដែលមិន វៀរលែងអ្វីនោះ មានចិត្ត ៦ដួង ។

ក្នុងអារម្មណ៍សង្គហ មានសង្គហន័យ ៧ន័យ ដូចដែលពោលមកហើយ ។

## ពាក្យសួរ-ឆ្លើយក្នុងអារម្មណ៍សង្គហ

**សួរ** ពាក្យថាអារម្មណ៍ និង ពាក្យថាអាលម្ពណ ទាំងពីរនេះឃើញក្នុងគម្ពីរផ្សេងៗជាច្រើន តើអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថាអារម្មណ៍ ១បទនេះតាមវិគ្គហ ថា :

**ចិត្តចេតសិកេហិ អាគន្ត្វា រមន្តិ ឯត្ថាតិ អារម្មណំ**

**ប្រែ** ចិត្តបរមត្ថ ចេតសិកបរមត្ថ ទាំងពីរមកទទួលសេចក្ដីរីករាយក្នុងទីនេះ ហៅថា អារម្មណ៍ ។

ពាក្យថាអាលម្ពណ ១បទនេះតាមវិគ្គហ ថា :

**ចិត្តចេតសិកេហិ អាលម្ពិយតីតិ អារម្មណំ**

**ប្រែ** ចិត្តបរមត្ថ និង ចេតសិកបរមត្ថទាំងពីរ រមែងចាប់ ( ឬកាន់យក ) ហៅថាអាលម្ពណ ។ តាមវិគ្គហពីរបទនេះ

មានសេចក្តីបំណងជាមួយគ្នា មានន័យថា ចិត្ត និងចេតសិក ទាំងពីរ រមែងហូរមកកាន់ទីនេះ ព្រោះហេតុដូច្នេះ ហៅថា អារម្មណ៍ ឬ គម្ពីរខ្លះសំដែងថា អាលម្ពណបានដល់អារម្មណ៍ទាំង ៦ ។

**សួរ** ក្នុងអារម្មណ៍ទាំង ៦នេះ ពាក្យថាធម្មារម្មណ៍ មានន័យថាយ៉ាងណា និង បានធម៌អ្វី ?

**ឆ្លើយ** ពាក្យថាធម្មារម្មណ៍មានន័យថា ជាអារម្មណ៍នៃសភាវធម៌ គឺ សភាវធម៌ ដែលជាសាធារណដល់ចិត្តនោះឯង បានដល់ធម្មារម្មណ៍ ទាំង ៦ ប្រការគឺ បសាទរូប ៥ សុខុមរូប ១៦ ចិត្ត ៨៩ ចេតសិក ៥២ និព្វាន និង បញ្ញត្តិ រួម ៦ប្រការ ។

**សួរ** ពាក្យថាធម្មារម្មណ៍ បានដល់ប្រភពធម៌ ៦ ប្រការ ដែលពោលហើយ ពិចារណាហើយ មិនដាច់ស្រេច ព្រោះពាក្យឆ្លើយក្នុងអារម្មណ៍ពីរន័យនោះ ពាក្យថាអារម្មណ៍ បានដល់ធម្មជាតិ ចិត្ត និង ចេតសិកចាប់ (ឬកាន់យក )

ក្នុងអារម្មណ៍ គឺ ធម្មារម្មណ៍នោះ ឆ្លើយថាមានចិត្ត និង ចេតសិកទៀត ។ អ្នកចាប់គឺចិត្ត និង ចេតសិកអ្នកដែលត្រូវចាប់គឺ ចិត្តនិង ចេតសិក បានយ៉ាងណា ?

**ឆ្លើយ** - ពាក្យថាអារម្មណ៍ បានដល់សភាពចិត្ត និងចេត-សិក ទទួល ។

- ពាក្យថាធម្មារម្មណ៍ បានដល់ចិត្ត និង ចេតសិកទៀត ចិត្តទទួលអារម្មណ៍ និង ចិត្តក្នុង ធម្មារម្មណ៍ មានតួ-នាទីផ្សេងៗគ្នា គឺ

មនោទ្វារិកចិត្តទាំងអស់ អាចទទួលអារម្មណ៍ អតីត អនាគត បច្ចុប្បន្ន និង កាលវិមុត្តិបាន (សុំមេត្តាមើលក្នុង អភិធម្មត្ថសង្គហ អារម្មណ៍បរិច្ឆេទ មនោទ្វារិកចិត្តានំ បន ឆព្វិធម្បិ បច្ចុប្បន្នាតីតំ អនាគតំ កាលវិមុត្តញ្ច យថា រហមាសម្ពណំ ហោតិ· ប្រែថា ចិត្តជាមនោទ្វារ ទទួលអារម្មណ៍ទាំង ៦ បច្ចុប្បន្ន អតីត អនាគត ។ អារម្មណ៍កាលវិមុត្តិបានគឺកាលចិត្តនឹកដល់អតីត មនោទ្វារិកចិត្តក៏តាមទទួល

អារម្មណ៍បាន ។ កាលទឹកដល់អនាគត មនោទ្វារិកចិត្តក៏តាមទទួលទៀត ។ កាលចិត្តទឹកដល់កាលវិមុត្ត គឺនិព្វាន និង បញ្ញត្តិមនោទ្វារិកចិត្ត ក៏តាមទទួលបានទៀតក្នុងទីនេះ ចិត្តដែលគិតមុនទៅប៉ុន្មាន ចិត្តក្រោយក៏តាមទទួលបានទៀត ចិត្តមុនជាអារម្មណ៍ គឺ ធម្មារម្មណ៍នឹងចិត្តក្រោយនោះ ជាមនោទ្វារិកចិត្ត ព្រោះហេតុដូច្នេះ ចិត្ត និង ចេតសិកក្នុងធម្មារម្មណ៍កកើតឡើងបាន ដូចដែលបានអធិប្បាយមកហើយ ។

**សួរ** ពាក្យថាធម្មារម្មណ៍ ធម្មាយតន ធម្មធាតុ ផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា ធម្មារម្មណ៍បានដល់អារម្មណ៍ នៃសភាវធម៌ ៦ប្រការដែលពោលមកហើយ តែពាក្យថាធម្មាយតនគឺជាអាយតនម្យ៉ាងដែលសភាវធម៌រមែងកើត បានដល់ព្រះនិព្វាន សុខុមរូប ១៦ ចេតសិក ៥២ ប៉ុណ្ណោះ ។ ធម្មធាតុក៏ដូចគ្នាប្រហែល ធម្មាយតនៈ និង ជាធាតុដែលរមែង

ទ្រទ្រង់សភាពរបស់ខ្លួនប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ធម្មារម្មណ៍ ធម្មាយតន ធម្មធាតុ ផ្សេងគ្នាច្រើន មេត្តាមើលអាយតន និង ធាតុក្នុងបរិច្ឆេទទី ៧ផង ។

សួរ អារម្មណ៍របស់ទ្វារវិមុត្តិចិត្ត ១៩ដួង បានដល់និមិត្តទាំង ៣ ជាអារម្មណ៍យ៉ាងណាខ្លះ ? ហើយនិមិត្ត និង អារម្មណ៍ផ្សេងគ្នាយ៉ាងណាខ្លះ ?

ឆ្លើយ និមិត្តទាំង៣ របស់ទ្វារវិមុត្តិចិត្តទាំង ១៩ដួងនោះ គឺ កាលបុគ្គលណាមួយ ពេលជិតនិង ចុតិចុះនោះ រមែងឃើញនិមិត្តទាំង ៣ នោះ និង សំដែងក្នុងបរិច្ឆេទទី៥ មិនចាំបាច់អធិប្បាយច្រើនក្នុងទីនេះ ។ សេចក្តីពិតការឃើញ និមិត្តទាំង៣នោះ មានសេចក្តីថា អារម្មណ៍ទាំង៦នោះ ឯង មេត្តាមើលក្នុងអារម្មណ៍សង្គហ នេះថា :

**ទ្វារវិមុត្តានញ្ច បដិសន្ធិ ភវង្គចុតិ សង្ខាតានំ ឆព្វិធម្បិ យថាសម្ភវំ យេភុយ្យេន**

**កមន្តរេ ឆទ្វារគហិតំ បច្ចុប្បន្នមតីតំ បញ្ញត្តិភូតំ វា កម្មកម្មនិមិត្តគតិនិមិត្តសម្មតំ ហោតិ ។**

**ទ្វារវិមុត្តិចិត្ត** ១៩ដួង ដែលមានកិច្ចបដិសន្ធិ ភវង្គ ុតិនោះជាអារម្មណ៍ ។ អារម្មណ៍ទាំង ៦ ដែលជាកម្ម កម្ម-និមិត្ត គតិនិមិត្ត របស់បញ្ញត្តិ អតីត បច្ចុប្បន្ន ដែល មរណាសន្នជវនបានទទួលពីជាតិមុននោះ តាមបាលីនេះ ព្រះអនុរុទ្ធាចារ្យសំដែងថា កម្ម កម្មនិមិត្ត គតិនិមិត្ត និង អារម្មណ៍ជាមួយគ្នាគឺ ក្នុងវិថីដទៃៗ ហៅថាអារម្មណ៍ទាំង ៦ ក្នុងមរណាសន្នវិថី ហៅថានិមិត្ត តែកាលឃើញនិមិត្ត ក៏ ឃើញតែទ្វារមួយប៉ុណ្ណោះ មិនដែលឃើញទាំង ៦ទ្វារព្រម ្នាទេ ព្រោះហេតុដូច្នេះ លោកថា ឆព្វិធម្បិ និង ទ្វារគហិតំ ពីរបទនេះសំដែងជាពិសេសផង មានន័យថា និមិត្តទាំង ៣នេះ ត្រូវប្រាកដក្នុងទ្វារណាមួយ នៃទ្វារទាំង ៦ដោយអារម្មណ៍ទាំង ៦ ។

**សួរ** តាមពាក្យគាថាសង្គហថា បញ្ចវីស បរិត្តម្ហិ ប្រែ ចិត្តកាមារម្មណ៍ ២៥ដួង នោះ បានដល់ចិត្តអ្វីខ្លះ ? សុំ អធិប្បាយអារម្មណ៍ដទៃ១ផង ? ។

**ឆ្លើយ** ចិត្តដែលជាកាមារម្មណ៍ ២៥ដួង គឺ កាមាវចរវិបាក ២៣ ដួង បញ្ចទ្វារាវជ្ជនចិត្ត ១ដួង ហសិតុប្បាទ ១ដួង រួម ២៥ដួងជាកាមារម្មណ៍បាន ។ ក្នុងធម្មសង្គណី ព្រះ បាលីថា បរិត្តារម្មណា ធម្មា ដូចនេះ ពាក្យថា ឆចិត្តានិ មហគ្គតេ ប្រែថា ចិត្តជា មហគ្គតារម្មណ៍ ៦ដួង បានដល់ អរូបវិញ្ញាណញ្ចាយតនចិត្ត ៣ដួង និង នេវសញ្ញានាសញ្ញា យតនចិត្ត ៣ដួង រួម ៦ដួង ចិត្តដែលសល់ពីមហគ្គតារមណ៍ ៦ដួង គឺ មហគ្គត ២១ដួង នេះជាបញ្ញត្តិ ។

ចិត្តដែលមានអារម្មណ៍ព្រះនិព្វាន បានដល់លោកុត្តរ ចិត្ត ៨ដួង ។

**សួរ** សព្វារម្មណ៍ មាន ៣ន័យគឺ :

- ន័យទី ១ មាន២០ ដួង

- ន័យទី ២ មាន៥ ដួង

- ន័យទី ៣ មាន៦ ដួង តាមដែលសំដែងមកហើយ ។

ន័យទី ១ - ចិត្ត២០ដួង ជាសព្វារម្មណ៍ វៀរលែងលោកុត្តរចិត្ត ៨ ដួង ។ តើយ៉ាងណាខ្លះជាសព្វារម្មណ៍ ?

**ឆ្លើយ** អកុសលចិត្ត ១២ ដួង ញាណវិប្បយុត្តកុសលចិត្ត និងកិរិយាចិត្ត ៨ដួង រួម ២០ដួង ជាសព្វារម្មណ៍ វៀរលែងលោកុត្តរគឺអារម្មណ៍ទាំង ៦ នេះហៅថា ដោយសភាពចិត្ត ហើយមាន ៤អារម្មណ៍គឺ ១-កាមារម្មណ៍ ២- មហគ្គតារម្មណ៍ ៣-បញ្ញត្តារម្មណ៍ ៤- និព្វានារម្មណ៍

រួម ៤ អារម្មណ៍ ។

ក្នុងទីនេះចិត្ត២០ដួង ដែលពោលមកហើយ ជាកាមារម្មណ៍ មហគ្គតបញ្ញត្តិ បានទាំង ៣ ចំណែកលោកុត្តរមិនមែនតួនាទី នៃអកុសល និង ញាណវិប្បយុត្ត ព្រោះហេតុដូច្នេះ ទើបវៀរលែងលោកុត្តរ ។

**សួរ** ញាណសម្បយុត្តកុសលចិត្ត ៤ដួង និង បញ្ចមជ្ឈាន អភិញ្ញាកុសលចិត្ត ១ដួង ជាសព្វារម្មណ៍ ដែលវៀរចាក អរហត្តផលនោះមានសេចក្តីថាយ៉ាងណា ?

**ឆ្លើយ** ចិត្ត៥ដួង ដែលសួរនេះជាសព្វារម្មណ៍បាន ព្រោះជា កាមារម្មណ៍ មហគ្គតារម្មណ៍ បញ្ញត្តារម្មណ៍ និង លោកុត្ត-រារម្មណ៍ ដែលវៀរចាក អរហត្តមគ្គ-ផល រួម ៤អារម្មណ៍។

**សួរ** ញាណសម្បយុត្តកិរិយាចិត្ត ៤ ដួង បញ្ចមជ្ឈាន អភិញ្ញាកិរិយាចិត្ត ១ដួង មនោទ្វារាវជ្ជន ១ដួង រួម ៦ដួង នេះជាអារម្មណ៍គ្រប់ៗអារម្មណ៍បាន មានសេចក្តីថាយ៉ាង ណា ?

**ឆ្លើយ** ចិត្ត ៦ ដួងដែលសួរមកថាជា សព្វារម្មណ៍ បាននោះ មានសេចក្តីថា ចិត្ត ៦ដួងនេះ ប្រាកដនូវសន្តាននៃព្រះ-សម្មាសម្ពុទ្ធជាម្ចាស់នោះ ជាកាមារម្មណ៍ មហគ្គតារម្មណ៍ បញ្ញត្តារម្មណ៍ និង លោកុត្តរារម្មណ៍បាន ទាំងអស់ ។ តែបើប្រាកដក្នុងសន្តានព្រះអរហន្ត ធម្មតា រមែងជាអារម្ម-

ណ៍បានអារម្មណ៍ខ្លះៗប៉ុណ្ណោះ ព្រោះព្រះអរហន្តមិនមាន សេចក្តីអង់អាចនឹងដឹងធម៌ អស់ដូចសព្វញ្ញុពុទ្ធ ។

**សួរ** ក្នុងអារម្មណ៍ទាំង ៤ ដែលពោលមកហើយ ពាក្យថាអារម្មណ៍បញ្ញត្តិនេះ បានដល់បញ្ញត្តិអ្វីខ្លះ ?

**ឆ្លើយ** មហគ្គតចិត្ត ២១ដួង ជាបញ្ញត្តារម្មណ៍ តែពាក្យថាបញ្ញត្តិនេះ មិនមែនជាបញ្ញត្តិធម្មតាទេ ព្រោះមហគ្គតចិត្ត ២១ដួងនេះជាចិត្តដែលទាក់ទង និង ឈានផ្សេងៗ ព្រោះហេតុដូច្នេះ ពាក្យបញ្ញត្តារម្មណ៍ បានដល់និមិត្តរបស់កម្មដ្ឋានប៉ុណ្ណោះ មិនមែនបញ្ញត្តិធម៌ដទៃទេ ។

ពាក្យថា និមិត្តនៃកម្មដ្ឋាននោះ គឺ កម្មដ្ឋាន២៥អង្គ ជាអារម្មណ៍ ដល់បឋមជ្ឈាន ៣ដួងគឺ កសិណទាំង១០ អសុភទាំង ១០ កាយគតាសតិ ១ អានាបានុស្សតិ ១ មេត្តា ករុណា មុទិតា រួមកម្មដ្ឋាន ២៥អង្គ ។

កម្មដ្ឋាន ១៤អង្គ ជាអារម្មណ៍ ដល់ទុតិយ តតិយ

ចតុត្ថ រូបឈានទាំង ៣នេះ គឺ កសិណ ១០ អានាបានុស្សតិ ១មេត្តា ករុណា មុទិតា រូម ១៤អង្គ ។

កម្មដ្ឋាន ១២អង្គ ជាអារម្មណ៍ដល់ បញ្ចមជ្ឈានទាំង ៣បានគឺ កសិណ ១០ អានាបានុស្សតិ ១ ឧបេក្ខា១ រូម ១២អង្គ ។

---

## អាកាសានញ្ចាយតន ៣ដួង និង អាកិញ្ចញ្ញាយតន ៣ដួង

រូម ៦ដួង ជាអារម្មណ៍អាកាស និង នត្ថិភាវនាកម្ម-ដ្ឋានទាំងអស់ ដែលពោលមកហើយនេះ ជាបញ្ញត្តារម្មណ៍ នៃចិត្តជាមហគ្គតចិត្ត ២១ដួង ជាបញ្ញត្តារម្មណ៍ ដូចដែល គាថាសង្គហបានពោលមកហើយ ។

## សំដែងវត្ថុសង្គហតាមបាលី

វត្ថុសង្គហេ វត្ថូនិ នាម ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ ហទយវត្ថុ ចេតិ ឆព្វិធានិ ភវន្តិ ។ តានិ កាមលោកេ សព្វានិបិ លព្ភន្តិ ។ រូបលោកេ បន ឃានាទិត្តយំ នត្ថិ ។ អរូបលោកេ បន សព្វានិបិ ន សំវិជ្ជន្តិ ។

ប្រែ ក្នុងវត្ថុសង្គហនេះនៅមានវត្ថុ ៦ គឺ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ ហទយវត្ថុ រួម ៦វត្ថុ

វត្ថុទាំង ៦នោះ ក្នុងកាមភូមិ ១១ភូមិ មានទាំងអស់ រូបភូមិ ១៦ភូមិ មានវត្ថុទាំង ៣ គឺ ឃានវត្ថុជាដើម តែអរូបភូមិ ៤ នោះ វត្ថុទាំង ៦ រមែងមិនមាន ឡើយ ។

## សំដែងបាលី (ត)

តត្ថ បញ្ចវិញ្ញាណធាតុយោ យថាក្កមំ ឯកន្តេន បញ្ចបសាទវត្ថូនិ និស្សាយេវ

បវត្តន្តិ ។ បញ្ចទ្វារាវជ្ជនសម្បដិច្ឆន្នសង្ខាតា បន មនោធាតុ ច ហទយំ និស្សិតាយេវ បវត្តន្តិ ។

អវសេសា បន មនោវិញ្ញាណធាតុសង្ខាតា ច សន្តីរណមហាវិបាកបដិឃទ្វយបឋមមគ្គហសនរូបាវចរវសេន ហទយំ និស្សាយេវ បវត្តន្តិ ។

អវសេសា កុសលាកុសលកិរិយានុត្តរវសេន បន និស្សាយ វា អរូបវិបាកវសេន ហទយំ អនិស្សាយេ បវត្តន្តីតិ ។

ក្នុងទីនេះ បញ្ចវិញ្ញាណធាតុ ១០ប្រការ ទាំងអស់នេះរមែងកើតក្នុងបសាទវត្ថុទាំង ៥ តាមលំដាប់ជានិច្ច មនោធាតុទាំង ៣ដែលជាបញ្ចទ្វារាវជ្ជន និង សម្បដិច្ឆន្ន ២ ដួងនោះ រមែងកើតក្នុងហទយវត្ថុ ចិត្ត ៣០ដួង ទៀត ដែលជាមនោវិញ្ញាណធាតុគឺ សន្តីរណ ៣ដួង មហាវិបាក ៨

ដួង ទោសមូលចិត្ត ២ដួង សោតាបត្តិមគ្គចិត្ត ១ដួង ហសិតុប្បាទ ១ដួង រូបាវចរចិត្ត ១៥ដួង គឺ រួម ៣០ដួង អាស្រ័យហទយវត្ថុទើបកើត សល់ ៤២ដួង គឺ លោកិយកុសលចិត្ត ១២ដួង អកុសលចិត្ត ១០ដួង កិរិយាចិត្ត ១៣ដួង លោកុត្តរចិត្ត ៧ដួង រួម ៤២ដួង ។

ជួនកាលអាស្រ័យហទយវត្ថុ ជួនកាលក៏រមែងកើត ដោយមិនត្រូវអាស្រ័យហទយវត្ថុ ។

ចំណែកអរូបវិបាក ៤ដួង រមែងមិនអាស្រ័យ ហទយវត្ថុឡើយ ។

# អធិប្បាយក្នុងវត្ថុសង្គហ

ពាក្យថាវត្ថុ ជាទីកើតរបស់វិញ្ញាណធាតុ ដូចជា

ចក្ខុវត្ថុ ជាទីកើតរបស់ចក្ខុវិញ្ញាណចិត្តទាំងពីរនេះ ជាដើម ។

វត្ថុទាំង ៦ នេះ រមែងមានក្នុងកាមភូមិទាំងអស់ គឺ ទេវតា មនុស្ស សត្វតិរច្ឆានផ្សេងៗរហូតដល់នរក ។

ក្នុងរូបព្រហ្ម ១៦ជាន់នោះ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ រមែងមិនមាន ដែលថាមិនមាននោះ ព្រោះឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ មិនកើតមែនតែឃាន-ជីវ្ហា-កាយ មានដូចគ្នា និង មនុស្សដែរ ។

ក្នុងអរូបភូមិនោះ វត្ថុរូបទាំងអស់រមែងមិនមានឡើយ ព្រោះអរូបព្រហ្មមានតែនាម ( គ្មានរូបទេ ) ។

ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជីវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ រួមធាតុទាំង ៥ នេះ អាស្រ័យកើតក្នុង ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ រួមវត្ថុទាំង ៥ ដោយលំដាប់ ។

បញ្ចទ្វារាវជ្ជន ១ និង សម្បដិច្ឆន្ន ២ រួម៣យ៉ាងនេះ ហៅថា មនោធាតុ មនោធាតុនេះអាស្រ័យ ក្នុងហទយវត្ថុ ទើបកើត ។

ចិត្ត ៣០ដួង ទៀតគឺ សន្តីរណ ៣ដួង មហាវិបាកចិត្ត៨ដួង ទោសមូលចិត្ត ២ដួង សោតាបត្តិមគ្គចិត្ត ១ដួង

ហសិតុប្បាទចិត្ត ១ ដួង និង រូបាវចរចិត្ត ១៥ ដួង រួម ៣០ដួងនេះ ហៅថា មនោវិញ្ញាណធាតុ មនោវិញ្ញាណធាតុអាស្រ័យហទយវត្ថុរូប ទើបកើតដោយចំពោះ ។

ដែលពោលមកហើយនៅសល់ចិត្ត ៤២ដួងទៀត គឺ

កាមាវចរកុសលចិត្ត ៨ដួង អរូបាវចរកុសលចិត្ត ៤ ដួង អកុសលចិត្ត ១០ដួង ( វៀរទោសមូលចិត្ត ២ដួង ) កិរិយាចិត្ត ១៣ដួង ( វៀរ បញ្ចទ្វារាវជ្ជន ១ដួង ហសិតុប្បាទ ១ដួង និង រូបាវចរកិរិយា ៥ដួង ) លោកុត្តរ ៧ដួង ( វៀរ សោតាបត្តិមគ្គ) រួម ៤២ដួងនោះ ។

ការកើតក្នុង បញ្ចវោការភូមិ អាស្រ័យហទយវត្ថុ ហើយទើបកើត ។

ការកើតក្នុង ចតុវោការភូមិ មិនបានអាស្រ័យ ហទយវត្ថុ ។

ពាក្យថា ចតុវោការ បានដល់នាមខន្ធ ៤ ។ ចំណែក អរូបវិបាក ៤ដួង កើតដោយមិនបានអាស្រ័យហទយវត្ថុ

ឡើយព្រោះអរូបភូមិមិនមានរូប មានតែនាម ប៉ុណ្ណោះ ។

## សំដែងគាថាសង្គហ

**ឆ វត្ថុំ និស្សិតា កាមេ សត្ត រូបេ ចតុព្វិធា តិវត្ថុំ និស្សិតា រូបេ ធាតុវេកា និស្សិតា មតា តេចត្តាឡីស និស្សាយ ទ្វេចត្តាឡីសជាយរេ និស្សាយ ច អនិស្សាយ បាការុប្បា អនិស្សិតា**

**ប្រែសេចក្តីថា**

ក្នុងកាមភូមិ ១១ភូមិ វិញ្ញាណធាតុដែលអាស្រ័យវត្ថុទាំង៦កើតមានវិញ្ញាណធាតុ ៧ ។

ក្នុងរូបព្រហ្ម ១៥ភូមិ ( វៀរអសញ្ញីសត្ត ) វិញ្ញាណធាតុដែលអាស្រ័យវត្ថុ៣វត្ថុ ទើបកើតមាន ៤ វិញ្ញាណធាតុ

ក្នុងអរូបព្រហ្ម ៤ភូមិនោះ មានតែវិញ្ញាណធាតុ ១ ប៉ុណ្ណោះ ។

ចិត្ត ៤៣ដួង រមែងអាស្រ័យ ហទយវត្ថុរូប ទើបកើតជានិច្ច ។

ចិត្ត ៤២ដួង ជួនកាលក៏អាស្រ័យ ជួនកាលក៏មិនអាស្រ័យហទយវត្ថុ ។

អរូបវិបាក ៤ដួង រមែងមិនអាស្រ័យហទយវត្ថុ ប៉ុន្តែអាចកើតបានជានិច្ច ។

**ឥតិ អភិធម្មត្ថសង្គហេ បកិណ្ណកសង្គហវិ-ភាគោ នាម តតិយោ បរិច្ឆេទោ**

ក្នុងគម្ពីរអភិធម្មត្ថសង្គហនេះ មាននាមថា បកិណ្ណ-កសង្គហដែលជាបរិច្ឆេទទី ៣ ចប់តែប៉ុណ្ណោះ ។/

.................................

## សួរ-ឆ្លើយក្នុងវត្ថុសង្គហ

**សួរ** ពាក្យវត្ថុ ប្រែថាអ្វី ? ហើយបានដល់អ្វីខ្លះ ?

**ឆ្លើយ** ពាក្យថាវត្ថុ តាមវិគ្គហថា : វសន្តិ បតិដ្ឋហន្តិ ចិត្ត-ចេតសិកា ឯត្ថាតិ វត្ថុ

ប្រែថា ក្នុងទីនេះ ចិត្តនិងចេតសិកទាំងពីរ រមែងកើតហៅថាវត្ថុ បានដល់ចក្ខុបសាទ សោតបសាទ ឃាន

បសាទ ជីវ្ហាបសាទ កាយបសាទ និង ហទយរូប រួមបសាទរូបទាំង ៥ និង ហទយរូប ១ ហៅថាវត្ថុ ។ មានន័យថា វត្ថុទាំង ៦យ៉ាងនេះ ជារូបទាំងអស់គ្មានជានាមទេ ។

**សួរ** ពាក្យថា វត្ថុប្រែថា ទីកើតរបស់ចិត្ត និង ចេតសិក ពាក្យថា អាយតនជាទីតាំងរបស់ចិត្ត និង ចេតសិកតើពាក្យទាំងពីរនេះផ្សេងគ្នាយ៉ាងណាខ្លះ ?

**ឆ្លើយ** ពាក្យថា អាយតន បានដល់សភាពបរម័ត្ថទាំង ៤ ប្រការដោយបរិបូណ៌ ។ ឯពាក្យថា វត្ថុ បានដល់បសាទរូប ៥ និង ហទយរូបប៉ុណ្ណោះ ។ មានន័យ ថា : វត្ថុជាឈ្មោះនៃរូបធម៌ដោយចំពោះ ព្រោះហេតុដូច្នេះ ពាក្យថាអាយតន និង ពាក្យថាវត្ថុ ផ្សេងគ្នាដោយសរុបដូចនេះឯង ។

**សួរ** តាមបាលីដែលពោលមកហើយថា : ក្នុងរូបភូមិមិនមានឃាន ជីវ្ហា-កាយ វត្ថុទាំង ៣ វត្ថុនេះ រូបព្រហ្មមិនមានច្រមុះ មិនមានអណ្តាត មិនមានរាងកាយ អញ្ជើង ឬ ?

**ឆ្លើយ** តាមដែលព្រះអនុរុទ្ធាចារ្យ ក្នុងព្រហ្មលោកមិនមាន ឃាន ជីវ្ហា-កាយវត្ថុ នោះគឺធម្មជាតិព្រហ្មរមែងមិនមាន ឃានវិញ្ញាណ២ដួង ជីវ្ហាវិញ្ញាណ២ដួង និង សុខ-ទុក្ខ កាយ-វិញ្ញាណ ២ដួងជាធម្មនិយាម តែច្រមុះ អណ្តាត កាយមាន នៅប្រាកដ ។ មានន័យថាសេចក្តីដឹង នៃច្រមុះ អណ្តាត កាយ មិនមាន ដូច្នេះ ការមានច្រមុះ អណ្តាត កាយរបស់ ព្រហ្មក៏ដូចមិនមានប្រយោជន៍អ្វីឡើយ ។

ព្រះអនុរុទ្ធាចារ្យ លោកពោលថា រូបលោកេ បន ឃានទិយុគ្គំ នត្ថិ ដូចដែលបានសំដែងមកហើយក្នុងសង្គហ នេះ ។

**សួរ** តាមដែលលោកថា អរូបព្រហ្មវត្ថុទាំង ៦ រមែងមិន មាននោះ អរូបព្រហ្មតាំងនៅយ៉ាងណា ? កាលបើមិនមាន រូបរាងដូច្នេះ ?

**ឆ្លើយ** អរូបព្រហ្មជាធម្មជាតិ ដែលមិនមានរូប ឬ ព្រហ្ម ដែលជានាម គ្មានតួខ្លួនប្រាណ ដូចរូបទេ ជាទីអាស្រ័យ

របស់សត្វមួយបែបដែលបរិបូណ៌ ដោយនាម ទោះបីអរូប-ព្រហ្មមានតួខ្លួនប្រាណដូចមនុស្សក៏ដោយ ជាបុគ្គលមួយបែបដែលជាសត្វមួយចំពូកមាននៅ ។ ក្នុងអរូបព្រហ្មនេះមានព្រះអរិយបុគ្គល ៧ចំពូក និង ត្រៃហេតុបុថុជ្ជន ១ ចំពូករួម៨ចំពូកដូចដែលអធិប្បាយមកហើយ។ អធិប្បាយតាមពុទ្ធសាសនិកជនទាំងឡាយ ការរាប់អាន និង ជឿពាក្យសំដីជាពុទ្ធដីកា គួរជឿថាសត្វដែលមានតែរូប ដូចជាព្រហ្ម អសញ្ញីសត្ត និង សត្វដែលមាននាមដូចជា អរូបព្រហ្មទាំងនេះ មាននៅ បើមិនដូច្នេះក៏និងក្លាយជា មិច្ឆាទិដ្ឋិដែលមានសេចក្ដីឃើញខុស ផ្ទុយពីព្រះសាស្តានៃ យើង ។

**សួរ** ក្នុងវត្ថុសង្គហនេះ ពាក្យថាមនោធាតុ បញ្ចវិញ្ញាណ-ធាតុ មនោវិញ្ញាណធាតុ ទាំង ៣នេះមានន័យយ៉ាងណា ហើយផ្សេងគ្នាយ៉ាងណា ?

**ឆ្លើយ** ពាក្យថាមនោធាតុ តាមវិគ្គហថាៈ មនតិ ជានាតីតិ មនោ ឯវ ធាតុ មនោធាតុ ប្រែ សេចក្ដីដឹង ហៅថាមនោ

នេះឯង ជាធាតុ១បែប ហៅថា មនោធាតុបានដល់ចិត្ត បញ្ចទ្វារាវជ្ជនចិត្ត ១ដួង និង សម្បដិច្ឆន្ន ២ដួង រួម ៣ ដួង ។

- ពាក្យថា បញ្ចវិញ្ញាណធាតុ ញែកបាន ៣បទគឺ ៈ

| | | | | |
|---|---|---|---|---|
| បញ្ច | + | វិញ្ញាណ | + | ធាតុ |
| បញ្ច | | ប្រែថា | | ចំនួន៥ |
| វិញ្ញាណ | | ប្រែថា | | វិញ្ញាណ |
| ធាតុ | | ប្រែថា | | ធាតុ |

មានន័យថា វិញ្ញាណធាតុទាំង ៥ដួង គឺ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជីវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ រួមវិញ្ញាណធាតុ ៥ វិញ្ញាណ ប្រែថា សេចក្តីដឹងៗ ជាធាតុ ១បែប រមែងកើតដោយអាស្រ័យ ចក្ខុ សោត ឃាន ជីវ្ហា កាយ ក៏ដឹងទំនងដូចគ្នា ។

- ពាក្យថាមនោវិញ្ញាណធាតុ ប្រែថាមនោនោះឯង មនោជាវិញ្ញាណធាតុ មានន័យថា សេចក្តីដឹងពីរដង

( ពីរជាន់ ) គឺ :

មនោ ⟶ ដឹង និងវិញ្ញាណ ⟶ ដឹង

ឬសេចក្តី ដឹងពិសេស អធិប្បាយថា មិនមែនជាសេចក្តីដឹងជាសាមញ្ញទេ ដឹងច្រើនជាង មនោធាតុទាំង ៣ ហៅថាមនោវិញ្ញាណធាតុ បានដល់ចិត្ត ៧៦ ដួង ដែលសល់ពីបញ្ចវិញ្ញាណធាតុ មនោធាតុ ។

អធិប្បាយតទៅទៀតគឺ សេចក្តីដឹងនៃបញ្ចទ្វារ និងសម្បដិច្ឆន្នទាំង ២នោះ ដឹងមិនសព្វគ្រប់ ។ សេចក្តីដឹងនៃមនោវិញ្ញាណធាតុ ដឹងល្អ ដឹងសព្វគ្រប់ ។

ដូច្នេះមានឈ្មោះតាមវិគ្គហថា : វិសេសន ជានាតីតិវិញ្ញាណំ ប្រែ សេចក្តីដឹងជាពិសេស ហៅថា វិញ្ញាណ ។

**សួរ** សេចក្តីដឹងនៃវិញ្ញាណនោះ ជាដឹងពិសេស តើដឹងយ៉ាងណា ទើបជាសេចក្តីដឹងពិសេស តើ សេចក្តីដឹងពិសេសនោះ ហៅថា បញ្ញាបានទេ ? ព្រោះបញ្ញាក៏ប្រែថាដឹង ?

**ឆ្លើយ** សេចក្តីដឹង វិញ្ញាណ និង សេចក្តីដឹងនៃបញ្ញាផ្សេងគ្នាច្រើន ។ សេចក្តីដឹងវិញ្ញាណ ដឹងបានសព្វគ្រប់ ល្មមដែលមើលឃើញ និង បានឮ តែមិនអាចនិង ដឹងអស់ ក្នុងវត្ថុទាំងពួង ។ បញ្ញាអាចនិង ដឹងយ៉ាងពិសេស រហូតដល់ព្រះនិព្វានធាតុ ព្រោះហេតុដូច្នេះ ទើបមានឈ្មោះថាមហាបញ្ញា ហាសបញ្ញា បុថុបញ្ញា តិក្ខបញ្ញា ជវនបញ្ញា និព្វេធិកបញ្ញា ជាដើម ។

ខ. សំខាន់ក្នុងបរមត្ថនេះមានសេចក្តីដឹង ៣យ៉ាងគឺ

- សេចក្តីដឹងជាបញ្ញា

- សេចក្តីដឹងជាពិសេស សេចក្តីដឹងពិសេសក្នុងទីនេះ សេចក្តីដឹងរបស់មនោធាតុ ហៅថាសេចក្តីដឹង សាមញ្ញ សេចក្តីដឹងបែបនេះ បានឈ្មោះថា ដឹងព្រោះត្រឹម គ្រឿងដឹងប៉ុណ្ណោះឯង ។

- សេចក្តីដឹងរបស់វិញ្ញាណធាតុដទៃ១ ហៅថា សេចក្តីដឹងពិសេស ព្រោះសេចក្តីដឹងបែបនេះ ដឹងបាន

លក្ខណៈរូបរាងសណ្ឋាន ... របស់អារម្មណ៍ដែលបានឃើញ ដែលបានឮ ។

សេចក្ដីដឹង របស់បញ្ញាទាក់ទងមកពីសេចក្ដីដឹង របស់វិញ្ញាណ ទាក់ទងមកពីអាវជ្ជនចិត្ត ដែលជាមនោធាតុ សេចក្ដីដឹងទាំងបីយ៉ាងនេះ ត្រូវអាស្រ័យគ្នានឹងគ្នា

ពាក្យថា វិញ្ញាណនោះកើតមកពីស័ព្ទ វិជា ។

ពាក្យថា បញ្ញានោះ កើតមកពីស័ព្ទ បជានាតិ ។

ស័ព្ទដើម គឺ បជានាតិមួយបទ ប្រកប និង វិញ្ញាណ មួយបទ បញ្ញាមួយបទ កាលធ្វើជាបទវិគ្គហ គឺ : **វិជានាតីតិ វិញ្ញាណំ និង បការេន ជានាតីតិ បញ្ញា**

**ប្រែថា** វិញ្ញាណដឹងពិសេស បញ្ញាដឹងគ្រប់ប្រការ ទាំងពួងតែវិញ្ញាណ និង បញ្ញា ញែកចេញពីគ្នាមិនបាន គឺ វិញ្ញាណដឹងអារម្មណ៍ជាពិសេស ដឹងពិសេសយ៉ាងណាក៏ មានបញ្ញាដឹងពិសេសយ៉ាងនោះ មហាវេល្លសូត្រ ព្រះបាលី

មហាសារីបុត្រសំដែងថា. **យញ្ចាវុសោ បជានាតិ តំ បជានាតិ យំ វិជានាតិ តំ បជានាតិ** ប្រែថា

វត្ថុណាដឹងប្រាជ្ញា វិញ្ញាណក៏ដឹងវត្ថុនោះ វត្ថុណាដឹងដោយវិញ្ញាណ បញ្ញាក៏ដឹងវត្ថុនោះ មានសេចក្ដីថា វិញ្ញាណ និង បញ្ញា ញែកចេញពីគ្នាមិនបាន តែផ្សេងគ្នាម្យ៉ាង ៗ តាមធម្មជាតិ ។

**សួរ** ធម្មតាចិត្តទាំងអស់អាស្រ័យ ហទយវត្ថុកើតឡើង ដូចជាក្នុងធម្មបទថា : អសរីរំ គុហាសយំ ប្រែថា មិនមែនរាងកាយ និង រមែងកើតក្នុងគូហា គឺ ហទយវត្ថុរូប និង អត្ថកថាថា **សព្វេ មនោ មនោទ្វារំ** ចិត្តទាំងអស់ហៅថា មនោទ្វារក្នុងបកិណ្ណកសង្គហនេះ ដូចម្ដេចទើបថា ចិត្ត ៤៣ ដួងប៉ុណ្ណោះនោះ រមែងកើតដោយអាស្រ័យហទយវត្ថុឬ?

**ឆ្លើយ** កាលដែលព្រះអនុរុទ្ធាចារ្យ សំដែងគាថាសង្គហៈថា តេ ចត្តាឡីស និស្សាយ ទ្វេចត្តាឡីស ជាយរេ មានន័យថា

ចិត្ត ៤៣ដួង រមែងកើតដោយអាស្រ័យហទយវត្ថុជាប្រចាំ ចិត្ត ៤២ដួងទៀត ជួនកាលអាស្រ័យ ជួនកាលមិនអាស្រ័យ ឬចិត្តទាំងអស់នេះ ការកើតក្នុងបញ្ចវោការភូមិ គឺ ភូមិដែលមាន ខន្ធទាំង ៥នោះ រមែងអាស្រ័យ ហទយវត្ថុ ទើបកើត ។

ចិត្តចំនួនកាលកើតក្នុងចតុវោការភូមិ គឺ ភូមិដែលមានខន្ធ ៤ មិនបានអាស្រ័យហទយវត្ថុរូបឡើយ ព្រោះហេតុដូច្នេះ ចិត្តទាំងអស់កាលកើតក្នុងភូមិ ដែលមានខន្ធ ៥ ត្រូវអាស្រ័យ ហទយវត្ថុ ហើយហៅថាមនោទ្វារបានដូច ដែលមានបញ្ហាមក ។

**សួរ** ចិត្តដែលអាស្រ័យហទយវត្ថុ ៤៣ដួងបានដល់ចិត្តអ្វីខ្លះ ?

**ឆ្លើយ** ចិត្តដែលអាស្រ័យហទយវត្ថុជាប្រចាំនោះមាន ៤៣ ដួងគឺ ទ្វិបញ្ចវិញ្ញាណ ១០ បញ្ចទ្វារាវជ្ជន១ សម្បដិច្ឆន្ន ២ សន្តីរណ ៣ មហាវិបាក ៨ ទោសមូល ២ សោតាបត្តិមគ្គ១

ហសិតុប្បាទ ១ រូបាវចរ ១៥ រួម ៤៣ដួង រមែងអាស្រ័យ
ហទយរូបជានិច្ច ។

**សួរ** តាមបាលីព្រះអនុរុទ្ធាចារ្យថា :

**តត្ថ បញ្ចវិញ្ញាណធាតុយោ យថាក្កមំ ឯកន្តេន បញ្ចបសាទវត្ថូនិ និស្សយេច បវត្តន្តិ**

**ប្រែ ទ្វិបញ្ចវិញ្ញាណ ១០** រមែងអាស្រ័យបសាទរូបទាំង ៥ ហើយក្នុងពាក្យ អធិប្បាយចិត្ត ៤៣ដួង ក៏ថាអា-ស្រ័យហទយវត្ថុទៀត ។ ពាក្យអធិប្បាយទាំងពីរនោះមិនផ្ទុយគ្នាឬ ?

**ឆ្លើយ** គ្មានដូច្នេះទេ ទ្វិបញ្ចវិញ្ញាណ ១០ដួង រមែងកើតអាស្រ័យដោយវត្ថុទាំង ៥ និង ចិត្ត ៤៣ដួង រមែងអាស្រ័យហទយវត្ថុរូបជានិច្ច ។ ពាក្យអធិប្បាយទាំងពីរនេះសង្គ្រោះគ្នាបានដូចនេះគឺ ក្នុងប្រយោគទី ១ ទ្វិបញ្ចវិញ្ញាណ ១០ដួងនេះមានឈ្មោះថា ចក្ខុវិញ្ញាណ សោតវិញ្ញាណ

ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ដោយលំដាប់នៃ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ ។

កាលដែលមានឈ្មោះយ៉ាងនេះ ព្រោះវិញ្ញាណទាំងអស់នេះ កើតទាក់ទងមកអំពី ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុជានិច្ច ។

តែសេចក្តីដឹងនោះ ចិត្តរមែងដឹង ។ តែសេចក្តីដឹងត្រូវអាស្រ័យ ហទយវត្ថុរូបជាប្រធាន កុំគប្បីចូលចិត្តថា សេចក្តីដឹងនោះ ភ្នែក ដឹង ត្រចៀក ច្រមុះ អណ្តាត កាយ ដឹងព្រោះភ្នែក ។ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ទាំងអស់នេះ ជារូបធម៌ ដែលជាអហេតុក អព្យាកត មិនមាន សេចក្តីអង់អាច នឹងដឹងបាន សេចក្តីដឹងនោះជានាមធម៌ដោយត្រង់ ហើយត្រូវអាស្រ័យនាមធម៌នេះជាហទយវត្ថុរូប ។

ព្រោះដូច្នេះ ព្រះអនុរុទ្ធាចារ្យ ទើបសំដែងសង្គហថា ឆវត្ថុ និស្សិតា កាមេ សត្ត ប្រែ ក្នុងកាមភូមិ វិញ្ញាណធាតុ ដែលវត្ថុទាំង ៦ មាន ៧ធាតុ គឺ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោធាតុ និង មនោវិញ្ញាណធាតុ ។

**សួរ** ក្នុងព្រះអភិធម្មត្ថសង្គហព្រះអដ្ឋកថាចារ្យ ពោល ញយៗថា បញ្ចវោរ ចតុវោការ ដូចនេះ ពាក្យថាវោការ ប្រែថាយ៉ាងណា ?

**ឆ្លើយ** តាមដែលលោកពោលដោយស័ព្ទ វោការៈនេះអាស្រ័យព្រះអភិធម្មទេសនាថា **ឯកវោការភវោ ចតុវោការភវោ បញ្ចវោរភោ ភវេ** ដូច្នេះគឺជានាមធមិ១ បែប ដែលព្រះបរមសាស្តាទ្រង់ហៅ ថាខន្ធទាំង ៥ ខន្ធ ៤ ខន្ធ ១ ថា វោការ ក្នុងអភិធម្ម បាលីថា **វោការោ ឈាមកោ ខន្ធោ** ។ ប្រែ វោការ

ប្រែបានពីរន័យ គឺ លាមក និង ខន្ធ ដូច្នេះ សាមញ្ញដែលព្រះបរមសាស្តាតាំងទុកនោះ វេាការ និង ខន្ធ ជាមួយគ្នា ។

មានន័យថា វេាការ ក៏ជាខន្ធ ខន្ធក៏ជាវេាការនេះឯង ។/

**ចប់បរិច្ឆេទទី៣**

បរិច្ឆេទទី ៣

# ចូឡកម្មវិភង្គសូត្រ

អាយុខ្លីធ្វើអប្រិយខាងសម្លាប់    អាយុវែងផ្ទុយស្រឡះផេងពីអាយុខ្លី
អាពាធិកច្រើនៗបៀតបៀន    ហើយទន្រ្ទានរុកកួនជាប់ ។
អាពាធិកតិចនោះជាប់    ជានិស័យខាងមេត្តា
ចំណោកអសម្បុរសអាក្រក់ក្រោធខឹងសារ    សម្បុរសល្អនេះណាអហឹង្សានឹងប្រណី ។
សក្តិតូចអ្នកខិលខូចខាងឥស្សា    សក្តិធំនោះណាមិនត្រូវការយ៉ាងនោះទេ
សម្បត្តិតិចសូមកុំភិចមច្ឆរិយៈ    សម្បត្តិច្រើនទុកដាក់ខាងធ្វើទាន ។
ត្រកូលទាបមិនសុភាពរាបសា    ត្រកូលខ្ពស់មិនអោយហួសតែងគោរព
ប្រសិនជួបពេលថ្ងៃ ឬ ពេលយប់    ត្រូវគោរពកិច្ចគំរុបការជួបអើយ ។
ប្រាជ្ញាតិចតែមិនភ្លឹចតែមិនសាកច្ឆា    មិនចរចារកើតបញ្ហាពីណាបាន
ប្រាជ្ញាច្រើនស្រស់ចំណាន    ពោលមិនបានបន្ទុនប្រាណរាបចាំស្តាប់
ចូឡកម្មវិភង្គសូត្រ    ខ្ញុំបានបូតតាមចំណេះនៃបញ្ញា
បើមានខុសខ្វះចន្លោះត្រង់ណា    អ្នកមេត្តាជួយចាត់ការបន្ថែមហោង ។

សូមឧទិសជូនមាតា បិតារបស់ខ្ញុំ
នឹងញាតិព្រមទាំងសត្វលោក
ទូទាំងភពដែលកំពុងឆ្ងាញ់កាម

**ចៅខុត្តមរដ្ឋា**

បរិច្ឆេទទី ៣

# សត្វលោកីរងខ្លាំង

ជីវិតស្ទុះទៅនៅក្នុងសង្សារៈចក្រ    ពាសពេញវដ្តនាលោកី
មានភាពរឹងត្អឹងទាំងប្រុសស្រី  ភេទខ្ទើយទីបីណាលោកណា
មិនថាយ៉ាងមិចកប្បមានកើត  ហាមប្រាមមិនកើតនាលោកី
ឱ្យតែមានទឹកភពផែនដី  កម្មយកភេទទាំងបីដាក់តាមកាល ។
ឱ្យរាងថាកុំរឹងត្រូវឈឺឆ្អាល    លោកៈឆេះកាលវិនាសបង់
អ្នកប្រាជ្ញប្រាប់ទៀតទៀងពិតត្រង់ ហេតុអ្វីអ្នករឹងចង់វិនាស
វិនាសអើយគួរអាណិត    កប្បនេះឆេះពិតនាលោកី
ដីទឹកភ្លើងខ្យល់បានប្រុសស្រី   ទាស់គាត់ប្រល័យវិញដីដែល
ជីវិតរស់នៅដូចភ្លេកបន្ទោល    ស្ទុះចេញមិតចូលតាមទីធ្លា
កើតចាស់ឈឺស្លាប់ទ្រុតទ្រោមជរា   ប្រឹងលូនប្រឹងវារតាមអំណាចកម្ម
កម្មអើយអ្នកធំម្លេះ    ហេតុអ្វីអ្នកចេះចាត់ចែងភពធារ
បង្កើតតែខ្ញុំហេតុអ្វីនាំជរា  ចាស់ឈឺគ្រាំគ្រារទារុណកម្ម ។

ពិននោះកំថាខ្ញុំសត្វរាង ស្ទុះចេញជាសវាងពីភពកម្ម
នូវតែក្រសោបអោបជាប់ចាំ នេះជាបណ្តាំលោកសម្តេចមច្ចុ
លោកៈប្រែថាវិនាស លោកឱ្យខ្ញុំជាសចេញទៅណា
សម្តេចប្រែថាអ្នកប្រហារ មច្ចុប៉ុណ្ណារអ៊ូរដីដែល ។

និពន្ធដោយលោក **ចៅឧត្តមរដ្ឋា**
ថ្ងៃអង្គារ៍ ៧កើត ខែ ភទ្របទ
ពុទ្ធសករាជ ២៥៤៤

បរិច្ឆេទទី ៣

# មិនមានផលបីយ៉ាងមានផលបីយ៉ាង

បូរជាមានភ័យ តក់ស្លុតចង្រៃទុកបៀតបៀន
ឱ្យបានរូចទុកដែលខ្លួនមាន ថ្វាយតាមទំលាមដែលខ្លួនពោល
បូរជាព្រោះលោភលុន ខ្លួនបែរបន់តាមចិត្តនឹង
បានលាភច្រើនសន្ធឹក តាមចិត្តនឹកថាបូរជា ។
បូរជាព្រោះតែញាតិ មិនចង់ឃ្លាតចាកចេញឆ្ងាយ
បូរជានោះខ្លួនបានចំណោយ ហើយកុំទទឹងចាំថ្ងៃនឹងបានផល
បូរជាពិតបានផល អ្នកត្រូវយល់បូរជាគុណ
តិចច្រើនកើនតាមលះ ខ្លួនត្រូវឈ្នះក្តីកំណាញ់ ។
បូរជាបញ្ញាមិនសាមញ្ញ នឹកគុណឱ្យជាប់មិនត្រូវចាញ់
ចោលអកុសលវិញ ត្រូវទន្និញបញ្ញាគុណ ។
បូរជាវិសុទ្ធិគុណ ធំហើយសែនធ្ងន់លើសផែនដី
ប់ទាំងកាមភពរូបភពប្រសើរក្រៃ អរូបភពរួមបីមិនស្មើវិសុទ្ធិគុណ

បូរជាមិនមានផលមានបីយ៉ាង ជាភស្តុតាងដូចបានរាប់
បូរជាមិនចាស់ហើយមិនស្លាប់ ដូចបានរាប់ខាងក្រោមគ្នា ។
ព្រះពុទ្ធសម្តែងកាលទ្រង់ធម្មា ធម្មភពរាជាលើភពត្រៃ
ប្រសើរលើសលោកភពទាំងបី ព្រះឥន្ទព្រះព្រហ្មកោសិយប្រៀបពុំបាន
ចុងបញ្ចប់សូមដណ្តប់នូវព្រះធម៌ បរិសុទ្ធល្អស្អាតសុក្កុម
ចាត់ចែងទុកដាក់បានសមរម្យ លើកដាក់កុសលព្រះនិព្វាន ។

ឧទិសជូនឪពុកម្តាយខ្ញុំ

**ចៅឧត្តមរដ្ឋា**

# ចំណាំ ៧ ប្រភេទធំជាងចំណាំឯទៀត
# ចំណងស្វាយ

ភរិយាមាន៧យ៉ាង ដែលភស្តុតាងដូចខាងក្រោម
ទៅណាមកណាមិនខុសចំណោម ភរិយា៧ខាងក្រោមជា ការពិត ។
វធកាភរិយា គាត់នោះដូចជាអ្នកសម្លាប់
អោយតែនូវជិតគិតរាយរ៉ាប់ ប្រើយើងជូនជាប់គ្មានទំនេរ ។
ទីពីរគឺចោរីភរិយា បើមានទ្រព្យាពិតមិនគុង
ឱ្យតែមកដល់គេខ្វេះខ្វង់ យកទ្រព្យពេញអង្គអស់ពីប្រាណ
ទីបីអយ្យាភរិយា ដូចម្ចាស់ទ្រព្យាចៅហ្វាយនាយ
ចង្អុលរ៉ាយរ៉ាប់ប្រាប់កូននាយ ចៅហ្វាយនិយាយស្លូកស្លាំងស្លុត
ទីបួនស្ងួនពិស្សី ភរិយាដូចម្តាយកូនប្រុសស្រី
ថ្នាក់ថ្នមអង្អែលលោមបមបី ថ្នមកូនពិស្សីផ្តេកកូនណា ។
ទីប្រាំចាំឱ្យជាក់ ភរិយាលោកអ្នកភគិនី
ភរិយាសមសួនដូចប្អូនស្រី យកចិត្តស្វាមីចាំបំរើ ។

បរិច្ឆេទទី ៣

ទីប្រាំមួយជួយចងចាំ ភរិយាមុតមាំសហាយ្យៈ
ស្រឡាញ់ចិត្តជិតដូចមិត្តភក្តិ នាងជាសហាយភរិយា ។
ទីប្រាំពីរជាទីនឹកអាល័យ នាងមានហរទ័យជាទាសី
រងចាំបំរើតែលោកប្ដី កិច្ចការអ្វីៗមិនឱ្យទាស់ ។
ប្អូនខាងក្រោមនេះពិតជាល្អ មានចិត្តស្មោះសរបានសួគិសុខ
ព្រោះខ្លួនជាមនុស្សនាំមកសុខ ពីនេះទៅមុខសុខក្នុងលោក
នាងបីខាងលើពិតសោយសោក ចាកផុតពីលោកទុកវេទនា
ទៅលេងអបាយជាភពធា គរគារតាំងពីតិរច្ឆានទៅ ។

**ចៅខុត្តមរដ្ឋា**

បរិច្ឆេទទី ៣

# សុត្តន្តបិដកអង្គុត្តរនិកាយ ចតុក្កនិបាត
# ការប្រហារប្រាំយ៉ាងសាហាវ

..................................................

សម័យមួយព្រះពុទ្ធគង់ធម្មា ធម្មភពរាជាលើលោកា
ជាគ្រឹះដ៏ធំក្នុងសាសនា នូវគ្រប់ចក្រវាឡមានតែមួយ ។
ពេលនោះព្រះអង្គជំជាមួយ ទេវទត្តភិក្ខុព្រួយខ្លាំងអានេក
ទ្រាំនូវមិនបានក៏អល់ឯក ហើយបានពុះជ្រែកចរចេញទៅ ។
មិនយូរប៉ុន្មានព្រះអង្គត្រាសហៅ ភិក្ខុសំដៅជួបជុំគ្នា
លាភសក្ការៈសេចក្ដីសរសើរ កើនឡើងទទើរដល់ទេវទត្ត ។
ជាអ្នកសំលាប់យ៉ាងប្រាកដ ដល់ភិក្ខុទេវទត្តិនាសបង់
ដូចជាដើមចេកឈរត្រង់ បញ្ចេញត្រយូងខ្ទង់ទ្រេតកាយ ។
មិនដឹងផ្លែសំលាប់ពូជរុក្ខាចេក ផ្លែទំធំសមពេកចេក សំលាប់ដើម
ឫស្សីមានបន្លាការពារខ្លួន បើកាប់ខុសក្បួនមុតបន្លា ។
ឫកពារស្រទុនឃោលកាយា ចេញផ្លែចេញផ្កាប្រហារបង់

ដើមនោះទ្រេត ឬ ត្រង់ ផ្លែប្រហារបង់អស់គ្មានសល់ ។
ដើមបបុសពោរពេញដី ក្មេងចាស់ប្រុសស្រីច្រើនតែស្គាល់
តូចធំយ៉ាងណាលោកកុំឆ្ងល់ ចាស់ចុលផ្កាផ្លែតែស្លាប់ដើម ។
មេសេះអស្សតរល្អឆើតឆាយ មានគតិក្នុងផ្ទៃត្រូវវិនាស
នេះជាពន្លឺភ្លឺឱកាស ខ្ញុំអ្នកត្រូវជាសចរអោយឆ្ងាយ ។
លាភយសសរសើរប្រាកដកាយ ចាត់ចែងចំណាយឱ្យសមគួរ
កុំដូចអ្នកល្ងង់លុងអាក្រក់ សក្ការៈទាញឆក់យកមកបាន ។
ដូចជាទេវទត្តអាក្រក់ចំណោន អវីចីឆក់បានតាមទំនង
នេះលាភសការៈក្តីសរសើរសំពង ធ្លាក់ជ្រៅជ្រោះជ្រងជ្រុប អវីចី ។
សម្តីសម្តៅចូលចុងជូន តាមបែបច្បាប់ក្បួននៃចំណេះ
រៀនតាមបិដកដែលបានចេះ ក្បាល៤២នេះ ១៨០ ។/

**ចៅឧត្តមរដ្ឋា**

# កំលាំងដែលខ្លាំងមាន ៧យ៉ាង

ខ្ញុំសូមលំអុតលំអោនកាយ　　វន្ទាទន់ភ្លន់ឆ្ពោះព្រះពុទ្ធ
ហើយខ្ញុំលើកទូលខ្ពស់បំផុត　ទីពីរនោះប្រាកដគឺព្រះធម៌ ។
ដែលខ្ពស់ផ្ដើងបវរ　　ជ្រួងនូវព្រះធម៌សង្ឃាវក
ឧបាសកឧបាសិកាចូលរួមជាក់　ជាសង្ឃាវ័កព្រះសម្ពុទ្ធ ។
ខ្ញុំសូមគោរពអង្គសាវ័ក　　ព្រះសម្ពុទ្ធជាក់ទូទាំងលោក
ថាកែវពិទូរគួរបរិភោគ　　និង ពាំនាំយកនូវកម្លាំង ។
ដែលធំហើយពិតខ្លាំង　　ដែលនាំឱ្យញ៉ាំងឈ្នះសត្រូវ
ទោះជាយ៉ាងណាតែងតំរូវ　ឱ្យឈ្នះសត្រូវគ្រប់កំលាំង ។
ក្មេងយំថាក្មេងអន់　　អ្នកឈ្នះសង្កន់សង្កត់វា
តាមពិតជាពូជធា　　ក្មេងយំវាពិតជាឈ្នះ ។
មិនមែនខ្ញុំថាពិតជាដិកាព្រះ　ក្មេងយំក្មេងឈ្នះជាកម្លាំង១
មិនបង្អាប់មិនលើកស្ទួយ　ក្មេងឈ្នះជាកំលាំងមួយគឺក្មេងយំ
ស្រីស្អាតលើសអស់ព្រះសម្ពុទ្ធ　សរសើរបំផុតលើបុរសល្ងង់
អ្នកដែលស្រើបស្រាលហើយធ្លាក់លុង　នូវក្នុងអន្លង់នៃកាម តណ្ហា ។

ពេញចិត្តបំផុតស្រីដែលខ្លួនត្រូវការ នរកាជ្រៅយ៉ាងណា តាមទៅដល់

មិនគិតលំបាក និង អម្ពុល ខ្លួនតាមទៅដល់ទល់អវិចី ។

សរសើរស្រីស្អាតស្រស់ប្រិមប្រិយ សម្បត្តិអ្វីៗជូននាងអស់

ឱ្យបាននៅនេបនិតជិតស្រីស្រស់ នាងខឹងឈ្នះអស់លើប្រុស លួងលោម ។

ហេតុតែខ្លួនល្ងង់ ល្មោភមិនចេះល្មម

បបោសលួងលោម កុំអោយគ្រោធសារ ។

ទីបីចោរលួចឆក់ផ្លន់ ទ្រព្យកូនប្រពន្ធគេមិនណាយ

ខ្លួនមានកម្លាំងអាវុធនូវដៃ ចាប់កាន់កេះកាយបាញ់ប្រហារ

កុំលរ និង ចោរកំលាំងនេះណា អាវុធសត្រាប្រហារបង់

វាមិនចេះខ្លាចតាមចំណង់ អាវុធក្នុងវង្សចោរកម្លាំងមួយ

ទីបួនជូនសម្តី ចោរពាលប្រុសស្រីក្នុងសាសនា

ពោលពាក្យបង្កាច់គ្មានរអា ពោលពាក្យមុសាមិនជិនឆ្អន់ ។

ព្រោះមនុស្សពួកនេះគេចេះបន់ គេសម្រន់មិនសំរាកគ្មាន ទំនេរ

ចេះតែមានពាក្យពោលទោសគេ នេះជាដុំកេរ្តិ៍កម្លាំងពាល

ទីប្រាំចាំអោយជាក់ អស់លោកអ្នកចេះចំណាំ

ព្រះពុទ្ធសម្តែងព្រះធម៌ យើងអំណរហើយត្រូវចេះចាំ ។
យើងគេចំណាំគ្រប់ៗគ្នា បណ្ឌិតលោកមិនមានពូជសាធា
ពោលនិន្ទាទោសគេនោះឡើយ នេះជាកម្លាំងដ៏ខ្ពស់របស់បណ្ឌិតហើយ
យើងម្នាក់ៗគ្រប់ៗគ្នា ដែលត្រូវជាឧបាសកឧបាសិកា
កម្លាំងបណ្ឌិត្យធំប៉ុណ្ណា យើងខំឃាតត្រាតាមបណ្ឌិត្យ ។
ទីប្រាំមួយខំសិក្សា សមណៈនេះណាជាកម្លាំង
តើលោកមានអ្វីមកតតាំង បាំងជារនាំងកំលាំងគាត់ ។
មនុស្សយើងម្នាក់ៗភ័យបំផុត បើគេសំលុតកុំរាមថា
ដោយពាក្យអសុរស្សវាចា ទាត់ធាក់ប្រហារតាមកម្លាំង ។
សមណៈខន្តីមិនតតាំង មិនគេរវគ្រោតតាមកម្លាំងទេ
ហើយមិនតតាំងអ្នកបៀតបៀន . នេះជាពូជជាដើមទាន ។
សម្បូរធន់ធានស្ថានចំលង ព្រោះមានខ័ន្តធ្លាក់ជារបង
ខ្សែរវីតចង និព្វានខ័ន្ត ។
ទីប្រាំពីរត្រូវឧស្សាហ៍ ការពិចារណាជាកម្លាំង
យើងមានអ្វីអាងជាទីតាំង បានជាកម្លាំងទីប្រាំពីរ ។

យើងខំសិក្សាឱ្យវក់វី បិដកគម្ពីរពេញសិក្សា
មានទាំងបិដកអដ្ឋកថា ពុទ្ធដិកាថេរដិកាច្រើនអនេក ។
ខំសិក្សាកុំឱ្យអកុសលច្រើនពេក វិលក្នុងដំណេកវង់ សង្សារៈចក្រ
សង្សារៈកើតចាស់ឈឺស្លាប់ ជរាជាំជាប់គ្រប់អង្គារ ។
ទាំងខ្ញុំទាំងតេចាស់ជរា ត្រាំត្រាទ្រុតទ្រោមព្យាធិទុក្ខ ។
គ្មានពេលស្រាកស្រាន្តរហូតទុក្ខ កើតជាជង្រុកទុក្ខទល់ ដល់ស្លាប់ ។
យើងត្រូវ ជូនជាប់ទីប្រាំពីរ ពហុស្សូតវក់វីពិចារណា
ទាំងក្នុងបិដកអដ្ឋកថា លោកពិចារណាជាកម្លាំងមួយ ។
យើងខំសិក្សា ហើយលើកស្ទួយ
ពហុស្សូត កម្លាំងមួយការពិចារណា ។

**ចៅឧត្តមរដ្ឋា**

សូមអនុមោទនាសេចក្តី
ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា
ឧទិសជូនមាតា បិតាដែល លោក
ធ្វើមរណៈកាលទៅហើយ ។

បរិច្ឆេទទិ ៣

# ជោគជតាវាសនាថ្ងៃ

ថ្ងៃច័ន្ទជាថ្ងៃរបស់ឯង ថ្ងៃអង្គារ៍ជាថ្ងៃរបស់គេ
ថ្ងៃពុធជាថ្ងៃជេរ ថ្ងៃព្រហស្បតិ៍ជាថ្ងៃជា
ថ្ងៃសុក្រជាថ្ងៃបណ្ឌិត្យ ថ្ងៃសៅរ៍ជាថ្ងៃពាលា
ថ្ងៃអាទិត្យជាថ្ងៃវឡ្បនា ថ្ងៃ.ច.អ.ពុ.ព្រ.សុ.ស.អា
ថ្ងៃប្រាំពីរនេះអាក្រក់ ល្អមែនពិតសុទ្ធតែវិនាស
យើងទាំងប្រុសស្រី ក្នុងលោកៈសន្និវាស
សុទ្ធតែវិនាសគ្មានថ្ងៃសល់ បើសិនដូច្នោះតើយើងខ្វាយខ្វល់
កុសលអកុសល ថ្ងៃទាំងប្រាំពីរបានអ្វីដល់យើង ។

ចៅឧត្តមរដ្ឋា ចង់ប្រហារកិលេស
ព្រោះវាឆាប់ឆេះ ជារៀងរាល់ថ្ងៃ
ឱ្យតែបានសុខ មិនសម្ងៃ
ឱ្យរួចទុក្ខភ័យ លោកីវិនាស ។

# សប្បុរិសធម៌

មុននឹងថ្លាថ្លែងចែងពណ៌នា ពីរឿងធម្មាព្រះសម្ពុទ្ធ
នមស្ការជាមុនខ្ពស់បំផុត លើសអស់ចមកុងត្រៃលោក ។
គឺអង្គនៃព្រះពោធិញ្ញាណ ព្រះពុទ្ធទូន្មានសព្វសត្វា
វន្ទាបង្គំព្រះសម្មា ដាក់ដល់សិរសាត្បូងឧត្តម ។
រួចហើយបង្គំព្រះធម៌ម្តង ធម៌អាចចម្លងដាក់ទៅចំ
ទីខ្ពស់ប្រសើរឥតបន្លំ អាចជួយស័កសមអ្នកគោរព ។
វន្ទាបង្គំព្រះធម៌នោះ មានចិត្តត្រង់ស្មោះលើកម្រាមដប់
នមស្ការរាល់ថ្ងៃសូមប្រសប់ សុំជ្រកក្រោមម្លប់តរៀងទៅ ។
ម្យ៉ាងទៀតសូមបង្គំព្រះសង្ឃ ដែលលោកគ្រប់អង្គគង់វង់នៅ
ប្រតិបត្តិតាមធម៌ឥតហ្មងសៅ គួរដល់កូនចៅគេធ្វើទាន ។
សូមក្រាបថ្វាយបន្ទន់វន្ទា ចំពោះសង្ឃាដែលនៅមាន
និងអរិយសង្ឃជាប្រធាន នាំគ្នាធ្វើទានតែងបានផល ។
បង្គំរួចហើយសូមពណ៌នា រៀបតាមវគ្គឃ្លាប្រាជ្ញាយល់
លើកធម៌សំដែងចែងតំកល់ យកជាកុសលតរៀងទៅ ។

សប្បុរិសៈធម៌ប្រាំពីរ　　ធម៌នេះជាទីឥតហ្មងសៅ
ដែលអ្នកសប្បុរសធ្លាប់មាននៅ　រក្សាតទៅបានសុខសាន្ត ។
ទីមួយគឺធម្មញ្ញុតា　　អ្នកស្គាល់ហេតុកាណ៍យ៉ាងចំណាន
ដូចជាស្គាល់ថានេះហេតុបាន　ឬសុខក្សេមក្សាន្តឬក៏ទុក ។
ជាអ្នកបានស្គាល់អាក្រក់ល្អ　ស្គាល់នេះជាធម៌បានគ្រប់មុខ
គួរអាចរើសយកឬតាំងទុក　លំបាកស្រណុកដឹងយ៉ាងពិត ។
ទីពីរគឺអត្ថញ្ញុតា　　ជាអ្នកស្គាល់កាផលសុចរិត
ហេតុអ្វីកើតឡើងគេតែងគិត　ទោះជាខុសចិត្តឬយ៉ាងណា ។
ដូចជាស្គាល់សុខទុក្ខជាផល　ដឹងហេតុកុសលយ៉ាងម្តេចម្តា
នឹកគិតត្រិះរិះពិចារណា　តែងដឹងហេតុការណ៍ពីនេះនោះ ។
ទីបីគឺអត្តញ្ញុតា　　បើតាមធម្មតាយ៉ាងពិតស្មោះ
ស្គាល់ខ្លួនឯងច្បាស់ឥតមានខ្ចោះ　រួចចេះសង្គ្រោះញាតិសន្តាន ។
ដឹងខ្លួនថាជាមនុស្សសុទ្ធពិត　គួរធ្វើសុច្ចរិតជាប្រមាណ
ដើម្បីត្រកូលជាតិថ្កើងថ្កាន　យសសក្តិកើតបានសុខសួស្តី ។
ព្រមទាំងចេះដឹងនៅគុណធម៌　ប្រព្រឹត្តធម៌ល្អតាមប្រក្រតី

ពោលពាក្យពិរោះដោយវចី ទោះមានហេតុអ្វីសម្ដីល្អ ។
មិនតែប៉ុណ្ណោះគួរប្រព្រឹត្ត ធម៌ស្អាតសុចរិតចិត្តស្មោះស
ដឹងឋានៈខ្លួនដែលបង្ក បង្កើតធម៌សល្អរាល់ថ្ងៃ ។
មិនគួរធ្វើបាបដោយខ្លួនឯង ឬប្រើគេស្វែងពុំប្រពៃ
មិនគួរញុះញង់អ្នកដទៃ នាំអោយចង្រៃកើតមានទុក្ខ ។
ដឹងខ្លួនឯងហើយគួរសង្គ្រោះ បង្កើតសប្បុរសអោយគ្រប់មុខ
មនុស្សម្នាច្រើនគ្នាគេបានសុខ ព្រោះអីបានទុកធម៌ក្នុងចិត្ត ។
ទីបួនគឺមិត្តញ្ញូតា ភាពអ្នកស្គាល់ការដែលប្រព្រឹត្ត
ស្វះស្វែងរកគ្រឿងលៀងជីវិត ធ្វើដោយសុចរិតចិត្តទៀងត្រង់ ។
រកគ្រឿងបរិភោគមិនច្រអុះ ទោះស្រីឬប្រុសតាមចំណង់
ត្រូវដឹងប្រមាណបានតាមអង្គ ដឹងការទ្រទ្រង់គ្រប់បែបបទ ។
រួចដឹងប្រមាណការបរិភោគ មិនមានស្មោកគ្រោកត្រូវអំណត់
និងអនាម័យយ៉ាងម៉ត់ចត់ មិនលើសកំណត់ល្មមគ្រប់គ្រាន់ ។
ទីប្រាំគឺកាលញ្ញូតា ស្គាល់វេលាណាមិនគួរភាន់
ត្រូវដឹងសតិគិតមកទាន់ កិច្ចការរយពាន់មិនភ្លេចភ្លាំង ។

កំណត់ត្រឹមត្រូវនូវវេលា ប្រកបការងារពេញកំលាំង
ដឹងខ្លួនឯងខ្សោយឬក៏ខ្លាំង មិនហួសកំលាំងជាទម្ងន់ ។
ប្រាំមួយបរិសញ្ញូតា ជាអ្នកស្គាល់ការប្រជុំជន
និយាយជាមួយចិត្តទន់ភ្លន់ សំដីទោរទន់ពោលទៅរក ។
កិរិយាប្រព្រឹត្តទីប្រជុំ ទោះបីជុំនំមិនគំហក
និយាយស្រុះស្រួលមូលទៅមក មិនមានសៀតសិកនាំអោយក្តៅ ។
ដឹងថាអ្នកនេះពោលយ៉ាងនេះ រួចហើយត្រិះរិះឥតហ្មងសៅ
និយាយទន់ភ្លន់ពោលសំដៅ វាចាត្រឹមត្រូវគ្រប់ហេតុការណ៍ ។
ទីប្រាំពីរនោះមានបាលី ដែលលោកពោលស្តីសំដែងថា
បុគ្គលបរោបរញ្ញូតា ភាពស្គាល់ហេតុការណ៍ជាបុគ្គល ។
ដឹងថាអ្នកនេះជាអ្នកល្អ សេពគប់បន្តពុំមានឆ្ងល់
រាប់អានរាក់ទាក់ជាក់បានផល ស្គាល់អ្នកកុសលឬប្រាជ្ញា ។
អ្នកខ្លះគួរណាស់សេពគប់រក សួរទៅឆ្លើយមកមានវាចា
គួរគប់រាប់រកទៅមកប្រាថ្នា ឬក៏ហៅថាសប្បុរស ។
ព្រោះសេពគប់ប្រាជ្ញអាចបានល្អ គប់ពាលរឹកវរខុសទាំងអស់

គប់ប្រាជ្ញនាំប្រាណបានចិត្តស្មោះ គប់ពាលនាំគ្រោះជាប្រក្រតី ។
គប់ប្រាជ្ញនាំប្រាណរក្សាសីល គប់ពាលខូចខិលនាំអប្រិយ៍
គប់ប្រាជ្ញនាំប្រាណបានសួរស្តី គប់ពាលនាំក្ដីវិនាសតប ។
ធម៌សប្បុរសប្រាំពីរនេះ គួរតែត្រិះរិះអោយសមស្រប
សូមវិនិច្ឆ័យន័យប្រកប គួរធ្វើសម្របអោយត្រូវបទ ។
បណ្ឌិតទាំងឡាយអ្នកចេះដឹង គួរតែរំពឹងតាមកំណត់
កាន់ខ្ជាប់ខ្ជួនល្អមិនក្រក្សត់ បណ្ឌិតមិនអត់គង់យល់ដឹង ។
បញ្ចប់សេចក្តីខ្លីសិនចុះ ប្រសិនមានខុសសូមកុំខឹង
បានសុខក្សេមក្សាន្តជាទីពឹង ទុកជាពុំនឹងទៅខាងនាយ ។

និពន្ធដោយ ភិ. **ស៊ឹម រតនៈ** គង់នៅវត្តសំពៅមាស
ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ពុទ្ធសករាជ ២៥៤៣

# មិនចេះឆ្អែត ( មនុញ្ញាហ្វគតិ)

| | |
|---|---|
| សូមលើកហត្ថាកំបង់ | នៃឆ្ពោះត្រង់ព្រះសម្ពុទ្ធ |
| វន្ទាខ្ពស់បំផុត | ដោយលំអុតលំឱនកាយ ។ |
| ព្រះធម៌ជាពំនឹង | សត្វទីពឹងបានសប្បាយ |
| សុខស្រួលតទៅឆ្ងាយ | រាល់រូបកាយគួរគោរព ។ |
| ព្រះសង្ឃអង្គសាវ័ក | ប្រព្រឹត្តជាក់បានដោយគ្រប់ |
| សាសនាថាជាម្លប់ | អ្នកចាកភពព្រោះអស់តណ្ហ[១] ។ |
| មិនឆ្អែតមានដប់យ៉ាង | ជាភស្តុតាងមានគ្រប់គ្រាន់ |
| បណ្ឌិតគង់ដឹងទាន់ | មិនគួរភាន់ធម៌ទាំងនេះ ។ |
| * ភ្លើងមិនឆ្អែតនឹងអុស | សព្វសាយសុះនៅពេលឆេះ |
| ឈើព្រៃក្លាយជាផេះ | ក្តៅរលេះគ្រប់វេលា ។ |
| * សមុទ្រមិនឆ្អែតទឹក | ព្រែកសន្ទឹកច្រើននានា |

---

(១) តណ្ហ·អានថា តន់ គឺ តណ្ហា

ទន្លេស្ទឹងគង្គា ទោះច្រើនក្តាយ៉ាងណាក្តី ។
មិនដែលឆ្អែតម្តងសោះ ឬទឹកច្រោះហូរពេញដី
សមុទ្រមិនដែលក្តី បារម្ភអ្វីទឹកនោះឡើយ ។

* ស្តេចចក្រគ្រងរាជ្យរម្យ ប្រសើរសមតរៀងអើយ
ទោះប្រព្រឹត្តធម៌ហើយ មិនស្ងៀមឡើយខាងចង់បាន ។
ស្តេចមិនឆ្អែតដែនដី គ្រងបុរីទាំងប៉ុន្មាន
ចង់ធំលើសសព្វស្ថាន គ្មានប្រមាណគ្រប់ទិសា ។

* ស្រីមិនឆ្អែតរបស់ គ្រប់ទាំងអស់អលង្ការ
មាសពេជ្រស្រោបកាយា តែងប្រាថ្នាមិនចេះគ្រាន់ ។

* ជនពាលមិនឆ្អែតបាប ធ្វើថោកទាបក្លែងបំភាន់
ទោះបីម្ចាស់គេទាន់ ធាក់ទាត់ជាន់មិនរាងទេ ។
ឆក់ប្លន់មាសកែវកង វត្ថុផងគ្មានទំនេរ
មិនខ្លាចរបស់គេ វិនាសទេតាមចិត្តចង់ ។

* ទាយកមិនឆ្អែតទាន ឱ្យប៉ុន្មានគ្មានខ្លាចបង់
ដល់ជនអ្នកចំណង់ ដោយចិត្តចង់តាមប្រាថ្នា ។

* បុគ្គលមានវិរិយៈ មិនដែលអាក់ខាងឧស្សាហ៍
មិនចេះឆ្អែតដងណា ទោះកិច្ចការយ៉ាងណាក្តី ។
ព្យាយាមទល់សម្រេច មិនចេះគេចទោះចាស់ថ្មី
សតិដឹងប្រក្រតី ទោះកិច្ចអ្វីណាក៏ដោយ ។

* បុគ្គលអ្នកសន្តោស សប្បុរសតាមបណ្តោយ
ទោះជនម្តេចក៏ដោយ ចិត្តចង់អោយសុខចម្រើន ។
មិនចេះឆ្អែតសន្តោស ស្រីឬប្រុសបានយ៉ាងច្រើន
ចិត្តចង់ចំណេះកើន តែងក្រវើនមើលត្រូវខុស ។

* ឯពុទ្ធបរិស័ទ ច្រើនពេកក្តាត់ទាំងស្រីប្រុស
ជ្រះថ្លាចិត្តផុលផុស មានភ័ក្រឆ្ពោះគាល់ព្រះពុទ្ធ ។
មិនឆ្អែតគាល់ព្រះអង្គ តែងចិត្តចង់មិនអោយផុត
សន្តានស្អាតបរិសុទ្ធ ឱនលំអុតក្រាបវន្ទា ។

* បណ្ឌិតប្រាជ្ញាំគាប់ មិនឆ្អែតស្តាប់ព្រះធម្មា
ទុកដាក់ក្នុងទយា គោរពជាចិត្តអ្នកធម៌ ។
មិនឆ្អែតព្រះធម៌ថ្លៃ ទោះយប់ថ្ងៃចិត្តស្មោះស

រាប់អានបានយ៉ាងល្អ គ្រប់ដំណោជាតិអ្នកប្រាជ្ញ ។
មិនដែលលះធម្មា ទោះមានគ្រោះអ្វីកំណាច
តែងមានចិត្តអង់អាច ពុំដែលខ្លាចអំពើស្អាត ។
និងឱ្យអ្នកដទៃ ដឹងដោយន័យតាមច្បាប់ខ្នាត
ព្យាយាមប្រឹងសង្វាត ធមិជាអាទិ៍ទុកក្នុងខ្លួន ។
គឺមោះជាតិអ្នកចេះ តែងត្រិះរិះបានខ្ជាប់ខ្ជួន
លើកស្ទួយឱ្យមាំមួន ប្រយោជន៍ខ្លួននិងដទៃ ។
អ្នកប្រាជ្ញមានមួយនាក់ បានពឹងពាក់ស្នាក់អាស្រ័យ
សុខសាន្តរៀងរាល់ថ្ងៃ ល្អប្រពៃបានវឌ្ឍនា ។
មិនឆ្អែតដប់នេះឯង មានជាក់ស្តែងពុំឈ្លាតឃ្លា
គឺព្រះភគវា ទេសធម្មាក្នុងបិដក ។
ប្រដៅដល់បរិស័ទ ឱ្យប្រតិបត្តិជាមតិក
កុំអោយធ្វើអាក្រក់ ចេញចាកភក់គឺវាត ។
រឿងនេះមានពិតណាស់ បើចង់ច្បាស់សូមលោកអ្នក
ពិនិត្យកុំបីអាក់ គម្ពីរជាក់ជាដិកា ។

បរិច្ឆេទទី ៣

សូមបរិស័ទស្រីប្រុស ចិត្តសន្តោសដោយមេត្តា
អ្នករៀនក្នុងសាលា បានសុខាយូរអង្វែង ។

វត្តសំពៅមាស ( ភ.៣ ) ថ្ងៃសៅរ៍ ១១ រោច ខែចែត្រ
ព.ស ២៥៤៣ ត្រូវនឹងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០០
កវីនិពន្ធ ភិក្ខុ **ស៊ីម រតនៈ**

បរិច្ឆេទទី ៣

# សុភាសិត ស្រីសមស្នួន (បទពាក្យ៧)

ឥ. ស្វា. សុ អហំបង្គំអង្គ លើកហត្ថកំបង់ផ្គង់ស្មារតី
វន្ទាចំពោះព្រះជិនស្រី សូមសុខសួស្តីវិរមង្គល ។
បង្គំព្រះធម៌ល្អជាអនេក ប្រពៃពន់ពេកត្រេកបានមគ្គផល
ដាក់ស្មើសិរសាចាជាកុសល ទុកឱ្យបានដល់ផលជាប់ហ៊ទៅនាយ ។
និងបង្គំព្រះសង្ឃអង្គសាវ័ក លោកគោរពជាក់ដាក់ជាសំពាយ
ប្រតិបត្តិតាមធម៌ឥតឡើយណាយ បានសុខចិត្តកាយផុរាយតរៀងទៅ
បង្គំរួចហើយឆ្លើយពាក្យចាំចែង លើករឿងសម្ដែងថ្លែងពាក្យជាប់នៅ
រើសយកភាសិតពិតក្នុងសៀវភៅ លោកនីតិត្រូវឈ្មោះតិបករណ៍ ។
ទំព័រហាសិបពិតឥតមានរអាក់ តទៅយ៉ាងជាក់ដាក់សន្លឹកត
មានពីរគាថាចាបានយ៉ាងល្អ ជាប់ជាតំណេ-តដូច្នេះថា ÷ ។
-ស្រីឯណាសុចរិតចិត្តភក្តី ញាំងស្វាមីឱ្យត្រេកក្នុងកិច្ចការ
ពីក្នុងកាលបរិភោគនូវអាហារ ឬក្នុងការប្រដាប់សម្រាប់ប្រាណ
ស្រីយ៉ាងនេះលោកប្រៀបដូចជននី ព្រោះជាទីញាំងបុត្រឱ្យក្សេមក្សាន្ត

ស្រីឯណាមានខ្មាស់ក្នុងតួស្ថាន .. ការកំបាំងមិនបានបែកប្រេះព្រាយ ។
ស្រីយ៉ាងនេះលោកប្រៀបដូចប្អូនស្រី ព្រោះចេះក្តីបាំងហេតុផងទាំងឡាយ
ស្រីឯណាគោរពការសម្ងាយ ប្រតិបត្តិដូចនាយចៅហ្វាយពិត ។
ស្រីយ៉ាងនេះលោកប្រៀបដូចទាសី ព្រោះចេះក្តីចាត់ការតម្រូវចិត្ត
ទាំងរក្សាការភ័យពុំឱ្យជិត ចូលសណ្ឋិតខាងឆ្វេងនៃស្វាមី
មានទាំងវត្តប្រតិបត្តិឱ្យតម្រេក ក្នុងកាលគ្រែកនិទ្រាជាប្រក្រតី
តាក់តែងកាយប្រកបការមេត្រី ទាំងអស់អំត់ខន្តិគ្របក្រោធពាន ។
អ្នកប្រាជ្ញផងពោលថាស្រីពួកនោះ ចុះក្នុងឈ្មោះប្រសើររកស្មើគ្មាន
ស្រីពួកនោះលុះក្ស័យប្រល័យប្រាណ បានទៅកើតក្នុងស្ថានទេពត្រៃត្រឹង្ស
គាថាទីពីរលោកបានសម្តែង បានយ៉ាងជាក់ស្តែងបែងជាល់នឹង
សូមតគាថាជាទីពឹង សូមស្តាប់តង់ដឹងនិងដូច្នេះថា
-ស្រីក្រមុំឯណាកបរូបរាង សព្វសាពាំងលឿនដូចសុវណ្ណា
នេត្រាថ្លាយង់ភ្នែកដូចម្រឹគា ចង្កេះរៀវសមស្មាគាងរាវរាជហង្ស
ឱ្យស្រួលទំនូលសមឱរា មានកេសាខ្មៅយង់ចុងងខ្វង់
មានទិន្នាត្រឹមល្អសរលង់ នាភីទ្រង់ខ្វង់ជ្រៅកបមារយាទ
ទោះបីកើតក្នុងត្រកូលហីនជាតិ គួរសង្ខាតអភិសេកឯកមហេសី ។

បញ្ចប់គាថាចាទាំងឡាយពីរ　　សព្វសាកលទីបានសុខសួស្តី
ខុសឆ្គងមិនសមសូមតែប្រណី　　ខ្ញុំកែសេចក្តីស្តីថាចប់ហោង ។

វត្តសំពៅមាសម៉ោង ១:៤២ ថ្ងៃត្រង់
១២កើត ខែ ផល្គុន ថ្ងៃព្រហស្បតិ៍
ទី ១៦ ខែ មិនា ព.ស ២៥៤៣
និពន្ធនិងរៀបរៀងដោយ ភិ. ស៊ីម　រតនៈ

បរិច្ឆេទទី ៣

# គុណមាតាបិតា

បពិត្រលោកមាតាបិតា កូនទឹកខ្លោចផ្សាពេកអំពាយ
តាំងពីកូនកើតមានរូបកាយ អ្នកតែងខ្វល់ខ្វាយថែរក្សា ។
ឱះឱម្ចាស់ថ្លៃវិសេសលន់ អ្នករងទុក្ខធ្ងន់ពន់ពេកណា
អ្នកខំបីបាច់កូនស្ងួនភ្ងា ពុំអាចពណ៌នាឱ្យអស់បាន ។
ហេតុនេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
គោរពបាទាព្រះក្បៀបក្បាន្ត ទោសខុសប៉ុន្មានសូមប្រណី
ម្ចាស់អើយកាលកូនទ្រហោយំ អ្នកស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេរកូនដោយប្រឹមប្រិយ ដោយចិត្តមេត្រីផ្ដេកកូនណា
ទឹកមាត់ទឹកមូត្រលាមកផង ទាំងគ្រឿងសៅហ្មងផងនានា
អ្នកចាប់អ្នកកាន់អ្នកស្រវា លាងដោយហត្ថាឥតជិនឆ្អន់
បពិត្រអ្នកម្ដាយមានករុណា បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់ សូមព្រះសោភ័ណបានក្សេមក្សាន្ត
ហេតុនេះកូនសូមឧទ្ទិសផល ដឹកលស់ចេតនាដ៏ក្លាហាន

ទានសីលភាវនាដែលកូនបាន ស្អាងធ្វើប៉ុន្មានជូនទៅអ្នក ;
សូមលោកទទួលដោយសោមនស្ស ចិត្តកូនត្រង់ស្មោះចំពោះអ្នក
ដូចកូនបានពោលពាក្យសច្ចៈ សូមជូនទៅអ្នកគ្រានេះហោង ។

**ចៅ ឧត្តមរង្គោ**

នឹកឪពុកម្តាយ

សូមឧទិសជូនអ្នកនិពន្ធផងដែរ ។